# ពុទ្ធវង្សសង្ខេប

វត្តនិគ្រោធវ័ន "គល់ទទឹង"

រៀបរៀងដោយ
ខ្ញុំព្រះករុណាអាត្មាភាព
មុនីកោសល្យ **នៅ~ហៃឡុង**

ព.ស ២៥៥២
**ចែកជាធម្មទាន**

៥០០០ឆ្នាំ

WWW.5000-YEARS.ORG



ឯកសារនេះបាន ទាញចេញពី គេហទំព័រ
www.5000-years.org

# អារម្ភកថា

សៀវភៅឈ្មោះ **ពុទ្ធវង្សសង្ខេប**នេះ ជាសៀវភៅដែលស្រាវជ្រាវ ដកស្រង់ រៀបរៀង ចងក្រង ជាកម្រងអត្ថបទខ្លីៗ ដែលជាប់ទាក់ទង នឹងវង្សរបស់ព្រះសម្ពុទ្ធពីអតីត បច្ចុប្បន្ន និងទៅអនាគត ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងទុកក្នុងគម្ពីរព្រះត្រៃបិដកភាគ ៧៧ ជាដើម និងអដ្ឋកថា ព្រមទាំងសៀវភៅផ្សេងៗ ខ្លះទៀត ដែលអ្នកប្រាជ្ញខ្មែរយើងរៀបរៀងចងក្រងទុកហើយយកមករួមផ្សំ ។

សៀវភៅនេះ ដែលកើតឡើងដោយអាស្រ័យហេតុ ដូចមានខាងក្រោមនេះ ៖

១ ដោយការចង់ផ្សព្វផ្សាយ ព្រះមហាករុណាទិគុណ របស់ព្រះសម្ពុទ្ធគ្រប់ៗព្រះអង្គ ដែលមានមកលើសព្វសត្វមិនមានចំពោះមុខ ចាប់ដើមអំពីការតាំងក្នុងព្រះទ័យថា យើងនឹងជាព្រះពុទ្ធ **ពុទ្ធោ ពោធេយ្យំ** យើងត្រាស់ដឹងហើយ នឹងឱ្យអ្នកដទៃត្រាស់ដឹងផង **មុត្តោ មោចេយ្យំ** យើងផុតហើយនឹងឱ្យអ្នកដទៃផុតផង **តិណ្ណោ តារេយ្យំ** យើងឆ្លងហើយនឹងឱ្យអ្នកដទៃឆ្លងផង តាំងក្នុងព្រះទ័យផ្ដើមឡើងប៉ុណ្ណេះ រហូតព្រះអង្គបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ទល់នឹងទ្រង់បរិនិព្វាន អស់កាល ២០ អសង្ខេយ្យ ៤០ អសង្ខេយ្យ ៨០ អសង្ខេយ្យ នឹងកម្រៃ ១ សែនៗកប្ប ថែមទៀតផង ព្រះអង្គទ្រង់បំពេញអភិនិហាបារមី ធ្វើពលីកម្មគ្រប់យ៉ាង រហូតដល់អាយុជីវិត ជាអនេកជាតិ និងទ្រង់បំពេញពុទ្ធកិច្ចគ្រប់យ៉ាង ដើម្បីប្រយោជន៏ដល់សត្វលោកដែលជាបរហិតបដិបត្តិ ព្រះពុទ្ធដីកាទាំងអស់នោះដែលទ្រង់ត្រាស់សម្ដែងហើយ មាននៅច្រើនកន្លែង ខ្ញុំមានបំណងចង់ប្រមូលសេចក្ដីផមិនោះបញ្ចូលគ្នា ដើម្បីស្រួលងាយ ចំពោះពុទ្ធបរិស័ទដែលមានបំណងចង់សិក្សារៀនសូត្រ បានប្រៀបធៀបនូវព្រះគុណរបស់ព្រះសម្ពុទ្ធទាំងឡាយ ច្រើនព្រះអង្គនោះក្នុងសៀវភៅនេះ ។

២. អាស្រ័យកុលបុត្រ ៣ រូប ដែលបួសក្នុងព្រះពុទ្ធសាសនានេះ មកនៅរួមកុដិ

គាត់បានដឹងថា ខ្ញុំជាអ្នកចូលចិត្ត ធ្វើសៀវភៅធម៌ចែកជាធម្មទាន ដូច្នេះហើយក៏មានទឹកចិត្តជ្រះថ្លាចង់ចូលរួមចំណែកធម្មទានជាមួយ ពេលគាត់លាចាកសិក្ខាបទហើយ ក៏បាននិយាយជាមួយនឹងខ្ញុំថា សូមលោកម្ចាស់រៀបរៀងសៀវភៅអ្វីមួយទៀតទៅ ពេលត្រឡប់ទៅផ្ទះវិញ នឹងឆ្លៀតពេលទំនេរអំពីការងារ ចូលរួមជួយសរសេរជួយធ្វើទាល់តែបានសម្រេច ដើម្បីជាបុណ្យកុសល ជាឧបនិស្ស័យក្នុងព្រះពុទ្ធសាសនា ដល់ខ្ញុំព្រះករុណាទាំងឡាយផង ។ កុលបុត្រទាំង ៣ នោះគឺ ៖

១ លោក **ផ្លង ពន្លឺរត័ន៍**

២ លោក **ហេង ម៉ុនហុង**

៣ យុវសិស្ស **នៅ ពីឡុត**

ខ្ញុំក៏មានសេចក្ដីត្រិះរិះថា បើដូច្នោះ គួរតែរៀបសៀវភៅពុទ្ធវង្សចុះ ព្រោះថាបើរៀបសៀវភៅនេះ អាចញុំាងសេចក្ដីជ្រះថ្លា រីករាយ ពេញចិត្ត កើតមានសទ្ធារឹងមាំ និងបានជាប្រយោជន៏ដល់អ្នកសរសេរ អ្នកជួយឧបត្ថម្ភ ព្រមទាំងអ្នកអានបានច្រើននាក់ទៀតផង សេចក្ដីត្រិះរិះឃើញយ៉ាងនេះហើយ ទើបញុំាងឆន្ទៈឱ្យកើតឡើង បានព្យាយាមប្រមូលអត្ថបទ ឯកសារ តាមសមត្ថភាពមកចងក្រង រួចហើយចែកជា ៣ ចំណែកឱ្យដល់អ្នកជួយសរសេរ រហូតបានសម្រេចជារូបរាង សៀវភៅនេះឡើង ។

ខ្ញុំបានយកទៅប្រគេនព្រះគ្រូគម្ពីរត្ថេរោ **យី និត** ជាព្រះវិន័យធរគណ ស្រុកកៀនស្វាយ ខេត្តកណ្ដាល និងលោកម្ចាស់គ្រូ មេត្តាបាលោ **ទឹម សឿត** ចៅអធិការវត្តនិគ្រោធវ័ន ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល ព្រមទាំងព្រះថេរៈជាច្រើនអង្គ ដែលជាអ្នកឈ្លាសវៃក្នុងព្រះធម៌ សុំឱ្យលោកជួយផ្ទៀងផ្ទាត់ថែមទៀត លោកក៏បានជួយពិនិត្យផ្ទៀងផ្ទាត់យល់ថាត្រឹមត្រូវហើយ ទើបខ្ញុំយកទៅចាត់ចែងបោះពុម្ពតាមសេចក្ដីត្រូវការ ។ ដោយអំណាចនៃការប្រឹងប្រែងក្នុងការងារសៀវភៅនេះ

ផលបុណ្យនោះ សូមឱ្យបានសម្រេចបំណងប្រាថ្នា ដល់លោកអ្នកដូចបានរៀបរាប់ខាងលើនោះ ព្រមទាំងសព្វសត្វទាំងអស់ បានប្រកបដោយសតិ បញ្ញា ស្មារតីជាសម្មាទិដ្ឋិ បានសេចក្តីសុខក្នុងលោកនេះ លោកខាងមុខ រហូតអវសានជាតិ ។

ថ្ងៃ ច័ន្ទ ១៥ កើត ពេញបូណ៌មី ខែ ពិសាខ ឆ្នាំ ជូត សំរឹទ្ធិស័ក ព.ស. ២៥៥១

ត្រូវនឹងថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៨

ខ្ញុំព្រះករុណាអាត្មាភាព មុនីកោសល្យ **នៅ_ហៃឡុន**

## អ្នកមានឧបការៈ ក្នុងការចារធម្មទាន

- លោកម្ចាស់ **គូ_សុភាព**
- លោកម្ចាស់ **អ៊ិន_សំអឿន**
- លោកម្ចាស់ **តួង_សុវណ្ណ**
- លោកម្ចាស់ **ឆាយ_ភន**
- លោកម្ចាស់ **ឯម_ តា**
- លោកម្ចាស់ **គង់_សុមិត្ត**
- លោកម្ចាស់ **សូរ_ស៊ីម**
- លោកម្ចាស់ **ឈឿន_នាយ**
- សាមណេរ **សឹម_ស៊ីសាមុត**
- លោក **ផ្លុង_ពន្លឺរ័ត្ន**
- លោក **ហេង_ម៉ីនហុង**
- យុវសិស្ស **នៅ_ពីឡុត**
- លោកជំទាវ **នូច_ស៊ីរដ្ឋា**
- ឧបាសិកា **ហុង_ចេង**

### សេចក្តីបញ្ជាក់

សៀវភៅបោះពុម្ពលើកនេះ ខ្ញុំបានកែលំអពាក្យដែលខុសខ្លះ និងអក្ខរាវិរុទ្ធ ដែលបានពិនិត្យរកឃើញហើយ នឹងរៀបចំបោះពុម្ពចែកជូនជាធម្មទានតទៅទៀត ។

# បញ្ជីមាតិកា ពុទ្ធវង្សសង្ខេប

មាតិកា ទំព័រ

អារម្ភកថា..................................................ក

បញ្ជីមាតិកា..................................................ង

១ ពុទ្ធភាសិត..................................................១

២ សេចក្តីអស្ចារ្យរបស់ព្រះមានព្រះភាគ..................................................១

៣ ពុទ្ធវង្ស..................................................៣

៤ តារាងពុទ្ធវង្សសង្ខេបទី ១..................................................៤

តារាង ទី ២ ..................................................៥

តារាងទី ៣ ..................................................៦

តារាងទី ៤..................................................៧

តារាងទី ៥..................................................៨

តារាងទី ៦..................................................៩

តារាងទី ៧..................................................១០

តារាងទី ៨..................................................១១

តារាងទី ៩..................................................១២

តារាងទី ១០ ..................................................១៣

៥ បឋមបណិធាន ..................................................១៤

៦ ទ្រង់បានទទួលការព្យាករណ៍ពីព្រះពុទ្ធ ២៤ ព្រះអង្គ ..................................................១៨

មាតិកា ទំព័រ


៧ តារាងពុទ្ធប្បកិណ្ណកកណ្ឌ ........ ៣៧
៨ តារាងរយៈពេលព្យាយាម ........ ៣៨
៩ ពុទ្ធការកធម៌ ........ ៣៩
បារមី ១០ ប្រការ ........ ៣៩
ទានបារមី ........ ៤៤
សីលបារមី ........ ៥១
នេក្ខម្មបារមី ........ ៥៣
បញ្ញាបារមី ........ ៥៥
វីរិយបារមី ........ ៥៨
ខន្តិបារមី ........ ៦០
សច្ចបារមី ........ ៦២
អធិដ្ឋានបារមី ........ ៦៣
មេត្តាបារមី ........ ៦៤
ឧបេក្ខាបារមី ........ ៦៦
សម្បត្តិ ៨ ប្រការ ........ ៦៨
១០ បារមី ៣០ ........ ៧១
១១ ទំនៀមរបស់ព្រះពោធិសត្វ ........ ៧៥
១២ សេចក្ដីត្រិះរិះរបស់ព្រះពោធិសត្វ ........ ៨២

មាតិកា ទំព័រ

១៣ ស្ដេចចូលទៅរកអាឡារតាបសនិងឧទ្ទកតាបស ........ ៨៣

១៤ សេចក្ដីឧបមា ៣ យ៉ាង ........ ៨៥

១៥ ប្រភេទនៃទុក្ករកិរិយា ........ ៨៩

១៦ ឧទានគាថា ........ ១០២

១៧ ទំនៀមរបស់ព្រះពុទ្ធ ........ ១០៣

១៨ ពុទ្ធកិច្ច ៥ ប្រការ ........ ១០៥

១៩ ពុទ្ធាបទាន ........ ១០៦

២០ កិត្តិសព្ទរបស់ព្រះដ៏មានព្រះភាគ ........ ១១៦

២១ អធិប្បាយពាក្យថា ព្រះមានព្រះភាគ ........ ១១៧

២២ អធិប្បាយពាក្យថា ព្រះពុទ្ធ ព្រះនាមថាព្រះពុទ្ធ ........ ១៤៧

២៣ មហាបុរិសលក្ខណៈ ៣២ ប្រការ ........ ១៤៩

២៤ ឥរិយាបថរបស់ព្រះសម្ពុទ្ធ ........ ១៦៩

២៥ បុព្វកម្មបិលោតិ នាម ពុទ្ធាបទាន ........ ១៧៥

២៦ ព្រះមានព្រះភាគទ្រង់ដាក់ព្រះជន្ម និង បរិនិព្វាន ........ ១៧៨

២៧ ធាតុភាជនីយកថា ........ ២១២

២៨ អនាគតវង្ស ........ ២១៥

រឿងព្រះសិអារ្យមេត្រីយ៍ទី ១ ........ ២១៦

រឿងព្រះរាមសម្មាសម្ពុទ្ធទី ២ ........ ២២៦

មាតិកា ទំព័រ


រឿងព្រះធម្មរាជាសម្មាសម្ពុទ្ធទី ៣ ........ ២២៨

រឿងព្រះធម្មសាមីសម្មាសម្ពុទ្ធទី ៤ ........ ២៣០

រឿងព្រះនារទសម្មាសម្ពុទ្ធទី ៥ ........ ២៣២

រឿងព្រះរង្សីមុនីសម្មាសម្ពុទ្ធទី ៦ ........ ២៣៤

រឿងព្រះទេវទេពសម្មាសម្ពុទ្ធទី ៧ ........ ២៣៩

រឿងព្រះនរសីហសម្មាសម្ពុទ្ធទី៨ ........ ២៤២

រឿងព្រះតិស្សសម្មាសម្ពុទ្ធទី ៩ ........ ២៤៤

រឿងព្រះសុមង្គលសម្មាសម្ពុទ្ធទី ១០........ ២៥២

២៩ តារាងពុទ្ធប្បកិណ្ណកកណ្ឌ ........ ២៥៧

៣០ បច្ចេកពុទ្ធាបទាន ........ ២៥៨

# ពុទ្ធវចនសង្ខេប

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

## ១ ពុទ្ធភាសិត

**ចត្តារោ លោកេ បជ្ជោតា　　បញ្ចមេត្ថ ន វិជ្ជតិ**
**ទិវា តបតិ អាទិច្ចោ　　រត្តិមាភាតិ ចន្ទិមា ។**
**អថ អគ្គិ ទិវារត្តឹ　　តត្ថ តត្ថ បភាសតិ**
**សម្ពុទ្ធោ តបតំ សេដ្ឋោ　　ឯសា អាភា អនុត្តរាតិ ។**

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ពន្លឺក្នុងលោកនេះ មានតែ ៤ យ៉ាង មិនមានដល់ ៥ យ៉ាងទេ គឺ ព្រះអាទិត្យភ្លឺក្នុងវេលាថ្ងៃ ព្រះចន្ទភ្លឺក្នុងវេលាយប់ ឯភ្លើងភ្លឺក្នុងទីនោះៗ ទាំងយប់ទាំងថ្ងៃ ព្រះសម្ពុទ្ធ ប្រសើរលើសពន្លឺទាំងឡាយ ពន្លឺនេះ មិនមានពន្លឺដទៃលើសលប់ឡើយ ។

(បិដកលេខ២៩ ទំព័រ ១២៣)

## ២ សេចក្តីអស្ចារ្យរបស់ព្រះមានព្រះភាគ

ព្រះសារីបុត្រមានប្រាជ្ញាច្រើន ជាអ្នកឈ្លាសក្នុងសមាធិនិងឈាន ឋិតនៅលើភ្នំគិជ្ឈកូដ ឃើញព្រះលោកនាយក ។ សំឡឹងមើលព្រះសម្ពុទ្ធទ្រង់ប្រសើរជាងនរៈ ហាក់ដូចជាដើមរាំងភ្នំ ដែលមានផ្ការីកស្គុះស្គាយ ដូចព្រះចន្ទកណ្តាលអាកាស ឬ ដូចជាព្រះអាទិត្យត្រង់ជាក់ ។ ឃើញព្រះលោកនាយក មានរស្មី

ផ្សាយចេញមួយព្យាមរុងរឿងដូចឈើប្រចាំទ្វីប ឬ ដូចព្រះអាទិត្យស្រទន់ ដែលទើបនឹងរះឡើង ។ ខណៈនោះ ព្រះសារីបុត្រ បានប្រជុំពួកភិក្ខុចំនួន ៥០០ រូប ជាអ្នកមានសោឡសកិច្ចធ្វើហើយ ជាតាទិបុគ្គល ជាព្រះខីណាស្រព ប្រាសចាកមន្ទិល ហើយសំដែងនូវបាដិហារិយៈ ឈ្មោះ លោកប្បសាទនៈ ថា"ពួកយើងនឹងទៅក្នុងទីនោះ ហើយថ្វាយបង្គំព្រះជិនស្រី ។ លោកទាំងឡាយចូរមក យើងទាំងអស់គ្នានឹងទៅសាកសួរព្រះជិនស្រី បានជួបព្រះលោកនាយកហើយ នឹងបន្ទោបង់នូវសេចក្តីសង្ស័យ" ។ ព្រះមុនីទ្រង់ឈ្លាសក្នុងពាក្យឧបមា ទ្រង់ជ្រាបនូវចិត្តនៃភិក្ខុទាំងឡាយនុ៎ះ ទ្រង់មានព្យាយាមធំ កាត់នូវសេចក្តីសង្ស័យ ទ្រង់សំដែងនូវគុណរបស់ព្រះអង្គ ។ ទីបំផុតនៃអសង្ខេយ្យទាំងឡាយណា ដែលបុគ្គលដឹងមិនបាន អសង្ខេយ្យទាំងនោះ មាន ៤ ប្រការ អសង្ខេយ្យទាំងនុ៎ះគឺ ពួកសត្វ ១ អាកាស ១ ចក្កវាឡមិនមានទីបំផុត ១ ពុទ្ធញ្ញាណដែលប្រមាណមិនបាន ១ បុគ្គលមិនអាចដឹងបានឡើយ ។ (ព្រះសាស្តាទ្រង់ត្រាស់ថា) "ការដែលតថាគតធ្វើឫទ្ធិប្លែកៗណា ការធ្វើឫទ្ធិប្លែកៗនុ៎ះនឹងទុកជាហេតុអស្ចារ្យក្នុងលោក ដូចម្តេចបាន ព្រោះហេតុជាអស្ចារ្យចម្លែកគួរព្រឺរោមដទៃទៀតនៅមានច្រើន ។ កាលដែលតថាគតនៅជាទេវបុត្រ ឈ្មោះ សន្តុសិតៈ ក្នុងពួកទេវបុត្រជាន់តុសិត កាលនោះ ទេវតាមួយហ្មឺនលោកធាតុមកប្រជុំគ្នា ធ្វើអញ្ជលីអារាធនាតថាគតថា បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះគួរដល់ព្រះអង្គហើយ សូមព្រះអង្គទ្រង់កើតក្នុងផ្ទៃនៃព្រះមាតា ចម្លងមនុស្សលោកព្រមទាំងទេវលោក សូមទ្រង់ត្រាស់ដឹងនូវព្រះនិព្វាន ឈ្មោះ អមតៈ ។ កាលណា តថាគតច្យុតចាកពួកទេវតាជាន់តុសិត មកចាប់បដិសន្ធិក្នុងផ្ទៃ (នៃព្រះមាតា) កាលនោះ លោកធាតុមួយ

ហ្មឺននិងព្រះធរណីញាប់ញ័រ ។ កាលដែលតថាគត ប្រសូតចាកផ្ទៃព្រះមាតា ក៏ដឹងខ្លួនច្បាស់លាស់ ពួកទេវតាញ៉ាំងសាធុការឱ្យប្រព្រឹត្តទៅ លោកធាតុមួយហ្មឺនញាប់ញ័រ ។ តថាគតមិនមានបុគ្គលស្មើក្នុងការចុះកាន់គភ៌ព្រះមាតានៃតថាគត ជាបុគ្គលប្រសើរបំផុត ក្នុងការប្រសូតចាកផ្ទៃមាតា ក្នុងការត្រាស់ដឹង និង ការញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ។ ឱ! ព្រះពុទ្ធទាំងឡាយមានគុណដ៏ធំ ជាអស្ចារ្យក្នុងលោកពេកណាស់ លោកធាតុមួយហ្មឺនញាប់ញ័រអស់វារៈ ៦ លើក។ ពន្លឺដ៏ធំក៏កើតមានទាំងសេចក្តីអស្ចារ្យ គួរព្រឺរោមក៏កើតឡើង" ។

បិដកលេខ ៧៧ ទំព័រ ១៤

## ពុទ្ធវង្ស

ព្រះសម្ពុទ្ធទ្រង់ប្រកាសនូវរឿង[១] ដែលព្រះជិនស្រីជាអតីតពុទ្ធទាំងឡាយទ្រង់សំដែងចងទុកហើយ ដែលជាប់តមកតាំងពីព្រះពុទ្ធទីបង្ករ ជាប្រយោជន៍ក្នុងលោក ព្រមទាំងទេវលោក ដោយប្រាជ្ញាដែលប្រព្រឹត្តទៅតាមបុព្វេនិវាស ។ អ្នកទាំងឡាយ ចូរតាំងចិត្តប្រុងស្តាប់ (នូវពុទ្ធវង្សទេសនា) របស់តថាគត ជាគ្រឿងញ៉ាំងបីតិនិងបាមោជ្ជៈឱ្យកើតបន្ទោបង់នូវសរ គឺសេចក្តីសោកបានជាហេតុបាននូវសម្បត្តិទាំងពួង អ្នកទាំងឡាយ ចូរប្រតិបត្តិនូវមគ្គជាគ្រឿងញ៉ាំញីនូវសេចក្តីស្រវឹង បន្ទោបង់នូវសេចក្តីសោកអាចដោះខ្លួនឱ្យរួចចាកសង្សារ ជាគ្រឿងអស់ទៅនៃទុក្ខទាំងពួងបានដោយគោរពចុះ។

---

[១] រឿងដែលលោកចងទុកគឺ គោត្ត អាយុ ដើមពោធិព្រឹក្ស សាវ័ក សាវិកា សន្និបាត ឧបដ្ឋាក មាតា បិតា បុត្រ ភរិយា ជាដើម។ អដ្ឋកថា។

# ៤ ពុទ្ធវង្សសង្ខេប តារាងទី ១

| ល.រ | នាមព្រះពុទ្ធ | មានជាតិជា | ឈ្មោះព្រះនគរ | ព្រះបិតា | ព្រះមាតា |
|---|---|---|---|---|---|
| ១ | ព្រះពុទ្ធទីបង្ករ | ក្សត្រ | រម្មាវតី | សុទេវៈ | សុមេធា |
| ២ | ព្រះពុទ្ធកោណ្ឌញ្ញៈ | ក្សត្រ | រម្មវតី | សុនន្ទៈ | សុជាតាទេវី |
| ៣ | ព្រះពុទ្ធមង្គលៈ | ក្សត្រ | ឧត្តរៈ | ឧត្តរៈ | ឧត្តរា |
| ៤ | ព្រះពុទ្ធសុមនៈ | ក្សត្រ | ទីក្រុងមេខលៈ | សុទត្តៈ | សិរិមា |
| ៥ | ព្រះពុទ្ធរេវតៈ | ក្សត្រ | ទីក្រុងសុធញ្ញកៈ | វិបុលៈ | វិបុលា |
| ៦ | ព្រះពុទ្ធសោភិតៈ | ក្សត្រ | សុធម្មៈ | សុធម្មៈ | សុធម្មា |
| ៧ | ព្រះអនោមទស្សី | ក្សត្រ | ចន្ទវតី | យសវា | យសោធរា |
| ៨ | ព្រះពុទ្ធបទុមៈ | ក្សត្រ | ចម្បកៈ | អសមៈ | អសមា |
| ៩ | ព្រះពុទ្ធនារទៈ | បុត្រស្ដេចចក្រ | ធញ្ញវតី | សុទេវៈ | អនោមា |
| ១០ | ព្រះពុទ្ធបទុមុត្តរៈ | ក្សត្រ | ហង្សវតី | អានន្ទៈ | សុជាតា |
| ១១ | ព្រះពុទ្ធសុមេធៈ | ក្សត្រ | សុទស្សនៈ | សុទត្តៈ | សុទត្តា |
| ១២ | ព្រះពុទ្ធសុជាតៈ | ក្សត្រ | សុមង្គលៈ | ឧគ្គតៈ | បភាវតី |
| ១៣ | ព្រះពុទ្ធបិយទស្សី | ក្សត្រ | សុធញ្ញៈ | សុទត្តៈ | សុចន្ទា |
| ១៤ | ព្រះពុទ្ធអត្ថទស្សី | ក្សត្រ | ទីក្រុងសោភណៈ | សាគរៈ | សុទស្សនា |
| ១៥ | ព្រះពុទ្ធធម្មទស្សី | ក្សត្រ | ទីក្រុងសរណៈ | សរណៈ | សុនន្ទា |
| ១៦ | ព្រះពុទ្ធសិទ្ធត្ថៈ | ក្សត្រ | ទីក្រុងវេភារៈ | ឧទេនៈ | សុផស្សា |
| ១៧ | ព្រះពុទ្ធតិស្សៈ | ក្សត្រ | ទីក្រុងខេមកៈ | ជនសន្ធៈ | បទុមា |
| ១៨ | ព្រះពុទ្ធបុស្សៈ | ក្សត្រ | កាសិកៈ | ជយសេន | សិរិមា |
| ១៩ | ព្រះពុទ្ធវិបស្សី | ក្សត្រ | ពន្ធុមតី | ពន្ធុមៈ | ពន្ធុមតី |
| ២០ | ព្រះពុទ្ធសិខី | ក្សត្រ | អរុណវតី | អរុណៈ | បភាវតី |
| ២១ | ព្រះពុទ្ធវេស្សភូ | ក្សត្រ | អនោម | សុប្បតិតៈ | យសវតី |
| ២២ | ព្រះពុទ្ធកកុសន្ធៈ | ព្រាហ្មណ៍ | ខេមបូរី | អគ្គិទត្តព្រាហ្មណ៍ | វិសាខា |
| ២៣ | ព្រះកោនាគមនៈ | ព្រាហ្មណ៍ | សោភវតី | យញ្ញទត្តព្រាហ្មណ៍ | ឧត្តរា |
| ២៤ | ព្រះពុទ្ធកស្សបៈ | ព្រាហ្មណ៍ | ពារាណសី | ព្រហ្មទត្តព្រាហ្មណ៍ | ធនវតី |
| ២៥ | ព្រះពុទ្ធគោតម | ក្សត្រ | កបិលពស្តុ | សុទ្ធោទនៈ | មាយាទេវី |

# តារាងទី ២

| នាមព្រះពុទ្ធ | គ្រប់គ្រងផ្ទះ | មានប្រាសាទដ៏ប្រសើរ ៣ ខ្នង | | |
|---|---|---|---|---|
| | | ទី១ឈ្មោះ | ទី២ឈ្មោះ | ទី៣ឈ្មោះ |
| ព្រះពុទ្ធទីបង្ករ | ១ ម៉ឺនឆ្នាំ | ហង្សប្រាសាទ | កោញ្ចប្រាសាទ | មយុរប្រាសាទ |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ១ ម៉ឺនឆ្នាំ | រុចិ | សុរុចិ | សុភ |
| ព្រះពុទ្ធមង្គលៈ | ៩ ពាន់ឆ្នាំ | យសវ | សុចិម | សិរិម |
| ព្រះពុទ្ធសុមនៈ | ៩ ពាន់ឆ្នាំ | ចន្ទ | សុចន្ទ | វដំស |
| ព្រះពុទ្ធរេវតៈ | ៦ ពាន់ឆ្នាំ | សុទស្សន | រតនគ្ឃិ | អាវេឡ |
| ព្រះពុទ្ធសោភិតៈ | ៩ ពាន់ឆ្នាំ | កុមុទ | នឡិនី | បទុម |
| ព្រះពុទ្ធអនោមទស្សី | ១ ម៉ឺនឆ្នាំ | សិរី | ឧបសិរី | វឌ្ឍ |
| ព្រះពុទ្ធបទុមៈ | ១ ម៉ឺនឆ្នាំ | នន្ទ | វសុ | យសត្តរ |
| ព្រះពុទ្ធនារទៈ | ៩ ពាន់ឆ្នាំ | ជិត | វិជិត | អភិរាម |
| ព្រះពុទ្ធបទុមុត្តរៈ | ៩ ពាន់ឆ្នាំ | នារិ | ពាហន | យសវតី |
| ព្រះពុទ្ធសុមេធៈ | ៩ ពាន់ឆ្នាំ | សុចន្ទ | កញ្ចន | សិរិវឌ្ឍ |
| ព្រះពុទ្ធសុជាតៈ | ៩ ពាន់ឆ្នាំ | សិរិ | ឧបសិរិ | ចន្ទ |
| ព្រះពុទ្ធបិយទស្សី | ៩ ពាន់ឆ្នាំ | សុនិម្មល | វិមល | គិរិគូហា |
| ព្រះពុទ្ធអត្ថទស្សី | ៩ ពាន់ឆ្នាំ | អមរគិ | សុរគិ | គិរិពាហន |
| ព្រះពុទ្ធធម្មទស្សី | ៨ ពាន់ឆ្នាំ | អរជ | វិរជ | សុទស្សន |
| ព្រះពុទ្ធសិទ្ធត្ថៈ | ១ ម៉ឺនឆ្នាំ | កោកាស | ឧប្បល | កោកនុទ |
| ព្រះពុទ្ធតិស្សៈ | ៧ពាន់ឆ្នាំ | គុណសេលៈ | អនាទិយ | និសភ |
| ព្រះពុទ្ធបុស្សៈ | ៩ ពាន់ឆ្នាំ | គរុឡ | ហំស | សុវណ្ណតារ |
| ព្រះពុទ្ធវិបស្សី | ៨ ពាន់ឆ្នាំ | នន្ទ | សនន្ទ | សិរិម |
| ព្រះពុទ្ធសិខី | ៧ ពាន់ឆ្នាំ | សុវឌ្ឍក | គិរិ | នារីវាហន |
| ព្រះពុទ្ធវេស្សភូ | ៦ ពាន់ឆ្នាំ | រុចិ | សុរតិ | វឌ្ឍក |
| ព្រះពុទ្ធកកុសន្ធៈ | ៤ ពាន់ឆ្នាំ | កាមវឌ្ឍ | កាមសុទ្ធិ | រតិវឌ្ឍន |
| ព្រះពុទ្ធកោនាគមនៈ | ៣ ពាន់ឆ្នាំ | តុសិត | សន្តុសិត | សន្តុដ្ឋ |
| ព្រះពុទ្ធកស្សបៈ | ២ ពាន់ឆ្នាំ | ហំស | យស | សិរិចន្ទ |
| ព្រះពុទ្ធគោតម | ២៩ ឆ្នាំ | សុចន្ទ | កោកនុទ | កោញ្ច |

## តារាងទី ៣

| នាមព្រះពុទ្ធ | ស្ត្រីបំរើ | អគ្គមហេសី | ព្រះឱរសនាម | យាងទៅបួសដោយ |
|---|---|---|---|---|
| ព្រះពុទ្ធទីបង្ករ | ៣ សែនរូប | បទុមា | ឱសភក្ខន្ធ | យានដំរី |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ៣ សែនរូប | រុចិទេវី | ជីវិតសេន | យានរថ |
| ព្រះពុទ្ធមង្គលៈ | ៣ ម៉ឺនរូប | យសវតី | សវលៈ | យានសេះ |
| ព្រះពុទ្ធសុមនៈ | ៦៣ សែនរូប | វដំសកី | អនូបមំ | យានដំរី |
| ព្រះពុទ្ធរេវតៈ | ៣៣ សែនរូប | សុទស្សនា | វរុណៈ | យានរថ |
| ព្រះពុទ្ធសោភិតៈ | ៤ ពាន់រូប | កិមិលា | សីហៈ | ប្រាសាទ |
| ព្រះពុទ្ធអនោមទស្សី | ២៣ ពាន់រូប | សិរិមា | ឧបសាលៈ | គ្រែស្នែង |
| ព្រះពុទ្ធបទុមៈ | ៣៣ ពាន់រូប | ឧត្តរា | រម្ម | យានរថ |
| ព្រះពុទ្ធនារទៈ | ៣-៤ ពាន់រូប | វិជិតសេនា | ននុត្តរ | ព្រះបាទផ្ទាល់ |
| ព្រះពុទ្ធបទុមុត្តរៈ | ៣-៤ ពាន់រូប | វសុលទត្តា | ឧត្តរៈ | ប្រាសាទ |
| ព្រះពុទ្ធសុមេធៈ | ១៦ ពាន់រូប | សុមនា | បុនព្វៈ | យានដំរី |
| ព្រះពុទ្ធសុជាតៈ | ២៣ ពាន់រូប | សិរិនន្ទា | ឧបសេន | យានសេះ |
| ព្រះពុទ្ធបិយទស្សី | ៣៣ ពាន់រូប | វិមលា | កញ្ចនាវេឡៈ | យានរថ |
| ព្រះពុទ្ធអត្ថទស្សី | ៣៣ពាន់រូប | វិសាខា | សេលៈ | យានសេះ |
| ព្រះពុទ្ធធម្មទស្សី | ៤០ ពាន់រូប | វិចិកោលី | បុញ្ញវឌ្ឍនៈ | ប្រាសាទ |
| ព្រះពុទ្ធសិទ្ធត្ថៈ | ៤៨ ពាន់រូប | សុមនា | អនុបមៈ | គ្រែស្នែង |
| ព្រះពុទ្ធតិស្សៈ | ៣០ ពាន់រូប | សុភទ្រា | អានន្ទៈ | យានសេះ |
| ព្រះពុទ្ធបុស្សៈ | ២៣ ពាន់រូប | កីសាគោតមី | អានន្ទៈ | យានដំរី |
| ព្រះពុទ្ធវិបស្សី | ៤៣ ពាន់រូប | សុទស្សនា | សមវត្តក្ខន្ធៈ | យានរថ |
| ព្រះពុទ្ធសិខី | ២៤ ពាន់រូប | សព្វកាមា | អតុលៈ | យានដំរី |
| ព្រះពុទ្ធវេស្សភូ | ៣០ ពាន់រូប | សុចិត្តា | សុប្បពុទ្ធៈ | គ្រែស្នែង |
| ព្រះពុទ្ធកកុសន្ធៈ | ៣០ ពាន់រូប | រោបិនី | ឧត្តរៈ | យានរថ |
| ព្រះពុទ្ធកោនាគមនៈ | ១៦ ពាន់រូប | រុចិគត្តា | សត្ថវាហៈ | យានដំរី |
| ព្រះពុទ្ធកស្សបៈ | ៤៨ ពាន់រូប | សុនន្ទា | វិជិតសេនៈ | ប្រាសាទ |
| ព្រះពុទ្ធគោតម | ៤០ ពាន់រូប | យសោធរា | រាហុល | យានសេះ |

# តារាងទី ៤

| នាមព្រះពុទ្ធ | ព្យាយាមអស់ | ឈើព្រះអង្គត្រាស់ដឹង | ព្រះរស្មីប្រមាណ |
|---|---|---|---|
| ព្រះពុទ្ធទីបង្ករ | ១០ ខែឥតខ្វះ | ដើមល្មៀប | ១០ យោជន៍សព្វកាល |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ១០ ខែឥតខ្វះ | សាលកល្យាណិព្រឹក្ស | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធមង្គលៈ | ៨ ខែឥតខ្វះ | នាគព្រឹក្ស (ដើមខ្លឹង) | ១ ម៉ឺនលោកធាតុសព្វកាល |
| ព្រះពុទ្ធសុមនៈ | ១០ ខែឥតខ្វះ | នាគព្រឹក្ស (ដើមខ្លឹង) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធរេវតៈ | ៧ ខែឥតខ្វះ | នាគព្រឹក្ស (ដើមខ្លឹង) | ១ យោជន៍សព្វកាល |
| ព្រះពុទ្ធសោភិតៈ | ៧ ថ្ងៃ | នាគព្រឹក្ស (ដើមខ្លឹង) | រស្មីប្រមាណមិនបាន |
| ព្រះអនោមទស្សី | ១០ ខែឥតខ្វះ | អជ្ជុនព្រឹក្ស (ដើមអង្គ្រង) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធបទុមៈ | ៨ ខែគត់ | មហាសោណៈ (ដើមម្រុំ) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធនារទៈ | ៧ ថ្ងៃ | មហាសោណ (ដើមម្រុំ) | ១ យោជន៍សព្វកាល |
| ព្រះពុទ្ធបទុមុត្តរៈ | ៧ ថ្ងៃ | (ដើមស្រល់) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធសុមេធៈ | ៨ ខែគត់ | និម្ពព្រឹក្ស (ដើមស្ដៅ) | ១ យោជន៍សព្វកាល |
| ព្រះពុទ្ធសុជាតៈ | ៩ ខែគត់ | (ឫស្សីធំ) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធបិយទស្សី | ៦ ខែគត់ | កកុធព្រឹក្ស (ដើមថ្ងាន់) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធអត្ថទស្សី | ៨ ខែគត់ | ចម្បកព្រឹក្ស (ដើមចម្បា) | ១ យោជន៍សព្វកាល |
| ព្រះពុទ្ធធម្មទស្សី | ៧ ថ្ងៃ | (ដើមទន្លាប់) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធសិទ្ធត្ថៈ | ១០ ខែគត់ | កណ្ណិការព្រឹក្ស | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធតិស្សៈ | កន្លះខែគត់ | អសន (ដើមធ្នង់) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធបុស្សៈ | ៧ ថ្ងៃ | (ដើមកន្ទួតព្រៃ) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធវិបស្សី | ៨ ខែគត់ | បាដលិព្រឹក្ស (សង្កែ) | ៧ យោជន៍សព្វកាល |
| ព្រះពុទ្ធសិខី | ៨ ខែគត់ | បុណ្ឌរីកព្រឹក្ស (ស្វាយស) | រស្មី ៣ យោជន៍ជានិច្ច |
| ព្រះពុទ្ធវេស្សភូ | ៦ ខែ | មហាសាលព្រឹក្ស | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធកកុសន្ធៈ | ៨ ខែគត់ | សិរិសព្រឹក្ស (ច្រេស) | ១០ យោជន៍សព្វកាល |
| ព្រះកោនាគមនៈ | ៦ ខែ | ឧទុម្ពរព្រឹក្ស (ល្វា) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធកស្សបៈ | ៧ ថ្ងៃ | និគ្រោធព្រឹក្ស (ជ្រៃ) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធគោតម | ទុក្ករកិរិយា ៦ វស្សា | (ពោធិបាយ) | រស្មី ១ ព្យាមជានិច្ច |

# តារាងទី ៥

| នាមព្រះពុទ្ធ | សំដែងធម្មចក្រក្នុងទី | ញ៉ាំងពពួកសត្វឱ្យត្រាស់ដឹង ៣ លើក | | |
|---|---|---|---|---|
| | | លើកទី១ចំនួន | លើកទី២ចំនួន | លើកទី៣ចំនួន |
| ព្រះពុទ្ធទីបង្ករៈ | នន្ទារាម | ១០០កោដិទេវតា | ៩០ កោដិ | ៩០ កោដិ(ទេវតា) |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | | ១ សែនកោដិ | ៩០ ពាន់កោដិ | ៨០ ពាន់កោដិ |
| ព្រះពុទ្ធមង្គលៈ | | ១ សែនកោដិ | ១ សែនកោដិ | ៩០ កោដិ ឯហិភិក្ខុ |
| ព្រះពុទ្ធសុមនៈ | | ១ សែនកោដិ | ១ សែនកោដិ | ៩០ ពាន់កោដិ |
| ព្រះពុទ្ធរេវតៈ | | ច្រើនហួសគណនា | ១ ពាន់កោដិ | ១ រយកោដិ |
| ព្រះពុទ្ធសោភិតៈ | | ច្រើនហួសគណនា | ៩ ម៉ឺនកោដិ | ១ ពាន់កោដិ |
| ព្រះអនោមទស្សី | ឱទ្យានសុទស្សនៈ | ១ រយកោដិ | ៨០ កោដិ | ៧៨ កោដិ |
| ព្រះពុទ្ធបទុមៈ | | ១ រយកោដិ | ៩០ កោដិ | ៨០ កោដិ |
| ព្រះពុទ្ធនារទៈ | ឱទ្យានធនញ្ជៈ | ១ សែនកោដិ | ៩០ ពាន់កោដិ | ៨០ កោដិ |
| ព្រះពុទ្ធបទុមុត្តរៈ | ឱទ្យានមិថិលា | ១ សែនកោដិ | ៣៧ ពាន់ | ៥ លាន |
| ព្រះពុទ្ធសុមេធៈ | ឱទ្យានសុទស្សនៈ | ១ សែនកោដិ | ៩០ ពាន់កោដិ | ៨០ ពាន់កោដិ |
| ព្រះពុទ្ធសុជាតៈ | ឱទ្យានសុមង្គល | ៨០ កោដិ | ៣៧ សែន | ៦០ សែន |
| ព្រះពុទ្ធបិយទស្សី | ឱទ្យានឧសភៈ | ១ សែនកោដិ | ៩ ពាន់កោដិ | ៨០ កោដិ |
| ព្រះពុទ្ធអត្ថទស្សី | ឱទ្យាន | ១ សែនកោដិ | ១ សែនកោដិ | ១ សែនកោដិ |
| ព្រះពុទ្ធធម្មទស្សី | មិគទាយវ័ន | ១ សែនកោដិ | ៩០ កោដិ | ៨០ កោដិ |
| ព្រះពុទ្ធសិទ្ធត្ថៈ | មិគទាយវ័ន | ១ សែនកោដិ | ៩០ កោដិ | ៩០ កោដិ |
| ព្រះពុទ្ធតិស្សៈ | មិគទាយវ័ន | ១ រយកោដិ | ៩០ កោដិ | ៦០ កោដិ |
| ព្រះពុទ្ធបុស្សៈ | មិគទាយវ័ន | ៨០ សែន | ៩០ សែន | ៨០ សែន |
| ព្រះពុទ្ធវិបស្សី | មិគទាយវ័ន | ច្រើនហួសគណនា | ៨៤ ពាន់ | ៨៤ ពាន់ |
| ព្រះពុទ្ធសិខី | មិគទាយវ័ន | ១ សែនកោដិ | ៩០ ពាន់កោដិ | ៨០ ពាន់កោដិ |
| ព្រះពុទ្ធវេស្សភូ | | ៨ ម៉ឺនកោដិ | ៧០ ពាន់កោដិ | ៦០ កោដិ |
| ព្រះពុទ្ធកកុសន្ធៈ | មិគទាយវ័ន | ៤ ម៉ឺនកោដិ | ៣ ម៉ឺនកោដិ | ច្រើនហួសគណនា |
| ព្រះកោនាគមនៈ | មិគទាយវ័ន | ៣ ម៉ឺនកោដិ | ២ ម៉ឺនកោដិ | ១ ម៉ឺនកោដិ |
| ព្រះពុទ្ធកស្សបៈ | មិគទាយវ័ន | ២ ម៉ឺនកោដិ | ១ ម៉ឺនកោដិ | ៥ ពាន់កោដិ |
| ព្រះពុទ្ធគោតម | ឥសិបទនៈ | ១៨ កោដិ | ច្រើនហួសគណនា | ច្រើនហួសគណនា |

# តារាងទី ៦

| នាមព្រះពុទ្ធ | ជួបជុំ សាវ័ក សន្និបាត ៣ លើក | | | ភិក្ខុជាឧបដ្ឋាក |
|---|---|---|---|---|
| | លើកទី១ ចំនួន | លើកទី២ចំនួន | លើកទី៣ចំនួន | |
| ព្រះពុទ្ធទីបង្ករៈ | ១ សែនកោដិ | ១ រយកោដិ | ៩០ កោដិ | សាគតៈ |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ១ សែនកោដិ | ១ ពាន់កោដិ | ៩០ កោដិ | អនុរុទ្ធៈ |
| ព្រះពុទ្ធមង្គលៈ | ១ កោដិ | ១ សែនកោដិ | ៩០ កោដិ | បាលិតៈ |
| ព្រះពុទ្ធសុមនៈ | ១ សែនកោដិ | ៩០ កោដិ | ៨០ កោដិ | ឧទេនៈ |
| ព្រះពុទ្ធរេវតៈ | ច្រើនហួសគណនា | ១ សែនកោដិ | ១ សែនកោដិ | សម្ភវៈ |
| ព្រះពុទ្ធសោភិតៈ | ១ រយកោដិ | ៩០ កោដិ | ៨០ កោដិ | អនោមៈ |
| ព្រះពុទ្ធអនោមទស្សី | ៨ សែន | ៧ សែន | ៦ សែន | វរុណៈ |
| ព្រះពុទ្ធបទុមៈ | ១ សែនកោដិ | ៣ សែន | ២ សែន | វរុណៈ |
| ព្រះពុទ្ធនារទៈ | ១ សែនកោដិ | ៩០ ពាន់កោដិ | ៨០ សែន | វាសេដ្ឋៈ |
| ព្រះពុទ្ធបទុមុត្តរៈ | ១ សែនកោដិ | ៩០ ពាន់កោដិ | ៨០ ពាន់កោដិ | សុមនៈ |
| ព្រះពុទ្ធសុមេធៈ | ១ រយកោដិ | ៩០ កោដិ | ៨០ កោដិ | សាគរៈ |
| ព្រះពុទ្ធសុជាតៈ | ៦០ សែន | ៥០ សែន | ៤ សែន | នារទៈ |
| ព្រះពុទ្ធបិយទស្សី | ១ សែនកោដិ | ៩០ កោដិ | ៨០ កោដិ | សោភិតៈ |
| ព្រះពុទ្ធអត្ថទស្សី | ៩៨ ពាន់អង្គ | ៨៨ ពាន់ | ៧៨ ពាន់ | អភយៈ |
| ព្រះពុទ្ធធម្មទស្សី | ១ ពាន់កោដិ | ១ រយកោដិ | ៨០ កោដិ | សុទត្តត្ថេរៈ |
| ព្រះពុទ្ធសិទ្ធត្ថៈ | ១ រយកោដិ | ៩០ កោដិ | ៨០ កោដិ | រេវតៈ |
| ព្រះពុទ្ធតិស្សៈ | ១ សែនអង្គ | ៩០ សែន | ៨០ សែន | សមតៈ |
| ព្រះពុទ្ធបុស្សៈ | ៦០ សែន | ៥០ សែន | ៤០ សែន | សភិយៈ |
| ព្រះពុទ្ធវិបស្សី | ៦៨ សែន | ១ សែន | ៨ ម៉ឺន | អសោកៈ |
| ព្រះពុទ្ធសិខី | ១ សែន | ៨ ម៉ឺន | ៧ ម៉ឺន | ខេមង្ករៈ |
| ព្រះពុទ្ធវេស្សភូ | ៨០ ពាន់កោដិ | ៧០ ពាន់កោដិ | ៦០ ពាន់កោដិ | ឧបសន្តៈ |
| ព្រះពុទ្ធកកុសន្ធៈ | ៤ ម៉ឺន | | | ពុទ្ធិជៈ |
| ព្រះពុទ្ធកោនាគមនៈ | ៣ ម៉ឺន | | | សោត្ថិជៈ |
| ព្រះពុទ្ធកស្សបៈ | ២ ម៉ឺន | | | សព្វមិត្ត |
| ព្រះពុទ្ធគោតម | ១២៥០ អង្គ | | | អានន្ទៈ |

## តារាងទី ៧

| នាមព្រះពុទ្ធ | អគ្គសាវ័ក | | អគ្គសាវិកា | |
|---|---|---|---|---|
| | ទី១ ព្រះនាម | ទី២ ព្រះនាម | ទី១ ព្រះនាម | ទី២ ព្រះនាម |
| ព្រះពុទ្ធទីបង្ករៈ | សុមង្គលៈ | តិស្សៈ | នន្ទា | សុនន្ទា |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ភទ្ទៈ | សុភទ្ទៈ | តិស្សា | ឧបតិស្សា |
| ព្រះពុទ្ធមង្គលៈ | សុទេវៈ | ធម្មសេនៈ | សីវលា | អសោកា |
| ព្រះពុទ្ធសុមនៈ | សរណៈ | ភាវិតត្តៈ | សោណា | ឧបសោណា |
| ព្រះពុទ្ធរេវតៈ | វរុណៈ | ព្រហ្មទេវៈ | ភទ្ទា | សុភទ្ទា |
| ព្រះពុទ្ធសោភិតៈ | អសមៈ | សុនេត្តៈ | នកុលា | សុជាតា |
| ព្រះពុទ្ធអនោមទស្សី | និសភៈ | អនោមៈ | សុន្ទរា | សុមនា |
| ព្រះពុទ្ធបទុមៈ | សាលៈ | ឧបសាលៈ | រាធា | សុរាធា |
| ព្រះពុទ្ធនារទៈ | ភទ្ទសាលៈ | ជិតមិតៈ | ឧត្តរា | ផគ្គុនី |
| ព្រះពុទ្ធបទុមុត្តរៈ | ទេវិល | សុជាតៈ | អមិតា | អសមា |
| ព្រះពុទ្ធសុមេធៈ | សរណៈ | សព្វកាមៈ | រាមា | សុរាមា |
| ព្រះពុទ្ធសុជាតៈ | សុទស្សនៈ | សុទេវៈ | នាគា | នាគសមានា |
| ព្រះពុទ្ធបិយទស្សី | បាលិតៈ | សព្វទស្សី | សុជាតា | ធម្មទិន្នា |
| ព្រះពុទ្ធអត្ថទស្សី | សន្តៈ | ឧបសន្តៈ | ធម្មា | សុធម្មា |
| ព្រះពុទ្ធធម្មទស្សី | បទុមត្ថេរៈ | បុស្សទេវត្ថេរៈ | ខេមា | សច្ចនាមា |
| ព្រះពុទ្ធសិទ្ធត្ថៈ | សម្ពលត្ថេរៈ | សុមិត្តត្ថេរៈ | សីវលា | សុរាមា |
| ព្រះពុទ្ធតិស្សៈ | ព្រហ្មទេវត្ថេរៈ | ឧទយត្ថេរៈ | ផុស្សា | សុទត្តា |
| ព្រះពុទ្ធបុស្សៈ | សុរក្ខិតៈ | ធម្មសេនៈ | ចាលា | ឧបចាលា |
| ព្រះពុទ្ធវិបស្សី | ខន្ទៈ | តិស្សៈ | ចន្ទា | ចន្ទមិត្តា |
| ព្រះពុទ្ធសិខី | អភិភូ | សម្ភវៈ | មខិលា | បទុមា |
| ព្រះពុទ្ធវេស្សភូ | សោណៈ | ឧត្តរៈ | រាមា | សមានា |
| ព្រះពុទ្ធកកុសន្ធៈ | វិធុរៈ | សញ្ជីវៈ | សាមា | ចម្បា |
| ព្រះពុទ្ធកោនាគមនៈ | ភិយ្យោសៈ | ឧត្តរៈ | សុមុទ្ទា | ឧត្តរា |
| ព្រះពុទ្ធកស្សបៈ | តិស្សៈ | ភារទ្វាជៈ | អនុលា | ឧរុវេលា |
| ព្រះពុទ្ធគោតម | កោលិតៈ | ឧបតិស្សៈ | ខេមា | ឧប្បលវណ្ណា |

# តារាងទី ៨

| នាមព្រះពុទ្ធ | ឧបាសកជាឧបដ្ឋាក ២រូប | | ឧបាសិកាជាឧបដ្ឋាយិកា | | បល្ល័ង្កកំពស់ |
|---|---|---|---|---|---|
| | នាម | នាម | នាម | នាម | |
| ព្រះពុទ្ធទីបង្ករ: | តបុស្ស: | ភល្លុក: | សិរិមា | សោណា | ៥៣ ហត្ថ |
| ព្រះពុទ្ធកោណ្ឌញ្ញ: | សោណ: | ឧបសោណ: | នន្ទា | សិរិមា | ៥៧ ហត្ថ |
| ព្រះពុទ្ធមង្គល: | នន្ទ: | វិសាខ: | អនុឡា | សុមនា | ៥៧ ហត្ថ |
| ព្រះពុទ្ធសុមន: | វរុណ: | សរណ: | ចាលា | ឧបចាលា | ៦០ ហត្ថ |
| ព្រះពុទ្ធរេវត: | វរុណ: | សរភ: | បាលា | ឧបបាលា | ៥៣ ហត្ថ |
| ព្រះពុទ្ធសោភិត: | រម្ម: | សុនេត្ត: | នកុលា | ចិត្តា | ៣៨ ហត្ថ |
| ព្រះពុទ្ធអនោមទស្សី | នន្ទិវឌ្ឍ: | សិរិវឌ្ឍ: | ឧបលា | បទុមា | ៣៨ ហត្ថ |
| ព្រះពុទ្ធបទុម: | សភិយ: | អសម: | រុចិ | នន្ទិមារា | ៣៨ ហត្ថ |
| ព្រះពុទ្ធនារទ: | ឧគ្គិន្ទ: | វសភ: | ឥន្ទវរី | គណ្ឌី | ៥៧ ហត្ថ |
| ព្រះពុទ្ធបទុមុត្តរ: | អមិត: | តិស្ស: | ហត្ថា | សុចិត្តា | ៣៨ ហត្ថ |
| ព្រះពុទ្ធសុមេធ: | ឧរុវេល: | យសវ: | យសា | សិរិវា | ៥៧ ហត្ថ |
| ព្រះពុទ្ធសុជាត: | សុទត្ត: | ចិត្ត: | សុភទ្ទា | បទុមា | ៣២ ហត្ថ |
| ព្រះពុទ្ធបិយទស្សី | សន្ទក: | ធម្មិក: | វិសាខា | ធម្មទិន្នា | ៥៣ ហត្ថ |
| ព្រះពុទ្ធអត្ថទស្សី | អកុឡ: | និសភ: | មកិលា | សុនន្ទា | ៥៣ ហត្ថ |
| ព្រះពុទ្ធធម្មទស្សី | សុភទ្ទ: | កដិស្ស: | សាឡិសា | កឡិស្សា | ៥៣ ហត្ថ |
| ព្រះពុទ្ធសិទ្ធត្ថ: | សុប្បិយ: | សម្មុទ្ទ: | រម្មា | សុរម្មា | ៤០ ហត្ថ |
| ព្រះពុទ្ធតិស្ស: | សម្ពល: | សិរិ | កិសាគោតមី | ឧបសេនា | ៤០ ហត្ថ |
| ព្រះពុទ្ធបុស្ស: | អនញ្ជ: | វិសាខ: | បទុមា | សិរិនាគា | ៣៨ ហត្ថ |
| ព្រះពុទ្ធវិបស្សី | បុនព្វសុមិត្ត: | នាគ: | សិរិមា | ឧត្តរា | ៥៣ ហត្ថ |
| ព្រះពុទ្ធសិខី | សិរិវឌ្ឍ: | នន្ទ: | ចិត្តា | សុចិត្តា | ៣២ ហត្ថ |
| ព្រះពុទ្ធវេស្សភូ | សោត្ថិក: | រម្ម: | គោតមី | សិរិមា | ៤០ ហត្ថ |
| ព្រះពុទ្ធកកុសន្ធ: | អច្ចុគ្គត: | សុមន: | នន្ទា | សុនន្ទា | ២៦ ហត្ថ |
| ព្រះពុទ្ធកោនាគមន: | ឧគ្គ: | សោមទេវ: | សីវលា | សាមា | ២០ ហត្ថ |
| ព្រះពុទ្ធកស្សប: | សុមង្គល: | ឃដិការ: | វិជិតសេនា | ភទ្ទា | ១៥ ហត្ថ |
| ព្រះពុទ្ធគោតម | ចិត្ត: | ហត្ថាឡវក: | នន្ទមាតា | ឧត្តរា | ១៤ ហត្ថ |

# តារាងទី ៩

| នាមព្រះពុទ្ធ | មានកំពស់ | មានព្រះជន្ម | កន្លែងបរិនិព្វាន | ព្រះធាតុចេតិយ |
|---|---|---|---|---|
| ព្រះពុទ្ធទីបង្ករៈ | ៨០ ហត្ថ | ១ សែនឆ្នាំ | នន្ទារាម | កំពស់ ៣៦ យោជន៍ |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ៨៨ ហត្ថ | ១ សែនឆ្នាំ | នន្ទារាម | កំពស់ ៧ យោជន៍ |
| ព្រះពុទ្ធមង្គលៈ | ៨៨ ហត្ថ | ៩ ម៉ឺនឆ្នាំ | ឧទ្យានវេស្សរៈ | កំពស់ ៣០ យោជន៍ |
| ព្រះពុទ្ធសុមនៈ | ៩០ ហត្ថ | ៩ ម៉ឺនឆ្នាំ | អង្គារាម | កំពស់ ៤ យោជន៍ |
| ព្រះពុទ្ធរេវតៈ | ៨០ ហត្ថ | ៦ ម៉ឺនឆ្នាំ | | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធសោភិតៈ | ៥៨ ហត្ថ | ៩ ម៉ឺនឆ្នាំ | សីហារាម | ព្រះធាតុចែកជាចំណែក |
| ព្រះអនោមទស្សី | ៥៨ ហត្ថ | ១ សែនឆ្នាំ | ធម្មារាម | កំពស់ ២០ យោជន៍ |
| ព្រះពុទ្ធបទុមៈ | ៥៨ ហត្ថ | ១ សែនឆ្នាំ | ធម្មារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធនារទៈ | ៨៨ ហត្ថក្រពុំ | ៩ ម៉ឺនឆ្នាំគត់ | សុទស្សនបុរី | កំពស់ ៤ យោជន៍ |
| ព្រះពុទ្ធបទុមុត្តរៈ | ៥៨ ហត្ថក្រពុំ | ១ សែនឆ្នាំ | ននារាម | កំពស់ ១២ យោជន៍ |
| ព្រះពុទ្ធសុមេធៈ | ៨៨ ហត្ថក្រពុំ | ៩ ម៉ឺនឆ្នាំគត់ | មេធារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធសុជាតៈ | ៥០ ហត្ថក្រពុំ | ៩ ម៉ឺនឆ្នាំគត់ | សេលារាម | កំពស់ ៣ គាវុត |
| ព្រះពុទ្ធបិយទស្សី | ៨០ ហត្ថ | ៩ ម៉ឺនឆ្នាំ | អស្សត្ថារាម | កំពស់ ៣ យោជន៍ |
| ព្រះពុទ្ធអត្ថទស្សី | ៨០ ហត្ថ | ១ សែនឆ្នាំ | អនោមារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធធម្មទស្សី | ៨០ ហត្ថ | ១ សែនឆ្នាំ | កេសរាម | កំពស់ ៣ យោជន៍ |
| ព្រះពុទ្ធសិទ្ធត្ថៈ | ៦០ ហត្ថ | ១ សែនឆ្នាំ | អនោមារាម | កំពស់ ៤ យោជន៍ |
| ព្រះពុទ្ធតិស្សៈ | ៦០ ហត្ថ | ១ សែនឆ្នាំ | នន្ទារាម | កំពស់ ៣ យោជន៍ |
| ព្រះពុទ្ធបុស្សៈ | ៥៨ ហត្ថ | ៩ ម៉ឺនឆ្នាំ | សេនារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធវិបស្សី | ៨០ ហត្ថ | ៨ ម៉ឺនឆ្នាំ | សុមិត្តារាម | កំពស់ ៧ យោជន៍ |
| ព្រះពុទ្ធសិខី | ៧០ ហត្ថ | ៧ ម៉ឺនឆ្នាំ | អស្សារាម | កំពស់ ៣ យោជន៍ |
| ព្រះពុទ្ធវេស្សភូ | ៦០ ហត្ថ | ៦ ម៉ឺនឆ្នាំ | ខេមារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធកកុសន្ធៈ | ៤០ ហត្ថ | ៤ ម៉ឺនឆ្នាំ | ខេមារាម | កំពស់ ១ គាវុត |
| ព្រះកោនាគមនៈ | ៣០ ហត្ថ | ៣ ម៉ឺនឆ្នាំ | បព្វតារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធកស្សបៈ | ២០ ហត្ថ | ២ ម៉ឺនឆ្នាំ | សេតព្យារាម | កំពស់ ១ យោជន៍ |
| ព្រះពុទ្ធគោតម | ១៦ ហត្ថ | ១០០ ឆ្នាំ | នគរកុសិនារា | ព្រះធាតុចែកជាចំណែក |

# តារាងទី ១០

## ព្រះសមណគោតមបរមពោធិសត្វ កើតជួបនឹងព្រះពុទ្ធ ២៤ ព្រះអង្គ

| នាមព្រះពុទ្ធ | ព្រះបរមពោធិសត្វ | កប្បត្រូវបានត្រាស់ |
|---|---|---|
| ព្រះពុទ្ធទីបង្ករៈ | ជាព្រាហ្មណ៍ នាម សុមេធបណ្ឌិតតាបស | បួនអសង្ខេយ្យ ១សែនកប្ប |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ជាក្សត្រ នាម វិជិតាវី បានបួស | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធមង្គលៈ | ជាព្រាហ្មណ៍ នាម សុរុចិ បានបួស | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធសុមនៈ | ជាស្តេចនាគ នាម អតុលៈ រក្សាសីល | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធរេវតៈ | ជាព្រាហ្មណ៍ នាម អតិទេវ រក្សាសីល | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធសោភិតៈ | ជាព្រាហ្មណ៍ នាម សុជាត រក្សាសីល | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធអនោមទស្សី | ជាយក្ស មានឫទ្ធិច្រើន រក្សាសីល | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធបទុមៈ | ជាសត្វសីហៈ រក្សាសីល | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធនារទៈ | ជាតាបស | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធបទុមុត្តរៈ | ជាជដិល (តាបស) | កប្បទី ១ សែន |
| ព្រះពុទ្ធសុមេធៈ | ជាមាណព នាម ឧត្តរ បានបួស | កប្ប ទី ៣០ ពាន់ |
| ព្រះពុទ្ធសុជាតៈ | ជាស្តេចចក្រពត្តិ បានបួស | កប្ប ទី ៣០ ពាន់ |
| ព្រះពុទ្ធបិយទស្សី | ជាមាណព នាម កស្សបៈ រក្សាសីល | កប្ប ទី ១៨០០ |
| ព្រះពុទ្ធអត្ថទស្សី | ជាតាបស នាម សុសិមៈ មានឫទ្ធិអភិញ្ញា | កប្ប ទី ១៨០០ |
| ព្រះពុទ្ធធម្មទស្សី | ជាព្រះឥន្ទ្រ នាម បុរិន្ទទៈ | កប្ប ទី ១៨០០ |
| ព្រះពុទ្ធសិទ្ធត្ថៈ | ជាតាបស នាម មង្គល មានកម្លាំងអភិញ្ញា | កប្ប ទី ៩៤ |
| ព្រះពុទ្ធតិស្សៈ | ជាក្សត្រនាម សុជាតៈ បួសជាឥសីមានអភិញ្ញា | កប្ប ទី ៩២ |
| ព្រះពុទ្ធបុស្សៈ | ជាក្សត្រ នាម វិជិតៈ បានបួស | កប្ប ទី ៩២ |
| ព្រះពុទ្ធវិបស្សី | ជាស្តេចនាគ នាម អតុលៈ រក្សាសីល | កប្ប ទី ៩១ |
| ព្រះពុទ្ធសិខី | ជាក្សត្រ នាម អរិន្ទមៈ រក្សាសីល | កប្ប ទី ៣១ |
| ព្រះពុទ្ធវេស្សភូ | ជាក្សត្រ នាម សុទស្សនៈ បានបួស | កប្ប ទី ៣១ |
| ព្រះពុទ្ធកកុសន្ធៈ | ជាក្សត្រ នាម ខេមៈ បានបួស | ក្នុងភទ្ទកប្បនេះ |
| ព្រះពុទ្ធកោនាគមនៈ | ជាក្សត្រ នាម បព្វតៈ បានបួស | ក្នុងភទ្ទកប្បនេះ |
| ព្រះពុទ្ធកស្សបៈ | ជាមាណព នាម ជោតិបាល បានបួស | ក្នុងភទ្ទកប្បនេះ |

# ៦ បឋមបណិធាន

បើសង្ខេបព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ កាលប្រមូលមក មាន ត្រឹមតែ ៣ ប៉ុណ្ណោះ តែកាលពោលដោយពិស្តារមិនមានអ្នកណានឹងរាប់ នឹង ប្រមាណបាន ព្រោះព្រះអង្គតាំងប្រណិធាន ប្រាថ្នានឹងជួយសត្វទាំងឡាយ ឱ្យផុត ចាកសង្សារទុក្ខ ដោយផ្ដើមពីតាំងព្រះទ័យថា យើងនឹងជាព្រះពុទ្ធ គឺត្រឹមតែនឹក ក្នុងព្រះទ័យប៉ុណ្ណោះថា "**ពុទ្ធោពោធេយ្យំ មុត្តោ មោចេយ្យំ តិណ្ណោ តារេយ្យំ** យើងត្រាស់ដឹងហើយ នឹងឱ្យអ្នកដទៃត្រាស់ដឹងផង យើងផុតហើយ នឹងឱ្យអ្នក ដទៃផុតផង យើងឆ្លងហើយនឹងឱ្យអ្នកដទៃឆ្លងផង" អស់រយៈពេល ៧ អសង្ខេយ្យ ។ ប្រាថ្នានឹងជាព្រះពុទ្ធ ដោយថ្លែងវាចា តាមចិត្តដែលគិតនឹងជួយ សត្វ ( ដូចខាងលើ ) ៩ អសង្ខេយ្យទៀត ។

ទ្រង់ប្រាថ្នានឹងបំពេញបារមី ដោយកាយវាចាចិត្ត តាំងពីបានទទួល ព្យាករណ៍ថា "នឹងបានត្រាស់ជាព្រះពុទ្ធ" អស់រយៈពេល ៤ អសង្ខេយ្យ និង ១ សែនមហាកប្បទៀត ។ ទ្រង់បំពេញបារមីរួមទាំងអស់ ២០ អសង្ខេយ្យ និង ១សែនមហាកប្ប[២] ព្រះសព្វញ្ញូពោធិសត្វរបស់យើងទាំងឡាយ ទ្រង់បានប្រាថ្នា

---

[២] ២៥៦ អន្តរកប្ប = ១ មហាកប្ប ។ លេខ ១ មានសូន្យ ១៤០ មហាកប្ប= ១អសង្ខេយ្យកប្ប ។ ព្រះពុទ្ធបញ្ញាធិក នៅជាអនិយតពោធិសត្វ ១៦ អសង្ខេយ្យកប្ប ជានិយតពោធិសត្វ ៤ អសង្ខេយ្យ ១ សែនមហាកប្ប រួមជា ២០ អសង្ខេយ្យ និង ១ សែនមហាកប្ប ។

ព្រះពុទ្ធសទ្ធាធិក ៤០ អសង្ខេយ្យ និង ១ សែនមហាកប្ប ។

ព្រះពុទ្ធវិរិយាធិក ៨០ អសង្ខេយ្យ និង ១ សែនមហាកប្ប ។ ទើបបានត្រាស់ដឹងនូវអនុត្តរសម្មា សម្ពោធិញ្ញាណ ។

ជាព្រះពុទ្ធ ក្នុងខណៈចិត្តជាលើកដំបូងដែលនៅមិនទាន់បានធ្លាប់ជួបព្រះពុទ្ធអង្គណាៗ ឡើយ រាប់ជាតិមិនអស់ មានរឿងពោលទុកថាៈ រាប់តាំងពីភទ្ទកប្បនេះ ថយក្រោយទៅ ២០ អសង្ខេយ្យ និង ១ សែនមហាកប្ប ព្រះពោធិសត្វកើតជាមនុស្សក្រីក្រនៅក្នុងក្រុងគន្ធារៈ កាប់ឧសរែកមកអំពីព្រៃយកទៅលក់បានប្រាក់ចិញ្ចឹមមាតា ។ ថ្ងៃមួយ កំពុងរែករបស់ធ្ងន់មកហាលថ្ងៃស្រែកទឹក ក៏សម្រាកក្រោមដើមជ្រៃ ពិចារណាថា "ឥឡូវនេះយើងនៅមានកម្លាំង អាចអត់ធន់ ចំពោះសេចក្តីទុក្ខ ព្រោះក្តៅជាដើមបាន តែកាលយើងចាស់ ឬ ឈឺ ប្រាកដជាមិនអាចអត់ធន់ នឹងសេចក្តីទុក្ខបានឡើយ ណ្ហើយ យើងនឹងទៅសុវណ្ណភូមិជីកយកមាសមកចិញ្ចឹមមាតាឱ្យមានសេចក្តីសុខចុះ" ។ កាលគិតដូច្នោះហើយ ក៏បាននាំមាតាទៅកាន់សុវណ្ណភូមិ ជាមួយនឹងពួកឈ្មួញដោយសុំជាកូនឈ្នួលប្រចាំសំពៅ, ចេញទៅបាន ៧ ថ្ងៃសំពៅក៏បែក ពួកឈ្មួញក៏ដល់នូវសេចក្តីវិនាសទាំងអស់គ្នា ចំណែកព្រះពោធិសត្វលីមាតារបស់ខ្លួនហែលទឹកឆ្លងមហាសមុទ្រទៅ ។

គ្រានោះ ស្តេចមហាព្រហ្មជាន់សុទ្ធាវាសរំពឹងមើលសត្វលោកទូទៅដោយគិតថា "កន្លងមក ១ អសង្ខេយ្យហើយ សូម្បីបុរសណាមួយដែលត្រាស់ជាព្រះពុទ្ធក៏មិនមាន ចុះអ្នកដែលនឹងត្រាស់ដឹងជាព្រះពុទ្ធមានទេ ?" ទើបឃើញព្រះពោធិសត្វ ដែលកំពុងលះបង់ជីវិត នាំមាតារបស់ខ្លួនហែលឆ្លងមហាសមុទ្រដ៏ធំល្វឹងល្វើយ ក៏ជ្រាបបានថា "មហាបុរសនេះមានសេចក្តីព្យាយាមខ្លាំងក្លាណាស់ នឹងមានអធ្យាស្រ័យជួយអ្នកដទៃ" ព្រះពោធិសត្វនោះ ដោយអានុភាពមហាព្រហ្ម-បណ្តាចិត្ត ក៏កើតសេចក្តីគិតឡើងថា ៖

"យើងត្រាស់ដឹងហើយ នឹងឱ្យអ្នកដទៃត្រាស់ដឹងផង យើងផុតហើយនឹងឱ្យអ្នកដទៃផុតផង យើងឆ្លងហើយនឹងឱ្យអ្នកដទៃឆ្លងផង" ដូច្នេះ ហែលឆ្លងមហាសមុទ្រ ២-៣ ថ្ងៃ ក៏ដល់ត្រើយព្រមនឹងមាតា ។ តាំងពីនោះមក ព្រះពោធិសត្វ ចិញ្ចឹមមាតារហូតដល់អស់ជីវិត ហើយទៅកើតក្នុងទេវលោក ចំណែកមាតាទៅតាមយថាកម្ម នេះគឺជាកាលវេលា ដែលទ្រង់ដល់សេចក្ដីប្រាថ្នាជាព្រះពុទ្ធឡើង ក្នុងចិត្តជាគ្រាដំបូង ហៅថា បឋមចិត្តុប្បាទកាល ។

តាំងពីនោះមក ទ្រង់សន្សំបារមី រហូតដល់ភពចុងបំផុត បានប្រើសេចក្ដីព្យាយាមប្រកបដោយអង្គ ៤ ដែលហៅថា ចតុរង្គបធានដូចដែលទ្រង់ត្រាស់ថា÷

**កាមំ តចោ នហារុ អដ្ឋិ ច អវសុស្សតុ**

**អវសិស្សតុ មេ សរីរេ សព្វន្តំ មំសលោហិតំ ។**

សាច់និងឈាម ក្នុងកាយរបស់យើងទាំងអស់ នឹងស្ងួតហួតហែងទៅ នៅសល់តែស្បែក សរសៃ ឆ្អឹង ក៏ដោយចុះ, ធម៌ណាដែលនឹងសម្រេចបាន ដោយកម្លាំងរបស់បុរស ដោយសេចក្ដីព្យាយាមរបស់បុរស ដោយសេចក្ដីប្រឹងប្រែងរបស់បុរស នៅមិនទាន់សម្រេចធម៌នោះ យើងនឹងមិនបញ្ឈប់សេចក្ដីព្យាយាមនេះឡើយ ។

ព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ ដែលព្រះអង្គទ្រង់បានមកនោះ រាប់ថាជាការបានមកដោយសេចក្ដីលំបាកយ៉ាងក្រៃលែង ក្នុងព្រះជាតិចុងបំផុត ដោយហេតុនេះឯង ព្រះអដ្ឋកថាចារ្យ បានប្រព័ន្ធប្រណាមគាថា ដើម្បីឱ្យរលឹកដល់ព្រះគុណដ៏ធំក្រៃលែង រកប្រមាណមិនបានរបស់ព្រះសម្មាសម្ពុទ្ធ ដែលទ្រទ្រង់ទុកនូវ

ព្រះគុណទាំង ៣ គឺព្រះបញ្ញាគុណ ព្រះវិសុទ្ធិគុណនិងព្រះករុណាគុណ ដែលមិនមានអ្នកណាប្រៀបផ្ទឹមបាន ។ បើបុគ្គលមានចិត្តជ្រះថ្លា ពោលពាក្យនមស្ការដោយរលឹកដល់ព្រះគុណទាំងនោះជានិច្ច ក៏នឹងធ្វើឱ្យចិត្តស្អាតផូរផង់ ប្រាសចាកភ័យ និងអន្តរាយ សូម្បីកិច្ចការដែលគួរធ្វើក៏សម្រេចតាម ដែលប្រាថ្នានោះឯងហោង ។

ចប់ បឋមបណិធាន

# ៧ ទ្រង់បានទទួលការព្យាករណ៍ពីព្រះពុទ្ធ ២៤ ព្រះអង្គ

ព្រះសមណគោតមបរមគ្រូនៃយើង កាលនៅជាព្រះពោធិសត្វ ទ្រង់បាន បំពេញកុសល ជាមួយព្រះសម្ពុទ្ធ ២៤ ព្រះអង្គគឺ ÷

១- ក្នុង ៤ អសង្ខេយ្យនិងមួយសែនកប្ប មាននគរឈ្មោះ អមរវតី ជានគរ គួរពិតពិលរមិលមើលជានគរបរិបូណ៌ដោយគ្រឿងឧបភោគ និងបរិភោគ ជាទីរីករាយនៃចិត្ត ។ កាលនោះ តថាគតជាព្រាហ្មណ៍ឈ្មោះ សុមេធ (ជាបណ្ឌិត) នៅក្នុងនគរនោះជាអ្នកសន្សំនូវទ្រព្យដ៏ច្រើនកោដិ មានទ្រព្យ និងស្រូវច្រើន ។ ជាអ្នករៀនមន្តចេះចាំនូវមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ដល់នូវបារមីក្នុងលក្ខណៈផង ក្នុងគម្ពីរឥតិហាសផង ក្នុងធម៌របស់ ព្រាហ្មណ៍ផង ។ កាលនោះ តថាគតនៅក្នុងទីស្ងាត់ ក៏គិតយ៉ាងនេះថា ធម្មតាភពថ្មីទៀត តែងនាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយនៃសរីរៈ ក៏នាំ មកនូវសេចក្តីទុក្ខដូចគ្នា (សេចក្តីស្លាប់ប្រកបដោយមោហៈ នាំមកនូវទុក្ខ រូបដែលជរាញាំញីហើយ ក៏នាំមកនូវទុក្ខ) អាត្មាអញមានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញនឹងស្វែងរកនូវព្រះ និព្វាន ដែលមិនចាស់ មិនស្លាប់ ជាទីក្សេមក្សាន្ត ។ បើដូច្នោះ អាត្មា អញគួរតែលះបង់កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ជា អ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការហើយ នឹងចេញទៅ

។ល។ លុះតថាគតគិតឃើញយ៉ាងនេះហើយ ក៏ឱ្យទ្រព្យជាច្រើនរយកោដិដល់ពួកជនដែលមានទីពឹង និងពួកជនដែលឥតទីពឹង ហើយចូលទៅកាន់ព្រៃហិមពាន្ត ។ មានភ្នំមួយ ឈ្មោះធម្មិកៈ នៅជិតព្រៃហិមពាន្តនោះ តថាគតធ្វើអាស្រមសាងបណ្ណសាលាក្បែរភ្នំនោះ។ តថាគតផ្គងព្យាយាមក្នុងអាស្រមបទនោះ (ញ៉ាំងយប់ និង ថ្ងៃឱ្យកន្លងទៅ) ក្នុងទីអង្គុយទីឈរនិងទីចង្រ្កម បានលុះអភិញ្ញាពលៈក្នុងរវាង ៧ ថ្ងៃ ។ កាលតថាគតសម្រេចអភិញ្ញា ហើយជាអ្នកមានវសី ក្នុងសាសនានៃតាបស កាលនោះព្រះជិនស្រីព្រះនាមទីបង្ករ ជានាយកនៃលោក ទ្រង់កើតឡើង ។ សម័យនោះឯងតថាគតចេញអំពីអាស្រមរបស់ខ្លួន ហោះទៅកាន់អាកាស តថាគតឃើញជនកំពុងតែពេញចិត្តត្រេកអរ ស្រស់ស្រាយ រីករាយ ក៏ចុះអំពីអាកាសហើយសួរមនុស្សទាំងឡាយនោះថា មហាជនត្រេកអររីករាយពេញចិត្តជំរះផ្លូវគន្លងដើម្បីអ្នកណា ។ ពួកជនទាំងនោះ ក៏ឆ្លើយប្រាប់ថា ព្រះពុទ្ធដ៏ប្រសើរក្នុងលោកជាព្រះជិនស្រីព្រះនាមទីបង្ករ ជាលោកនាយកទ្រង់កើតឡើងហើយ ពួកយើងជម្រះផ្លូវ គន្លងប្រឡាយដើម្បីព្រះពុទ្ធទីបង្ករនោះ បីតិកើតឡើងដល់តថាគតក្នុងខណៈនោះ ព្រោះតែឮពាក្យថា ព្រះពុទ្ធ តថាគតទន្ទេញថា ព្រះពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះហើយក៏បាននូវសោមនស្ស។ តថាគតត្រេកអរ មានចិត្តតក់ស្លុតគិតថា អាត្មាអញនឹងបណ្តុះពូជកុសលក្នុងបុញ្ញក្ខេត្តនេះ ក៏និយាយទៅរកមហាជនថា "បើអ្នក

ទាំងឡាយជំរះផ្លូវថ្វាយព្រះពុទ្ធ ចូរឱ្យឱកាសមួយដល់អាត្មាផង អាត្មានឹងជម្រះផ្លូវប្រឡាយដែរ" ។ តថាគតគិតថា "ព្រះពុទ្ធ ព្រះពុទ្ធ" ដូច្នេះជម្រះបណ្ដើរ គិតបណ្ដើរ ។ កាលដែលឱកាសផ្លូវរបស់តថាគត ធ្វើមិនទាន់សម្រេចនៅឡើយ ស្រាប់តែព្រះជិនស្រីជាអ្នកប្រាជ្ញធំព្រះនាមទីបង្ករស្ដេចយាងមកតាមផ្លូវជាមួយនឹងព្រះខីណាស្រពបួនសែនរូប សុទ្ធតែជាអ្នកមានអភិញ្ញា ៦ ជាតាទិបុគ្គល ប្រាសចាកមន្ទិល ។ ពួកទេវតាដែលឋិតនៅឰដ៏អាកាស ក៏រោយលំអិតខ្លឹមចន្ទន៍ជាទិព្វផង គ្រឿងក្រអូបដ៏ប្រសើរទាំងអស់ផង អំពីទិសតូចទិសធំ ឰដ៏អាកាស ។ ពួកមនុស្សដែលឋិតនៅលើផែនដី ក៏រោយរាយផ្កាចំប៉ា ផ្កាស្រល់ ផ្កាក្ទម្ព ផ្កាខ្ទឹងផ្កាបុសនាគ និងផ្កាកាកេស អំពីទិសតូច ទិសធំ ។ តថាគតរំសាយសក់ត្រង់ប្រទេសនោះ ហើយក្រាលចីវរសំបកឈើ និងកំណាត់ស្បែកលើភក់ហើយដេកផ្កាប់មុខ (អធិដ្ឋានថា) "សូមព្រះពុទ្ធ ព្រមទាំងពួកសិស្សជាន់អាត្មាអញយ៉ាងនេះចុះ សូមកុំជាន់ភក់ឡើយ ការមិនជាន់ភក់នេះ ជាប្រយោជន៍ដល់អាត្មាអញ" ។ កាលតថាគតដេកលើផែនដី ក៏មានសេចក្ដីត្រិះរិះដោយចិត្តយ៉ាងនេះថា "បើអាត្មាអញ ប្រាថ្នាដុតកិលេសទាំងឡាយរបស់អញក្នុងថ្ងៃនេះក៏បាន ។ តែថា ប្រយោជន៍អ្វីអាត្មាអញធ្វើឱ្យជាក់ច្បាស់នូវធម៌ដោយភេទដែលគេមិនស្គាល់ក្នុងទីនេះ អាត្មាអញគប្បីដល់សព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះចាកកិលេស ញ៉ាំងលោក ព្រមទាំង

ទេវលោកឱ្យរួចរំដោះ (ចាកសង្សារ) ។ អាត្មាអញនឹង បានដល់នូវសព្វញ្ញុតញ្ញាណ ចម្លងប្រជុំជនច្រើន ដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធ ជាបុរសដ៏ខ្ពង់ខ្ពស់ ។ ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលនូវគ្រឿងបូជាទាំងឡាយ ទ្រង់ឈរក្បែរសីសៈរបស់តថាគត ត្រាស់ពាក្យនេះថា (ម្នាលភិក្ខុទាំងឡាយ) អ្នកទាំងឡាយ ចូរមើលតាបសនេះ ជាជដិលមានតបៈដ៏ខ្ពង់ខ្ពស់ តាបសនេះ នឹងបានត្រាស់ ជាព្រះពុទ្ធក្នុងលោក ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ ។ សត្វនេះ នឹងចេញចាកក្រុងឈ្មោះកបិលវត្ថុ ជាទីរីករាយ តម្កល់ព្យាយាមធ្វើទុក្ករកិរិយា ។ សត្វនេះ អង្គុយជិតគល់អជបាលព្រឹក្ស ទទួលបាយាសដែលនាងសុជាតាថ្វាយក្នុងទីនោះ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីនោះ បានទទួលបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរាហើយ នឹងត្រឡប់មកតាមផ្លូវ ដែលគេតាក់តែងយ៉ាងប្រសើរ (អង្គុយ) ទៀបគល់ពោធិព្រឹក្ស លំដាប់នោះ តាបសមានយសនេះ ធ្វើប្រទក្សិណពោធិមណ្ឌល នឹងបានត្រាស់ដឹងនូវអនុត្តរសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជនិកា មាតារបស់តាបសនោះ នឹងមាននាមថា ព្រះនាងមាយាទេវី ព្រះបិតាព្រះនាម សុទ្ធោទនៈ តាបសនេះនឹងមានឈ្មោះថា ព្រះគោតម អគ្គសាវ័កទាំងពីររូបគឺ កោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់ មានចិត្តខ្ជាប់ខ្ជួន ភិក្ខុជាឧបដ្ឋាក ឈ្មោះ

អានន្ទ នឹងបម្រើព្រះជិនស្រីនេះ ។ អគ្គសាវិកា ពីររូបគឺ នាងខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ឈើជាទីត្រាស់ដឹងរបស់ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឯឧបាសកជាឧបដ្ឋាកដ៏ប្រសើរពីររូប គឺ ចិត្តៈ ១ ហត្ថាឡវកៈ ១ ។ នាងនន្ទមាតា និង នាងឧត្តរា ជាឧបដ្ឋាយិកាដ៏ប្រសើរ ព្រះគោតមមានយសនេះ ព្រះជន្ម ១០០ វស្សា ។ តថាគតបានស្ដាប់ព្ទ ព្រះពុទ្ធដីកាទ្រង់ត្រាស់ព្យាករណ៍ហើយ ក៏ញ៉ាំងចិត្តឱ្យត្រេកអរ រីករាយ រំភើបយ៉ាងក្រៃលែង ។ កាលព្រះលោកនាយក ព្រមទាំងព្រះសង្ឃ ស្ដេច យាងទៅ កន្លងនូវការឃើញរបស់តថាគតហើយ ។ តថាគតជាអ្នកមាន សេចក្ដីសុខ ដោយសេចក្ដីសុខ រីករាយដោយបាមោជ្ជៈ ផ្សព្វផ្សាយដោយ បីតិ អង្គុយពែនភ្នែនក្នុងទីនោះ ហើយមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើ ដូច្នោះ អាត្មាអញនឹងជ្រើសរើស រកពុទ្ធការកធម៌ទាំងឡាយ ពីខាងនេះ ពីខាងនោះ គឺខាងលើ ខាងក្រោម ទិសទាំង ១០ ដរាបដល់ធម្មធាតុ ។ តថាគតបានឃើញនូវបារមីទាំង ១០ សព្វគ្រប់ ដែលពោធិសត្វទាំងឡាយ អំពីបូរាណធ្លាប់សន្សំមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទានធ្វើនូវបារមីទាំង ១០ ឱ្យមាំមួន បើអ្នកចង់លុះនូវ ពោធិញ្ញាណ ចូរបំពេញនូវបារមីទាំង ១០ នេះចុះ ។ តថាគត ខិតខំ ប្រឹងប្រែងព្យាយាម ដើម្បីពោធិញ្ញាណ ជាប្រយោជន៍ដល់សត្វលោក

ដរាបដល់អស់ជីវិត ។

២- កាលសាសនាព្រះកោណ្ឌញ្ញៈ សម្មាសម្ពុទ្ធព្រះអង្គប្រតិស្ឋានឡើង ក្នុងលោក ។ សម័យនោះ តថាគតជាព្រះរាជាព្រះនាមវិជិតាវី បានញ៉ាំងឥស្សរិយយស ឱ្យប្រព្រឹត្តទៅរហូតដល់សមុទ្រជាទីបំផុត ។ ព្រះតថាគតនិមន្តព្រះខីណាស្រព មួយសែនកោដិដែលប្រាសចាកមន្ទិល ព្រមទាំងព្រះពុទ្ធជាទីពឹងដ៏ប្រសើររបស់សត្វលោក ឱ្យឆាន់ស្កប់ស្កល់ ដោយម្ហូបចំណីថ្លៃថ្លា ។ ព្រះសម្ពុទ្ធជាលោកគ្គនាយក ព្រះនាមកោណ្ឌញ្ញអង្គនោះទ្រង់ព្យាករណ៍តថាគតថា ។ល។ តថាគតស្តាប់ព្រះពុទ្ធព្យាករណ៍ថា នឹងបានត្រាស់ជាព្រះពុទ្ធ ក៏ធ្វើចិត្តឱ្យជ្រះថ្លាក្រៃពេក បានថ្វាយរាជសម្បត្តិចំពោះព្រះជិនស្រីលុះថ្វាយរាជសម្បត្តិដ៏ធំហើយ ទើបបួសក្នុងសំណាក់របស់ព្រះអង្គ ។ តថាគតបានរៀនព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនាមានអង្គ ៩ ទាំងអស់ញ៉ាំងសាសនា ព្រះជិនស្រីឱ្យរុងរឿង ដោយមិនប្រមាទរហូតអស់ជីវិត។

៣- កាលព្រះលោកនាយកព្រះនាមមង្គល បានត្រាស់ដឹងក្នុងលោក ។ សម័យនោះ តថាគតជាព្រាហ្មណ៍ ឈ្មោះសុរុចិ ។ តថាគតជាអ្នករៀនមន្តចេះចាំមន្តដល់នូវត្រើយនៃវេទទាំង ៣ ហើយចូលទៅគាល់ព្រះសម្ពុទ្ធអង្គនោះ សូមដល់នូវព្រះសាស្តាជាទីពឹង ។ តថាគតបានបូជាព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដោយគ្រឿងក្រអូប និងកម្រងផ្កា ហើយញ៉ាំងព្រះភិក្ខុសង្ឃ ឱ្យឆាន់ស្កប់ស្កល់ ដោយទឹកដោះគោ ។ ព្រះសម្ពុទ្ធមង្គល

អង្គនោះ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ ទ្រង់ទំនាយតថាគតថា ក្នុងរវាងកប្បប្រមាណ មិនបានអំពីកប្បនេះទៅ បុរសនេះនឹងបានត្រាស់ ជាព្រះពុទ្ធ ។ល។ តថាគតបានស្ដាប់ព្យាករណ៍ហើយ មានចិត្តរីករាយក្រៃពេក បានថ្វាយផ្ទះរបស់តថាគត ចំពោះព្រះពុទ្ធហើយបួសក្នុងសំណាក់ព្រះអង្គ ដើម្បីសម្រេចពោធិញ្ញាណដ៏ប្រសើរ ។ តថាគតរៀនព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនា មានអង្គ ៩ ទាំងអស់ ហើយញ៉ាំងសាសនាព្រះជិនស្រី ឱ្យរុងរឿងដោយមិនប្រមាទរហូតអស់ជីវិត ។

៤- កាលព្រះសុមនសម្មាសម្ពុទ្ធ ត្រាស់ជាពន្លឺក្នុងលោក សម័យនោះ តថាគតកើតជាស្ដេចនាគមានឫទ្ធិច្រើនមានឈ្មោះថា អតុលៈ ជាអ្នកសន្សំកុសល ។ តថាគតចេញអំពីភពនាគ ជាមួយពួកញាតិបានទៅបម្រើព្រះជិនស្រីព្រមទាំងព្រះសង្ឃ ដោយតន្ត្រីជាទិព្វរបស់នាគ។ តថាគតបានញ៉ាំងភិក្ខុសង្ឃ ១ សែនកោដិឱ្យឆាន់ស្កប់ស្កល់ដោយបាយ និងទឹក ហើយថ្វាយសំពត់មួយគូៗមួយអង្គ ហើយយកព្រះសង្ឃនោះជាទីពឹង ។ ព្រះសម្ពុទ្ធព្រះនាមសុមនៈ ជាលោកនាយកអង្គនោះ ទ្រង់ព្យាករណ៍តថាគតថា ។ល។ តថាគតបានស្ដាប់ព្រះតម្រាស់ព្យាករណ៍ហើយ មានចិត្តជ្រះថ្លា ក្រៃពេក អធិដ្ឋានទូវវត្តតទៅទៀត ដោយការបំពេញបារមីទាំង ១០ ។

៥- ព្រះលោកនាយក ព្រះនាមរេវតៈ ត្រាស់ដឹងឡើងក្នុងលោក សម័យនោះ តថាគតកើតជាព្រាហ្មណ៍ឈ្មោះអតិទេវៈបានចូលទៅគាល់ព្រះរេវតៈ សម្ពុទ្ធហើយយកព្រះអង្គជាទីពឹង ។ តថាគតបានសរសើរសីល សមាធិ និង

បញ្ញា គុណដ៏ប្រសើររបស់ព្រះអង្គ ហើយថ្វាយសំពត់ឧត្តរាសង្គៈតាមកម្លាំង ។ ព្រះសម្ពុទ្ធព្រះនាមរេវតៈ ជាលោកនាយកអង្គនោះ ទ្រង់ព្យាករណ៏តថាគតថា ។ល។ តថាគតបានស្តាប់ព្រះពុទ្ធព្យាករណ៍ហើយក៏ធ្វើចិត្តឱ្យត្រេកអរក្រៃពេក បានអធិដ្ឋាននូវវត្តតទៅទៀត ដោយការបំពេញបារមី ១០ តាមសមគួរ ដល់សេចក្តីប្រាថ្នារបស់តថាគត ។

៦- កាលសាសនាព្រះសោភិតៈ សម្មាសម្ពុទ្ធប្រតិស្ថានឡើង។ សម័យនោះតថាគត កើតជាព្រាហ្មណ៏ ឈ្មោះសុជាតៈ កាលនោះ តថាគតនិមន្តព្រះពុទ្ធ ព្រមទាំងសាវ៏ក ឱ្យឆាន់ស្កប់ស្កល់ដោយបាយ និង ទឹក ។

ព្រះសម្ពុទ្ធព្រះនាមសោភិតៈ ជាលោកគ្គនាយកអង្គនោះ ទ្រង់ព្យាករណ៏តថាគតថា ។ល។ ចំណែកតថាគត លុះបានស្តាប់ព្រះពុទ្ធដីការបស់ព្រះសម្ពុទ្ធអង្គ ក៏មានចិត្តត្រេកអរ បានធ្វើប្រាជ្ញាឱ្យខ្ពង់ខ្ពស់ បំពេញបារមីតទៅ ។

៧- ព្រះអនោមទស្សីសម្មាសម្ពុទ្ធជាលោកនាយកបានត្រាស់ក្នុងលោក សម័យនោះ តថាគតកើតជាយក្ស មានឫទ្ធិច្រើនជាធំជាងពួកយក្សច្រើនកោដិ កាលនោះ តថាគតបានចូលទៅគាល់ព្រះសម្ពុទ្ធដ៏ប្រសើរ អង្គនោះព្រះអង្គស្វែងរកគុណដ៏ធំ ហើយអង្គាសព្រះលោកនាយក ព្រមទាំងព្រះសង្ឃឱ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ។ ឯព្រះមុនីអង្គនោះ ទ្រង់មានព្រះនេត្រដ៏បរិសុទ្ធទ្រង់ព្យាករណ៏តថាគតថា ។ល។ ចំណែកតថាគតលុះបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអនោមទស្សីអង្គនោះព្យាករណ៍ហើយក៏ញ៉ាំងចិត្តត្រេកអរ រីករាយ មានចិត្តតក់ស្លុត បានអធិដ្ឋាននូវវត្តតទៅ

ទៀត ដោយការបំពេញនូវបារមីទាំង ១០ ។

៨- មានព្រះសម្ពុទ្ធព្រះនាមបទុមៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ត្រាស់ឡើងហើយ សម័យនោះ តថាគតកើតជាសត្វសីហៈ គ្របសង្កត់លើពួកម្រឹគ បានឃើញព្រះជិនស្រី ព្រះអង្គកំពុងចម្រើននូវវិវេកក្នុងព្រៃធំ ។ តថាគតបានថ្វាយបង្គំនូវព្រះបាទ ទាំងគូ ដោយសិរសី ហើយធ្វើប្រទក្សិណ ព្រះអង្គរួចបន្លឺនូវសីហនាថអស់ ៣ ដង បានបម្រើ ព្រះជិនស្រី អស់ ៧ ថ្ងៃ ។ ព្រះតថាគតទ្រង់ចេញចាកសមាបត្តិដ៏ប្រសើរអស់ ៧ ថ្ងៃហើយ ទ្រង់ព្រះចិន្តាដោយព្រះហឫទ័យរួចទ្រង់ប្រមូលមកនូវភិក្ខុចំនួន ១ កោដិ ។ កាលនោះព្រះមហាវីរៈនោះទ្រង់ព្យាករណ៍តថាគត ក្នុងកណ្តាលភិក្ខុសង្ឃទាំង ១ កោដិ នោះថា ។ល។ ឯតថាគតបានស្តាប់ព្រះពុទ្ធព្យាករណ៍ហើយ មានចិត្តត្រេកអរ រីករាយក្រៃលែង បានអធិដ្ឋាននូវវត្តដ៏ប្រសើរលើសលប់ដោយការបំពេញនូវបារមីទាំង ១០ តទៅ ។

៩- ក្នុងសាសនាព្រះនារទសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់ឡើងហើយបំភ្លឺលោក ។ សម័យនោះ តថាគតជាតាបសមានផ្នួងសក់ មានព្យាយាមក្លៀវក្លា បានដល់នូវត្រើយនៃអភិញ្ញាទាំង ៥ ត្រាច់ ទៅតាមអាកាសបាន ។ គ្រានោះតថាគត បានញ៉ាំងព្រះសម្ពុទ្ធដែលស្មើដោយព្រះពុទ្ធមិនមានបុគ្គលស្មើ ព្រមទាំងព្រះសង្ឃ និងជនជាបរិស័ទ ឱ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ហើយបូជាដោយខ្លឹមចន្ទន៍ ។ គ្រានោះ ព្រះនារទៈ ជា

លោកនាយកអង្គនោះទ្រង់បានព្យាករណ៍តថាគតថា ។ល។ តថាគតបាន ឮព្រះពុទ្ធព្យាករណ៍ហើយ មានចិត្តត្រេកអររីករាយដ៏លើសលប់ ដោយការបំពេញបារមីទាំង ១០ តទៅ ។

១០- ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ទ្រង់ឈ្នះមារ ទ្រង់មិនរំភើប ឧបមាដូចសាគរ ព្រះអង្គទ្រង់កើតឡើងហើយ ។ សម័យនោះ តថាគតជាជដិលអ្នកនៅក្នុងដែនតថាគតបានថ្វាយសំពត់ ព្រមទាំងភត្តដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់នៅកណ្ដាលនៃភិក្ខុសង្ឃ ហើយព្យាករណ៍តថាគតថា ។ល។ តថាគតបានឮព្រះបន្ទូលព្យាករណ៍ហើយ មានចិត្តរីករាយ អធិដ្ឋានវត្តដ៏លើសលប់ឡើងទៅបានធ្វើនូវព្យាយាមដ៏ខ្ពង់ខ្ពស់ មាំមួនដោយការបំពេញនូវបារមីទាំង ១០ ។

១១- ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ព្រះអង្គជានាយក គេគ្របសង្កត់បានដោយក្រ ទ្រង់មានតេជះដ៏ខ្ពង់ខ្ពស់ ជាព្រះជិនស្រីដ៏ប្រសើរឧត្តមជាងលោកទាំងមូល ។ សម័យនោះតថាគត កើតជាមាណព ឈ្មោះ ឧត្តរៈ មានទ្រព្យទុកក្នុងផ្ទះ ប្រមាណ ៨០ កោដិ ។ តថាគតបានថ្វាយទ្រព្យទាំងអស់ ឥតមានសល់ដល់ព្រះលោកនាយក ព្រមទាំងព្រះសង្ឃបានយកព្រះលោកនាយក ជាទីពឹងបានពេញចិត្តចំពោះបព្វជ្ជា ។ គ្រានោះ ព្រះអង្គទ្រង់ធ្វើនូវអនុមោទនា ហើយព្យាករណ៍តថាគតថា ។ល។ តថាគតបានស្ដាប់ព្រះបន្ទូលព្យាករណ៍ហើយ ក៏ញ៉ាំងចិត្តឱ្យជ្រះថ្លាក្រៃលែងបាន អធិដ្ឋាន

វត្ថុដ៏លើសលប់ដោយការបំពេញបារមីទាំង ១០ ។ តថាគតបានរៀននូវព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនា ដែលមានអង្គ ៩ ទាំងអស់ បានដល់អភិញ្ញាបារមី ហើយញ៉ាំងសាសនាព្រះជិនស្រីឱ្យរុងរឿង ។

១២- ព្រះសម្មាសម្ពុទ្ធ ជានាយកទ្រង់ព្រះនាមសុជាត ទ្រង់មានព្រះគុណប្រមាណមិនបាន គេគ្របសង្កត់មិនបាន ។ សម័យនោះ តថាគតជាស្តេចចក្រពត្តិ មានកម្លាំងច្រើនជាធំក្នុងទ្វីបទាំង ៤ អាចហោះទៅ ក្នុងអាកាសបាន ។ តថាគតបានថ្វាយនូវរាជសម្បត្តិជាច្រើន ក្នុងទ្វីបទាំង ៤ នូវកែវដ៏ឧត្តមទាំង ៧ ប្រការចំពោះព្រះពុទ្ធ ហើយបួសក្នុងសំណាក់នៃព្រះសម្ពុទ្ធអង្គនោះ ។ពួកអារាមិកជនទាំងឡាយ ក្នុងជនបទបាន ប្រមូលមកនូវសួយសារអាករជាបច្ច័យទីដេក ទីអង្គុយមកថ្វាយដល់ភិក្ខុសង្ឃ ។ កាលនោះ ព្រះសុជាតសម្មាសម្ពុទ្ធនោះ ទ្រង់ព្យាករណ៏តថាគតថា ។ល។ តថាគតបានស្តាប់ព្រះបន្ទូលព្យាករណ៏ហើយ ក៏ញ៉ាំងសេចក្តីរីករាយឱ្យកើតយ៉ាងក្រៃលែង ហើយអធិដ្ឋាននូវវត្ថុដ៏លើសលប់ ដោយការបំពេញបារមីទាំង ១០ ។ តថាគតរៀនព្រះសូត្រ ព្រះវិន័យ សត្ថុសាសនា ដែលមានអង្គ ៩ ទាំងអស់ ហើយបានដល់នូវអភិញ្ញាបារមី បានញ៉ាំងសាសនា ព្រះជិនស្រីឱ្យរុងរឿង ។

១៣- ព្រះសម្ពុទ្ធទ្រង់ព្រះនាមបិយទស្សី ជាសយម្ភូ ជាលោកនាយក ទ្រង់មានយសច្រើន ព្រះអង្គប្រសើរ ឥតមានបុគ្គលស្មើ ។ សម័យនោះ តថាគតកើតជាមាណពឈ្មោះកស្សបៈ ជាអ្នកស្វាធ្យាយមន្ត ចងចាំមន្តដល់នូវ

ត្រៃយនៃវេទ ។ តថាគតបានស្តាប់ពាក្យរបស់ព្រះពុទ្ធបិយទស្សីនោះ ក៏កើតសេចក្តីជ្រះថ្លា បានសាងនូវសង្ឃារាម ដោយទ្រព្យប្រមាណមួយសែនកោដិ ។ តថាគតបានថ្វាយ អារាមដល់ព្រះពុទ្ធអង្គនោះហើយ មានចិត្តរីករាយ មានចិត្តសង្វេគ បានសមាទានសរណគមន៍ និងសីល ៥ ឱ្យមាំមួន ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់កណ្តាលសង្ឃ ហើយទ្រង់ព្យាករណ៍ តថាគតថា ។ល។ តថាគតបានស្តាប់ព្រះពុទ្ធព្យាករណ៍ហើយ ញ៉ាំងសេចក្តីជ្រះថ្លាក្រៃលែង អធិដ្ឋានវត្តដ៏លើសលប់ ដោយការបំពេញបារមីទាំង ១០ តទៅ ។

១៤- ព្រះអត្ថទស្សីសម្មាសម្ពុទ្ធ ព្រះអង្គមានយសធំ ទ្រង់កំចាត់បង់ងងឹតធំ សម្រេចពោធិញ្ញាណដ៏ឧត្តម។ ក្នុងសម័យនោះ តថាគតកើតជាជដិលឈ្មោះសុសិមៈ មានតបះដ៏ខ្ពង់ខ្ពស់ដែលគេសន្មតថា ជាបុគ្គលប្រសើរលើផែនដី ។ តថាគតបាននាំយកផ្កាមន្ទារវបុស្ស ផ្កាឈូកនិងផ្កាបារិច្ឆត្តព្រឹក្សជាទិព្វ អំពីទេវលោកមកបូជាចំពោះព្រះពុទ្ធ ។ ឯព្រះពុទ្ធជាមហាមុនីព្រះនាមអត្ថទស្សីអង្គនោះ ទ្រង់បានព្យាករណ៍តថាគតថា ។ ល។ លុះតថាគតបានស្តាប់ពុទ្ធភាសិតព្យាករណ៍ហើយ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុត ខំអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមី ១០ ប្រការ ។

១៥- ព្រះពុទ្ធធម្មទស្សីសម្មាសម្ពុទ្ធ ព្រះអង្គមានយសធំ ទ្រង់កំចាត់បង់ងងឹតអន្ធការ ហើយញ៉ាំងមនុស្សលោក ព្រមទាំងទេវលោកឱ្យរុងរឿង ។ សម័យនោះ តថាគតកើតជាព្រះឥន្ទឈ្មោះបុរិន្ទទៈ បានបូជាព្រះពុទ្ធជា

ម្ចាស់ដោយគ្រឿងក្រអូប កម្រងផ្កា និងតូរ្យតន្ត្រីទិព្វ ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់ចំកណ្តាលពួកទេវតា ហើយព្យាករណ៍តថាគតថា ។ល។ តថាគត លុះបានស្តាប់ភាសិតនៃព្រះជិនស្រីអង្គនោះ ទ្រង់ព្យាករណ៍ ហើយក៏ញុំាង ចិត្តឱ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តតទៅដើម្បីបំពេញបារមីទាំង ១០ ។

១៦- ព្រះលោកនាយកព្រះនាមសិទ្ធត្ថៈ ទ្រង់កំចាត់បង់ងងឹតទាំងអស់បីដូចជា ព្រះអាទិត្យរះឡើង ។ ព្រះសិទ្ធត្ថអង្គនោះ ទ្រង់ដល់នូវសម្ពោធិញ្ញាណ ហើយ ចម្លងមនុស្សព្រមទាំងទេវតាបង្អុរភ្លៀង គឺធម៌ហើយញុំាងមនុស្ស ព្រមទាំងទេវតាឱ្យរលត់ទុក្ខ ។ សម័យនោះ តថាគតជាតាបសឈ្មោះ មង្គលៈ មានតេជៈខ្ពង់ខ្ពស់ គេគ្របសង្កត់មិនបាន ជាអ្នកប្រកបដោយ កម្លាំងនៃអភិញ្ញា ។ តថាគតបាននាំផ្លែព្រីង មកថ្វាយព្រះពុទ្ធ ព្រះនាម សិទ្ធត្ថៈ ព្រះអង្គទ្រង់ទទួលហើយ ។ ទ្រង់បានត្រាស់ព្រះតម្រាស់នេះថា អ្នកទាំងឡាយចូលមើលជដិលតាបស ដែលមានតបៈខ្ពង់ខ្ពស់នោះចុះ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ។ល។ តថាគត លុះស្តាប់ព្រះសិទ្ធត្ថសម្មាសម្ពុទ្ធ ព្យាករណ៍ហើយ ក៏ធ្វើចិត្តឱ្យ ជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ។

១៧- ព្រះពុទ្ធព្រះនាមតិស្សៈ ជានាយកដ៏ប្រសើរក្នុងលោក ទ្រង់មិនមានបុគ្គល ស្មើ មានចក្ខុទ្រង់កើតឡើងក្នុងលោក កំចាត់បង់នូវងងឹតគឺអន្ធការញុំាង លោកនេះ ព្រមទាំងទេវលោកឱ្យភ្លឺស្វាងហើយ ។ គ្រានោះ តថាគត

ជាក្សត្រឈ្មោះ សុជាតៈ លះចោលភោគៈដ៏ច្រើនហើយទៅបួសជាឥសី ។ កាលដែលតថាគត បួសស្រេចហើយ ព្រះលោកនាយកក៏ទ្រង់កើតឡើង តថាគតកើតមានបីតិ ព្រោះបានស្តាប់សំឡេងថា ព្រះពុទ្ធ ។ តថាគតបាន កាន់យកផ្កាមន្ទារវព្រឹក្ស ផ្កាឈូក និង ផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វដោយដៃ ទាំងពីរជជុះរលាស់ជាសណ្ឋាន ហើយចូលទៅគាល់ ។ តថាគតកាន់ផ្កា នោះបាំងលើព្រះសិរ្សនៃព្រះជិនស្រី ព្រះនាមតិស្សៈ ជាលោកនាយក ។ ដែលមានបរិស័ទទាំងបួនចោមរោម ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់ កណ្តាលប្រជុំជន ហើយព្យាករណ៍តថាគតកាលនោះថា ។ល។ តថាគត លុះបានស្តាប់ព្រះពុទ្ធព្យាករណ៍ហើយ ធ្វើចិត្តឱ្យរីងរឹតតែជ្រះថ្លាថែម ទៀត ខំអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ។

១៨- ព្រះសម្ពុទ្ធព្រះនាមបុស្សៈទ្រង់ប្រតិស្ឋានឡើង ជានាយកដ៏ប្រសើរក្នុង លោក ។ ព្រះអង្គទ្រង់ញ៉ាំងមនុស្សព្រមទាំងទេវតា ឱ្យឆ្អែតស្កប់ស្កល់ ទ្រង់បង្អុរភ្លៀង ទឹកអម្រិតចុះមក ។ សម័យនោះ តថាគតជាក្សត្រ ព្រះនាមវិជិតៈ លះចោលរាជសម្បត្តិដ៏ធំ ទៅបួសក្នុងសំណាក់ព្រះសម្ពុទ្ធ នោះ ។ ព្រះពុទ្ធជាម្ចាស់ ព្រះនាមបុស្សៈ ជាលោកនាយកនេះ បានទ្រង់ ព្យាករណ៍តថាគតថា ។ល។ ចំណែកតថាគត ក៏បានស្តាប់ព្រះបុស្សៈ សម្ពុទ្ធទ្រង់ព្យាករណ៍ហើយ ក៏ញ៉ាំងចិត្តឱ្យរីងរឹតតែជ្រះថ្លា ហើយខំ អធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមីទាំង ១០ ប្រការ ។ តថាគត

រៀនយកនូវព្រះសូត្រផង ព្រះវិន័យផង ពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ប្រកបដោយអង្គ ៩ ទាំងអស់ផង ហើយញ៉ាំងសាសនាព្រះជិនស្រី ឱ្យរុងរឿង ។

១៩- ព្រះសម្ពុទ្ធព្រះនាមវិបស្សីដ៏ឧត្ដមជាងសត្វជើងពីរ ទ្រង់មានចក្ខុកើតឡើងក្នុងលោក ។ ព្រះអង្គ ទ្រង់ទំលាយស៊ុត គឺអវិជ្ជាចេញហើយ ដល់សម្ពោធិញ្ញាណដ៏ឧត្ដម ។ សម័យនោះ តថាគតកើតជាស្ដេចនាគ ឈ្មោះអតុលៈ មានឫទ្ធិច្រើន មានបុណ្យទ្រទ្រង់ពន្លឺ ។ ក្នុងកាលនោះ តថាគតមានពួកនាគច្រើនកោដិចោមរោមប្រគុំតូរ្យតន្ត្រីជាទិព្វ ហើយចូលទៅជិតព្រះលោកជេដ្ឋៈ ។ លុះចូលទៅដល់ហើយ ក៏និមន្តព្រះសម្ពុទ្ធ ព្រះនាមវិបស្សីជាលោកនាយក ហើយថ្វាយតាំងមាស ដែលដាំដោយកែវមណី និងកែវមុក្ដា ដែលស្អិតស្អាងហើយដោយអភរណៈគ្រប់យ៉ាងដល់ព្រះអង្គ ជាធម្មរាជ ។ ព្រះពុទ្ធជាម្ចាស់នោះ ទ្រង់គង់កណ្ដាលពួកសង្ឃ ហើយព្យាករណ៏តថាគតថា ។ល។ តថាគតបានស្ដាប់ព្រះពុទ្ធដីកានៃព្រះជិនស្រីអង្គនោះ ទ្រង់ត្រាស់ព្យាករណ៏តថាគតហើយ ក៏ញ៉ាំងចិត្តឱ្យរីងរឹតតែជ្រះថ្លាបានអធិដ្ឋានវត្តតទៅដើម្បីបំពេញបារមីទាំង១០ ប្រការ ។

២០- ព្រះសម្ពុទ្ធព្រះនាមសិខីជិនស្រី ទ្រង់ឧត្ដមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ។ ព្រះអង្គកំចាត់បង់នូវសេនានៃមារហើយដល់សម្ពោធិញ្ញាណដ៏ប្រសើរ ។ កាលនោះ តថាគតជាក្សត្រ ព្រះនាមអរិន្ទមៈ បានញ៉ាំងព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ឱ្យឆ្អែតស្កប់ស្កល់

ដោយបាយនិងទឹក ។ តថាគតបានប្រគេនសំពត់ជាច្រើន គឺកោដិនៃសំពត់មិនតិច ហើយថ្វាយយានដំរីប្រដាប់ហើយដល់ព្រះពុទ្ធ ។ តថាគតសាងយានដំរី ហើយបង្ហោនចូលទៅជិតឱ្យជារបស់គួរបំពេញចិត្តរបស់តថាគត ឱ្យតម្កល់នៅមាំអស់កាលជានិច្ច ។ ព្រះពុទ្ធព្រះនាមសិខី ជាលោកនាយកនោះ ទ្រង់ព្យាករណ៍តថាគតថា ។ល។ តថាគតបានស្តាប់ព្រះពុទ្ធព្យាករណ៍ហើយ រឹងរឹតតែធ្វើចិត្តឱ្យជ្រះថ្លា ហើយបានខំអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ប្រការ ។

២១- ក្នុងមណ្ឌកប្បនោះឯង មានព្រះជិនស្រី ព្រះនាមវេស្សភូ ព្រះអង្គមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់កើតឡើងក្នុងលោក ។ សម័យនោះ តថាគតជាក្សត្រព្រះនាមសុទស្សនៈ បានស្តាប់នូវធម៌ដ៏ប្រសើរ ហើយពេញចិត្តនឹងផ្នួសយ៉ាងក្រៃលែង បានបូជានូវព្រះជិនស្រីព្រមទាំងព្រះសង្ឃ ដោយបាយ ទឹកនិងសំពត់ ។ តថាគតបានញុំាងមហាទានឱ្យប្រព្រឹត្តទៅ ជាអ្នកមិនខ្ជិល ទាំងយប់ទាំងថ្ងៃ ហើយចូលទៅកាន់ផ្នួស ដែលបរិបូណ៌ដោយគុណក្នុងសំណាក់ព្រះជិនស្រី ។ តថាគតញុំាងសទ្ធានិងបីតិឱ្យកើតឡើង ហើយថ្វាយបង្គំព្រះសម្ពុទ្ធជាសាស្តាបីតិរបស់តថាគតក៏កើតឡើង ព្រោះហេតុនៃការត្រាស់ដឹង ។ ព្រះសម្ពុទ្ធទ្រង់ជ្រាបចិត្តមិនវិលត្រឡប់ហើយ ទ្រង់ត្រាស់ថា ក្នុងកប្បទី ៣១ អំពីកប្បនេះក្សត្រនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ល។ តថាគតបានស្តាប់ព្រះពុទ្ធដីកានៃព្រះសាស្តានោះព្យាករណ៍ហើយ ក៏ញុំាងចិត្តឱ្យជ្រះថ្លាក្រៃ

លែង បានខំអធិដ្ឋានវត្តតទៅ ដោយការបំពេញបារមីទាំង ១០។

២២- ព្រះសម្ពុទ្ធព្រះនាមកកុសន្ធៈ ទ្រង់ប្រសើរជាងសត្វទ្វេបាទ មានគុណរាប់មិនបាន គេគ្រុបសង្កត់បានដោយកម្រ ព្រះអង្គរំលើងនូវភពទាំងពួងដល់នូវបារមី ដោយចរិយា ហើយសម្រេចនូវពោធិញ្ញាណដ៏ឧត្តម ដូចសីហទំលាយនូវទ្រុង ។ សម័យនោះ តថាគតជាក្សត្រ ព្រះនាមខេមៈ បានថ្វាយទានដ៏ច្រើនចំពោះព្រះតថាគត និងព្រះសង្ឃជាជិនបុត្រ។ តថាគតបានចាត់ចែងថ្វាយបាត្រ ចីវរ ថ្នាំបន្តក់ និងដើមឈើអែមទាំងអស់នេះជារបស់ប្រសើរក្រៃពេកដែលតថាគតប្រាថ្នាហើយ ។ ព្រះមុនីកកុសន្ធៈជានាយកអង្គនោះ ទ្រង់ព្យាករណ៍តថាគតថា ។ល។ តថាគតបានស្តាប់ព្រះសម្ពុទ្ធកកុសន្ធៈ ត្រាស់ព្យាករណ៍ហើយ ក៏ញុំាងចិត្តឱ្យជ្រះថ្លាដ៏ក្រៃលែង បានអធិដ្ឋានវត្តតទៅដោយបំពេញបារមីទាំង ១០ ប្រការ ។ កាលនោះ នគរឈ្មោះខេមវតី ឯតថាគតជាបុរស ឈ្មោះខេមៈ ស្វែងរកនូវសម្ពោធិញ្ញាណ បានបួសក្នុងសំណាក់ព្រះពុទ្ធអង្គនោះ។

២៣- ព្រះជិនស្រីសម្ពុទ្ធព្រះនាមកោនាគមនៈ ព្រះអង្គឧត្តមជាងសត្វទ្វេបាទជាធំក្នុងលោក ទ្រង់ប្រសើរជាងពួកជន ។ សម័យនោះ តថាគតជាក្សត្រឈ្មោះបព្វតៈ បរិបូណ៌ដោយមិត្រនិងអាមាត្យ មានពលនិងពាហនៈច្រើន ។ តថាគតទៅ គាល់ព្រះសម្ពុទ្ធ ស្តាប់ធម៌ដ៏ប្រសើរហើយ និមន្តព្រះសង្ឃ ព្រមទាំងព្រះជិនស្រី ថ្វាយទានតាមសេចក្តីប្រាថ្នា ។ តថាគតបានថ្វាយវត្ថុ ៤ មុខ គឺសំពត់ចិនប្រទេស ១ សំពត់សូត្រ ១ សំពត់កម្ពល

១ ស្បែកជើងមាស ១ ចំពោះព្រះសាស្ដា ព្រមទាំងសាវ័ក ។ ព្រះមុនីនោះ ទ្រង់គង់កណ្ដាលសង្ឃទ្រង់ ព្យាករណ៏តថាគតថា ។ល។ តថាគតបានស្ដាប់ព្រះសម្ពុទ្ធត្រាស់ព្យាករណ៍ហើយ ក៏ញុាំងចិត្តឱ្យជ្រះថ្លាក្រៃលែង បានខំអធិដ្ឋានវត្តតទៅ ដោយការបំពេញនូវបារមីទាំង ១០ ។ តថាគតប្រសើរជាងជន កាលស្វែងរកសព្វញ្ញុតញ្ញាណ បានឱ្យទានលះបង់រាជសម្បត្តិដ៏ធំ ហើយបួសក្នុងសំណាក់ព្រះជិនស្រី ។

២៤- ព្រះសម្ពុទ្ធព្រះនាមកស្សបៈ ដ៏ឧត្ដមជាងសត្វទ្វេបាទ ជាធម្មរាជ ទ្រង់ធ្វើពន្លឺ ។ ទ្រង់ញុាំងព្រះទ័យ ឱ្យពេញដល់សម្ពោធិញ្ញាណដ៏ឧត្ដម ដូចជាគោឧសភៈ ទំលាយនូវក្រោល ។ កាលនោះ តថាគតជាមាណព ឈ្មោះជោតិបាល ជាអ្នករៀនមន្ត ចេះចាំមន្តដល់នូវត្រៃយនៃវេទទាំង ៣ ។ តថាគតដល់នូវបារមី ក្នុងគម្ពីរលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងព្រះសទ្ធម្មផង ឈ្លាសវៃក្នុងផែនដី និង អាកាស មានវិជ្ជាធ្វើរួចហើយ ជាអ្នកមិនមានរោគ ។ ឧបាសក ឈ្មោះឃដិកា ជាឧបដ្ឋាករបស់ព្រះមានព្រះភាគ ព្រះនាមកស្សបៈ ប្រកបដោយសេចក្ដីគោរព ប្រកបដោយសេចក្ដីកោតក្រែង និព្វានក្នុងផលទី ៣ ឃដិកានាំតថាគត ចូលទៅគាល់ព្រះជិនស្រី ព្រះនាមកស្សបៈ តថាគតស្ដាប់ធមិរបស់ព្រះពុទ្ធនោះ ក៏បួសក្នុងសំណាក់នៃព្រះអង្គ ។ តថាគតមានព្យាយាម ក្លៀវក្លា ឈ្លាសវៃ ក្នុងវត្តតូចនិងវត្តធំ មិនមានសេចក្ដីសាបសូន្យក្នុងសីល និង សមាធិមួយឡើយ ញុាំងសាសនានៃព្រះជិនស្រី ឱ្យពេញបរិបូណ៌ ។ សាសនាព្រះ

សាស្តាមានអង្គ ៩ ដែលព្រះអង្គសំដែងហើយទាំងប៉ុន្មាន តថាគតបាន រៀននូវធម៌ទាំងអស់នោះ ហើយញ៉ាំងសាសនាព្រះជិនស្រីឱ្យរុងរឿង ។ ព្រះពុទ្ធនោះ ឃើញហេតុដ៏អស្ចារ្យរបស់តថាគត ក៏ទ្រង់ព្យាករណ៍ថា ជោតិបាល មាណពនេះនឹងបានត្រាស់ដឹងជាព្រះពុទ្ធ ក្នុងភទ្ទកប្បនេះឯង ។ល។ តថាគតបានស្តាប់ព្រះពុទ្ធដីការបស់ព្រះសម្ពុទ្ធ អង្គនោះហើយ ក៏ញ៉ាំងចិត្តឱ្យជ្រះថ្លាក្រៃលែង បានខំអធិដ្ឋានវត្តតទៅទៀត ដោយការ បំពេញបារមីទាំង ១០ ។

(បញ្ជាក់ព្រះពុទ្ធដីកា ទ្រង់ត្រាស់ព្យាករណ៍ដល់ព្រះបរមពោធិសត្វ ជាតួ អង្គរបស់ព្រះសមណគោតមបរមគ្រូរបស់យើង ព្រះពុទ្ធដីកានោះស្មើគ្នាទាំង២៤ ព្រះអង្គ ប្លែកតែត្រង់ចំនួនកប្បប៉ុណ្ណោះ) តែខ្ញុំមានសរសេរក្នុងពុទ្ធបកិណ្ណកកណ្ឌ ក្នុងខាងមុខនេះហើយ ។

(បិដកលេខ ៧៧ ទំព័រ ២១ ដល់ ២៣២)

# ពុទ្ធប្បកិណ្ណកកណ្ឌ

| ព្រះពុទ្ធ២៨អង្គ | កប្បព្រះពុទ្ធសមណគោតមបរមគ្រូទទួលការព្យាករណ៍រហូតបានត្រាស់ | កប្បទី |
|---|---|---|
| សារមណ្ឌកប្ប៤. | តណ្ហង្ករៈ មេធង្ករៈ សរណង្ករៈ ទីបង្ករៈ | |
| សុញ្ញកប្ប | ប្រមាណជា១អសង្ខេយ្យកប្បនេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| សារកប្ប១អង្គ | កោណ្ឌញ្ញៈ | |
| សុញ្ញកប្ប | ប្រមាណជា១អសង្ខេយ្យកប្បនេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| សារមណ្ឌកប្ប៤. | មង្គលៈ សុមនៈ រេវតៈ សោភិតៈ | |
| សុញ្ញកប្ប | ប្រមាណជា១អសង្ខេយ្យកប្បនេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| វរកប្ប ៣អង្គ | អនោមទស្សី បទុមៈ នារទៈ | |
| សុញ្ញកប្ប | ប្រមាណជា១អសង្ខេយ្យកប្បនេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| សារកប្ប ១អង្គ | បទុមុត្តរៈ | ១សែន |
| សុញ្ញកប្ប | ៧០០០០កប្បនេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| មណ្ឌកប្ប ២អង្គ | សុមេធៈ សុជាតៈ | ៣ម៉ឺន |
| សុញ្ញកប្ប | ២៨២០០កប្បនេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| វរកប្ប ៣អង្គ | បិយទស្សី អត្ថទស្សី ធម្មទស្សី | ១៨០០ |
| សុញ្ញកប្ប | ១៧០៥កប្ប (១) នេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| សារកប្ប ១អង្គ | សិទ្ធត្ថៈ | ៩៤ |
| សុញ្ញកប្ប | ១កប្បនេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| មណ្ឌកប្ប ២អង្គ | តិស្សៈ បុស្សៈ | ៩២ |
| សារកប្ប ១អង្គ | វិបស្សី | ៩១ |
| សុញ្ញកប្ប | ៥៩កប្បនេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| មណ្ឌកប្ប ២អង្គ | សិខី វេស្សភូ | ៣១ |
| សុញ្ញកប្ប | ២៩កប្បនេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| ភទ្ទកប្ប ៥ អង្គ | កកុសន្ធៈ កោនាគមនៈ កស្សបៈ គោតម (មេត្តេយ្យៈអនាគត) | |

៤អសង្ខេយ្យ១សែនមហាកប្ប

(បិដក លេខ ៧៧ ទំព័រ ២៣៣)

# រយៈពេលព្យាយាម

ការបំពេញបារមីរបស់ព្រះពោធិសត្វបីប្រភេទ

អស់កាលជាច្រើន នឹងបានជួបព្រះពុទ្ធចំនួនច្រើនព្រះអង្គ

ជានិយតៈពោធិសត្វ បានទទួលពុទ្ធព្យាករណ៍ក្នុងចន្លោះកាល វចីបណិធាន

| ព្រះពោធិសត្វ បីប្រភេទ / តាំងប្រណិធាន | បញ្ញាធិក | សទ្ធាធិក | វីរិយាធិក | ចំនួន |
|---|---|---|---|---|
| មនោបណិធាន (តាំងប្រាថ្នាក្នុងចិត្តថា នឹងឱ្យបានជាព្រះពុទ្ធ) | ៧<br>១២៥,០០០ | ១៤<br>២៥០,០០០ | ២៨<br>៥០០,០០០ | អសង្ខេយ្យកប្ប<br>ជួបព្រះពុទ្ធ |
| វចីបណិធាន (បញ្ចេញវាចាប្រាថ្នាថា នឹងឱ្យបានជាព្រះពុទ្ធ) | ៩<br>៣៨៧,០០០ | ១៨<br>៧៧៤,០០០ | ៣៦<br>១,៥៤៨,០០០ | អសង្ខេយ្យកប្ប<br>ជួបព្រះពុទ្ធ |
| កាយវចីបណិធាន (ការតាំងប្រាថ្នាដោយកាយនិងវាចា) គឺបានទទួលព្រះពុទ្ធព្យាករណ៍ | ៤<br>១៣<br>១សែនមហាកប្ប<br>១៥ | ៨<br>២៥<br>១សែនមហាកប្ប<br>៣០ | ១៦<br>៤៩<br>១សែនមហាកប្ប<br>៦០ | អសង្ខេយ្យកប្ប<br>ជួបព្រះពុទ្ធ<br>..................<br>ជួបព្រះពុទ្ធ |
| រួមកប្ប<br>រួមព្រះពុទ្ធ | ២០<br>៥១២,០២៨<br>(១) | ៤០<br>១,០២៤,០៥៥<br>(២) | ៨០<br>២,០៤៨,១០៩<br>(៣) | អសង្ខេយ្យកប្ប<br>ព្រះអង្គ |

បានបំពេញអភិនីហារ បារមីបរិបូរណ៍ទើបសម្រេចជាព្រះពុទ្ធ

# ១០ ពុទ្ធការកធម៌

ពុទ្ធធម៌គឺធម៌ដែលធ្វើបុគ្គលឱ្យបានត្រាស់ជាព្រះពុទ្ធ មាន ១៨ ប្រការគឺ បារមី ១០ ប្រការ និង សម្បត្តិ ៨ ប្រការ ។

## បារមី ១០ ប្រការ

ធម៌ដែលជាគុណឬជាយានសម្រាប់នាំសត្វទៅកាន់សិវស្ថានគឺ ព្រះនិព្វាន ហៅថា បារមី ។ បារមី សព្ទនេះ ប្រែថា គុណជាតជាហេតុ ដល់នូវត្រើយពោលគឺ ព្រះនិព្វានរបស់ជន ឬ នឹងហៅថា អរិយធម៌ដូច្នេះវិញ ក៏បានអរិយធម៌នោះ ប្រែថា ធម៌ដ៏ប្រសើរ ឬ ថាធម៌របស់ព្រះអរិយបុគ្គល ។

បារមីធម៌ទាំងឡាយនេះហើយដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង សាវ័កនៃព្រះពុទ្ធទាំងឡាយទាំងពួងតែងប្រតិបត្តិប្រាថ្នាយក ។ អធិប្បាយថា កាលបើជនជាសប្បុរសទាំងឡាយណាមួយ មានចេតនានឹងប្រាថ្នានូវភាវៈនៃខ្លួន ជាព្រះពុទ្ធក្តី ជាព្រះបច្ចេកពុទ្ធក្តី ជាព្រះអរហន្តក្តី ជនទាំងឡាយនោះ លុះតែ ញ៉ាំងបារមីធម៌ទាំងឡាយនោះឱ្យពេញបរិបូរណ៌ឡើង អស់កាលជាអង្វែង ទើប បានសម្រេច ។

បណ្តាជនជាសប្បុរសទាំងឡាយនោះ កាលបើអ្នកណាមួយ ត្រូវការ ប្រាថ្នាយកនូវទីនៃខ្លួន ជាព្រះអរហន្ត បានញ៉ាំងបារមីធម៌ទាំងឡាយនោះ ឱ្យ ពេញបរិបូរណ៌ ទើបព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ឱ្យឈ្មោះនូវបារមីធម៌ របស់អ្នកនោះថា សាវ័កបារមី ។ បើមិនដូច្នោះទេ អ្នកណាមួយចូលចិត្ត ចង់ ប្រាថ្នានូវឋាននៃខ្លួនជាព្រះបច្ចេកពុទ្ធ បានបំពេញនូវបារមីធម៌ទាំងឡាយនោះ

ឱ្យបរិបូរណ៍ ទើបព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ហៅនូវបារមីធម៌របស់អ្នកនោះថា បច្ចេកពោធិបារមី ។

ម្យ៉ាងទៀត បើជនជាសប្បុរសណាមួយ នឹងប្រាថ្នានូវភាវៈនៃខ្លួនជាព្រះពុទ្ធ បានញ៉ាំងបារមីធម៌ទាំងឡាយនោះ ឱ្យបរិបូរណ៍គ្រប់គ្រាន់ទើបព្រះអនាវរណញ្ញាណ ទ្រង់ត្រាស់ឱ្យឈ្មោះនូវបារមីធម៌របស់អ្នកនោះថា សម្មាសម្ពោធិបារមី ។

ម្យ៉ាងទៀតថា ធម៌ទាំងឡាយឯណា មានទាននិងសីលជាដើម ដែលជនបានធ្វើហើយដោយកិរិយាសន្សំ ចង់បាននូវលាភ និងសក្ការៈនិងកេរ្តិ៍ឈ្មោះក្តី ដោយចេតនាប្រាថ្នានូវសេចក្តីចម្រើនយសក្តី និង ភោគសម្បទាក្តី ដោយភាវៈនៃពាក្យពោលលើកខ្លួន ឬសរសើរខ្លួនឯង និងពោលតិះដៀល ឬបង្អាប់បង្អន់នូវបុគ្គលដទៃក្តី ដោយកិរិយា តម្កល់នូវគំនិតអាក្រក់ ជាមិច្ឆាទិដ្ឋិ តាមអំណាចនៃការយល់ខុសដូច្នេះថា

**នត្ថិទិន្នំ** ទានដែលបុគ្គលធ្វើហើយ មិនអាចនឹងឱ្យផលប្រយោជន៍ដល់អ្នកម្ចាស់ ដែលធ្វើនោះវិញទេ ។

**នត្ថិកម្មវិបាកោ** ផលនៃកុសលកម្មនិងអកុសលកម្មមិនមានទេ យ៉ាងនេះជាដើម ធម៌ទាំងឡាយនោះនឹងឱ្យឈ្មោះថា បារមីធម៌មិនបានឡើយ ព្រោះមិនមានន័យ សេចក្តីករុណោបាយ គឺថា មិនមានសេចក្តីអាណិតជាឧបាយ ។

ន័យមួយទៀតថា ធម៌ទាំងឡាយឯណា មានទានជាដើម បើមិនមានសេចក្តីឈ្វេងយល់ ឬ ឆ្លៀវឆ្លាស ដោយឧបាយនៃករុណាចិត្តមិនបានថែរក្សា

ទំនុកបំរុងទេធម៌ទាំងឡាយនេះ មិនបានរាប់បញ្ចូលជាបារមីធម៌ឡើយ ព្រោះមិនមាននៃកុរណោបាយ កោសល្លនោះឯង ។

ម្យ៉ាងទៀត លោកអ្នកសប្បុរសណាមួយ ដែលជាអ្នកបំពេញនូវបារមីធម៌ទាំងឡាយដោយតាំងចិត្តប្រកបដោយអធ្យាស្រ័យដើម្បីនឹងរើខ្លួន រលាស់ចេញចាកសេចក្តីដែលយើងពោលមកហើយ ខាងដើមនោះ សប្បុរសទាំងឡាយនោះលោកតែងមិនមានរន្ធត់ញាប់ញ័រដោយពាក្យតិះដៀល នឹងសេចក្តីសរសើរឡើយ ប្រៀបដូចដុំថ្មតាន់ ដែលតាំងនៅនឹងមិនកម្រើករំភើប ដោយខ្យល់ព្យុះបក់បោកមកឡើយ ។

ប្រការមួយទៀត លោកអ្នកសប្បុរសទាំងនោះ លោកមិនរលឹកនូវអំពើកម្មដែលលោកបានធ្វើហើយ គឺថា មិនបានក្តៅក្រហាយស្តាយក្រោយ ព្រោះតែអ្នកឯទៀត គេថ្កោលទោស ឬ លើកទោសចំពោះខ្លួនដោយមិនមានហេតុអ្វីដែលគួរនឹងលើកទោសក្តី ដោយសេចក្តីច្រណែន ឬ អំណាចនៃបុគ្គលដទៃក្តី ដោយការងងឹតល្ងង់របស់អ្នកដទៃក្តី ក៏អ្នកសប្បុរសទាំងនោះមិនដែលទោមនស្សតូចចិត្ត អាក់អន់ឡើយ ។

ឯបារមីធម៌ទាំង ១០ យ៉ាងនេះ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងទុកមកថាដូច្នេះ ÷

**ទានសីលញ្ច នេក្ខម្មំ បញ្ញាវីរិយេន បញ្ចមំ ខន្តិសច្ចអធិដ្ឋានំ មេត្តុបេក្ខាតិ មេទស ។**

ប្រែជាសេចក្តីថា បារមីធម៌ទាំងឡាយ ១០ ប្រការនេះគឺ÷

១- **ទានំ** ទេយ្យវត្ថុដែលបុគ្គលគប្បីឱ្យ ។

២- **សីលំ** កិរិយាប្រព្រឹត្តនៅជាប្រក្រតីឬសេចក្តីរក្សាកាយវាចាឱ្យល្អ ។

៣- **នេក្ខម្មំ** កិរិយាចេញទៅដើម្បីគុណធំ ឬថា បព្វជ្ជាគឺផ្នួស ឬកិរិយាចេញកសាង ។

៤- **បញ្ញា** ធម្មជាតិដឹងដោយបការៈ ឬសេចក្តីយល់ឃើញជាក់ច្បាស់ ។

៥- **វីរិយ** សេចក្តីព្យាយាមសេចក្តីប្រឹងប្រែង ។

៦- **ខន្តិ** សេចក្តីអត់ធន់ ការប្រឹងអត់ទ្រាំ ។

៧- **សច្ចំ** ការពិតប្រាកដ សេចក្តីទៀងត្រង់ ។

៨- **អធិដ្ឋានំ** កិរិយាតាំងចិត្តទទួលកិច្ចដែលគួរគប្បីកាន់យក ។

៩- **មេត្តា** សេចក្តីស្នេហស្និទ្ធស្រឡាញ់ដោយតាំងចិត្ត មិនព្យាបាទ អាឃាតដល់ជនដទៃ ។

១០- **ឧបេក្ខា** សេចក្តីស្មើរទុក្ខស្មើរសុខយ៉ាងកណ្តាល ។

## ១ ទានបារមី

**ករុណូបាយកោសល្លបរិគ្គហិតា អត្ថុបករណបរិច្ចាគចេតនា ទានបារមិតា ។**

សេចក្តីថា ចេតនាដែលជាគុណសម្រាប់លះ ឬសម្រាប់ឱ្យនូវវត្ថុដែលជាគ្រឿងប្រើប្រាស់របស់ខ្លួន ទៅជាទានដោយកិរិយាឈ្លាស ក្នុងឧបាយនៃសេចក្តីអាណិតអាសូរ យ៉ាងនេះ ឈ្មោះថា ទានបារមី ។

ឯព្រះបរមពោធិសត្វ ព្រះអង្គមានសេចក្តីត្រេកអរចំពោះត្រង់ទានជានិច្ចកាល តែងស្វែងរកតែទីឱកាសឯណាមួយ ដើម្បីនឹងធ្វើនូវទាន ហើយទើបស្ថិត

នៅដោយស្រួល ។

ម្យ៉ាងទៀត ព្រះពោធិសត្វនោះ ព្រះអង្គតែងមានព្រះហឫទ័យ ជាទុក្ខ អផ្សុក ធុញទ្រាន់ ព្រោះតែការសុំនូវរបស់អ្វីនីមួយអំពីអ្នកដទៃដើម្បីខ្លួនឯង ក្រៃពេកណាស់ បានជាលោកខំធ្វើទាន ឥតមានស្រាកស្រាន្ត ដូចមានរឿងនិទាន បន្តិច ក្នុងព្រហ្មទត្ត ជាតកថា កាលគ្រាមួយនោះ ព្រះពោធិសត្វនៃយើងនេះ លោកកើតជាអាមាត្យនៃស្ដេចព្រហ្មទត្ត អាមាត្យនោះ មានប្រាថ្នាចង់បានស្បែក ជើង និងឆត្រស្លឹកត្នោតរបស់មហាក្សត្រនោះក្រៃពេក អស់ប្រមាណ ១២ ឆ្នាំ តែមិនអាចនឹងហ៊ានហើបមាត់ឡើង ក្រាបបង្គំទូលសុំនូវរបស់ទាំងនោះ អំពីព្រះ មហាក្សត្រដែលជាម្ចាស់របស់ខ្លួននោះឡើយ ព្រោះអាមាត្យនោះមានសេចក្ដី អៀនខ្មាស ត្រង់ការសុំគេនោះពេកណាស់ ហេតុយ៉ាងនេះហើយ បានជាព្រះ ពោធិសត្វ ព្រះអង្គខំស្វែងរកឱកាស តែនឹងធ្វើទានឥតមានសេចក្ដីធុញទ្រាន់ ឡើយ តែថាបើព្រះអង្គបានឱ្យនូវរបស់អ្វីនីមួយជាទានដល់អ្នកឯណាមួយ ហើយ លោកមិនទទឹងចាំទាររកគុណប្រយោជន៍ ឬ រងចាំឧបការកិច្ច ដែលគេធ្វើតប វិញនោះឡើយ គឺថា បើព្រះអង្គឱ្យនូវទ្រព្យសម្បត្តិអ្វីមួយដល់បុគ្គលណាមួយ ហើយ ព្រះអង្គមិនរីរារង់ចាំយកគុណប្រយោជន៍ ឬរង្វាន់អ្វីអំពីបដិគ្គាហកៈនោះ ទេ ព្រះអង្គតែងតាំងព្រះហឫទ័យ ហាក់ដូចជាភ្លេចឬច្រឡំបាត់ទៅ មិនមានព្រះ ចិន្ដាអាឡោះអាល័យ ចង់បានប្រយោជន៍អំពីអ្នកនោះវិញឡើយ ។

ម្យ៉ាងទៀត ថាបើរបស់ទ្រព្យខ្លួនមានហើយ លោកមិនដែលពោលប្រាប់ គេឯងថា របស់នោះគ្មានទេ ក្នុងកាលណាមួយឡើយ គឺថា បើរបស់អ្វីមាន

ក៏ប្រាប់ថា របស់នេះមាន បើរបស់អ្វីគ្មានក៏ប្រាប់ថាគ្មាន បើបដិគ្គាហកៈឯណាត្រូវការចង់បានវត្ថុអ្វី ព្រះពោធិសត្វក៏ត្រូវការឱ្យនូវវត្ថុនោះដល់អ្នកទទួលនោះមិនខាន ទុកជាអ្នកណាមួយ ដែលត្រូវការនោះ គ្រាន់តែនឹកចង់បានក្នុងចិត្តមិនអាចហាមាត់សុំទេ បើប្រសិនណាជាពោធិសត្វ លោកអាចដឹងដោយខ្លួនលោកបាន ក៏អាចនឹងឱ្យនូវរបស់ដែលគេត្រូវការនោះមិនខាន នឹងបាច់ពោលទៅថ្វីដល់អ្នកនិយាយសុំនោះ ទានរបស់ពោធិសត្វយ៉ាងនេះបានឈ្មោះថា ជាទានដ៏ប្រពៃក្រៃពេក ។ ម្យ៉ាងទៀត ពោធិសត្វព្រះអង្គមិនដែលឱ្យនូវភោជនាហារ គឺបាយ និងម្ហូបចំណី ដែលជារបស់មិនឆ្ងាញ់ពិសា ឬ មិនជាទីសប្បាយ ពេញចិត្តដល់អ្នកជម្ងឺ ឬ អ្នកសុំឯណាមួយឡើយ លោកតែងឱ្យតែរបស់ដែលត្រូវចិត្ត គាប់អធ្យាស្រ័យដល់ស្មូម កាលបើនឹងឱ្យអាមិសទាននោះសោត ព្រះអដ្ឋកថាចារ្យលោកតែងពោលសរសើរទុក ក្នុងអដ្ឋកថានៃគម្ពីរចរិយាបិដក យ៉ាងនេះថា មហាបុរសដែលនឹងឱ្យនូវអាមិសទាន គឺវត្ថុដែលទូទៅក្នុងបច្ច័យទាំង ៤ យ៉ាង ដែលគេគប្បីឱ្យមានចីវរប្បច្ច័យជាដើមនោះ លោកតែងឱ្យនូវវត្ថុ ១០ ប្រការគឺ៖

១- **អន្នទាន** គឺឱ្យបាយឬភោជនាហារទាំងពួងដល់ស្មូមទាំងឡាយ ដោយសេចក្តីត្រិះរិះរបស់ព្រះអង្គថា អាត្មាអញនឹងញុំាងសម្បត្តិ ៥ យ៉ាង គឺ អាយុវែង ១ ពណ៌សម្បុរល្អចាំនៅ ១ សេចក្តីសុខកាយ សប្បាយចិត្ត ១ កម្លាំងកាយ ១ ប្រាជ្ញាស្មារតី ១ និងសម្បត្តិគឺលោកុត្តរផល ដែលបុគ្គលគប្បីត្រេកអរ ឱ្យសម្រេចដល់សត្វលោកទាំងពួង ដោយផលនៃទានដែលអាត្មាអញបានឱ្យនេះ ។

២- **បានទាន** គឺឱ្យទឹកក្តៅឬទឹកត្រជាក់ដល់អ្នកសូមទាំងឡាយ ដើម្បីរម្ងាប់បំបាត់នូវសេចក្តីស្រេចឃ្លាន គឺកាមកិលេសនៃសត្វទាំងឡាយ ។

៣- **វត្ថទាន** គឺឱ្យសំពត់សម្រាប់ស្លៀកដណ្តប់ដល់យាចកទាំងឡាយ ដើម្បីរក្សានូវពណ៌សម្បុរឱ្យល្អ ដូចជាពណ៌នៃមាសផង ដើម្បីអភិបាលនូវសេចក្តីខ្មាសបាប និងសេចក្តីតក់ស្លុតចំពោះបាប និងគ្រឿងប្រដាប់សម្រាប់ស្លៀកពាក់នៃសត្វទាំងឡាយផង ។

៤- **យានទាន** គឺឱ្យគ្រឿងជិះ គ្រឿងសែង ឬឱ្យស្ពានដល់បដិគ្គាហកៈទាំងឡាយ ដើម្បីសម្រេចនូវឥទ្ធិឫទ្ធិផង ដើម្បីសំរួលឱ្យបាននូវសេចក្តីសុខ ក្នុងព្រះនិព្វានផង ។

៥- **គន្ធទាន** គឺឱ្យគ្រឿងក្រអូបជាទាន ដើម្បីសម្រេចកេរ្តិ៍ឈ្មោះក្រអូបអំពីសីលគុណ ។

៦- **មាលាវិលេបនទាន** គឺឱ្យផ្កាកម្រងនិងគ្រឿងម្សៅ គ្រឿងលុបលាបផ្សេងៗជាទាន ដើម្បីសម្រេចនូវសុន្ទររាសីនៃព្រះពុទ្ធគុណ ។

៧- **អាសនទាន** គឺឱ្យទីស្ថានសម្រាប់អង្គុយជាទាន ដើម្បីប្រយោជន៍ដល់ពោធិមណ្ឌាសនៈ គឺ ញាណដ៏ថ្កូវថ្កើងជាទីត្រាស់ដឹង ឈ្មោះថា ពោធិ ។

៨- **សេយ្យទាន** គឺឱ្យនូវទីស្ថានសម្រាប់ដេកជាទាន ដើម្បីសម្រេចសម្រាន្តនូវទីស្ថានក្រឡាព្រះបន្ទំ ឈ្មោះថា តថាគតសេយ្យាសនៈ ។

៩- **អាវាសថទាន** គឺឱ្យលំនៅជាទាន ដើម្បីសម្រេចនូវតេជានុភាពនៃខ្លួនព្រះអង្គ ឱ្យបានជាទីពឹងទីជ្រកនៃសត្វលោក ។

១០- **បទីបេយ្យទាន** គឺឱ្យនូវគ្រឿងសម្រាប់បំភ្លឺមានពន្លឺគោម និងពន្លឺចង្កៀង ជាដើម ជាទាន ដើម្បីសម្រេចនូវចក្ខុ ៥ យ៉ាង មានទិព្វចក្ខុជាដើម ។

ន័យមួយទៀត ព្រះពោធិសត្វឱ្យនូវទាន ៦ ប្រការទៀត គឺ ៖

១- **រូបទាន** ឱ្យរបស់មានរូបជាទាន គឺបូជានូវវត្ថុមានពណ៌ទាំងឡាយ មានផ្កាកម្រង និងសំពត់ ដែលមានពណ៌ល្អជាដើម ដល់ពុទ្ធាទិរតនៈ ដើម្បីបានសម្រេចឆព្វណ្ណរង្សី ប្រមាណមួយព្យាមចេញពីព្រះអង្គជាដើម ។

២- **សទ្ទទាន** ឱ្យសំឡេងជាទាន គឺបូជាតូរ្យតន្ត្រី ដល់ព្រះរតនត្រ័យ និងប្រគេននូវប្រេង និងទឹកអំពៅជាថ្នាំសំឡេងដល់ធម្មកថិកទាំងឡាយ និងឃោសនាឱ្យគេមកប្រជុំស្តាប់ធម៌ នឹងសំដែងធម្មទេសនា ឱ្យអ្នកទាំងពួងស្តាប់ជាដើម ដើម្បីឱ្យមានសំឡេងពីរោះក្បោះក្បាយ ដូចសំឡេងមហាព្រហ្ម ។

៣- **គន្ធទាន** ឱ្យក្លិនជាទាន គឺបូជានូវគ្រឿងក្រអូប មានឫសក្រអូបជាដើម ដែលជាទីគាប់ចិត្តដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដើម្បីឱ្យបានសរីរទ្ធិដោយសីលាទិគុណ ។

៤- **រសទាន** ឱ្យរសជាទាន គឺបូជានូវវត្ថុដែលមានរសឆ្ងាញ់ពិសា មានរសមើម និង ផ្លាជាដើម ដល់ពុទ្ធាទិវត្ថុ ដើម្បីឱ្យបានសម្រេចនូវគុណវិសេសគ្រាន់ជាទី ស្នេហាស្រឡាញ់ ដល់សត្តនិកក្នុងត្រៃភព ។

៥- **ផោដ្ឋព្វទាន** ឱ្យនូវវត្ថុផ្សព្វផ្សាយនូវកាយជាទាន គឺបូជានូវសេយ្យាសនៈ ទាំងឡាយ មានគ្រែ និងតាំងជាដើម ដល់ពុទ្ធាទិរតនត្រ័យដើម្បីសេចក្តី

ក្បៀមក្សាន្តយ៉ាងសុខុម ជាព្រះសព្វញ្ញុពុទ្ធ ។

៦- **ភេសជ្ជទាន** ឱ្យនូវថ្នាំរម្ងាប់រោគជាទាន គឺបូជានូវវត្ថុ ៣ មុខ គឺ សប្បិ និង នវនីតៈ ១ ទឹកអដ្ឋបាន ១ ភត្ត ១៤ ប្រការ ១ ដល់ព្រះរតនៈ ទាំង ៣ ដើម្បីឃាត់នូវជាតិ ជរា ព្យាធិ មរណទុក្ខ មិនឱ្យកើតមានដល់ព្រះអង្គ ឡើយ ។

ម្យ៉ាងទៀត ព្រះពោធិសត្វតែងឱ្យនូវទាន ឯទៀត ១០ ប្រការគឺ ÷

១- **ទាសាទំភុជិស្សទាន** គឺកិរិយាលោះលែងនូវបាវព្រាវ ខ្ញុំកំដរឱ្យរួចជាអ្នកជា ជាទាន ដើម្បីដោះស្រាយនូវព្រះអង្គមិនឱ្យជាខ្ញុំនៃកិលេសតណ្ហា ។

២- **អនវជ្ជខិឌ្ឌារតិហេតុទាន** គឺឱ្យនូវវត្ថុសម្រាប់លេង ដែលមិនមានទោស ទៅជាទាន ដើម្បីសេចក្តីត្រេកអរចំពោះព្រះសទ្ធម្មរបស់ព្រះអង្គ ។

៣- **បុត្តទាន** គឺឱ្យនូវកូនប្រុសទៅជាទាន ដល់ជនទាំងឡាយ ដើម្បីកិរិយា នាំចូលទៅជិតកាន់ភាវៈនៃកូននោះ ជាកូននៃព្រះអង្គក្នុងជាតិជាអរិយ បុគ្គល ។

៤- **ទារទាន** គឺ ឱ្យនូវប្រពន្ធជាទានដល់ជនទាំងឡាយ ដើម្បីកិរិយាបាននូវ ភាវៈនៃព្រះអង្គជាម្ចាស់នៃសត្វលោកទាំងអស់ ។

៥- **រជ្ជទាន** គឺឱ្យនូវរាជសម្បត្តិជាទាន ដើម្បីបាននូវភាវៈនៃព្រះអង្គជាស្តេច ព្រោះព្រះអង្គត្រាស់ដឹងនូវធម៌ ។

៦- **ហត្ថទាន** គឺឱ្យនូវព្រះហស្តជាទាន ដើម្បីឱ្យមានព្រះសទ្ធម្មក្នុងព្រះហស្ត

ជាប្រយោជន៍ដល់សត្វទាំងឡាយ និងបានរើខ្លួនចេញចាកអន្លង់ទាំង ៤ មានបញ្ចពិធកាមគុណជាដើម ។

៧- **កណ្ណនាសាទិទាន** គឺឱ្យនូវចំណែករាងកាយ មានត្រចៀកនិងច្រមុះជាដើមទៅជាទាន ដើម្បីបានចំពោះនូវឥន្ទ្រិយជាកុសល មានសទ្ធិន្ទ្រិយ ជាដើម ។

៨- **ចក្ខុទាន** គឺឱ្យនូវព្រះនេត្រទៅជាទាន ដើម្បីបានចំពោះនូវសមន្តចក្ខុ ។ ព្រះបរមពោធិសត្វ ព្រះអង្គតែងស្វែងរកនូវប្រយោជន៍និងសេចក្តីសុខ ឱ្យដល់សត្វទាំងឡាយ គ្រប់កាលទាំងពួង ។ ម្យ៉ាងទៀត សត្វលោកទាំងឡាយ គប្បីចូលទៅជិត រស់នៅក្នុងកិច្ចទាំងឡាយដ៏ឧត្តម មានកិរិយាឃើញនិងឮ និងរលឹករឿយៗ និងធ្វើការបម្រើជាដើមចំពោះព្រះអង្គ ។

៩- **មំសលោហិតទាន** គឺកិរិយាឱ្យនូវសាច់ និងឈាមទៅជាទាន ព្រោះព្រះអង្គ មានបំណងថា សូមឱ្យអាត្មាអញមានសរីរៈរាងកាយបរិបូណ៌ ។

១០- **ឧត្តមង្គទាន** គឺកិរិយាឱ្យនូវអង្គដ៏ឧត្តម គឺព្រះសីសៈរបស់ព្រះអង្គទៅជាទាន ព្រោះព្រះអង្គគិតបំណងថា សូមឱ្យអាត្មាអញបានជាបុគ្គលឧត្តមខ្ពង់ខ្ពស់ជាងសត្វលោកទាំងពួង ។

ទាននោះចាត់ជាទាន ៣ ប្រការ ដោយអំណាចទានបារមី ១ ទាន-ឧបបារមី ១ ទានបរមត្ថបារមី ១ ដូចមានសេចក្តីខាងក្រោមនេះ៖

ក) **បុត្តទារធនាទិឧបករណបរិច្ចាគោ ទានបារមី នាម** សេចក្តីលះនូវគ្រឿងប្រើប្រាស់របស់ខ្លួន មានកូន និងប្រពន្ធនិងទ្រព្យជាដើម ឱ្យទៅជាទាន

ឈ្មោះថា **ទានបារមី** ប្រែថា ធម្មជាតិជាហេតុដល់នូវត្រើយ គឺ ព្រះនិព្វាននៃជន ព្រោះទាន ។

ខ) **អត្តនោ អង្គបរិច្ចាគោ ទានឧបបារមី នាម** កិរិយាលះនូវអង្គនៃខ្លួន គឺ ឱ្យនូវអវយវៈធំ និងតូចរបស់ខ្លួនទៅជាទាន ឈ្មោះថា **ទានឧបបារមី** ប្រែថា ធម្មជាតិជាហេតុដល់នូវត្រើយខាងលើ គឺ ព្រះនិព្វាននៃជន ព្រោះទាន ។

គ) **អត្តនោ ជីវិតបរិច្ចាគោ ទានបរមត្ថបារមី នាម** កិរិយាដែលលះបង់នូវជីវិតនៃខ្លួនឱ្យទៅជាទាន ឈ្មោះថា ទានបរមត្ថបារមី ប្រែថា ធម្មជាតជាហេតុ ដល់នូវត្រើយដ៏ឧត្តមគឺទាន ។

ម្យ៉ាងទៀត មានន័យក្នុងអដ្ឋកថា ចរិយាបិដកនិងអដ្ឋកថាជាតកនេះថា លោកពោលទុកក្នុងសេចក្តីលះបង់នូវចំណែករាងកាយ មានដៃនិងជើងជាដើមរបស់ខ្លួន ឱ្យទៅជាទាន ដោយអំណាចនៃទានបារមី កិរិយាលះបង់នូវទ្រព្យរបស់ដែលជាទីស្រឡាញ់ មានកូននិងប្រពន្ធជាដើមឱ្យទៅជាទាន ដោយអំណាចនៃទានឧបបារមី ។

ឯសេចក្តីដែលលោកពោលយ៉ាងនេះ ប្រហែលជាលោកពោលតាមសន្តានចិត្តរបស់មាតាបិតា ដែលមានសេចក្តីស្នេហាខ្លាំងទៅលើកូន និងប្រពន្ធនៃខ្លួនជាង សេចក្តីស្រឡាញ់អង្គកាយរបស់ខ្លួនទេដឹង ។

ព្រះបរមពោធិសត្វ លោកឱ្យនូវវត្ថុខាងក្រៅព្រះអង្គលោកទាំងប៉ុន្មានក៏ពុំដល់នូវសេចក្តីស្មើច សេចក្តីប្រសើរព្រះអង្គលោកឡើយ ទើបលោកឱ្យនូវវត្ថុ

ជាចំណែកតូច និង ចំណែកធំនៃអង្គកាយនោះទៀត ក៏នៅពុំទាន់ពេញព្រះហឫទ័យឡើយ ហើយក៏មានប្រាថ្នានឹងបរិច្ចាគនូវជីវិតរបស់ព្រះអង្គថែមទៀត ដើម្បីបំពេញព្រះចិន្តា ទើបព្រះអង្គខំស្វែងរកទីឱកាសនឹងឱ្យនូវជីវិតនោះជាទាន ដូចកាលព្រះពោធិសត្វនៃយើង កាលដែលកើតជាព្រះវេស្សន្តររាជ កាលព្រះអង្គនៅជាព្រះរាជកុមារនៅឡើយ ព្រះជន្មទើបនឹងបាន ៨ ឆ្នាំគត់ ព្រះអង្គតាំងព្រះហឫទ័យថា អាត្មាអញនេះ បានឱ្យនូវពាហិរទានដែលជារបស់ខាងក្រៅនៃខ្លួនហើយ តែកម្លាំងនៃទាននោះ មិនអាចញុំាងសន្តានចិត្តរបស់អញឱ្យសោមនស្សត្រេកអរណាស់ណានៅឡើយ បើដូច្នោះ អញនឹងឱ្យនូវអជ្ឈត្តិកទាន គឺទានដែលមាននៅក្នុងខ្លួននៃអញនេះទៀត ទើបទាននោះឯងអាចនឹងធ្វើចិត្តនៃអញឱ្យត្រេកអរក្រៃលែងបាន ទើបព្រះអង្គតាំងតម្កល់សេចក្ដីប្រាថ្នានេះឡើងថា អាត្មាអញសព្វថ្ងៃនេះ ប្រសិនណាបើមានអ្នកណាមួយ មកនិយាយសុំចំពោះត្រង់សាច់បេះដូង ដែលជាទីជ្រកកោន ឬជាទីអាស្រ័យនៅនៃចិត្ត គឺដួងជីវិតរបស់អញៗក៏នឹងពុះទំលាយនូវឆ្អឹងទ្រូងនោះ ហើយទាញយកនូវសាច់ជាលំដាប់នៃចិត្តនោះប្រគល់ឱ្យទៅអ្នកនោះជាទានមិនខានឡើយ បើគេមិនអាចនឹងសុំនូវហទយវត្ថុនេះទេ គេគ្រាន់តែមកសុំចំពោះត្រង់ឥន្ទ្រិយ ដែលជាប្រធាននៃមុខ គឺភ្នែករបស់អញនេះ អញក៏នឹងស្វែងរកនូវចុងដែកស្រួចដ៏មុត មកចាក់ឆ្កៀលខ្វេះយកចក្ខុទាំងគូនេះមកដាក់លើបាតដៃ ហើយនឹងបរិច្ចាគឱ្យទៅជាទានដល់អ្នកសុំនោះពុំខានឡើយ បើមិនដូច្នោះទេ គេមកសុំត្រឹមតែសាច់កាយរបស់អញ អញក៏នឹងពន្លះនូវសាច់ទាំងនោះអំពីសរីរកាយ ហើយលើកឱ្យទៅជាទានដោយសេចក្ដីជ្រះថ្លាមិនខាន ។

## ២ សីលបារមី

**ករុណូបាយកោសល្លបរិគ្គហិតំ វចីសុចរិតំ អត្ថតោ អកត្តព្វវិរតិ កត្តព្វករណចេតនាទយោច សីលបារមិតា ។**

សេចក្តីថា វចីសុចរិត គឺពោធិសត្វរក្សាទុកដោយសេចក្តីឆ្លាសក្នុងឧបាយនៃករុណាចិត្តរបស់ព្រះអង្គ គឺថា ព្រះអង្គតែងពោលនូវពាក្យពិតពាក្យប្រកបដោយប្រយោជន៍ និងវៀរបង់នូវពាក្យកុហក ពាក្យឥតប្រយោជន៍ចេញ ព្រោះលោកជាអ្នកឆ្លាស ក្នុងឧបាយនៃសេចក្តីអាណិតអាសូរដល់សត្វមិនមានចំពោះមុខ ។

អធិប្បាយថា កិរិយាវៀរចាកបាប គឺពោធិសត្វមិនបានធ្វើដោយយល់ប្រយោជន៍ មានតែធ្វើនូវធម្មជាតិទាំងឡាយ មានវិរតិចេតនាជាដើម ជាអំពើគឺពោធិសត្វគប្បីធ្វើយ៉ាងនេះ ឈ្មោះថា **សីលបារមី** ប្រែថា គុណជាតិជាហេតុដល់នូវត្រើយ ពោលគឺព្រះនិព្វានរបស់ជនព្រោះសីល ។

អធិប្បាយថា ព្រះបរមពោធិសត្វនោះ ទោះបីព្រះអង្គ នៅជាគ្រហស្ថក្តី ឬ ជាអ្នកបួសក្តី លោកតែងរក្សាសីល ហើយធ្វើនូវសីលនោះ មិនឱ្យមានមន្ទិលបាន ប្រសិនណាបើព្រះអង្គនៅជាគ្រហស្ថ ក៏ខំសង្វាតអភិបាល រក្សានូវបញ្ចង្គិកសីល គឺសីលប្រកបដោយអង្គ ៥ ហើយអាចធ្វើនូវសីលទាំងនោះ មិនឱ្យដាច់មិនឱ្យវិនាសទៅបាន ឬ ថា បើខ្លួនលោកទៅជាអ្នកបួសវិញ ក៏រឹងរឹតតែព្យាបាលរក្សានូវចតុប្បារិសុទ្ធិសីល គឺសីល ដែលហ្មត់ចត់ស្អាត ដោយចេតសិក ៤ ប្រការគឺ

សទ្ធា ១ សតិ ១ វីរិយៈ ១ បញ្ញា១ ឱ្យបរិបូណ៌ប្រពៃ។

(អធិប្បាយថា **បាតិមោក្ខសំវរសីល** តែងបរិសុទ្ធដោយសទ្ធាចេតសិក ឥន្ទ្រិយសំវរសីល តែងបរិបូណ៌ដោយសតិចេតសិក អាជីវបារិសុទ្ធិសីល តែងហ្មត់ចត់ដោយវីរិយចេតសិក បច្ចយសន្និស្សិតសីល តែងរុងថ្លាដោយបញ្ញាចេតសិក)។

ម្យ៉ាងទៀត អ្នកប្រាជ្ញទាំងឡាយ កុំគប្បីចូលចិត្តដូច្នេះថា ព្រះពោធិសត្វទាំងឡាយនោះអាចរក្សាសីល ជាប់បរិបូណ៌គ្រប់គ្រាន់ដោយអាការទាំងពួងរាល់ជាតិទាំងអស់ឡើយ ។ កិរិយាសម្រេចនៃការប្រព្រឹត្តរបស់ព្រះពោធិសត្វនោះ មាននៅក្នុងគណវេរជាតក ។ ព្រះពោធិសត្វនៃយើងទាំងឡាយ លោកសម្រេចនូវកិរិយានៅដោយចរកម្មក្នុងអត្តភាពនោះ។

សីលបារមីនេះចែកចេញជា ៣ ស្ថានគឺ ៖

ក) **បុត្តទារហេតុបិ សីលំ អខណ្ឌំ កត្វា បរិបូរណំ សីលបារមី នាម** ថា កិរិយារក្សានូវសីលឱ្យពេញបរិបូរណ៏មិនឱ្យដាច់ មិនឱ្យសៅហ្មងបាន ព្រោះហេតុតែកូន និងប្រពន្ធរបស់ព្រះអង្គនោះឡើយ សេចក្ដីសង្រួមយ៉ាងនេះឈ្មោះថា **សីលបារមី** ប្រែថា ធម្មជាតជាហេតុដល់នូវត្រើយ គឺ ព្រះនិព្វាននៃជនព្រោះសីល ។

ខ) **អត្តនោ អង្គប្បច្ចង្គហេតុបិ សីលំ អខណ្ឌំ កត្វា បរិបូរណំ សីលឧបបារមី នាម** ថា កិរិយារក្សានូវសីលឱ្យប្រពៃបរិបូរណ៏ មិនឱ្យដាច់ មិនឱ្យមានមន្ទិល ព្រោះហេតុតែអវយវៈធំតូច ក្នុងរាងកាយរបស់ព្រះអង្គ មានដៃ

និងជើងជាដើម សេចក្ដីប្រព្រឹត្តរវាំងកាយវាចាយ៉ាងនេះ ឈ្មោះថា **សីល ឧបបារមី** ប្រែថា ធម្មជាតជាហេតុដល់នូវត្រើយខាងលើ គឺ ព្រះនិព្វាន នៃជនព្រោះសីល ។

គ) **អត្តនោ ជីវិតហេតុបិ សីលំ អខណ្ឌំ កត្វា បរិបូរណំ សីលបរមត្ថបារមី នាម** ថា កិរិយារក្សាសីល ឱ្យបរិបូរណ៍ផូរផង់ មិនឱ្យដាច់ធ្លុះ ព្រោះហេតុតែជីវិតនៃព្រះអង្គ សេចក្ដីសំអាតសីលយ៉ាងនេះ ឈ្មោះថា **សីលបរមត្ថបារមី** ប្រែថា ធម្មជាតិជាហេតុដល់នូវត្រើយដ៏ឧត្ដម គឺព្រះនិព្វាននៃជនព្រោះសីល ។

## ៣ នេក្ខម្មបារមី

**ករុណូបាយកោសល្លបរិគ្គហិតោ អាទីនវទស្សនុព្វង្គមោ កាមភវេហិ និក្ខមនចិត្តុប្បាទោ នេក្ខម្មបារមិតា ។**

សេចក្ដីថា ព្រះពោធិសត្វ តែងមានព្រះហឫទ័យកំណត់ទុក ដោយសេចក្ដីឆ្លាស ក្នុងឧបាយនៃករុណាចិត្តរបស់ព្រះអង្គ នឹងមានកិរិយាឃើញនូវទោសនៃកាមគុណ ជាប្រធាន មានព្រះហឫទ័យផ្គងឡើង ដើម្បីចេញចាកកាមភពទាំងឡាយ ព្រះហឫទ័យរបស់ព្រះពោធិសត្វ តែងងាកចេញចាកកាមគុណ ៥ យ៉ាងៗ នឹងហើយ បានជាលោកសន្មត ព្រះហឫទ័យនោះថា ជាបារមីទី ៣ ឱ្យឈ្មោះថា **នេក្ខម្មបារមី** ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយគឺព្រះនិព្វាន ។

អធិប្បាយថា ឯពាក្យដែលថា បព្វជ្ជា នេះជាឈ្មោះនៃកិរិយាចេញទៅកសាង ចាកវត្ថុកាម ។ម្យ៉ាងទៀត គុណទាំងឡាយឯណា មានបឋមជ្ឈានជា

ដើម គុណទាំងនោះ ជាឈ្មោះនៃកិរិយាចេញទៅ ដើម្បីគុណធំ ចាកកិលេសកាមទាំងឡាយ ចាកកាមភពទាំងឡាយផង ។

ឯព្រះពោធិសត្វទាំងឡាយ លោកមិនមែនជាអ្នកបួសគ្រប់ៗជាតិទាំងអស់ ដែលលោកអន្ទោលទៅក្នុងសង្សារវដ្តនោះទេ លោកនៅជាគ្រហស្ថនោះច្រើនជាងចេញទៅបួសឯផ្នួសរបស់ព្រះពោធិសត្វទាំងឡាយ ជួនកាលលោកកំណត់ត្រង់សក់ស្កូវ សូម្បីតែមួយសរសៃក៏យកមកជាប្រមាណ ហើយលោកចេញទៅទ្រង់ព្រះផ្នួសទៅ ក៏មានដូចមាននិទាន ក្នុងមខាទេវជាតក ។

ម្យ៉ាងទៀត ព្រះពោធិសត្វទាំងឡាយ ជួនកាលលោកមិនបានបួសទេ លោកនៅជាគ្រហស្ថដូចគេធម្មតា តែលោកអាចរក្សានូវព្រហ្មចរិយធម៌បាន មិនឱ្យដាច់ ដូចមាននិទានក្នុងអននុសោចិយកាលជាតក ជួនកាលលោកជាអ្នកស្រវឹងទៅដោយកាមគុណក៏មាន ដូចមាននិទានក្នុងជាតកទាំងឡាយ មានទរិមុខជាតកជាដើម ។ ឯនេក្ខម្មបារមីនេះចែកចេញជា ៣ យ៉ាងគឺ ៖

ក) **បុត្តទារស្សបិ អាលយំ ចជិត្វា និក្ខមនំ នេក្ខម្មបារមី នាម** ថាកិរិយាលះលែងនូវកូននិងប្រពន្ធ ដែលជាទីស្រឡាញ់ ជាទីអាល័យហើយ ចេញទៅកសាង ឬ ចេញទៅបួសឈ្មោះថា **នេក្ខម្មបារមី** ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយ គឺព្រះនិព្វាននៃជនព្រោះផ្នួស ។

ខ) **អង្គប្បច្ចង្គស្សបិ អាលយំ ចជិត្វា និក្ខមនំ នេក្ខម្មឧបបារមី នាម** ថាកិរិយាលះបង់នូវសេចក្តីអាល័យ ក្នុងរបស់ធំនិងតូច ក្នុងរាងកាយហើយ ចេញ

ទៅកសាងដើម្បីគុណធំឈ្មោះថា **នេក្ខម្មឧបបារមី** ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយខាងលើ គឺព្រះនិព្វាននៃជនព្រោះបព្វជ្ជា ។

គ) **ជីវិតស្សបិ អាលយំ ចជិត្វា និក្ខមនំ នេក្ខម្មបរមត្ថបារមី នាម** ថាកិរិយាលះបង់នូវសេចក្តីអាល័យក្នុងជីវិត ដែលជាគ្រឿងរស់នៅ និងជាទីស្នេហាបំផុតហើយចេញទៅបួស យ៉ាងនេះឈ្មោះថា **នេក្ខម្មបរមត្ថបារមី** ប្រែថាគុណជាតិជាគ្រឿងដល់នូវត្រើយដ៏ឧត្តមគឺព្រះនិព្វានព្រោះបព្វជ្ជា ។

## ៤ បញ្ញាបារមី

**ករុណូបាយកោសល្លបរិគ្គហិតោ នាមរូបធម្មានំ សាមញ្ញវិសេស លក្ខណាវពោធោ បញ្ញាបារមិតា ។**

សេចក្តីថា សភាពដែលជាគ្រឿងត្រាស់ដឹងនូវសាមញ្ញលក្ខណៈ និងវិសេសលក្ខណៈនៃនាមធម៌ និងរូបធម៌ទាំងឡាយ គឺព្រះបរមពោធិសត្វកំណត់កាន់យក ដោយសេចក្តីឈ្វេងយល់ក្នុងឧបាយនៃសេចក្តីអាណិតអាសូររបស់លោកដល់សត្វទាំងឡាយ ឈ្មោះថា **បញ្ញាបារមី** ប្រែថា គុណជាតិជា គ្រឿងដល់នូវត្រើយ គឺព្រះនិព្វានព្រោះបញ្ញា ។

អធិប្បាយថា សេចក្តីក្រិតទុកឬកត់ចំណាំទុកថា នាមធម៌និងរូបធម៌ទាំងឡាយនេះ ជាធម៌តែងលុះ ក្នុងអំណាចនៃទោសអន្តរាយ ៣ យ៉ាង គឺសេចក្តីមិនទៀង ១ សេចក្តីព្រួយ ១ សេចក្តីមិនមែន ១ បញ្ញាដែលដឹងហើយ កំណត់ទុកយ៉ាងនេះ ឈ្មោះសាមញ្ញលក្ខណៈ ប្រែថា ធម្មជាតិសម្រាប់ក្រិតទុកនូវនាមធម៌

និងរូបធម៌ទូទៅ ។ មួយ៉ាងទៀតថា នាមធម៌មានកិរិយាឱនទៅកាន់អារម្មណ៍ ឬត្រង់យកអារម្មណ៍ជាលក្ខណៈនូវរូបធម៌ មានកិរិយាវិនាសទៅដោយសេចក្ដីក្ដៅនឹងត្រជាក់ជាលក្ខណៈ បញ្ញាដែលដឹងហើយ កំណត់ទុកយ៉ាងនេះ ឈ្មោះថា វិសេសលក្ខណៈ ប្រែថា ធម្មជាតសម្រាប់ចារិកទុកនូវនាមធម៌ និង រូបធម៌ដោយវិសេស ។ ចំណែកឯព្រះពោធិសត្វទាំងឡាយ លោកតែងធ្វើទុកនូវព្រះត្រៃលក្ខណញាណ ទាំង ៣ ប្រការនេះ ឱ្យស្និទ្ធនៅស៊ុបក្នុងចិត្តរបស់លោកមិនឱ្យមានរើរុះឡើយ តែថាព្រះអង្គ មិនបានធ្វើព្យាយាម ឱ្យបានត្រាស់ដឹងធ្លុះធ្លាយនូវព្រះអរហត្តផលនោះទេ ។

មានពាក្យសួរថា ហេតុអ្វីមនុស្សនិងទេវតាទាំងឡាយ គេតែងធ្វើព្យាយាម ប្រាថ្នាយកព្រះអរហត្តមគ្គ និងអរហត្តផលជាព្រះអរហន្តនោះតែរាល់ៗគ្នា ចំឡែកអ្វីតែព្រះពោធិសត្វនោះ ក៏មិនចង់បាននូវព្រះអរហត្តផល ជាព្រះអរហន្តដូចគេ ព្រោះព្រះអង្គជាប់ជំពាក់ព្រះហឫទ័យអាល័យនូវរបស់អ្វី ?

ពាក្យឆ្លើយថា ព្រះពោធិសត្វទាំងឡាយ បានជាមិនព្យាយាមយកត្រឹមព្រះអរហត្តផល ជាព្រះអរហន្តនោះ មិនមែន លោកអាល័យនូវក្នុងវត្ថុដទៃទេ គឺព្រះអង្គ មានព្រះហឫទ័យជាប់ជំពាក់ជិត ដោយទៅជាមួយនឹងសម្មាសម្ពោធិញ្ញាណ បញ្ជូនហួសទៅខាងមុខហើយ បានជាព្រះអង្គធ្វើកន្តើយ មិនត្រូវការនឹងរបស់តូចទាបនោះឡើយ ញាណរបស់ព្រះអង្គសោតក៏ផ្សាយទូទៅដល់ជនច្រើន ។

មួយ៉ាងទៀត ព្រះពោធិសត្វទាំងឡាយ បើលោកបានដឹងនូវធម៌អ្វីនីមួយៗជារបស់ពិតហើយ លោកមិនធ្វើនូវធម៌ទាំងនោះ ឱ្យនៅក្នុងកណ្ដាប់ដៃអាចារ្យ

ដែលជាអ្នកប្រព្រឹត្តខុសនោះទេ លោកតែងសំដែងប្រាប់គេប្រាប់ឯងឱ្យបានដឹងទូទៅថា ជារបស់មែន មិនលាក់លៀមឡើយ ។

បញ្ញាបារមីនេះ ចែកចេញជា ៣ ស្ថានគឺ ÷

ក) **បុត្តទារំ អនបេក្ខិត្វា ហិតាហិតំ វិនិច្ឆយករណំ បញ្ញាបារមី នាម** ជាគំនិតព្រះពោធិសត្វ ព្រះអង្គ មិនមានអាឡោះអាល័យ ត្រង់កូននិងប្រពន្ធរបស់ព្រះអង្គនោះប៉ុន្មានឡើយ ព្រះអង្គខំធ្វើនូវអំពើ ដែលជាប្រយោជន៍ធំ និងប្រយោជន៍តូចរបស់សត្វទាំងឡាយ ឱ្យបានសម្រេចគំនិតនោះឯង បានឈ្មោះថា **បញ្ញាបារមី** ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះបញ្ញា ។

ខ) **អង្គប្បច្ចង្គំ អនបេក្ខិត្វា វិនិច្ឆយករណំ បញ្ញាឧបបារមី នាម** ព្រះហប្ញទ័យរបស់ព្រះពោធិសត្វ មិនមានអាឡោះអាល័យចំពោះត្រង់អវយវៈធំ និងតូច ក្នុងរាងកាយរបស់ព្រះអង្គ មានដៃនិងជើងជាដើម លោកខំតែធ្វើនូវប្រយោជន៍ ឱ្យបានសម្រេចដល់សត្វទាំងឡាយ ព្រះហប្ញទ័យយ៉ាងនេះ បានឈ្មោះថា **បញ្ញាឧបបារមី** ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយខាងលើ គឺព្រះនិព្វានព្រោះបញ្ញា ។

គ) **អត្តនោ ជីវិតំបិ អនបេក្ខិត្វា វិនិច្ឆយករណំ បញ្ញាបរមត្ថបារមី នាម** ថា ព្រះហប្ញទ័យ ព្រះពោធិសត្វ មិនបានជាត្រូវការនឹងជីវិតរបស់ព្រះអង្គនោះប៉ុន្មានឡើយ ព្រះអង្គត្រូវការតែនឹងធ្វើនូវកិច្ចដែលជាប្រយោជន៍ដល់ជនទាំងឡាយ ឱ្យបានសម្រេចព្រះហប្ញទ័យយ៉ាងនេះ ឈ្មោះថា **បញ្ញាបរមត្ថបារមី**

ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយដ៏ឧត្តម គឺព្រះនិព្វានព្រោះបញ្ញា ។

## ៥ វីរិយបារមី

**ករុណូបាយកោសល្លបរិគ្គហិតោ កាយចិត្តេហិ បរហិតារម្ភោវីរិយបារមិតា ។**

សេចក្តីថា ព្រះពោធិសត្វមានកិរិយាប្រារព្ធនូវអំពើជាប្រយោជន៍ដល់បុគ្គលដទៃ តែងទំនុកបំរុង ដោយសេចក្តីឆ្លាសក្នុងឧបាយនៃករុណាចិត្តរបស់លោក ឈ្មោះថា **វីរិយបារមី** ប្រែថា គុណជាតិ សម្រាប់ដល់នូវត្រើយ គឺព្រះនិព្វាននៃជន ព្រោះព្យាយាម ។

អធិប្បាយថា ព្រះពោធិសត្វទាំងឡាយ លោកតែងមានអធ្យាស្រ័យ ជាប្រយោជន៍ដល់សត្វដទៃ តែងប្រព្រឹត្តធ្វើនូវប្រយោជន៍ឱ្យដល់ជនដទៃឥតធុញទ្រាន់តែថាបើទុកជាលោកខំធ្វើយ៉ាងហ្នឹងហើយ ចំណែកខ្លួនលោក ក៏គង់មិនដល់នូវលទ្ធិជាត្រៃយទ្បើយ ។ ម្យ៉ាងទៀត ឯព្រះពោធិសត្វទាំងឡាយ បើទុកជាមានសេចក្តីព្រួយនិងឧបទ្រវន្តរាយទាំងឡាយមកបៀតបៀនដល់ខ្លួនលោកយ៉ាងណាៗក្តី ក៏គង់នៅតែមានព្យាយាមឱ្យខាងតែបានសម្រេចនូវប្រយោជន៍ដ៏ឧត្តម មិនខានព្រះពោធិសត្វទាំងឡាយ មានសេចក្តីឈ្វេងយល់យ៉ាងណា ការព្យាយាមរបស់ព្រះពោធិសត្វតែងប្រព្រឹត្តទៅ ដើម្បីឱ្យសម្រេចប្រយោជន៍ដល់សត្វទាំងឡាយ យ៉ាងនោះមិនខាន ។ វីរិយបារមីនេះ ចែកចេញជា ៣ ស្ថានគឺ ៖

ក) **បុត្តទារំបិ ចជិត្វា វាយមនំ វីរិយបារមី នាម** សេចក្តីថា ការលះបង់នូវកូន

និងប្រពន្ធចេញ ហើយខំព្យាយាមធ្វើនូវអំពើជាកុសល ឈ្មោះថា វីរិយបារមី ប្រែថា គុណជាតិសម្រាប់ដល់នូវត្រើយ គឺ ព្រះនិព្វានព្រោះព្យាយាម ។

ខ) **អង្គប្បច្ចង្គំបិ ចជិត្វា វាយមនំ វីរិយឧបបារមី នាម** សេចក្ដីថា ការលះបង់នូវអង្គកាយ គឺ អវយវៈតូចនិងធំ មានដៃនិងជើងជាដើម មិនមានស្ដាយ ហើយខំព្យាយាមចម្រើនធម៌ជាកុសលរឿយៗ បានឈ្មោះថា **វីរិយឧបបារមី** ប្រែថា គុណជាតិសម្រាប់ដល់នូវត្រើយខាងលើ គឺ ព្រះនិព្វានព្រោះព្យាយាម ។

គ) **ជីវិតំបិ ចជិត្វា វាយមនំ វីរិយបរមត្ថបារមី នាម** សេចក្ដីកាត់ចិត្តត្រង់ការដែលរស់នៅ ហើយខំសង្វាតដុសខាត់កុសលរឿយៗ ឈ្មោះថា **វីរិយបរមត្ថបារមី** ប្រែថា គុណសម្បត្តិសម្រាប់ដល់នូវត្រើយដ៏ខ្ពង់ខ្ពស់ គឺ ព្រះនិព្វានព្រោះព្យាយាម ។

## ៦ ខន្តិបារមី

**ករុណូបាយកោសល្លបរិគ្គហិតំ សត្តសង្ខារា បរាធសហនំ អទោសប្បធានោ តទាការប្បវត្តោ ចិត្តុប្បាទោ ខន្តិបារមិតា ។**

សេចក្ដីថា កិរិយាអត់សង្កត់នូវសេចក្ដីឆ្គាំឆ្គងរបស់សត្វ និងសង្ខារទាំងឡាយ គឺ ពោធិសត្វកាន់យកហើយ ដោយសេចក្ដីឆ្លាសក្នុងឧបាយនៃសេចក្ដីករុណាចិត្តរបស់លោក ។ ម្យ៉ាងទៀត ពោធិសត្វមានសេចក្ដីមិនក្រោធជាប្រធាន

មានចិត្តនិងចេតសិក តែងប្រព្រឹត្តទៅតាមអាការមិនក្រោធនោះ ឈ្មោះថា **ខន្តិបារមី** ប្រែថា គុណសម្បត្តិសម្រាប់ដល់នូវត្រើយ គឺព្រះនិព្វាន។

អធិប្បាយថា ព្រះពោធិសត្វទាំងឡាយ តែងធ្វើទុកក្នុងចិត្ត ឬនឹកសំគាល់នូវសត្វទាំងឡាយទាំងពួងថា ដូចជាបងប្អូនរបស់លោក ឬ ដូចជាញាតិសាលោហិត លោកតែងអត់នូវសេចក្តីល្មើសរបស់សត្វទាំងឡាយនោះ ដោយចិត្តល្អរបស់លោកជាប្រធាន ម្យ៉ាងទៀតថា បើជនទាំងឡាយឯណា គេខឹងនឹងព្រះអង្គក្តី ឬ គេជេរប្រទេចព្រះអង្គក្តី ដោយមិនមានហេតុអ្វីដែលគួរនឹងខឹង គួរនឹងជេរប្រទេចនោះសោះ ព្រះអង្គក៏មិនលើកឡើងនូវទោសនោះ ឬ ប្រមូលនូវទោសនោះមកដាក់ក្នុងខ្លួនរបស់លោក ព្រោះតែហេតុនោះ ហើយមិនជាតូចចិត្តទោមនស្សប៉ុន្មានឡើយ ។ ទោះបីជនទាំងឡាយនោះ គេមានសេចក្តីក្រោធយ៉ាងខ្លាំង ហើយគេទៅកាត់ដៃ ឬកាត់ជើង ឬកាត់ទាំងដៃទាំងជើងរបស់លោកក្តី លោកក៏មិនអាចបៀតបៀនគេវិញឡើយ ទៅជាពោលពាក្យថា អ្នកទាំងឡាយ ចូរមានជីវិតរស់នៅឱ្យយឺនយូរចុះ។

ខន្តិបារមីនេះចែកចេញជា ៣ ស្ថានគឺ ÷

ក) **បុត្តទារាទីនំ កត្វា បរាធំ អធិវាសនំ ខន្តិបារមី នាម** ថាសេចក្តីអត់ធន់នូវការកំហុសនៃជនទាំងឡាយ មានកូននិងប្រពន្ធជាដើម សេចក្តីអត់សង្កត់ចិត្តយ៉ាងនេះ ឈ្មោះថា **ខន្តិបារមី** ប្រែថា គុណសម្បត្តិសម្រាប់ឆ្លងទៅកាន់ត្រើយ គឺព្រះនិព្វាន ព្រោះសេចក្តីអត់ធន់មិនក្រោធ តែមិនមែនតមមាត់ មិននិយាយនោះទេ គឺមាត់នៅតែនិយាយស្តី ដោយសំដីពីរោះ

និងដោយចិត្តមិនប្រកាន់ទោសនោះឯង ។

ខ) **អត្តនោ អង្គប្បច្ចង្គស្ស កត្វា បរាធំ អធិវាសនំ ខន្តិឧបបារមី នាម** ថា កិរិយាអត់សង្កត់នូវទោសនៃសត្វទាំងពួង ទុកដូចជាទោសអវយវៈធំ និងតូចនៃរាងកាយរបស់ខ្លួន សេចក្តីអត់ទ្រាំយ៉ាងនេះ ឈ្មោះថា **ខន្តិឧបបារមី** ប្រែថា គុណសម្បត្តិសម្រាប់ឆ្លងទៅកាន់ត្រើយខាងលើ គឺព្រះនិព្វាន ព្រោះខន្តី ។

គ) **អត្តនោ ជីវិតស្ស កត្វា បរាធំ អធិវាសនំ ខន្តិបរមត្ថបារមី នាម** ថាកិរិយាទប់ទល់នូវទោសខុសរបស់ជនទាំងពួង ដែលបាញ់ចំពោះមកត្រង់ព្រះអង្គសូម្បីដល់ជីវិតរបស់ព្រះអង្គ ព្រះអង្គក៏ឥតមានប្រទូស្តវិញឡើយ ។ សេចក្តីអត់ធន់យ៉ាងនេះ ឈ្មោះថា **ខន្តិបរមត្ថបារមី** ប្រែថា គុណសម្បត្តិសម្រាប់ឆ្លងទៅកាន់ត្រើយដ៏ខ្ពង់ខ្ពស់ គឺព្រះនិព្វានព្រោះខន្តី ។

## ៧ សច្ចបារមី

**ករុណូបាយកោសល្លបរិគ្គហិតំ វិរតិចេតនាទិភេទំ អវិសំវាទនំ សច្ចបារមិតា ។**

សេចក្តីថា កិរិយាមិនព្រមពោលនូវពាក្យមិនពិត ព្រោះមានវិរតិចេតនាជាដើមជាប្រភេទ គឺ ពោធិសត្វកំណត់កាន់យក ដោយសេចក្តីឆ្លាសក្នុងឧបាយនៃសេចក្តីករុណាចិត្តរបស់លោក ឈ្មោះថា **សច្ចបារមី** ប្រែថា គុណសម្បត្តិសម្រាប់ ដល់នូវត្រើយ គឺព្រះនិព្វានព្រោះពាក្យពិត ។

សច្ចបារមីនេះ ចែកចេញជា ៣ ស្ថានដូចគ្នាគឺ ÷

ក) **បុត្តទារាទីនំ ហេតុបិ អវិសំវាទនំ សច្ចបារមី នាម** ថាកិរិយាមិនពោលនូវពាក្យឱ្យឃ្លាត ព្រោះហេតុតែបុត្រ និងភរិយាឡើយ យ៉ាងនេះ ឈ្មោះថា **សច្ចបារមី** ប្រែថា គុណសម្បត្តិសម្រាប់ដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះពាក្យពិត ។

ខ) **អត្តនោ អង្គប្បច្ចង្គស្ស ហេតុបិ អវិសំវាទនំ សច្ចឧបបារមី នាម** ថាកិរិយាមិនពោលនូវពាក្យខុស ព្រោះហេតុតែអង្គធំនិងតូចរបស់រាងកាយខ្លួនឡើយ យ៉ាងនេះ ឈ្មោះថា **សច្ចឧបបារមី** ប្រែថា គុណសម្បត្តិសម្រាប់ដល់នូវត្រើយខាងលើ គឺព្រះនិព្វានព្រោះសច្ចវាទី ។

គ) **អត្តនោ ជីវិតហេតុបិ អវិសំវាទនំ សច្ចបរមត្ថបារមី នាម** ថាកិរិយាមិនពោលនូវពាក្យ ឱ្យភ្លាត់ ព្រោះហេតុតែជីវិតនៃខ្លួនឡើយ យ៉ាងនេះឈ្មោះថា **សច្ចបរមត្ថបារមី** ប្រែថា គុណសម្បត្តិ សម្រាប់ដល់នូវត្រើយដ៏បំផុតគឺព្រះនិព្វានព្រោះពាក្យត្រឹមត្រូវ ។

## ៨ អធិដ្ឋានបារមី

**ករុណូបាយកោសល្លបរិគ្គហិតំ អចលសមាទានាធិដ្ឋានំ តទាការប្បវត្តោ ចិត្តុប្បាទោ អធិដ្ឋានបារមិតា ។**

សេចក្ដីថា កិច្ចដែលនឹងអធិដ្ឋានសមាទាន កាន់យកមិនបានវៀរុស គឺព្រះពោធិសត្វកាន់យកដោយសេចក្ដីឆ្លាសក្នុងឧបាយនៃសេចក្ដីករុណាចិត្ត របស់ពោធិសត្វ ហើយមានចិត្តនិងចេតសិក តែងប្រព្រឹត្តទៅតាមអាការៈនៃសេចក្ដីអធិដ្ឋាននោះ ឈ្មោះថា **អធិដ្ឋានបារមី** ប្រែថា គុណជាតិសម្រាប់ចម្លងសត្វទៅកាន់ត្រើយ គឺព្រះនិព្វាន ព្រោះសេចក្ដីតាំងព្យាយាមធំ ។

អធិដ្ឋានបារមីនេះ ចែកចេញជា ៣ ស្ថានគឺ ÷

ក) **បុត្តទារេ វិហញ្ញមានេបិ កុសលធម្មេសុ អចលសមាទានំ អធិដ្ឋានបារមី នាម** ថា កាលបើកូន និងប្រពន្ធ បានសេចក្ដីលំបាកដូចម្ដេចក្ដី អំពើដែលកាន់យកនូវធមិជាកុសលរបស់ពោធិសត្វនោះ មិនវៀរុះចោលឡើយ សេចក្ដីតាំងចិត្តមាំយ៉ាងនេះ ឈ្មោះថា **អធិដ្ឋានបារមី** ប្រែថា គុណជាតិសម្រាប់ចម្លងសត្វទៅកាន់ត្រើយ គឺព្រះនិព្វានព្រោះសេចក្ដីតាំងចិត្តមាំ ។

ខ) **អត្តនោ អង្គប្បច្ចង្គេ វិហញ្ញមានេបិ កុសលធម្មេសុ អចលសមាទានំ អធិដ្ឋានឧបបារមី នាម** ថា កាលបើអង្គធំនិងអង្គតូចរបស់រាងកាយនៃខ្លួន បាននូវសេចក្ដីលំបាកយ៉ាងណាៗក្ដី កិច្ចដែលខ្លួនកាន់យកនូវធមិ ជាកុសលនោះ មិនបានប្រែប្រួលឡើយ សេចក្ដីមិនវៀរុះយ៉ាងនេះ ឈ្មោះថា **អធិដ្ឋានឧបបារមី** ប្រែថា គុណជាតិសម្រាប់ចម្លងសត្វទៅកាន់ត្រើយខាងលើ គឺព្រះនិព្វាន ព្រោះសេចក្ដីអធិដ្ឋាន។

គ) **អត្តនោ ជីវិតេ វិហញ្ញមានេបិ កុសលធម្មេសុ អចលសមាទានំ អធិដ្ឋាន**

**បរមត្ថបារមី នាម** ថា កាលបើសេចក្ដីលំបាកដល់ជីវិតនៃខ្លួនក្ដី កិរិយាដែលបាននូវកុសលធមិឯណាមួយហើយនោះ ពោធិសត្វមិនអាចរលាស់ចោលឡើយ ការមិនកម្រើកយ៉ាងនេះ ឈ្មោះថា **អធិដ្ឋានបរមត្ថបារមី** ប្រែថា គុណជាតិសម្រាប់ចម្លងសត្វទៅកាន់ត្រើយដ៏ប្រសើរ គឺ ព្រះនិព្វាន ព្រោះការអធិដ្ឋាន ។

## ៩ មេត្តាបារមី

**ករុណូបាយកោសល្លបរិគ្គហិតោ លោកស្ស ហិតសុខូបសំហារោ អត្ថតោ អព្យាបាទោ មេត្តា បារមិតា ។**

សេចក្ដីថា កិរិយាប្រមូលមកនូវសេចក្ដីចម្រើន និងសេចក្ដីសុខឱ្យដល់សត្វលោក និងមិនមានព្យាបាទដល់អ្នកដទៃ គឺព្រះពោធិសត្វកាន់យកហើយ ដោយសេចក្ដីឆ្លាសក្នុងឧបាយនៃករុណាចិត្តរបស់លោក ឈ្មោះថា **មេត្តាបារមី** ប្រែថា ធម្មជាតិសម្រាប់កៀរគរសត្វឱ្យទៅកាន់ត្រើយ គឺ ព្រះនិព្វាន ព្រោះសេចក្ដីរាប់អានយ៉ាងស្និទ្ធ ។

មេត្តាបារមីនេះ ចែកចេញជា ៣ ស្ថានគឺ ÷

ក) **បុត្តទារំ ឃាតកសត្តេសុបិ បវត្តោ អព្យាបាទោ មេត្តាបារមី នាម** ថា កិរិយាមិនបានញុំាងការចម្រើន និងសេចក្ដីសុខរបស់សត្វទាំងឡាយ ឱ្យវិនាស ដើម្បីជនឯណាដែលជាអ្នកបៀតបៀន ឬ សម្លាប់នូវកូននិងប្រពន្ធ

របស់ព្រះអង្គ ព្រះអង្គក៏មិនមានព្យាបាទដល់ជននោះវិញឡើយ សេចក្តីមិនព្យាបាទ យ៉ាងនេះ ឈ្មោះថា **មេត្តាបារមី** ប្រែថា ធម្មជាតសម្រាប់កៀរគរសត្វឱ្យឆ្លងទៅកាន់ត្រើយ គឺព្រះនិព្វាន ព្រោះសេចក្តីរាប់អាន គឺមេត្តា ។

ខ) **អត្តនោ អង្គប្បច្ចង្គំ ឃាតកសត្តេសុបិ បរត្តោ អព្យាបាទោ មេត្តាឧបបារមី នាម** ថា កិរិយាមិនបានធ្វើការរុងរឿង និងសេចក្តីស្រួលបួលរបស់សត្វដទៃឱ្យវិនាស សូម្បីជនទាំងឡាយឯណា ដែលជាអ្នកចងពៀរបៀតបៀនអង្គកាយរបស់លោកក្តី លោកក៏មិនមានព្យាបាទដល់ជនទាំងនោះឡើយ សេចក្តីមិនចងពៀរយ៉ាងនេះ ឈ្មោះថា **មេត្តាឧបបារមី** ប្រែថា ធម្មជាតសម្រាប់កៀរគរសត្វ ឱ្យឆ្លងទៅកាន់ត្រើយខាងលើ គឺព្រះនិព្វាន ព្រោះសេចក្តីមេត្តាយ៉ាងស្និទ្ធ ។

គ) **អត្តនោ ជីវិតំ ឃាតកសត្តេសុបិ បរត្តោ អព្យាបាទោ មេត្តាបរមត្ថបារមី នាម** ថា កិរិយាមិនធ្វើនូវប្រយោជន៍ និងសេចក្តីសុខរបស់សត្វដទៃឱ្យវិនាស សូម្បីដល់សត្វដែលមានពៀរវេរាបៀតបៀន សម្លាប់នូវជីវិតរបស់ព្រះអង្គក្តី ព្រះអង្គក៏មិនមានព្យាបាទឡើយ សេចក្តីមិនចងពៀរវិញយ៉ាងនេះ ឈ្មោះថា **មេត្តាបរមត្ថបារមី** ប្រែថា ធម្មជាតសម្រាប់កៀរគរសត្វទាំងឡាយ ឱ្យឆ្លងទៅកាន់ត្រើយដ៏ត្រដួច គឺព្រះនិព្វានព្រោះមេត្តាចិត្ត ។

## ១០ ឧបេក្ខាបារមី

**ករុណោបាយកោសល្លបរិគ្គហិតា អនុនយបដិឃវិធំសិនី ឥដ្ឋានិដ្ឋេសុ សត្តសង្ខារេសុ សមប្បវត្តិ ឧបេក្ខាបារមិតា ។**

សេចក្ដីថា កិរិយាកំចាត់បង់នូវសេចក្ដីត្រេកអរ និងសេចក្ដីថ្នាំងថ្នាក់ហើយប្រព្រឹត្តទៅស្មើក្នុងសត្វ និងសង្ខារទាំងឡាយ គឺព្រះពោធិសត្វកាន់យកហើយដោយសេចក្ដីឆ្លាសក្នុងឧបាយនៃករុណាចិត្តមានឈ្មោះថា **ឧបេក្ខាបារមី** ប្រែថា ធម្មជាតជាទីដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះសេចក្ដីមិនត្រេកអរ មិនថ្នាំងថ្នាក់ ។

ឧបេក្ខាបារមីនេះចែកចេញជា ៣ ស្ថានគឺ ៖

ក) **បុត្តទារាទីនំ ឧបការកេសុបិ អនុបការកេសុបិ សត្តសង្ខារេសុ បវត្តិមជ្ឈត្តតា ឧបេក្ខាបារមី នាម** ថា ចិត្តនៃព្រះពោធិសត្វតាំងនៅជាកណ្ដាលក្នុងសត្វនិងសង្ខារទាំងឡាយ ដែលមានឧបការគុណក្ដី មិនមានឧបការគុណក្ដីដល់ជនទាំងឡាយ មានកូននិងប្រពន្ធរបស់លោកជាដើម យ៉ាងនេះបាន ឈ្មោះថា **ឧបេក្ខាបារមី** ប្រែថា ធម្មជាតជាទីដល់នូវត្រើយ គឺព្រះនិព្វានព្រោះចិត្តមធ្យម ។

ខ) **អត្តនោ អង្គប្បច្ចង្គស្ស ឧបការកេសុបិ អនុបការកេសុបិ សត្តសង្ខារេសុ បវត្តិមជ្ឈត្តតា ឧបេក្ខា ឧបបារមី នាម** ថាសន្ដានចិត្តរបស់ពោធិសត្វតាំងនៅយ៉ាងមធ្យមគឺយ៉ាងកណ្ដាលក្នុងសត្វ និងសង្ខារទាំងឡាយ ដែល

មានឧបការគុណ និងមិនមានឧបការគុណ ដល់អង្គធំ និងតូចក្នុងរាងកាយរបស់ព្រះអង្គក្តី យ៉ាងនេះបាន ឈ្មោះថា **ឧបេក្ខាបារមី** ប្រែថា ធម្មជាតជាទីដល់នូវត្រើយខាងលើ គឺព្រះនិព្វាន ព្រោះឧបេក្ខាចិត្ត ។

គ) **អត្តនោ ជីវិតស្ស ឧបការកេសុបិ អនុបការកេសុបិ សត្តសង្ខារេសុ បវត្តិមជ្ឈត្តតា ឧបេក្ខា បរមត្ថបារមី នាម** ថាសន្តានចិត្តរបស់ពោធិសត្វតាំងនៅយ៉ាងមធ្យម គឺយ៉ាងកណ្តាលក្នុងសត្វ និងសង្ខារទាំងឡាយដែលមានឧបការគុណ និងមិនមានឧបការគុណដល់ជីវិតនៃព្រះអង្គក្តី យ៉ាងនេះ ឈ្មោះថា **ឧបេក្ខាបរមត្ថបារមី** ប្រែថា ធម្មជាតជាទីដល់នូវត្រើយជាទីបំផុត គឺព្រះនិព្វាន ព្រោះចិត្តមធ្យម គឺចិត្តជាកណ្តាល ។

មានពាក្យសួរថា ឯបារមីទាំងអស់នេះ មានកិរិយាអនុគ្រោះដល់សត្វដទៃជាលក្ខណៈ និងមានកិរិយាធ្វើនូវឧបការគុណដល់សត្វឯទៀតជាកិច្ច ឬថា មានកិរិយាមិនរំភើបញាប់ញ័រជាកិច្ច និងមាននូវកិរិយាស្វែងរកនូវសេចក្តីចម្រើនជាផល ឬថា មានភាវៈត្រាស់ដឹងជាផល និងមានសេចក្តីអាណិតអាសូរខ្លាំងដល់សត្វទាំងឡាយជាអាសន្នហេតុ ឬថា មានភាវៈឆ្លាសក្នុងឧបាយនៃសេចក្តីករុណាជាអាសន្នហេតុ ដោយមិនបានប្លែកគ្នាឡើយ ។

វាចាដែលពោលនូវបារមីទាំង ១០ ប្រការនេះ ជាសេចក្តីសង្ខេបយ៉ាងខ្លីៗ ឯសេចក្តីពិស្តារនោះ មាន នៅក្នុងគម្ពីរចរិយាបិដកឯនោះ ។

ម្យ៉ាងទៀត ញាណដែលជាទីត្រាស់ដឹងនោះមាន ៣ ប្រការគឺ សម្មាសម្ពោធិ ១ បច្ចេកពោធិ១ សាវ័កពោធិ ១ ជនទាំងឡាយទាំងពួង ដែលជា

សម្មាទិដ្ឋិ គួរប្រាថ្នាយកនូវពោធិញ្ញាណណា ១ ក្នុងញាណ ទាំង ៣ នោះកុំខានឡើយ ។

មួយវិញទៀត ថាបើជនទាំងឡាយឯណា វៀរនូវបារមីទាំងឡាយនេះហើយ ជនទាំងឡាយនោះ មិនអាចនឹងបាននូវពោធិញ្ញាណណាមួយឡើយ ក្នុងញាណទាំង ៣ ប្រការនោះឯង ។ ហេតុដូច្នោះ សូម្បីព្យាយាមដើម្បីបំពេញនូវបារមីទាំងឡាយ គឺ លោកជាសប្បុរសទាំងឡាយ គប្បីធ្វើបន្តិចៗរឿយៗទៅដោយលំដាប់ៗ កុំធ្វេសប្រហែសឡើយ គង់នឹងបានសម្រេចនូវទីក្សេមក្សាន្តសម្រាន្តសុខ ដែលអ្នកប្រាជ្ញទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម លោកតែងនៅតែងបានហើយនោះឯងហោង ។

ស្រង់ចាកទសបារមីកថា ព្រះឧត្តមមុនី អ៊ុំ-ស៊ូ

## សម្បត្តិ ៨ ប្រការមាន ៖

១- **មនុស្សត្តំ** = បានដល់អត្តភាពរបស់មនុស្ស ព្រោះសេចក្តីប្រាថ្នារមែងសម្រេចដល់អ្នកដែលតាំងនៅក្នុងអត្តភាពរបស់មនុស្សតែប៉ុណ្ណោះ ហើយដែលការប្រាថ្នានោះ គឺប្រាថ្នាជាព្រះសម្មាសម្ពុទ្ធ ។ រមែងមិនសម្រេចដល់អ្នកដែលតាំងនៅក្នុងជាតិផ្សេង មាននាគ និងគ្រុឌជាដើមឡើយ ។ ព្រោះ មនុស្សសមគួរដល់ភាពជាព្រះពុទ្ធ។

២- **លិង្គសម្បត្តិ=** សូម្បីតាំងនៅក្នុងអត្តភាពជាមនុស្សហើយតែសេចក្តីប្រាថ្នារមែងសម្រេចបានចំពោះតែមនុស្សប្រុសប៉ុណ្ណោះ ។ រមែងមិនសម្រេច

ដល់ស្ត្រីឬខ្ទើយ ឬ មនុស្សដែលមានភេទពីរឡើយ ។ ព្រោះភេទប្រុសសមគួរដល់ភាពជាព្រះពុទ្ធនិងព្រោះមានភាពបរិបូណ៌នៃលក្ខណៈ ។

៣- **ហេតុ** = គឺដល់ព្រមដោយឧបនិស្ស័យ ពិតណាស់ សេចក្ដីប្រាថ្នារមែងសម្រេចដល់មនុស្សប្រុស ដែលសម្បូណ៌ដោយឧបនិស្ស័យ បើមិនប្រាថ្នាជាព្រះពុទ្ធទេ អាចបានជាព្រះអរហន្តក្នុងជាតិនេះ ព្រោះហេតុសម្បត្តិ ។ ក្រៅអំពីនេះ គឺមិនអាចសម្រេចបានឡើយ ។

៤- **សត្ថារទស្សនំ** = គឺការដែលមានព្រះសាស្ដានៅចំពោះមុខ ព្រោះសេចក្ដីប្រាថ្នា រមែងសម្រេចដល់បុគ្គលណា ដែលប្រាថ្នាក្នុងសំណាក់នៃព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ព្រះជន្មនៅឡើយ ។ កាលបើព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានហើយ សេចក្ដីប្រាថ្នារមែងមិនសម្រេចក្នុងមុខព្រះចេតិយ ឬ គល់ព្រះពោធិព្រឹក្ស ទីព្រះបដិមា ឬ សំណាក់នៃព្រះបច្ចេកពុទ្ធ និងសាវ័ករបស់ព្រះសម្មាសម្ពុទ្ធឡើយ ព្រោះមិនមានអធិការ ព្រោះការពេញចិត្តដ៏មានកម្លាំង ក្នុងការធ្វើដ៏ក្រៃលែង ។

៥- **បព្វជ្ជា** = គឺសេចក្ដីប្រាថ្នារមែងសម្រេច ដល់អ្នកប្រាថ្នាក្នុងសំណាក់របស់ព្រះដ៏មានព្រះភាគ ត្រូវតែជាអ្នកបួស ជាតាបស ឬបួសក្នុងសំណាក់ភិក្ខុទាំងឡាយនិងជាអ្នកជឿកម្ម និងផលរបស់កម្ម ។ មិនសម្រេចដល់អ្នកដែលតាំងនៅក្នុងភេទ ជាគ្រហស្ថឡើយ ។ ព្រោះគ្រហស្ថមិនសមគួរជាព្រះសម្មាសម្ពុទ្ធ ។ មានតែបព្វជិតតែប៉ុណ្ណោះ ជាព្រះមហាពោធិសត្វហើយបានសម្រេចនូវព្រះសម្មាសម្ពោធិញ្ញាណ ព្រោះដូច្នោះ ក្នុងពេល

តាំងប្រណិធានគួរដល់ភេទបព្វជិតតែប៉ុណ្ណោះ ជាការអធិដ្ឋានដោយគុណសម្បត្តិ ដ៏យ៉ាងពិតប្រាកដ ។

៦- **គុណសម្បត្តិ** = គឺដល់ព្រមដោយគុណ មានអភិញ្ញាជាដើម ។ សេចក្ដីប្រាថ្នារមែងសម្រេចដល់បព្វជិតដែលមានសមាបត្តិ ៨ និងអភិញ្ញា ៥ ។ រមែងមិនសម្រេចដល់អ្នកដែលប្រាសចាកនូវគុណសម្បត្តិទាំងនេះឡើយ ព្រោះអាចស្រាវជ្រាវរកបារមីធមិឃើញបាន ។ ព្រះមហាបុរសបំពេញអភិនីហារ ជាអ្នកអាចស្រាវជ្រាវរកឃើញនូវបារមីដោយខ្លួនឯង ជាអ្នកប្រកបដោយឧបនិស្ស័យ សម្បត្តិ ឬអភិញ្ញាសម្បត្តិ ។

៧- **អធិការោ** = គឺមានឧបការៈដ៏ក្រៃលែង។ ពិតណាស់ បុគ្គលណាដល់ព្រមដោយគុណសម្បត្តិ តាមដែលបានពោលហើយ ទោះបីជីវិតរបស់ខ្លួន ក៏ហ៊ានលះបង់ បូជាចំពោះដល់ព្រះសម្មាសម្ពុទ្ធដែរ រមែងធ្វើនូវឧបការៈដ៏យ៉ាងក្រៃលែងក្នុងកាលនោះ ។ អភិនីហាររមែងសម្រេចដល់បុគ្គលនោះឯង រមែងមិនសម្រេចដល់បុគ្គលក្រៅអំពីនេះឡើយ។

៨- **ឆន្ទតា** = គឺពេញចិត្តក្នុងកុសល ដែលបំណងប្រាថ្នានឹងធ្វើ ។ សេចក្ដីប្រាថ្នារមែងសម្រេចដល់អ្នកដែលប្រកបដោយធមិ តាមដែលបានពោលហើយ មានការពេញចិត្តខ្លាំង បំណងនឹងធ្វើដ៏ក្រៃលែង ដើម្បីប្រយោជន៍ដល់ធមិដែលធ្វើឱ្យបានសម្រេចជាព្រះសម្មាសម្ពុទ្ធតែប៉ុណ្ណោះ។

ស្រង់ ចេញពីសៀវភៅបារមីភាគ ១ របស់ លោកគ្រូអគ្គបណ្ឌិត

ចប់ ពុទ្ធការកធមិ

## ១១ បារមី៣០

**- ឥតិបិ { ទានបារមី / ទានឧបបារមី / ទានបរមត្ថបារមី } សម្បន្នោ សោ ភគវា**

-ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ដោយ { ទានបារមី / ទានឧបបារមី / ទានបរមត្ថបារមី } ដូច្នេះផង ។

**- ឥតិបិ { សីលបារមី / សីលឧបបារមី / សីលបរមត្ថបារមី } សម្បន្នោ សោ ភគវា**

-ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ដោយ { សីលបារមី / សីលឧបបារមី / សីលបរមត្ថបារមី } ដូច្នេះផង ។

**- ឥតិបិ { នេក្ខម្មបារមី / នេក្ខម្មឧបបារមី / នេក្ខម្មបរមត្ថបារមី } សម្បន្នោ សោ ភគវា**

-ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ដោយ { នេក្ខម្មបារមី, នេក្ខម្មឧបបារមី, នេក្ខម្មបរមត្ថបារមី } ដូច្នេះផង ។

**- ឥតិបិ { បញ្ញាបារមី, បញ្ញាឧបបារមី, បញ្ញាបរមត្ថបារមី } សម្បន្នោ សោ ភគវា**

-ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ដោយ { បញ្ញាបារមី, បញ្ញាឧបបារមី, បញ្ញាបរមត្ថបារមី } ដូច្នេះផង ។

**- ឥតិបិ { វីរិយបារមី, វីរិយឧបបារមី, វីរិយបរមត្ថបារមី } សម្បន្នោ សោ ភគវា**

-ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ដោយ { វីរិយបារមី, វីរិយឧបបារមី, វីរិយបរមត្ថបារមី } ដូច្នេះផង ។

**- ឥតិបិ**
**ខន្តិបារមី**
**ខន្តិឧបបារមី**
**ខន្តិបរមត្ថបារមី**
**សម្បន្នោ សោ ភគវា**

-ព្រះដ៏មានព្រះភាគអង្គនោះ
ព្រះអង្គបរិបូរណ៍ដោយ
ខន្តិបារមី
ខន្តិឧបបារមី
ខន្តិបរមត្ថបារមី
ដូច្នេះផង ។

**- ឥតិបិ**
**សច្ចបារមី**
**សច្ចឧបបារមី**
**សច្ចបរមត្ថបារមី**
**សម្បន្នោ សោ ភគវា**

-ព្រះដ៏មានព្រះភាគអង្គនោះ
ព្រះអង្គបរិបូរណ៍ដោយ
សច្ចបារមី
សច្ចឧបបារមី
សច្ចបរមត្ថបារមី
ដូច្នេះផង ។

**- ឥតិបិ**
**អធិដ្ឋានបារមី**
**អធិដ្ឋានឧបបារមី**
**អធិដ្ឋានបរមត្ថបារមី**
**សម្បន្នោ សោ ភគវា**

-ព្រះដ៏មានព្រះភាគអង្គនោះ
ព្រះអង្គបរិបូរណ៍ដោយ
អធិដ្ឋានបារមី
អធិដ្ឋានឧបបារមី
អធិដ្ឋានបរមត្ថបារមី
ដូច្នេះផង ។

**- ឥតិបិ { មេត្តាបារមី / មេត្តាឧបបារមី / មេត្តាបរមត្ថបារមី } សម្បន្នោ សោ ភគវា**

-ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៌ដោយ { មេត្តាបារមី / មេត្តាឧបបារមី / មេត្តាបរមត្ថបារមី } ដូច្នេះផង ។

**- ឥតិបិ { ឧបេក្ខាបារមី / ឧបេក្ខាឧបបារមី / ឧបេក្ខាបរមត្ថបារមី } សម្បន្នោ សោ ភគវា**

-ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៌ដោយ { ឧបេក្ខាបារមី / ឧបេក្ខាឧបបារមី / ឧបេក្ខាបរមត្ថបារមី } ដូច្នេះផង ។

**ឥតិបិ សមត្តឹស បារមី សម្បន្នោ សោ ភគវាតិ**

-ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៌ដោយបារមីទាំង ៣០ ដូច្នេះឯង ។

ចប់ បារមី ៣០

000

# ១២ ទំនៀមរបស់ព្រះពោធិសត្វ

១- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វ កើតក្នុងទេវតាជាន់តុសិត តែងមានសតិសម្បជញ្ញៈ ។

២- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វឋិតនៅក្នុងទេវតាជាន់តុសិត តែងមានសតិសម្បជញ្ញៈ ។

៣- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺ ព្រះពោធិសត្វឋិតនៅក្នុងទេវតាជាន់តុសិត ដរាបដល់អស់ជីវិត ។

៤- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វចុះចាកទេវតាជាន់តុសិតមកកាន់ផ្ទៃនៃព្រះមាតា តែងមានសតិសម្បជញ្ញៈ ។

៥- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺព្រះពោធិសត្វច្យុតចាកឋានតុសិតចុះកាន់ផ្ទៃនៃព្រះមាតា ។ គ្រានោះពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបានក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក៏កើតប្រាកដឡើងក្នុងលោកដ៏កន្លងបង់នូវទេវានុភាពនៃទេវតាទាំងឡាយ ។ ឱកាសណាដែលលំហទទេ នៅក្នុងទីបំផុតនៃលោកឥតមានអ្វីបាំងរាំង មានតែអ័ព្ទងងឹត ព្រះចន្ទ ព្រះអាទិត្យ ទាំងនេះសឹងមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ក៏ផ្សាយពន្លឺទៅមិនដល់ក្នុងទីណា ពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបានកន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ក៏កើតប្រាកដឡើងក្នុងទីទាំងនោះ ។ ពួកសត្វណា

ដែលកើតឡើងក្នុងទីទាំងនោះ សត្វអម្បាលនោះ ក៏ស្គាល់គ្នានឹងគ្នាច្បាស់ ដោយសារពន្លឺនោះថា អើហ្ន៎ មានពួកសត្វ ឯទៀតកើតក្នុងទីនេះដែរ ។ លោកធាតុទាំងមួយហ្មឺននេះ ក៏កក្រើករំពើកញាប់ញ័រ ទាំងពន្លឺដ៏ភ្លឺស្វាងច្បាស់រកប្រមាណមិនបាន ក៏កើតប្រាកដឡើងក្នុងលោកកន្លងទេវានុភាពនៃទេវតាទាំងឡាយ ។

៦- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វ ចុះកាន់ផ្ទៃនៃព្រះមាតា មានទេវបុត្រ ៤ អង្គ តែងចូលទៅរក្សាក្នុងទិសទាំង ៤ ដោយគិតថា កុំឱ្យមនុស្ស និងអមនុស្សណានីមួយបៀតបៀនព្រះពោធិសត្វនិងព្រះមាតានៃព្រះពោធិសត្វនោះបានឡើយ ។

៧- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា ព្រះមាតានៃព្រះពោធិសត្វ ជាអ្នកមានសីល[៣] ដោយប្រក្រតី ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ។

៨- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺកាលដែលព្រះពោធិសត្វ ចុះកាន់ផ្ទៃនៃព្រះមាតា ព្រះមាតានៃព្រះពោធិសត្វមិនមានចិត្ត ប្រកបដោយកាម

---

[៣] អដ្ឋកថា ថាកាលដែលព្រះពុទ្ធជាម្ចាស់មិនទាន់កើតឡើង មនុស្សទាំងឡាយតែងថ្វាយបង្គំ ក្នុងសំណាក់នៃពួកតាបស និងបរិព្វាជកហើយ អង្គុយច្រហោងសមាទានសីល សូម្បីព្រះមាតានៃព្រះពោធិសត្វរបស់យើងទាំងឡាយ ក៏ទ្រង់សមាទានសីលក្នុងសំណាក់នៃកាលទេវិលតសីដែរ តែដល់ពោធិសត្វគង់នៅក្នុងផ្ទៃព្រះនាងៗមិនគង់ជិតបាទមូលនៃអ្នកដទៃឡើយ ទ្រង់គង់លើអាសនៈដ៏ស្មើ គ្រាន់តែពិចារណាសីល ដែលសមាទានហើយប៉ុណ្ណោះ ហេតុដូច្នេះបានជាលោកថាព្រះមាតាពោធិសត្វទ្រង់កាន់សីលដោយព្រះអង្គឯង ។

គុណក្នុងបុរសទាំងឡាយ ព្រះមាតានៃព្រះពោធិសត្វ មិនដែលមានបុរសណាមួយ មានចិត្តត្រេកអរប្រព្រឹត្តកន្លងបានឡើយ ។

៩- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺកាលដែលព្រះពោធិសត្វ ចុះកាន់ផ្ទៃនៃព្រះមាតា។នៃព្រះពោធិសត្វ តែងបាននូវកាមគុណទាំង ៥ជាប្រក្រតី ។ ព្រះមាតានៃព្រះពោធិសត្វនោះ តែងស្កប់ស្កល់ ប្រកបព្រមមានអ្នកផ្គាប់បម្រើដោយកាមគុណទាំង ៥ ។

១០- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺកាលដែលព្រះពោធិសត្វ ចុះកាន់ផ្ទៃនៃព្រះមាតា អាពាធណានីមួយក៏មិនកើតឡើងដល់ព្រះមាតានៃព្រះពោធិសត្វឡើយ ព្រះមាតានៃព្រះពោធិសត្វមានតែសេចក្ដីសុខជាប្រក្រតី មានកាយមិនបានលំបាក មួយទៀត មាតានៃព្រះពោធិសត្វតែងមើលឃើញព្រះពោធិសត្វ ហាក់ដូចជាឋិតនៅក្រៅផ្ទៃសព្វអវយវៈទាំងធំ ទាំងតូចមានឥន្ទ្រិយ ក៏មិនថោកថយ ។ ម្នាលភិក្ខុទាំងឡាយកែវមណីពិទូរ្យដ៏ល្អ មានកំណើតដ៏បរិសុទ្ធ មានជ្រុង ៨ ដែលជាងច្នៃល្អហើយដ៏ថ្លាស្អាតប្រាសចាកមន្ទិល សមរម្យដោយអាការៈគ្រប់យ៉ាង ចេសពណ៌ខៀវក្ដី ពណ៌លឿងក្ដី ពណ៌ក្រហមក្ដី ពណ៌សក្ដី ពណ៌លឿងទុំក្ដី ដែលគេដោតហើយក្នុងកែវនោះ បុរសដែលមានភ្នែកដាក់កែវនោះលើដៃ ពិចារណាឃើញច្បាស់ថា កែវមណីពិទូរ្យនេះឯងដ៏ល្អមានកំណើតបរិសុទ្ធ មានជ្រុង ៨ ដែលជាងបានច្នៃល្អ ហើយដ៏ថ្លាស្អាតប្រាសចាកមន្ទិល សមរម្យដោយអាការៈគ្រប់យ៉ាង ចេសពណ៌ខៀវក្ដី ពណ៌លឿងក្ដី ពណ៌ក្រហមក្ដី

ពណិសក្តិ ពណិលឿងទុំក្តិ ដែលគេដោតហើយក្នុងកែវនោះ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយក្នុងកាលដែលពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតាអាពាធណានីមួយ មិនដែលកើតឡើងដល់ព្រះមាតាព្រះពោធិសត្វឡើយ ព្រះមាតានៃព្រះពោធិសត្វជាអ្នកមានសេចក្តីសុខជាប្រក្រតីមានកាយមិនបានលំបាក មួយទៀត ព្រះមាតានៃព្រះពោធិសត្វ តែងមើលឃើញនូវព្រះពោធិសត្វ ហាក់ដូចជាឋិតនៅក្រៅផ្ទៃទាំងអវយវៈធំតូចទាំងអស់ មានឥន្ទ្រិយមិនថោកថយ មានឧបមេយ្យដូច្នោះឯង ។

១១- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វប្រសូតមកបាន ៧ ថ្ងៃ ព្រះមាតានៃព្រះពោធិសត្វ តែងធ្វើមរណកាលទៅកើតក្នុងឋានតុសិត ។

១២- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺស្ត្រីទាំងឡាយដទៃ តែងទ្រទ្រង់គភ៌អស់ ៩ ខែខ្លះ ១០ ខែខ្លះ ទើបបានប្រសូតយ៉ាងណា ព្រះមាតានៃព្រះពោធិសត្វ មិនបានប្រសូតយ៉ាងនោះឡើយ ។ ព្រះមាតានៃព្រះពោធិសត្វ តែងទ្រង់គភ៌ពោធិសត្វអស់ ១០ ខែគត់ ទើបបានប្រសូត ។

១៣- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺស្ត្រីទាំងឡាយដទៃតែងអង្គុយសម្រាលក៏មាន ដេកសម្រាលក៏មាន យ៉ាងណា ព្រះមាតានៃព្រះពោធិសត្វ ប្រសូតព្រះពោធិសត្វមិនមែនយ៉ាងដូច្នោះទេ ព្រះមាតានៃព្រះពោធិសត្វ រមែងស្ថិត (ឈរ) ប្រសូតព្រះពោធិសត្វ ។

១៤- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វប្រសូត

ចាកផ្ទៃនៃព្រះមាតាទេវតា[៤] ទាំងឡាយតែងទទួល (ព្រះពោធិសត្វ) មុន ទើបមនុស្សទាំងឡាយទទួលក្រោយ ។

១៥- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតា ព្រះពោធិសត្វមិនទាន់ចុះដល់ផែនដី មានទេវបុត្រទាំង ៤ ទទួលព្រះអង្គ តម្កល់ក្នុងខាងមុខនៃព្រះមាតាថា បពិត្រព្រះនាងទេវី សូមព្រះនាងមានចិត្តរីករាយចុះ បុត្ររបស់ព្រះនាងជាអ្នកមានស័ក្តិធំ ទ្រង់កើតឡើងហើយ ។

១៦- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតាដ៏ល្អល្អះ (ស្រស់បស់) ចេញមកមិនប្រឡាក់ ដោយទឹក (ភ្លោះ) មិនប្រឡាក់ដោយស្លេស្ម៍ មិនប្រឡាក់ដោយឈាម មិនប្រឡាក់ដោយអសោចណានីមួយឡើយ ជាអ្នកស្អាតបរិសុទ្ធិ ។ ម្នាលភិក្ខុទាំងឡាយ កែវមណីដែលបុគ្គលដាក់ចុះលើកាសិកពស្ត្រ កែវមណី (នោះ) មិនប្រឡាក់នូវកាសិកពស្ត្រឡើយ កាសិកពស្ត្រក៏មិនប្រឡាក់នូវកែវមណីដែរ ហេតុអ្វីបានជាថាដូច្នោះ ព្រោះសំពត់និងកែវមណីទាំងពីរជារបស់ស្អាត មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលព្រះពោធិសត្វ ប្រសូតចាកផ្ទៃនៃព្រះមាតាដ៏ល្អល្អះចេញមក មិនប្រឡាក់ដោយទឹក (ភ្លោះ) មិនប្រឡាក់ដោយស្លេស្ម៍ មិនប្រឡាក់ដោយ

---

[៤] អដ្ឋកថា ថាពួកទេវតាដែលមកទទួលព្រះពោធិសត្វនោះ គឺពួកព្រហ្មជាព្រះខីណាស្រពជាន់សុទ្ធាវាស ។

ឈោម មិនប្រឡាក់ដោយអសោចិ៍ណានីមួយឡើយ ជាអ្នកស្អាតបរិសុទ្ធ មានឧបមេយ្យដូច្នោះឯង ។

១៧- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតា មានធារទឹកពីរហូរចុះមកអំពីអាកាស ធារទឹកមួយត្រជាក់ ធារទឹកមួយក្ដៅ ធ្វើនូវការលាងជំរះព្រះពោធិសត្វផង ព្រះមាតាផង ។

១៨- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វប្រសូតមកភ្លាម ទ្រង់ប្រតិស្ឋាន (ឈរលើផែនដី) ដោយព្រះបាទជាន់ស៊ុប ឆ្ពោះព្រះភក្ត្រទៅកាន់ទិសឧត្តរ ទ្រង់យាងឈានទៅបាន ៧ ជំហាន កាលដែលមហាជនកំពុងបាំងស្វេត្រឆត្រថ្វាយក៏រមិលមើលនូវទិសទាំងពួងផង ទ្រង់ពោលនូវអាសភិវាចា គឺវាចាដ៏ឧត្ដមផងថា **អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ** ប្រែថា អញជាបុគ្គលខ្ពង់ខ្ពស់របស់លោក អញជាបុគ្គលធំបំផុតរបស់លោក អញជាបុគ្គលប្រសើរបំផុតរបស់លោក នេះជាកំណើតបំផុតរបស់អញ ឥឡូវនេះភពថ្មីតពីនេះទៅទៀតមិនមានឡើយ ។

១៩- ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតា គ្រានោះពន្លឺភ្លឺច្បាស់រកប្រមាណមិនបានកើតប្រាកដឡើងក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និង

មនុស្សដ៏សេសកន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ។ ឱកាសណាដែលចំហទទេ នៅក្នុងទីបំផុតនៃលោក ឥតមានអ្វីបាំងរាំង មានតែអ័ព្ទងងឹត ព្រះចន្ទនិងព្រះអាទិត្យមានឫទ្ធិយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ផ្សាយពន្លឺទៅមិនដល់ក្នុងទីណា ពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបាន ក៏កើតប្រាកដឡើងក្នុងទីទាំងនោះកន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ។ ពួកសត្វណាដែលកើតក្នុងទីទាំងនោះ សត្វអម្បាលនោះក៏ស្គាល់ច្បាស់នូវគ្នានឹងគ្នាដោយសារពន្លឺនោះថា អើហ្ន៎ មានពួកសត្វដទៃ កើតក្នុងទីនេះដែរ ។ លោកធាតុទាំងមួយហ្មឺននេះ ក៏កក្រើករំពើកញាប់ញ័រទាំងពន្លឺភ្លឺស្វាងច្បាស់ក៏រកប្រមាណមិនបាន ក៏កើតប្រាកដឡើងក្នុងលោកកន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ។ ទាំងអស់នេះជាធម្មតារបស់ព្រះពោធិសត្វ ។

ខាងក្រោមនេះ ជាសេចក្ដីមាននៅក្នុងអដ្ឋកថា ÷

១- ព្រះពោធិសត្វ ប្រថាប់ពែនភ្នែន បែរខ្នងស្របតាមខ្នងព្រះមាតា ព្រះភក្ត្របែរទៅមុខ ( ខាងពោះមាតា ) សមាធិក្នុងគភ៌របស់ព្រះមាតា ។

២- ព្រះពោធិសត្វ ប្រសូតក្នុងឧទ្យានប៉ុណ្ណោះ ។

៣- ព្រះពោធិសត្វ ប្រថាប់ឈរលាតព្រះហស្ត និងព្រះបាទប្រសូតចាកគភ៌ព្រះមាតា ។

៤- ព្រះពោធិសត្វ ទ្រង់យាងចេញមហាភិនេស្ក្រមណ៍ ក្នុងថ្ងៃដែលព្រះឱរសរបស់ព្រះអង្គ ទ្រង់ប្រសូត ។

៥- ព្រះពោធិសត្វ ទ្រង់ផ្ចួស ទ្រង់ផ្ដើមបំពេញព្យាយាម ។

៦- ព្រះពោធិសត្វ ទ្រង់មានព្រះមហាសុបិន ៥ ប្រការ ក្នុងយប់មុនថ្ងៃត្រាស់ដឹង ។

៧- ព្រះពោធិសត្វ ទ្រង់សោយចង្ហាន់ មធុបាយាសជាព្រះក្រយាហារ ក្នុងគ្រាចុងក្រោយបំផុត មុនការត្រាស់ដឹង ។

៨- ព្រះពោធិសត្វ ប្រថាប់លើបល្ល័ង្កស្មៅ ក្រោមម្លប់ពោធិព្រឹក្ស ទ្រង់បំពេញសមាធិ ។

៩- ព្រះពោធិសត្វ ទ្រង់បរិកម្មអានាបានស្សតិកម្មដ្ឋាន ។

១០- ព្រះពោធិសត្វ ទ្រង់កំចាត់ពលមារ ។

ចប់ ទំនៀមរបស់ព្រះពោធិសត្វ ។

(បិដកលេខ១៦ ទំព័រ២៣)

## ១៣ សេចក្ដីត្រិះរិះរបស់ព្រះពោធិសត្វ

តថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ នៅក្នុងទីឯណោះ មានសេចក្ដីត្រិះរិះដូច្នេះថា ការនៅគ្រប់គ្រងផ្ទះ ជាគ្រឿងចង្អៀតចង្អល់ ជាផ្លូវប្រកបដោយធូលី ឯបព្វជ្ជា ជាទីឱកាសទំនេរ បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឱ្យបរិបូណ៌ បរិសុទ្ធដោយចំណែកមួយ ដូចស័ង្ខដែលបុគ្គលខាត់ហើយទេ បើដូច្នោះមានតែអាត្មាអញកោរសក់និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្ដប់សំពត់កាសាយៈទាំងឡាយ ចេញចាកផ្ទះ ចូលទៅ

កាន់ផ្នួស ។ នែអគ្គិវេស្សនៈ សម័យជាខាងក្រោយ កាលដែលតថាគតនៅជាកំលោះ មានសក់ខ្មៅស្រិលប្រកបដោយវ័យដ៏ចម្រើន គឺបឋមវ័យ កាលដែលមាតានិងបិតាទាំងឡាយមិនត្រូវការឱ្យចេញទៅបួស មានព្រះភក្ត្រទទឹក ដោយព្រះអស្សុទ្រទង់ព្រះកន្សែង ក៏នៅតែកោរសក់និងពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយ ចេញចាកផ្ទះ ចូលមកកាន់ផ្នួស ។

## ១៤ ស្តេចចូលទៅរកអាឡារតាបសនិងឧទ្ទកតាបស

លុះតថាគតបួសរួចហើយ ក៏ស្វែងរកកីកុសល ស្វែងរកសន្តិវរបទ គឺព្រះនិព្វាន ជាគ្រឿងរម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេសដ៏ប្រសើរ ហើយចូលទៅរកអាឡារតាបស កាលាមគោត្រ លុះចូលទៅដល់ហើយ បាននិយាយដូច្នេះនឹងអាឡារតាបស កាលាមគោត្រថា ម្នាលអាវុសោកាលាមៈ ខ្ញុំប្រាថ្នានឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងធម្មវិន័យនេះ ។ ម្នាលអគ្គិវេស្សនៈ កាលតថាគតបាននិយាយយ៉ាងនេះហើយ ទើបអាឡារកាលាមតាបស ពោលដូច្នេះវិញនឹងតថាគតថា អ្នកមានអាយុចូរនៅចុះ នេះធម៌ដែលប្រាកដដូចជាអ្នកត្រូវការនោះជាធម៌ដែលវិញ្ញូបុរសធ្វើឱ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង នូវលទ្ធិនៃអាចារ្យជារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅ ដោយកាលមិនយូរប៉ុន្មាន ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះក៏រៀនធម៌នោះ (បានធ្វើឱ្យជាក់ច្បាស់ដោយបញ្ញា ដ៏ឧត្តមដោយខ្លួនឯង ចាំមួយរំពេច មិនយឺតយូរឡើយ) ។ល។ នែអគ្គិវេស្សនៈ តថាគតក៏មានសេចក្តីត្រិះរិះដូច្នេះថា ធម៌នេះមិនប្រព្រឹត្តទៅដើម្បីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ

ដើម្បីរំលត់នូវរាគាទិក្កិលេស មិនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ ប្រព្រឹត្តទៅបានត្រឹមតែកើតក្នុងអាកិញ្ចញ្ញាយតនភពប៉ុណ្ណោះឯង ។ នែអគ្គិវេស្សនៈ តថាគតនោះ មិនពេញចិត្តនិងធម៌នោះ ហើយនឿយណាយចាកធម៌នោះ ក៏ដើរចៀសចេញទៅ ។

តថាគតស្វែងរកកឹកុសល ស្វែងរកសន្តិវរបទគឺព្រះនិព្វាន ជាគ្រឿងរម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេសដ៏ប្រសើរ ហើយចូលទៅរកឧទ្ទករាមបុត្តតាបស លុះចូលទៅដល់ហើយបាននិយាយពាក្យនេះ នឹងឧទ្ទករាមបុត្តថា អាវុសោរាមៈ យើងប្រាថ្នាដើម្បីប្រព្រឹត្តនូវព្រហ្មចរិយធម៌ ក្នុងធម្មវិន័យនេះ ។ នែអគ្គិវេស្សនៈ កាលបើតថាគត ពោលយ៉ាងនេះហើយ ឧទ្ទករាមបុត្ត ក៏និយាយពាក្យនេះនឹងតថាគតថា អ្នកដ៏មានអាយុ ចូរនៅចុះ នេះធម៌ដែលប្រាកដដូចជាអ្នកត្រូវការនោះ ជាធម៌ដែលវិញ្ញូបុរស គួរធ្វើឱ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នៅលទ្ធិនៃអាចារ្យជារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅ ដោយមិនយូរប៉ុន្មាន ។ នែអគ្គិវេស្សនៈ តថាគតនោះ ក៏បានធ្វើឱ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងនូវធម៌នោះមួយរំពេច មិនយឺតយូរឡើយ ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ ល ។

ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា ធម៌នេះមិនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយចាករាគាទិក្កិលេស មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីរំលត់កងទុក្ខ មិនប្រព្រឹត្តទៅ

ដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ ប្រព្រឹត្តទៅបានត្រឹមតែកើតក្នុងនេវសញ្ញានាសញ្ញាយតនភពប៉ុណ្ណោះ ។ នៃអគ្គិវេស្សនៈ តថាគតនោះ មិនពេញចិត្តនឹងធម៌នោះ ក៏នឿយណាយចាកធម៌នោះ ហើយចៀសចេញទៅ ។

## ១៥ សេចក្តីឧបមា ៣ យ៉ាង

នៃអគ្គិវេស្សនៈ កាលដែលតថាគតស្វែងរកកឹកុសល ស្វែងរកសន្តិវរបទ គឺព្រះនិព្វាន ជាគ្រឿងរម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេសដ៏ប្រសើរ ហើយក៏ត្រាច់ទៅកាន់ចារិក តាមលំដាប់ក្នុងដែនមគធៈ បានដល់សេនានិគម ក្នុងឧរុវេ-លាប្រទេស ។ តថាគតបានឃើញនូវភូមិភាគ គួរជាទីសប្បាយក្នុងសេនានិគមនោះផង នូវដងព្រៃជាទីជ្រះថ្លាផង នូវស្ទឹងដែលមានទឹកហូរមានទឹកថ្លា កំពង់ដ៏ល្អជាទីសប្បាយផង នូវស្រុកជាទីគោចរជិតល្មមផង ។ កន្លែងនេះជាកន្លែងគួរដើម្បីប្រព្រឹត្តព្យាយាមនៃកុលបុត្តជាអ្នកមានព្យាយាម ។

នៃអគ្គិវេស្សនៈ សេចក្តីឧបមាទាំង ៣ មិនជាអស្ចារ្យណាស់ណា តថាគតមិនធ្លាប់បានឮមកក្នុងកាលមុនទេ ស្រាប់តែប្រាកដដល់តថាគត ។ នៃអគ្គិវេស្សនៈ (សេចក្តីឧបមាទី១) ដូចជាកំណាត់ឈើស្រស់នៅមានជ័រដែលត្រាំនៅក្នុងទឹក ។ លំដាប់នោះ មានបុរសម្នាក់កាន់យកឈើពំនួតភ្លើងខាងលើ (កូនពំនួត) ដើរមកដោយគិតថា អាត្មាអញនិងពួតភ្លើងឱ្យកើតឡើង អាត្មាអញនឹងធ្វើភ្លើងនោះឱ្យឆេះឡើង ។ ល ។

(បុរសនោះបានត្រឹមតែ ចំណែកនៃសេចក្ដីលំបាកសេចក្ដីចង្អៀតចង្អល់ ឥត ប្រយោជន៍ភ្លើងនោះមិនគប្បីឆេះឡើងបានឡើយ មានឧបមាដូចម្ដេចមិញ) នែអគ្គិវេស្សនៈ ពួកជនណានីមួយ ទោះបីជាសមណក្ដី ព្រាហ្មណ៍ក្ដី មានកាយ មិនបានចៀសចេញ ចាកវត្ថុកាមទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះ មិនបាន លះបង់មិនបានរម្ងាប់នូវសេចក្ដីប្រាថ្នា ក្នុងកិលេសកាម សេចក្ដីស្រឡាញ់ក្នុង កិលេសកាម សេចក្ដីជ្រុលជ្រប់ក្នុងកិលេសកាម សេចក្ដីស្រេកឃ្លានក្នុងកិលេស- កាម សេចក្ដីក្ដៅក្រហាយក្នុងកិលេសកាមឰដ៏ខាងក្នុងផង ។ បើទុកជាសមណ ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ទទួលទុក្ខវេទនា ក្លៀវក្លា រឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាម ក៏គង់សមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីដឹង ដើម្បី ឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរឡើយ ។ បើទុកជាសមណព្រាហ្មណ៍ទាំង នោះ មិនបានទទួលទុក្ខវេទនា ក្លៀវក្លា រឹងរូស ក្រហល់ក្រហាយ ដែលកើតអំពី ព្យាយាម ក៏គង់សមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរដែរ មានឧបមេយ្យដូច្នោះឯង ។

នែអគ្គិវេស្សនៈ សេចក្ដីឧបមាជាគម្រប់ពីរដទៃទៀត មិនជាទីអស្ចារ្យ ណាស់ណា ដែលតថាគតមិនធ្លាប់បានឮមកក្នុងកាលមុន ក៏ស្រាប់តែប្រាកដដល់ តថាគត ។ ម្នាលអគ្គិវេស្សនៈ កំណាត់ឈើស្រស់នៅមានជ័រ ដែលដាក់នៅលើ គោកឆ្ងាយអំពីទឹក ។ លំដាប់នោះ មានបុរសម្នាក់កាន់យកនូវឈើពំនួតភ្លើង ខាងលើដើរមក ដោយគិតថា អាត្មាអញនឹងធ្វើភ្លើងឱ្យកើតឡើង នឹងធ្វើភ្លើងឱ្យ ឆេះឡើង ។ល។ (ឯបុរសនោះ គ្រាន់តែជាអ្នកមានចំណែកនៃសេចក្ដីលំបាក

និងសេចក្ដីចង្អៀតចង្អល់ប៉ុណ្ណោះឯងភ្លើងនោះមិនគប្បីឆេះបានឡើយ មានឧបមាដូចម្ដេចមិញ) នែអគ្គិវេស្សនៈជនទាំងឡាយណានីមួយ ទោះជាសមណក្ដីព្រាហ្មណ៍ក្ដី មានកាយចៀសចេញ ចាកវត្ថុកាមទាំងឡាយ ពិតមែនហើយ តែថាសមណព្រាហ្មណ៍ទាំងនោះ មិនបានលះបង់ មិនបានរម្ងាប់នូវសេចក្ដីប្រាថ្នាក្នុងកិលេសកាម សេចក្ដីស្រឡាញ់ក្នុងកិលេសកាម សេចក្ដីជ្រុលជ្រប់ក្នុងកិលេសកាមសេចក្ដីស្រេកឃ្លានក្នុងកិលេសកាម សេចក្ដីក្ដៅក្រហាយក្នុងកិលេសកាមឲ្យដ៏ខាងក្នុង ។ បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ សោយនូវទុក្ខវេទនាក្លៀវក្លាវឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាម ក៏គង់សមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹង យ៉ាងប្រសើរឡើយ ។ បើទុកជាសមណព្រាហ្មណ៍ទាំងនោះ មិនបានសោយទុក្ខវេទនា ក្លៀវក្លា វឹងរូសក្រហល់ក្រហាយ ដែលកើតអំពីសេចក្ដីព្យាយាមទេ ក៏គង់សមណព្រាហ្មណ៍នោះមិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹង យ៉ាងប្រសើរដែរ មានឧបមេយ្យដូច្នោះឯង ។

នែអគ្គិវេស្សនៈ សេចក្ដីឧបមាទី ៣ ដទៃទៀតមិនជាទីអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់ឮមកក្នុងកាលមុន ក៏ស្រាប់តែប្រាកដដល់តថាគត ។ នែអគ្គិវេស្សនៈ កំណាត់ឈើស្ងួត ជាឈើសល់ ដែលដាក់នៅលើគោកឆ្ងាយអំពីទឹក ។ លំដាប់នោះមានបុរសម្នាក់កាន់នូវឈើពំនួតភ្លើងខាងលើ ដើរមកដោយគិតថា អាត្មាអញនឹងធ្វើភ្លើងឱ្យកើតឡើង អាត្មាអញនឹងធ្វើភ្លើងឱ្យឆេះឡើង ។ នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះដូចម្ដេច បុរសនោះ កាន់នូវ

ឈើពំនួតភ្លើងខាងលើ មកពួតនឹងកំណាត់ឈើស្ងួត ជាឈើសល់ដែលដាក់នៅលើគោក ឆ្ងាយអំពីទឹកឯណោះ ហើយគប្បីធ្វើភ្លើងឱ្យកើតឡើង គប្បីធ្វើភ្លើងឱ្យឆេះឡើងបានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន គប្បីធ្វើភ្លើងឱ្យឆេះឡើងបាន ព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចម្រើន ព្រោះកំណាត់ឈើស្ងួតឯណោះជាឈើសល់ស្រាប់ ហើយថែមទាំងកំណាត់ឈើនោះនៅលើគោក ឆ្ងាយអំពីទឹកទៅទៀត មានឧបមាយ៉ាងណាមិញ នែអគ្គិវេស្សនៈ ពួកជនណានីមួយ ទោះបីជាសមណៈក្តី ព្រាហ្មណ៍ក្តី មានកាយចៀសចេញចាកវត្ថុកាមទាំងឡាយផង សមណព្រាហ្មណ៍ទាំងនោះ បានលះបង់ បានរម្ងាប់សេចក្តីប្រាថ្នា ក្នុងកិលេសកាម សេចក្តីស្រឡាញ់ក្នុងកិលេសកាម សេចក្តីជ្រុលជ្រប់ក្នុងកិលេសកាម សេចក្តីស្រេកឃ្លានក្នុងកិលេសកាម សេចក្តីក្តៅក្រហាយក្នុងកិលេសកាម ឰដ៏ខាងក្នុងផង ។ បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ មិនទទួលទុក្ខវេទនា ក្លៀវក្លារឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាម ក៏គង់សមណៈព្រាហ្មណ៍ទាំងនោះ គួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរបាន ។ បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ទទួលទុក្ខវេទនាក្លៀវក្លា រឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាមទេ ក៏គង់ សមណព្រាហ្មណ៍ទាំងនោះ គួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរបានដែរ មានឧបមេយ្យយ៉ាងនោះឯង នែអគ្គិវេស្សនៈ សេចក្តីឧបមាទាំងបីនេះឯង មិនជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានឮមក ក្នុងកាលមុនទេ ក៏ស្រាប់តែប្រាកដដល់តថាគត ។

# ១៦ ប្រភេទនៃទុក្ករកិរិយា

នែអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអាត្មាអញ ខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិតាន( ក្រអូមមាត់) ដោយអណ្តាត សង្កត់គាបផ្ចប់នូវចិត្តដោយចិត្ត ។ នែអគ្គិវេស្សនៈ តថាគតនោះក៏ខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយទល់ពិតាន ដោយអណ្តាតសង្កត់គាបផ្ចប់នូវចិត្តដោយចិត្ត នែអគ្គិវេស្សនៈ កាលដែលតថាគតនោះ ខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយទល់ពិតាន ( ក្រអូមមាត់) ដោយអណ្តាតសង្កត់គាបផ្ចប់នូវចិត្តដោយចិត្ត ញើសក៏ហូរចេញអំពីក្លៀកទាំងសងខាង ។ នែអគ្គិវេស្សនៈ ដូចបុរសដែលមានកម្លាំង ចាប់បុរសដែលមានកម្លាំងថយជាងខ្លួន ត្រង់ក្បាលផង ចាប់ត្រង់កផង គប្បីសង្កត់គាបផ្ចប់ មានឧបមាយ៉ាងណាមិញ នែអគ្គិវេស្សនៈ កាលដែលតថាគត ខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិតានដោយអណ្តាតសង្កត់គាបផ្ចប់នូវចិត្តដោយចិត្ត ញើសក៏ហូរចេញអំពីក្លៀកទាំងសងខាង មានឧបមេយ្យយ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគត តឹងតែងណាស់ មិនធូរថយ សតិក៏តម្កល់ខ្ជាប់ មិនមានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគតដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ដោយសារសេចក្តីព្យាយាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

នែអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះមាន តែអាត្មាអញពិចារណានូវអប្បាណកជ្ឈាន គឺឈានដែលគ្មានដង្ហើមចេញចូល ។ នែអគ្គិវេស្សនៈ តថាគត ក៏បិទខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង ។ នែអគ្គិវេស្សនៈ លុះតថាគត បិទខ្យល់ដង្ហើមចេញ និង ខ្យល់ ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង សំឡេងរបស់ខ្យល់ដែលចេញមក អំពីរន្ធត្រចៀកទាំងសងខាង ក៏ឮខ្លាំងក្រៃពេក ។ សំឡេងស្នប់របស់ជាងមាស ដែលកំពុងសប់លាន់ឮខ្លាំង យ៉ាងណាមិញ ម្នាលអគ្គិវេស្សនៈ លុះតថាគត បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង សំឡេងរបស់ខ្យល់ ដែលចេញអំពីរន្ធត្រចៀកទាំងសងខាងក៏លាន់ឮខ្លាំង យ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគតតឹងតែងណាស់ មិនបន្ធូរបន្ថយ ទាំងសតិក៏តម្កល់ខ្ជាប់ មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ដោតហើយ ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ដោយសារសេចក្តីព្យាយាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

នែអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ពិចារណានូវអប្បាណកជ្ឈាន ។ នែអគ្គិវេស្សនៈ តថាគតក៏បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ នែអគ្គិវេស្សនៈ លុះតថាគត បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល

អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏ចាក់ដោតនូវក្បាល ។ នែអគ្គិវេស្សនៈ បុរសមានកម្លាំងចាក់ឆ្មៀលនូវក្បាល ដោយចុងដែកស្រួចដ៏មុត យ៉ាងណាមិញ នែអគ្គិវេស្សនៈ លុះតថាគត បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ហើយខ្យល់ដ៏ខ្លាំងក្រៃលែង ក៏ចាក់ដោតនូវក្បាលយ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគត តឹងតែងណាស់ មិនធូរថយឡើយ សតិក៏តម្កល់ខ្ជាប់ មិនបានវង្វេងភ្លេចឡើយ តែចំណែកខាងកាយរបស់តថាគតដែលត្រូវព្យាយាមចាក់ដោតទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ដោយសារសេចក្តីព្យាយាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

នែអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះគួរតែអាត្មាអញ ពិចារណានូវអប្បាណកជ្ឈានតែម្យ៉ាង ។ នែអគ្គិវេស្សនៈ តថាគតក៏បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង។ នែអគ្គិវេស្សនៈ លុះតថាគតនោះ បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សីសវេទនា[៥] ដ៏ខ្លាំងក្រៃលែង ក៏កើតប្រាកដក្នុងក្បាល ។ នែអគ្គិវេស្សនៈ បុរសមានកម្លាំង

[៥] ជម្ងឺក្បាលដ៏មានកម្លាំង កើតអំពីកងខ្យល់ដែលមិនបានចេញមកអំពីទ្វារណាមួយសោះនោះឯង ។ អដ្ឋកថា ។

រុំក្បាល ដោយកំណាត់ព្រ័តដ៏មាំ យ៉ាងណាមិញ នែអគ្គិវេស្សនៈ លុះតថាគត បិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សីសវេទនាដ៏ខ្លាំងក្រៃលែងក៏កើតប្រាកដក្នុងក្បាល ក៏យ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្ដីព្យាយាមរបស់តថាគតតឹងតែងណាស់ មិនធូរថយឡើយ ទាំងសតិក៏តម្កល់ខ្ជាប់ មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគតដែលត្រូវព្យាយាមចាក់ដោតទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ដោយសារសេចក្ដីព្យាយាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះកើតឡើងដល់តថាគត ក៏គ្របសង្កត់ចិត្តរបស់តថាគតមិនបានឡើយ ។

នែអគ្គិវេស្សនៈ តថាគតនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះគួរតែអាត្មាអញ ពិចារណានូវអប្បាណកជ្ឈាន ។ នែអគ្គិវេស្សនៈ តថាគតនោះ បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ នែអគ្គិវេស្សនៈ លុះតថាគតនោះ បិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែងក៏សៀតធ្លុះផ្ទៃ ។ នែអគ្គិវេស្សនៈ បុរសអ្នកសម្លាប់គោ ឬកូនសិស្សនៃបុរសអ្នកសម្លាប់គោដ៏ឈ្លាសវៃ គប្បីអារនូវផ្ទៃដោយកាំបិតសម្រាប់អារគោដ៏មុត យ៉ាងណាមិញ នែអគ្គិវេស្សនៈ លុះតថាគត បិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏សៀតធ្លុះផ្ទៃ យ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្ដីព្យាយាម

របស់តថាគត តឹងតែងណាស់ មិនធូរថយឡើយ ទាំងសតិក៏តម្កល់ខ្ជាប់ មិនបាន វង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ដោតទៅ ជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ដោយសារសេចក្តីព្យាយាមដ៏លំបាក នោះឯង ។ នៃអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើង ដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញពិចារណានូវអប្បាណកជ្ឈាន ។ ម្នាលអគ្គិវេស្សនៈ តថាគត នោះឯង ក៏បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ ម្នាលអគ្គិវេស្សនៈ លុះតថាគតនោះ បិទខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ហើយសេចក្តី ក្តៅក្រហាយដ៏ខ្លាំងក្រៃលែងក៏កើតឡើងក្នុងកាយ ។ ម្នាលអគ្គិវេស្សនៈ បុរស មានកម្លាំងពីរនាក់ ចាប់នូវបុរសមានកម្លាំងថយជាងខ្លួន ត្រង់ដៃទាំងសងខាង ឆ្អើរកំដៅលើរណ្តៅរងើកភ្លើង យ៉ាងណាមិញ ម្នាលអគ្គិវេស្សនៈ លុះតថាគតបិទ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀក ផង ហើយសេចក្តីក្តៅក្រហាយដ៏ខ្លាំងក្រៃលែង ក៏កើតឡើងក្នុងកាយ យ៉ាងនោះ ឯង ។ ម្នាលអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគត តឹងតែងណាស់ មិនធូរ ថយឡើយ ទាំងសតិក៏តម្កល់ខ្ជាប់ខ្ជួន មិនបានវង្វេងភ្លេច តែចំណែកខាងកាយ របស់តថាគត ដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបាន ស្ងប់រម្ងាប់ដោយសារសេចក្តីព្យាយាមដ៏លំបាកនោះឯង ។ ម្នាលអគ្គិវេស្សនៈ ទុក

ណាជាទុក្ខវេទនាមានសភាព ដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតឡើយ ។ ម្នាលអគ្គិវេស្សនៈ មានពួកទេវតាបានឃើញតថាគតដូច្នោះហើយ និយាយយ៉ាងនេះថា ព្រះសមណគោតមធ្វើមរណកាលហើយ ។ ទេវតាពួកខ្លះនិយាយយ៉ាងនេះថា ព្រះសមណគោតមមិនទាន់ធ្វើមរណកាលនៅឡើយទេ តែគង់នឹងធ្វើមរណកាលពុំខាន។ ទេវតាពួកខ្លះនិយាយ យ៉ាងនេះថា ព្រះសមណគោតម មិនបានធ្វើមរណកាលទៅហើយទេ ទាំងនឹងមិនធ្វើមរណកាលឡើយ ព្រះសមណគោតមជាអរហន្ត ទ្រង់គង់ព្រះជន្មាយុ ដោយពិតការគង់ព្រះជន្មាយុរបស់ព្រះអរហន្តនោះ មានសភាពយ៉ាងនេះ។

ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះគួរតែអាត្មាអញប្រតិបត្តិ ដើម្បីផ្តាច់បង់នូវអាហារដោយប្រការទាំងពួង ។ ម្នាលអគ្គិវេស្សនៈ លំដាប់នោះឯង ពួកទេវតាចូលទៅរកតថាគត ហើយនិយាយដូច្នេះថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះអង្គកុំប្រតិបត្តិដើម្បីផ្តាច់បង់នូវអាហារដោយប្រការទាំងពួងឡើយ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ បើព្រះអង្គនឹងប្រតិបត្តិដើម្បីផ្តាច់បង់នូវអាហារ ដោយប្រការទាំងពួងតទៅ យើងទាំងឡាយនឹងញ៉ាំងឱជាទិព្វ ឱ្យជ្រួតជ្រាបទៅតាមរណ្តៅរោមទាំងឡាយរបស់ព្រះអង្គៗនឹងរស់នៅដោយឱជាទិព្វនោះបាន ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើអាត្មាអញនឹងប្តេជ្ញាថា ខ្លួនជាអ្នកគ្មានភោជនដោយប្រការទាំងពួងផង ទេវតាទាំងឡាយនេះ នឹងញ៉ាំងឱជាទិព្វឱ្យជ្រួតជ្រាបចូលទៅតាមរណ្តៅរោមទាំងឡាយរបស់អាត្មាអញផង អាត្មាអញនឹងរស់នៅដោយឱជាទិព្វនោះផង

អំពើនោះជាអំពើកុហករបស់អាត្មាអញ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង ក៏និយាយឃាត់ទេវតាទាំងនោះវិញ តថាគតប្រាប់ថា កុំឡើយដូច្នេះ ។

ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្ដីត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអាត្មាអញ បរិភោគនូវអាហារបន្តិច១ ទោះបីគ្រាប់សណ្ដែកបាយក្ដី គ្រាប់ពពាយជ្រុងក្ដី គ្រាប់សណ្ដែកកង់ក្ដី គ្រាប់សណ្ដែកទ្រើងក្ដី ត្រឹមតែមួយទូកដៃ១ ។ ម្នាលអគ្គិវេស្សនៈ តថាគតក៏បានបរិភោគនូវអាហារបន្តិច១ ទោះបីគ្រាប់សណ្ដែកបាយក្ដី គ្រាប់ពពាយជ្រុងក្ដី គ្រាប់សណ្ដែកកង់ក្ដី គ្រាប់សណ្ដែកទ្រើងក្ដី ត្រឹមតែមួយទូកដៃ១ ។ ម្នាលអគ្គិវេស្សនៈ កាលដែលតថាគតនោះ បរិភោគអាហារបន្តិច១ ទោះបីគ្រាប់សណ្ដែកបាយក្ដី គ្រាប់ពពាយជ្រុងក្ដី គ្រាប់សណ្ដែកកង់ក្ដី គ្រាប់សណ្ដែកទ្រើងក្ដី ត្រឹមតែមួយទូកដៃ១ កាយរបស់តថាគតក៏ដល់នូវអាការស្គាំងស្គមក្រៃលែង ។ អវយវៈតូចធំរបស់តថាគត ដូចជាថ្នាំងនៃវល្លិ ឈ្មោះអសីតិកៈ ឬដូចជាថ្នាំងនៃវល្លិប្រែង ព្រោះមានអាហារតិចនោះឯង ។ គគូថរបស់តថាគត ដូចជាស្នាមជើងនៃសត្វឱដ្ឋ ព្រោះមានអាហារតិចនោះឯង ។ ឆ្អឹងខ្នងរបស់តថាគត រងិបរងុប ដូចជាលំពង់ឈើ ដែលវល្លិព័ទ្ធវេញ ព្រោះមានអាហារតិចនោះឯង ។ របៀបនៃឆ្អឹងជំនីទាំងឡាយរបស់តថាគត ក៏រគីមរគាម ដូចជាបង្កង់នៃសាលាចាស់ដ៏រគីមរគាមព្រោះមានអាហារតិចនោះឯង ។ ប្រស្រីភ្នែកក្នុងរណ្ដៅភ្នែករបស់តថាគត ក៏ជ្រៅខូងចុះទៅ ដូចក្រពេញទឹកក្នុងអណ្ដូងទឹកជ្រៅដ៏ជ្រៅខូងចុះទៅ ព្រោះមានអាហារតិចនោះឯង ។ ស្បែកក្បាលឰដ៏ក្បាលរបស់តថាគត ដែលអាហារតិចនោះពាល់ត្រូវហើយ ក៏ស្វិតជ្រីវ ដូចជា

ផ្លែនទោងព្រៃដែលគេកាត់អំពីខ្សែ លុះខ្យល់និងកំដៅថ្ងៃពាល់ត្រូវហើយ ក៏ស្វិតជ្រីវ ដូច្នោះឯង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯងគិតថា អាត្មាអញនឹងស្ទាបស្បែកពោះ ក៏ចាប់ត្រូវលើឆ្អឹងខ្នងទៅវិញ គិតថាអាត្មាអញនឹងស្ទាបឆ្អឹងខ្នង ក៏ចាប់ត្រូវលើស្បែកពោះទៅវិញ ម្នាលអគ្គិវេស្សនៈ ព្រោះថា ស្បែកពោះរបស់តថាគតជាប់នឹងឆ្អឹងខ្នង ព្រោះមានអាហារតិចនោះឯង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯងគិតថា អាត្មាអញនឹងបន្ទោបង់នូវវច្ចៈ ឬទឹកមូត្រ ក៏ដួលផ្កាប់ក្នុងទីនោះ ព្រោះមានអាហារតិចនោះឯង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯងធ្វើកាយនេះឱ្យស្រួលបួល ដុសខ្លួនប្រាណដោយដៃ ម្នាលអគ្គិវេស្សនៈ កាលបើតថាគតនោះ ដុសខ្លួនប្រាណដោយដៃ រោមទាំងឡាយ មានគល់ស្អុយ ក៏ធ្លាក់ចុះអំពីកាយ ព្រោះមានអាហារតិចនោះឯង ។ ម្នាលអគ្គិវេស្សនៈ មនុស្សទាំងឡាយបានឃើញតថាគត ហើយពោលពាក្យយ៉ាងនេះថា ព្រះសមណគោតមមានសម្បុរខ្មៅ ។ មនុស្សពួកខ្លះ និយាយយ៉ាងនេះថា ព្រះសមណគោតមមិនខ្មៅទេ ព្រះសមណគោតម មានសម្បុរសណ្តែកបាយ ។ មនុស្សពួកខ្លះ និយាយយ៉ាងនេះថា ព្រះសមណគោតមមិនមែនសម្បុរខ្មៅ មិនមែនសម្បុរសណ្តែកបាយទេ ព្រះសមណគោតមមានសម្បុរស្បែកប្រផេះ ។ ម្នាលអគ្គិវេស្សនៈ សម្បុរស្បែករបស់តថាគត បរិសុទ្ធផូរផង់ដល់ម្លោះ ក៏ត្រឡប់ជាអាប់អន់ ព្រោះមានអាហារតិចនោះឯង ។

ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា ជនទាំងឡាយណាមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងអតីតកាល បានសោយនូវទុក្ខ

វេទនាដ៏ក្លៀវក្លា រឹងរូស ផ្សាខ្លោច ដែលកើតអំពីព្យាយាម មានកំណត់តែត្រឹមប៉ុណ្ណោះ មិនលើសលប់ជាងនេះទៅទៀតទេ ។ ជនទាំងឡាយណានីមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងអនាគតកាលនឹងរងនូវទុក្ខវេទនាដ៏ក្លៀវក្លា រឹងរូស ផ្សាខ្លោច ដែលកើតអំពីព្យាយាម មានកំណត់តែត្រឹមប៉ុណ្ណោះ មិនលើសលប់ជាងនេះទៅទៀតទេ ។ ជនទាំងឡាយណានីមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងកាលឥឡូវនេះ តែងរងនូវទុក្ខវេទនាដ៏ក្លៀវក្លា រឹងរូស ផ្សាខ្លោច ដែលកើតអំពីព្យាយាម មានកំណត់តែត្រឹមប៉ុណ្ណោះ មិនមានលើសលប់ជាងនេះទៅទៀតទេ ។ ចំណែកខាងអាត្មាអញ មិនទាន់បានត្រាស់ដឹងនូវគុណវិសេស គឺញាណទស្សនៈដ៏ឧត្តមដែលអាចកំចាត់បង់នូវកិលេសដ៏ក្រៃលែង ជាងមនុស្សធម៌ដោយទុក្ករកិរិយាដ៏ផ្សាខ្លោចនេះនៅឡើយ ។ ផ្លូវដទៃប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹងគប្បីមានដែរឬហ្ន៎ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា កាលដែលអាត្មាអញអង្គុយ នៅក្រោមម្លប់នៃដើមព្រីងដ៏ត្រជាក់ក្នុងកិច្ចការរបស់សក្យរាជជាបិតា ក៏ធ្លាប់បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ និងវិចារៈមានបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះ ហើយសម្រេចសម្រាន្តនៅ ឱហ្ន៎ នុ៎ះឯងជាផ្លូវនៃការត្រាស់ដឹងហើយទេដឹង ។ ម្នាលអគ្គិវេស្សនៈ វិញ្ញាណជាគ្រឿងរលឹកតាមនូវស្មារតី ក៏កើតឡើងដល់តថាគតនោះថា ផ្លូវនុ៎ះឯងហើយ ជាផ្លូវនៃការត្រាស់ដឹង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីសុខណាក្រៅចាកកាមទាំងឡាយ ក្រៅចាកអកុសលធម៌ទាំង

ឡាយ អាត្មាអញខ្លាចសេចក្ដីសុខនោះឬហ្ន៎ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្ដីត្រិះរិះដូច្នេះថា សេចក្ដីសុខណាក្រៅចាកកាមទាំងឡាយ ក្រៅចាកអកុសលធម៌ទាំងឡាយ អាត្មាអញមិនខ្លាចសេចក្ដីសុខនោះទេ ។

ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្ដីត្រិះរិះដូច្នេះថា បុគ្គលមានកាយដល់នូវអាការស្គាំងស្គមក្រៃលែងយ៉ាងនេះ មិនងាយបាននូវសេចក្ដីសុខនោះទេ បើដូច្នោះ គួរតែអាត្មាអញបរិភោគនូវអាហារដ៏គ្រោតគ្រាត គឺបាយ និងនំវិញ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង ក៏បរិភោគនូវអាហារដ៏គ្រោតគ្រាត គឺបាយ និងនំ ។ ម្នាលអគ្គិវេស្សនៈ សម័យនោះឯង ភិក្ខុទាំង ៥ រូប តាមមកបម្រើតថាគត ដោយគិតថា ព្រះសមណគោតមរបស់យើង នឹងបានត្រាស់នូវធម៌ណា លោកនឹងប្រាប់នូវធម៌នោះដល់យើងទាំងឡាយ ។ ម្នាលអគ្គិវេស្សនៈ ព្រោះហេតុតែតថាគតបរិភោគនូវអាហារដ៏គ្រោតគ្រាត គឺបាយនិងនំ ក្នុងកាលណា ភិក្ខុទាំង ៥ រូបនោះ លះបង់រត់ចោលតថាគតក្នុងកាលនោះ ដោយគិតថា ព្រះសមណគោតម ប្រកបដោយល្មោភច្រើន ដោះចោលព្យាយាម ត្រឡប់ទៅដើម្បីសេចក្ដីល្មោភច្រើន ។

ម្នាលអគ្គិវេស្សនៈ លុះតថាគតនោះឯង បរិភោគនូវអាហារដ៏គ្រោតគ្រាតហើយ ក៏មានកម្លាំងបានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខដែលកើតអំពីសេចក្ដីស្ងាត់នោះ ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះកើតឡើង

ដល់តថាគត ក៏មិនគ្របសង្កត់ចិត្តរបស់តថាគតបានឡើយ ។ លុះតថាគតរម្ងាប់វិតក្កៈនិងវិចារៈហើយ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតិកើតមានក្នុងសន្ដាននៃខ្លួនប្រកបដោយសេចក្ដីជ្រះថ្លា គឺសទ្ធា ជាសភាពនៃចិត្តដ៏ខ្ពស់ឯក ឥតមានវិតក្កៈនិងវិចារៈមានតែបីតិនិងសុខដែលកើតអំពីសមាធិគឺបឋមជ្ឈាន..ក៏បានដល់នូវតតិយជ្ឈាន...បានដល់នូវចតុត្ថជ្ឈាន... ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះកើតឡើងដល់តថាគត ក៏មិនគ្របសង្កត់ចិត្តរបស់តថាគតបានឡើយ ។ កាលដែលចិត្តរបស់តថាគត ខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានទីទួលពោលគឺកិលេសប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ (ដោយអំណាចឈាន ទាំង ៤) ដោយប្រការដូច្នេះហើយតថាគតបង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ តថាគតនោះរលឹកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរលឹកឃើញជាតិ ១ ខ្លះ ជាតិ ២ ខ្លះ ។ល។ រលឹកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការ គឺរូបនិងអាហារជាដើម ព្រមទាំងឧទ្ទេសគឺ ឈ្មោះ និង គោត្រត្រកូលជាដើម ដោយប្រការដូច្នេះ ។ ម្នាល អគ្គិវេស្សនៈវិជ្ជាទី ១ នេះឯង តថាគតបានឃើញហើយក្នុងបឋមយាមនៃរាត្រី អវិជ្ជាខ្ជាត់បាត់ទៅហើយ វិជ្ជាក៏កើតឡើង សេចក្ដីងងឹតខ្ជាត់បាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគត ដូចបុគ្គលដែលមិនប្រមាទមានព្យាយាមញ៉ាំងកិលេសឱ្យក្ដៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែលបាននូវវិជ្ជាទី១នោះដែរ ។

ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

កាលបើចិត្តរបស់តថាគតខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានទីទួលពោល គឺកិលេសប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្មជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ ដោយប្រការដូច្នេះហើយ តថាគតក៏បង្អោនចិត្តទៅ ដើម្បីសត្តចុតូបបាតញ្ញាណ។ តថាគតនោះ មានចក្ខុដូចជាទិព្វដ៏ស្អាតកន្លងហួសចក្ខុរបស់មនុស្សធម្មតា ក៏បានឃើញនូវពួកសត្វដែលច្យុត ដែលកើតឡើង ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានរូបល្អខ្លះ រូបអាក្រក់ខ្លះ មានគតិល្អខ្លះ គតិអាក្រក់ខ្លះ មួយវិញទៀត តថាគតដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម ។ល។ ម្នាលអគ្គិវេស្សនៈវិជ្ជាទី ២ នេះឯង តថាគតបានហើយក្នុងមជ្ឈិមយាមនៃរាត្រីអវិជ្ជាខ្ចាត់បាត់ទៅហើយ វិជ្ជាក៏កើតឡើង សេចក្តីងងឹតខ្ចាត់បាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគត ដូចបុគ្គលដែលមិនប្រមាទមានព្យាយាមញុំាងកិលេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែលបាននូវវិជ្ជាទី ២ ដូច្នោះដែរ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

កាលបើចិត្តរបស់តថាគតខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានទីទួលពោលគឺកិលេសប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ ។ តថាគតនោះបានដឹងច្បាស់តាមពិតថា នេះជាទុក្ខបានដឹងច្បាស់តាមពិតថា នេះជាហេតុនាំឱ្យកើតទុក្ខ បានដឹងច្បាស់តាមពិតថា

នេះជាទីរលត់ទុក្ខ បានដឹងច្បាស់តាមពិតថា នេះសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់ទុក្ខ បានដឹងច្បាស់តាមពិតថា នេះជាអាសវៈ បានដឹងច្បាស់តាមពិតថា នេះជាធមិនាំឱ្យកើតអាសវៈ បានដឹងច្បាស់តាមពិតថា នេះជាទីរលត់អាសវៈ បានដឹងច្បាស់តាមពិតថា នេះសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់អាសវៈ ។ កាលតថាគតនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តរបស់តថាគតរួចចាកកាមាសវៈផង ចិត្តរបស់តថាគត រួចចាកភវាសវៈផង ចិត្តរបស់តថាគតរួចចាកអវិជ្ជាសវៈផង ។ល។ តថាគតដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលអគ្គិវេស្សនៈវិជ្ជាទី៣ នេះឯង តថាគតបានហើយក្នុងបច្ឆិមយាមនៃរាត្រីអវិជ្ជាខ្ចាត់បាត់ទៅហើយ វិជ្ជាក៏កើតឡើង សេចក្តីងងឹតខ្ចាត់បាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគតដូចបុគ្គលដែលមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែលបាននូវវិជ្ជាទី ៣ ដូច្នោះដែរ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះកើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

ក្នុងកាលឥឡូវនេះ តថាគត ជាព្រះសម្ពុទ្ធព្រះនាមគោតមសម្រេចដោយការតាំងព្យាយាមដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម នាមណ្ឌលពោធិព្រឹក្សតថាគត ជាព្រះជិនស្រីបានញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅក្នុងព្រៃឥសិបតនៈទៀបក្រុងពារាណសី តថាគត ជាគោតមសម្ពុទ្ធជាទីពឹងនៃសត្វទាំងពួង ។

ចប់ប្រភេទនៃទុក្ករកិរិយា

អត្ថបទទាំង ៤ នេះដកពីមហាសច្ចកសូត្របិដកលេខ ២២ ទំព័រ ៨៨

## ១៧ ឧទានគាថា

កាលព្រះអង្គគង់លើរតនបល្ល័ង្ក ទៀបគល់ពោធិព្រឹក្ស ទ្រង់ផ្ចាញ់មារាធិរាជព្រមទាំងពួកពលឱ្យបរាជ័យ បាក់បបខ្លបខ្លាចចុះចាញ់ ព្រះអង្គហើយ ទ្រង់រំពឹងដល់ ពុទ្ធប្បវេណី ដោយឈានសមាបត្តិ លះបង់នូវរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ ព្រមទាំងកិលេស ១៥០០ តណ្ហា ១០៨ ឱ្យឃ្លាតពីសន្តានព្រះអង្គ ដូចដំណក់ទឹក ដែលជ្រុះចុះចាកស្លឹកឈូកយ៉ាងនេះ ហៅថា កិលេសនិព្វាន ។ ពេលដែលព្រះអង្គទ្រង់បានកិលេសនិព្វាននោះ ព្រះអង្គទ្រង់បន្លឺ នូវឧទានវាចាថាៈ

**អនេកជាតិ សំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ**
**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសំខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគាតិ ។**

កាលដែលតថាគត កំពុងស្វែងរកជាងឈើ គឺតណ្ហា អ្នកធ្វើនូវផ្ទះ គឺអត្តភាពរបស់តថាគត កាលដែលមិនទាន់បានជួបប្រទះនៅឡើយ តថាគតតែង តែអន្ទោលទៅកាន់សំសារវដ្ត រាប់ជាតិជាអនេក ( ម្ល៉ោះហើយ) ជាតិក៏តែងនាំសេចក្តីទុក្ខមកឱ្យតថាគតរឿយៗ ឥតស្រាកស្រាន្តឡើយ នែជាងផ្ទះ ឥឡូវតថាគត រកអ្នកឃើញហើយណា៎ះ ពីនេះទៅអ្នកឯងអស់ធ្វើផ្ទះ គឺអត្តភាពឱ្យតថាគតបានទៀតហើយ បង្កង់ គឺ

កិលេសដ៏សេសទាំងឡាយរបស់អ្នកឯង តថាគតបានកាច់បំបាក់អស់ទៅហើយ ទាំងកំពូលផ្ទះគឺអវិជ្ជា ដែលអ្នកឯងធ្វើរួចហើយ (នោះ) តថាគតក៏បានកំចាត់បង់ហើយ ឥឡូវនេះ ចិត្តរបស់តថាគត បានដល់នូវព្រះនិព្វាន ដែលប្រាសចាកសង្ខារហើយ តថាគតបានត្រាស់ដឹងនូវព្រះអរហត្ត ដែលជាធមិក្ស័យតណ្ហាទាំងឡាយហើយ ។

## ១៨ ទំនៀមរបស់ព្រះពុទ្ធ

- ទ្រង់ត្រាស់ដឹងសម្មាសម្ពោធិញាណ លើពោធិបល្ល័ង្គ ក្នុងវេលាទៀបភ្លឺ ខណៈនោះ ផែនដីញាប់ញ័រ ១២ លើក ។
- ទ្រង់ប្រថាប់នៅក្នុងបរិវេណ ពោធិមណ្ឌល ៧ សប្តាហ៍ ។
- មហាព្រហ្មទូលអារាធនា ឱ្យទ្រង់សំដែងធមិ ។
- មារទូលសូមឱ្យព្រះអង្គទ្រង់បរិនិព្វាន ។
- ទ្រង់សំដែងធមិជាដំបូង គឺ ធម្មចក្កប្បវត្តនសូត្រ ក្នុងឥសិបតនមិគទាយវ័នក្នុងថ្ងៃ អាសាឡ្ហបុណ្ណមី ។
- ទ្រង់សំដែងឱវាទបាតិមោក្ខក្នុងថ្ងៃចតុរង្គសន្និបាត មាឃបុណ្ណមី ។
- ទ្រង់ត្រាស់ពុទ្ធវង្ស ក្នុងសមាគមពពួកញាតិ ។
- ទ្រង់សំដែងបាដិហារិយ៍ជិតក្រុងសាវត្ថី ។
- ទ្រង់សំដែងព្រះអភិធម្ម ប្រោសពុទ្ធមាតា ក្នុងឋានតាវត្តិង្ស ។
- ទ្រង់យាងចុះចាកទេវលោក ក្នុងដែនសង្កស្ស នាថ្ងៃមហាបវារណា ។

- ទ្រង់បញ្ញត្តសិក្ខាបទ កាលមានហេតុកើតឡើង ។
- ទ្រង់ត្រាស់ជាតក ដែលជាដើមហេតុ នៃរឿងដែលកើត ។
- ទ្រង់ធ្វើបដិសណ្ឋារៈ ចំពោះភិក្ខុអាគន្តុកៈ ។
- ទ្រង់រមិលមើល វេនេយ្យសត្វពីរវារៈ ។
- ទ្រង់បដិបត្តិពុទ្ធកិច្ច ៥ ប្រការជាវត្ត
- ទ្រង់ឱ្យគណៈសង្ឃដឹងគ្រប់វេលា ប្រសិនបើត្រូវស្តេចចារិក ក្នុងរវាងវស្សា ។
- ទ្រង់ប្រថាប់ក្នុងវត្តជេតពនជាប្រក្រតី ។
- ទ្រង់ចូលផលសមាបត្តិតជាប់គ្នា ( តាំងពីក្នុងប្រឈួន ក្នុងវេឡុវគ្រាម) ។
- ទ្រង់សោយសូករមទ្ទវៈក្នុងថ្ងៃចូលព្រះនិព្វាន ។
- ទ្រង់ចូលសមាបត្តិ ដោយអនុលោមនិងបដិលោម ហើយស្តេចចូលបរិនិព្វាន ។
- ព្រះពុទ្ធគ្រប់ព្រះអង្គ មិនទ្រង់លះបង់ស្ថានទី ៤ កន្លែងគឺ ÷

  ១- កន្លែងដែលព្រះអង្គត្រាស់ដឹងលើពោធិបល្ល័ង្ក ទៀបគល់អស្សត្ថព្រឹក្ស ក្នុងឧរុវេលាសេនានិគម ។

  ២- កន្លែងដែលព្រះអង្គសំដែងបឋមទេសនា ក្នុងឥសិបតនមិគទាយវ័ន ។

  ៣- កន្លែងដែលព្រះអង្គ ចុះចាកទេវលោក ក្នុងដែនសង្កស្ស ។

  ៤- កន្លែងដែលព្រះអង្គផ្ទំ ក្នុងគន្ធកុដិនាជេតវនវិហារ ។

មិនមានវត្ថុណា អាចធ្វើឱ្យអន្តរាយ ៤ ប្រការ ដល់ព្រះពុទ្ធគ្រប់ព្រះអង្គបានគឺ ÷

១- អន្តរាយដោយបច្ច័យ ៤ ដែលជាចំណែករបស់ព្រះអង្គ ។

២- អន្តរាយដល់ព្រះជន្មាយុរបស់ព្រះអង្គ។

៣- អន្តរាយដល់មហាបុរិសលក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០។

៤- អន្តរាយដល់ពុទ្ធរង្សីរបស់ព្រះអង្គ។

(អដ្ឋកថា)

## ១៩ ពុទ្ធកិច្ច ៥ ប្រការ

ពុទ្ធកិច្ច គឺកិច្ចដែលព្រះអរហន្ត សម្មាសម្ពុទ្ធគ្រប់ព្រះអង្គ កាន់យកជាវត្តបដិបត្តិក្រោយអំពីការត្រាស់ដឹង ព្រះសម្មាសម្ពោធិញ្ញាណ ដោយបញ្ញាដ៏ល្អិតរបស់ព្រះអង្គ ហើយព្រះពុទ្ធអង្គ ទ្រង់បំពេញពុទ្ធចរិយា ដែលជាប្រយោជន៍ដល់សត្វលោក ទ្រង់ប្រោសវេនេយ្យសត្វ ដោយព្រះអធ្យាស្រ័យដ៏ពោរពេញ ដោយព្រះមហាករុណា ទ្រង់អនុគ្រោះពពួកសត្វឱ្យជាសុខ ផុតចាកទុក្ខ ឱ្យតាំងនៅក្នុងសរណៈ និងបានសម្រេចអមតធម៌ គឺព្រះនិព្វាន មិនថាព្រះពុទ្ធអង្គ ប្រថាប់នៅក្នុងកន្លែងណា ព្រះអង្គក៏មិនបានទ្រង់លះបង់កិច្ច ៥ ប្រការ គឺ ៖

១ កិច្ចក្នុងបុរេភត្ត

២ កិច្ចក្នុងបច្ឆាភត្ត

៣ កិច្ចក្នុងបឋមយាម

៤ កិច្ចក្នុងមជ្ឈិមយាម

៥ កិច្ចក្នុងបច្ឆិមយាមដូចបុរាណាចារ្យ
ចងជាគាថាទុកថា

**បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ**
**បទោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហានំ**
**បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ**
**ឯតេ បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោតិ ។**

ព្រះសម្មាសម្ពុទ្ធ ជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជម្រះនូវពុទ្ធកិច្ច ទាំងឡាយ ៥ ប្រការនេះ គឺក្នុងពេលព្រឹក ទ្រង់ស្តេចទៅបិណ្ឌបាត ១ ក្នុងពេលល្ងាច ទ្រង់សម្តែងធម៌ទេសនា ១ ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ ១ ក្នុងពេលអធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា ១ ក្នុងពេលជិតភ្លឺ[៦] ទ្រង់ប្រមើល មើលនូវសត្វលោក ដែលគួរត្រាស់ដឹងនិងមិនគួរត្រាស់ដឹង ១ ។

## ២០ ពុទ្ធាបទាន

ព្រះបរមសាស្តាចារ្យ ជាកំពូលលើអស់អ្នកប្រាជ្ញក្នុងលោក ជាទីពឹងនៃសព្វសត្វ កាលជាព្រះបរមពោធិសត្វនៅឡើយ ក៏ជាអ្នកប្រាជ្ញមានបញ្ញាមុតថ្លា ក្នុងការបំពេញអភិនីហារបារមីអង់អាចក្លាហាន ឈ្លាសវៃចំពោះកិច្ចការបុណ្យ

៦. ក្នុងអដ្ឋកថាធម្មបទ សម្តែងថា ព្រះអង្គប្រមើលមើល ឧបនិស្ស័យសត្វក្នុង ១ថ្ងៃ ១យប់ ពីរដង គឺក្នុងពេលជិតភ្លឺម្តង។ ពេលល្ងាចម្តង ពេលជិតភ្លឺ ទ្រង់ប្រមើលមើលពីកណ្តាប់មាត់ចក្រវាឡ រហូតដល់មកគន្ធកុដិ ពេលល្ងាច ទ្រង់ប្រមើលមើលពីគន្ធកុដិ រហូតដល់ទៅកណ្តាប់មាត់ចក្រវាឡ ។

កុសលធ្លាប់បានសូម្បីមិនមានបដិគ្គាហកជាបុញ្ញក្ខេត្តដ៏ឧត្តមប្រសើរមួយសោះ មិនបាន ចំណាយទ្រព្យធនឱ្យប្រាកដសោះ កាលបើសេចក្តីជ្រះថ្លាកើតឡើង ហើយព្រះ អង្គ គ្រាន់តែអធិដ្ឋាន ដោយចិត្ត អាចញុំាងប្រយោជន៍ឱ្យកើតឡើង ទទួលបាន សេចក្តីសុខក្នុងទេវលោក ក្នុងមនុស្សលោក រហូតបានសម្រេចសម្ពោធិញ្ញាណ បាន ។

ព្រះអង្គទ្រង់ត្រាស់សំដែងចំពោះព្រះអានន្ទដោះសំណួររបស់នតង្គះជាអ្នក ប្រាជ្ញ ជាបុត្រនៃនាងទេវី ក្នុងដែនវេទេហៈ បានសួរព្រះតថាគត កាលគង់នៅក្នុង វត្តជេតពនថា បានឮថា ព្រះសព្វញ្ញុពុទ្ធទាំងឡាយតែងមាន តើព្រះសព្វញ្ញុពុទ្ធ ជាអ្នកប្រាជ្ញទាំងនោះ ទ្រង់កើតមានដោយហេតុដូចម្តេច ។ គ្រានោះ ព្រះ សព្វញ្ញុពុទ្ធដ៏ប្រសើរ ទ្រង់ស្វែងរកនូវគុណដ៏ធំ ទ្រង់បែរទៅត្រាស់នឹងព្រះអានន្ទដ៏ ចម្រើន ដោយព្រះសូរសៀងដ៏ពីរោះថា ពោធិសត្វទាំងឡាយណា មានការ កសាងបានធ្វើទុកហើយ ក្នុងសំណាក់នៃព្រះពុទ្ធទាំងពួង តែមិនទាន់បានមោក្ខ ធម៌ ក្នុងសាសនានៃព្រះជិនស្រីទេ ពោធិសត្វទាំងនោះ ជាអ្នកប្រាជ្ញមានបញ្ញា មុតថ្លា រមែងបាននូវភាពជាសព្វញ្ញុពុទ្ធ ព្រោះប្រធាននៃការត្រាស់ដឹងនោះផង ព្រោះអធ្យាស្រ័យមានកម្លាំងដ៏ធំនោះផង ព្រោះតេជះនៃបញ្ញានោះផង ។

សូម្បីតថាគត ក៏បានប្រាថ្នានូវភាពជាព្រះពុទ្ធ ក្នុងសំណាក់នៃព្រះពុទ្ធ មុនៗទាំងឡាយរាប់មិនអស់ ដែលជាព្រះរាជាហេតុធម៌ បរិបូណ៌ដោយបារមី ៣០ ។ តថាគតបាននមស្ការថ្វាយបង្គំដោយម្រាមដៃ ១០ ដោយក្បាលចំពោះ

ព្រះសម្ពោធិញ្ញាណរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយផង ចំពោះព្រះសម្ពុទ្ធទាំងឡាយ ជានាយកនៃសត្វលោក ព្រមទាំងព្រះសង្ឃផង ។ រតនៈទាំងឡាយ រាប់មិនអស់ មានក្នុងពុទ្ធក្ខេត្តទាំងប៉ុន្មាន ទេវតាដែលឋិតនៅឰដ៏អាកាសផង ឋិតនៅលើដែនដីផង រមែងនាំមកនូវរតនៈទាំងពួងនោះ ដោយចិត្ត ។ ក្នុងទីនោះ តថាគតបានសាងប្រាសាទជាវិការៈនៃកែវ មានជាន់ច្រើនខ្ពស់ត្រដែតទៅក្នុងអាកាស ត្រង់ភូមិភាគជាវិការៈនៃប្រាក់ មានសសរធ្វើល្អដ៏វិចិត្រហើយ ចែកជាល្វែងល្អ ហើយជាប្រាសាទមានតម្លៃច្រើន មានក្របជាវិការៈនៃមាសប្រដាប់ដោយឆត្រកំពូលស្រួច ។ ជាន់ទីមួយ ជាវិការៈនៃកែវពៃទូរ្យ ប្រាសចាកមន្ទិលល្អស្មើពពកដ៏ដេរដាសដោយឈូកដ៏ល្អជាងជាន់ ដែលក្រាលដោយមាសដ៏ប្រសើរ ។ (ជាន់ខ្លះ) វិចិត្រដោយកែវប្រពាឡមានពណ៌នៃកែវប្រពាឡ (ជាន់ខ្លះ) មានពណ៌ក្រហមល្អ (ជាន់ខ្លះ) មានពន្លឺដូចស្លាបអណ្ដើកមាស (ជាន់ខ្លះ) ភ្លឺផ្លេកគ្រប់ទិស ។ ទីអង្គុយ ដៃកែវ បង្អួច សុទ្ធសឹងចាត់ត្រូវរបៀប មានកម្រងផ្កាក្លិនក្រអូបជាទីគាប់ចិត្ត (សំយុងចុះមក) តាមចម្រឹងទាំង ៤ និង តាមសន្ទះបង្អួច ។ (ជាន់ប្រាសាទទាំងឡាយ) មានពណ៌ខៀវ លឿង ក្រហម ស និង ពណ៌ខ្មៅសុទ្ធ ដែលប្រដាប់ដោយផ្ទះកំពូលដ៏ប្រសើរ តាក់តែងហើយដោយកែវ ៧ ប្រការ ។ មានក្បាច់ផ្កាឈូកគួរក្រឡេកមើលស្រស់ដោយរូបម្រឹគ និងបក្សី ដេរដាសដោយរូបផ្កាយនក្ខត្តឫក្ស ដោយរូបព្រះចន្ទ និងព្រះអាទិត្យទាំងដាសពាសដោយបណ្ដាញមាសប្រកបដោយកណ្ដឹងមាសសន្លឹកផ្កាមាសជាទីត្រេកអរនៃចិត្ត រមែងលាន់ឮដោយកំលាំងខ្យល់ ។ (ផ្ទៃនៃប្រាសាទនោះ) មានទង់ពណ៌ហង្សបាទ

ពណិក្រហម ពណិលឿង ពណិលឿងទុំ មានទង់វិចិត្រល្អដោយពណិផ្សេងៗ ប្រកបរបៀបទង់ដែលគេលើកឡើង ។ មានផែនក្តារផ្សេងៗ ច្រើនរយជាអនេក ជាក្តារប្រាក់ខ្លះ ក្តារកែវមណីខ្លះ ក្តារកែវទទឹមខ្លះ ក្តារកែវមរកតខ្លះ ។ (ផ្ទៃខាងក្នុងប្រាសាទនោះ) វិចិត្រដោយសយនៈផ្សេងៗ ក្រាលដោយសំពត់កាសិកៈ មានសាច់ល្អិត សំពត់រោមសត្វ សំពត់សូត្រ សំពត់ស្រុកចីនៈ សំពត់ស្រុកបត្តុណ្ណៈ សំពត់ស្រុកបណ្ឌុ ។ តថាគត បានក្រាលនូវកម្រាលផ្សេងៗទាំងអស់ដោយចិត្តឯង តថាគតពាក់តែងនូវហោជាងកែវក្នុងជាន់នោះៗ ។ មានពួកជន ឈរកាន់ប្រទីបកែវមណីភ្លឺរុងរឿង ឯសសរខឿន សសរផ្ទះ ខ្លោងទ្វារ ជាវិការៈនៃមាស ជាវិការៈនៃមាសជម្ពូនទៈ ជាវិការៈនៃឈើខ្លឹម ជាវិការៈនៃប្រាក់ដ៏ស្រស់ល្អទាំងទីតំណដ៏ច្រើនដែលចែកល្អ វិចិត្រដោយសន្ទះទ្វារ និងគន្លឹះសុទ្ធសឹងល្អៗ ។ ក្អមពេញ (ដោយទឹក) ច្រើនដែលដាក់ផ្កាឈូក និងឧប្បលជាតិ រៀបតាំងទាំងសងខាងនៃប្រាសាទនោះ ។ ព្រះបច្ចេកពុទ្ធទាំងពួង ព្រមទាំងសាវ័កនិម្មិតនូវព្រះសព្វញ្ញុពុទ្ធជានាយកនៃសត្វលោក ព្រមទាំងព្រះសង្ឃក្នុងកាលដ៏កន្លងទៅហើយផង (នូវព្រះបច្ចេកពុទ្ធទាំងឡាយ) ព្រមទាំងសាវ័ក ដោយរូបភេទជាប្រក្រតីផង ហើយចូលទៅតាមទ្វារនោះ រួចគង់ជាអរិយមណ្ឌលលើតាំងជាវិការៈនៃមាសទាំងអស់ ព្រះពុទ្ធទាំងឡាយណា ប្រសើរផុតក្នុងលោកមានក្នុងកាលឥឡូវនេះក្តី ព្រះពុទ្ធទាំងឡាយណាកន្លងទៅហើយក្តី ព្រះពុទ្ធទាំងអស់អង្គនោះបានឡើងមកគង់ក្នុងប្រាសាទរបស់តថាគត ឯតថាគតក៏បានអង្គាសព្រះបច្ចេកពុទ្ធជាច្រើនរយអង្គ ដែលជាអ្នកត្រាស់ដឹងឯង ជាអ្នកឈ្នះមារក្នុងអតីតកាលនិង

បច្ចុប្បន្នកាល (ឱ្យឆ្អែតស្កប់ស្កល់) ។ មានដើមកប្បព្រឹក្សច្រើនដើម ទាំងជាទិព្វ ទាំងជារបស់មនុស្ស តថាគតបាននាំយកសំពត់ទាំងពួង (អំពីដើមកប្បព្រឹក្ស នោះ) មកធ្វើជាត្រៃចីវរហើយថ្វាយ (ព្រះបច្ចេកពុទ្ធ) ឱ្យស្លៀកដណ្ដប់ (រួច និមន្តឱ្យឆាន់) នូវបង្អែម និងចំអាប ដែលមានរសឆ្ងាញ់ ព្រមទាំងទឹក និង ភោជន ។ តថាគតបានញុំាងបាត្រដ៏ល្អ ជាវិការៈនៃកែវមណីឱ្យពេញ (ដោយ វត្ថុទាំងនោះ) ហើយប្រគេនសំពត់ទិព្វមានសាច់ដ៏រលីង ដែលគួរដល់ចីវរ ។ មណ្ឌលនៃព្រះអរិយៈទាំងអស់ឆ្អែតស្កប់ស្កល់ហើយ ដោយទឹកឃ្មុំផង ស្ករក្រាម ផង ប្រេងផង ទឹកឃ្មុំនិងស្ករអំពៅផង បាយដ៏ប្រសើរផង ។ (ព្រះអរិយៈទាំង នោះ) ចូលទៅកាន់បន្ទប់កែវសម្រេចសីហសេយ្យាលើសយនៈ មានតម្លៃច្រើន ដូចកេសររាជសីហ៍ក្នុងគូហា ។ (ព្រះអរិយៈទាំងនោះ) មានសម្បជញ្ញៈក្រោក ឡើង ហើយផ្គត់ព្រះភ្នែនលើសំណិងបំពេញសេចក្ដីត្រេកអរ ក្នុងឈានជា អារម្មណ៍របស់ព្រះពុទ្ធទាំងពួង ។ ពួកព្រះអរិយៈខ្លះសម្ដែងធម៌ ពួកខ្លះក្រសាល ដោយឫទ្ធិ ពួកខ្លះក្រសាលដោយអប្បនាសមាធិ ពួកខ្លះចម្រើននូវវសីក្នុងអភិញ្ញា ធ្វើវិកុព្វនាឥទ្ធិ[៧] ច្រើនសែន ។ ព្រះពុទ្ធទាំងឡាយ ទ្រង់សួរនូវប្រស្នាជាវិស័យ ព្រះពុទ្ធ ជារបៀបនៃសព្វញ្ញុពុទ្ធចំពោះព្រះពុទ្ធទាំងឡាយដែលត្រាស់ដឹងហេតុដ៏ ជ្រៅល្អិត ដោយប្រាជ្ញាសាវ័កទាំងឡាយ សួរព្រះពុទ្ធទាំងឡាយ ឯព្រះពុទ្ធទាំង ឡាយ ក៏សួរសាវ័កទាំងឡាយ ។ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវ័កជាអ្នក

[៧] បានដល់ឫទ្ធិដែលធ្វើមនុស្សម្នាក់ឱ្យទៅជាមនុស្សច្រើននាក់ ។

បម្រើទាំងនោះ សួរគ្នានឹងគ្នាផង ឆ្លើយដល់គ្នានឹងគ្នាផង ។ ព្រះអរិយបុគ្គលទាំងនោះ កាលត្រេកអរក្នុងពុទ្ធកិច្ច យ៉ាងនេះហើយ រមែងរីករាយលើប្រាសាទ ឯឆត្ររួត ប្រាកដស្មើដោយរបៀបនៃកែវក៏ឋិតនៅ ។ តថាគតប្រកាសថា ឆត្រដែលប៉ាក់ដោយបណ្តាញមាស ដែលរចនាដោយបណ្តាញប្រាក់ដែលព័ទ្ធព័ទ្ធដោយបណ្តាញកែវមុក្តាឆត្រទាំងអស់នោះ សូមបាំងលើព្រះកេសព្រះពុទ្ធ ។ ពិតានសំពត់ដែលវិចិត្រដោយរូបផ្កាមាស ដែលវិចិត្រដោយរបៀបផ្កា ពិតានទាំងនោះ សូមបាំងលើព្រះកេសព្រះពុទ្ធ ។ សូមស្រះបោក្ខរណី ដេរដាសដោយចង្កោមផ្កា (មានក្លិនក្រអូប) និងចង្កោមផ្កាឈើមានក្លិនក្រអូបល្អ ដោយចង្កោមផ្កាក្រអូប ដេរដាសដោយផ្ទាំងសំពត់ តាក់តែងដោយចង្កោមកែវ ។ សូមស្រះបោក្ខរណី ដេរដាសដោយផ្កាវិចិត្រល្អ អប់ដោយក្លិនក្រអូប តាក់តែងដោយគ្រឿងប្រស់ព្រំដ៏ក្រអូប បិទបាំងដោយពិតានមាស ។ សូមស្រះបោក្ខរណី ក្នុងទិសទាំង៤ ព្រោងព្រាតដោយឈូក និងឧប្បល រោយរាយដោយលំអងផ្កាឈូក កើតប្រាកដក្បែរប្រាសាទមាស ។ ដើមឈើទាំងអស់ជុំវិញប្រាសាទ សូមបញ្ចេញផ្កា លុះបញ្ចេញផ្កាហើយ សូមរោយរាយក្លិនទៅលើប្រាសាទ ។ សូមពួកក្ងោកពង់លើប្រាសាទនោះ សូមពួកហង្ស ជាទិព្វស្រែកកញ្ជ្រៀវ សូមពួកករវិកយំ សូមពួកបក្សីរងាវ ជុំវិញប្រាសាទនោះ ។ សូមពួកស្គរទាំងអស់ លាន់ឮខ្ទរខ្ទារ សូមពួកពិណទាំងអស់លាន់ឮ សូមពួកចម្រៀងទាំងអស់ច្រៀងជុំវិញប្រាសាទ ។ សូមបល្ល័ង្កមាសដ៏ធំដែលបរិបូណ៌ដោយពន្លឺមិនដាច់ដែលរចនាដោយកែវ ឋិតនៅក្នុងចក្រវាឡ ជាពុទ្ធក្ខេត្តទាំងប៉ុន្មានផង ក្នុងចក្រវាឡ (ដទៃពីនោះផង) ។ សូម

ពួកឈើប្រទីបភ្លឺរុងរឿង សូមឈើទាំងហ្នឹន មានពន្លឺតែបែបមួយគ្នា ។ សូមពួកស្រ្តីគណិកា ពួកស្រ្តីរបាំ និងពួកស្រ្តីអប្សរ ដែលប្រដាប់ដោយពណ៌ផ្សេងៗនាំគ្នារាំ នាំគ្នាច្រៀងជុំវិញប្រាសាទ ។ តថាគតឱ្យគេលើកទង់ជ័យទាំងអស់ដ៏វិចិត្រមានពណ៌ ៥ លើចុងឈើខ្លះ លើកំពូលភ្នំខ្លះ លើកំពូលភ្នំសិនេរុខ្លះ ។ តថាគតប្រកាសថា សូមពួកមនុស្ស នាគ គន្ធព្វ និងទេវតាទាំងអស់នោះ នាំគ្នាមកនមស្ការ ធ្វើអញ្ជលិកម្ម ចោមរោមប្រាសាទរបស់យើងនេះ ។ អំពើជាកុសលណាមួយ ដែលខ្ញុំគប្បីធ្វើដោយកាយវាចាចិត្ត (អំពើជាកុសលនោះ) ដែលខ្ញុំបានធ្វើហើយ ជាកុសលគួរដល់ការកើតក្នុងសុគតិក្នុងត្រៃត្រិង្ស ។ សត្វទាំងឡាយណា មានសញ្ញា និងសត្វទាំងឡាយណាមិនមានសញ្ញា សត្វទាំងអស់នោះ ចូរបាននូវចំណែកផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ សត្វទាំងឡាយណាបានដឹងច្បាស់នូវបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ សត្វទាំងនោះ (ចូរបានទទួល) នូវផលនៃបុណ្យដែលខ្ញុំឱ្យហើយ ម្យ៉ាងទៀត បណ្តាសត្វទាំងនោះ សត្វទាំងឡាយណាមិនបានដឹង សូមទេវតាទាំងឡាយអញ្ជើញទៅឱ្យដំណឹង (ដល់សត្វទាំងនោះ) ផង ។ សត្វទាំងអស់ណា ក្នុងលោកដែលអាស្រ័យអាហារហើយរស់នៅសត្វទាំងអស់នោះ ចូរបាននូវភោជនជាទីគាប់ចិត្តតាមចិត្តខ្ញុំចុះ ។ តថាគតបានឱ្យទានដោយចិត្ត តថាគតបានបណ្តុះនូវសេចក្តីជ្រះថ្លា ដោយចិត្តបានបូជាចំពោះព្រះសម្ពុទ្ធទាំងពួង បូជាចំពោះព្រះបច្ចេកពុទ្ធទាំងឡាយ ។ តថាគតលះបង់រាងកាយជារបស់មនុស្សហើយ ទៅកើតក្នុងឋានតាវត្តិង្ស ព្រោះកម្មដែលតថាគតធ្វើល្អនោះផង ព្រោះការតំកល់ទុកចេតនានោះផង ។ តថាគតស្គាល់ច្បាស់នូវភព

ទាំងពីរ គឺភពជារបស់ទេវតា ១ ជារបស់មនុស្ស ១ តថាគតមិនស្គាល់គតិដទៃឡើយ នេះជាផលនៃសេចក្តីប្រាថ្នាដោយចិត្ត ។ តថាគត បានជាបុគ្គលប្រសើរជាងទេវតាទាំងឡាយជាធំ ក្នុងពួកមនុស្សបរិបូណ៌ដោយរូបឆោមនិងលក្ខណៈ ឥតមានបុគ្គលស្មើដោយប្រាជ្ញា ។ ភោជនដ៏ប្រសើរផ្សេងៗផង កែវច្រើនយ៉ាងផង សំពត់មានបែបផ្សេងៗផង ក៏ធ្លាក់ចុះចាកអាកាស មកកាន់ទីជិតតថាគតឆាប់រហ័ស ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹកនិងព្រៃ អាហារទិព្វក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹកនិងព្រៃ កែវទាំងពួងក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹកនិងព្រៃ គ្រឿងក្រអូបទាំងពួងក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹកនិងព្រៃ យានទាំងពួង ក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាដៃ ក្នុងទីណា គឺ ផែនដី ភ្នំ អាកាស ទឹក និងព្រៃ កម្រងផ្កាទាំងពួង ក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាដៃ ក្នុងទីណា គឺ ផែនដី ភ្នំ អាកាស ទឹកនិងព្រៃ គ្រឿងអលង្ការទាំងឡាយ ក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាដៃក្នុងទីណា គឺ ផែនដី ភ្នំ អាកាស ទឹក និងព្រៃ ស្រ្តីកញ្ញាទាំងអស់ ក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគត លាដៃក្នុងទីណា គឺ ផែនដី ភ្នំ អាកាស ទឹកនិងព្រៃ ទឹកឃ្មុំ និងស្ករ ក៏មកដល់តថាគត (អំពីទីនោះ) ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹកនិងព្រៃ គ្រឿងបង្អែមគ្រប់យ៉ាង ក៏មកដល់តថាគត (អំពីទីនោះ) ។ ដើម្បីដល់នូវសម្ពោធិញ្ញាណដ៏ប្រសើរ តថាគតឱ្យនូវ

ទានដ៏ប្រសើរនោះ ដល់ជនអ្នកឥតទ្រព្យ (ជនអ្នកដំណើរ) យាចក និង អ្នកដើរតាមផ្លូវ ។ តថាគតញ៉ាំងភ្នំថ្ម ឱ្យលាន់ឮ ញ៉ាំងភ្នំដ៏ក្រាស់ឱ្យឮខ្ទរខ្ទារ ញ៉ាំងលោកព្រមទាំងទេវតាឱ្យរីករាយ ទើបបានជាព្រះពុទ្ធក្នុងលោក ។ ទីបំផុតនៃសត្វកាលទៅកាន់ទិសទាំង ១០ ក្នុងលោក មិនមានឡើយ ចំណែកខាងពុទ្ធក្ខេត្ត ក្នុងចំណែកនៃទិសនោះ គេមិនអាចរាប់បាន ។ ពន្លឺជាគ្រឿងនាំទៅនូវរស្មីទាំងគូប្រាកដ ហើយដល់តថាគត ពន្លឺគឺបណ្ដាញនៃរស្មីដ៏ធំទូលាយ ក៏កើតឡើងក្នុងចន្លោះនៃលោកធាតុនេះ ។ ចូរពួកជនទាំងអស់នេះ ក្នុងលោកធាតុឃើញនូវតថាគតចុះ ចូរពួកជនគ្រប់គ្នាមានចិត្តល្អចុះ ចូរពួកជនរាល់រូបប្រព្រឹត្តតាមតថាគតចុះ ។ តថាគតទូងស្គរ គឺ ព្រះនិព្វានឈ្មោះអមតៈ ដោយពាក្យដ៏ពីរោះប្រសើរក្រៃលែង ចូរពួកជនគ្រប់គ្នា ក្នុងលោកធាតុនេះ ស្ដាប់នូវសំឡេងដ៏ពីរោះចុះ ។ កាលបើតថាគតបង្អុរចុះ ដោយទឹកភ្លៀងគឺធម៌ ពួកជនគ្រប់គ្នាជាអ្នកមិនមានអាសវៈចុះ បណ្ដាសត្វទាំងនោះ ពួកសត្វណាមាននិស្ស័យជាន់ក្រោម ចូរពួកសត្វទាំងនោះ បានជាសោតាបន្នបុគ្គលចុះ ។ ព្រោះតថាគតឱ្យទានដែលគួរឱ្យបានបំពេញសីល ឥតមានសេសសល់ដល់នូវនេក្ខម្មបារមី ទើបបាននូវសម្ពោធិញ្ញាណដ៏ឧត្ដម ។ ព្រោះតថាគតបានប្រឹក្សានឹងពួកបណ្ឌិត ហើយធ្វើនូវវីរិយបារមីឱ្យខ្ពង់ខ្ពស់ដល់នូវខន្តិបារមី ទើបបាននូវសម្ពោធិញ្ញាណដ៏ឧត្ដម ។ ព្រោះតថាគតធ្វើអធិដ្ឋានបារមីឱ្យមាំមួន បំពេញនូវសច្ចបារមីដល់នូវមេត្តាបារមី ទើបបាននូវសម្ពោធិញ្ញាណដ៏ឧត្ដម ។ ព្រោះតថាគត ជាអ្នកមានចិត្តស្មើ ក្នុងលោកធម៌ទាំងអស់ គឺលាភ និងឥតលាភ សុខនិងទុក្ខ ការសរសើរ និងនិន្ទា ទើបបាននូវ

សម្មោធិញ្ញាណដ៏ឧត្តម ។ អ្នកទាំងឡាយ ចូរឃើញនូវកោសជ្ជៈ ថាជាភ័យផង ឃើញនូវវីរិយៈថាជាធម៌ក្សេមផង ហើយចូរជាអ្នកប្រារព្ធព្យាយាមឡើង នេះជាអនុសាសនីរបស់ព្រះពុទ្ធ ។ អ្នកទាំងឡាយ ចូរឃើញនូវវិវាទថា ជាភ័យផង ឃើញនូវការមិនវិវាទ ថាជាគុណដ៏ក្សេមផង ហើយចូរជាអ្នកព្រមព្រៀង ស្រុះស្រួលនឹងគ្នាចុះ នេះជាអនុសាសនីរបស់ព្រះពុទ្ធ ។ អ្នកទាំងឡាយ ចូរឃើញនូវបមាទៈ ថាជាភ័យផង ឃើញនូវអប្បមាទៈ ថាជាគុណដ៏ក្សេមផង ហើយចូរចម្រើនមគ្គមានអង្គ ៨ នេះ ជាអនុសាសនីរបស់ព្រះពុទ្ធ ។ ព្រះពុទ្ធ និង ព្រះអរហន្តច្រើនអង្គ បានមកជួបជុំដោយសព្វគ្រប់ហើយ អ្នកទាំងឡាយចូរថ្វាយបង្គំនមស្ការចំពោះព្រះសម្ពុទ្ធ និងព្រះអរហន្តចុះ ។ ព្រះពុទ្ធទាំងឡាយជាអចិន្តិយបុគ្គល (បុគ្គលដែលគេមិនគប្បីគិតកើត) ធម៌របស់ព្រះពុទ្ធជាអចិន្តិយធម៌ យ៉ាងនេះ កាលបុគ្គលជ្រះថ្លាចំពោះគុណជាអចិន្តិយៈ រមែងបានផលអចិន្តិយៈ ។

បានឮថា ព្រះមានព្រះភាគ កាលត្រាស់ដឹងនូវពុទ្ធចរិតរបស់ព្រះអង្គ ទើបសម្តែងនូវធម្មបរិយាយ ឈ្មោះ ពុទ្ធាបទាន ដោយប្រការដូច្នេះ ។

ចប់ ពុទ្ធាបទាន

បិដកលេខ៧២ ទំព័រ ១

## ២១ កិត្តិសព្ទរបស់ព្រះដ៏មានព្រះភាគ

**ឥតិបិ សោ ភគវា អរហំ ។ល ។ ពុទ្ធោ ភគវាតិ សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណី បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតិ ។**

ប្រែថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូរណ៍ដោយវិជ្ជានិងចរណៈ គឺសេចក្ដីចេះដឹងនិងក្រិតដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀតហើយ ព្រះអង្គបានត្រាស់ដឹងបានធ្វើឱ្យជាក់ច្បាស់ចំពោះព្រះអង្គ ហើយញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឱ្យបានត្រាស់ដឹងផង ហើយប្រកាស ទ្រង់សំដែងធម៌មានលម្អបទដើម បទកណ្ដាល និងបទចុង ទ្រង់ប្រកាសព្រហ្មចរិយធម៌ព្រមទាំងអត្ថៈនិងព្យញ្ជនៈដ៏ពេញបរិបូរណ៍ បរិសុទ្ធទាំងអស់ ក៏ការដែលបានឃើញបានជួបនូវព្រះអរហន្តទាំងឡាយ មានសភាព ដូច្នោះ ជាការប្រពៃពេក ។

ចប់កិត្តិសព្ទរបស់ព្រះដ៏មានព្រះភាគ

(បិដកលេខ១៤ទំព័រ២១៦)

## ២២ អធិប្បាយពាក្យថា ព្រះមានព្រះភាគ

(ព្រះសារីបុត្តមានអាយុ ពោលដូច្នេះថា) ក្នុងកាលមុនអំពីកាលនេះ ខ្ញុំមិនបានឃើញ ទាំងមិនបានឮ (អំពីសំណាក់) អ្នកណាមួយទេ ព្រះសាស្តា មានព្រះសូរសៀងដ៏ពីរោះយ៉ាងនេះ ទ្រង់ចុះចាកឋានតុសិតមកកាន់ពួក ។

ពាក្យថា ក្នុងកាលមុនអំពីកាលនេះ ខ្ញុំមិនបានឃើញ គឺក្នុងកាលមុនអំពីកាលនេះ ព្រះមានព្រះភាគអង្គនោះ ខ្ញុំមិនធ្លាប់ឃើញដោយចក្ខុនេះ ដោយអត្តភាពនេះទេ ។ កាលដែលព្រះមានព្រះភាគ គង់ចាំវស្សាលើថ្មបណ្ឌុកម្ពល ក្រោមម្លប់បារិឆ្ឆត្តព្រឹក្ស នាឋានតាវត្តិង្ស មានពួកទេវតាហែហម ទ្រង់យាងចុះកាន់ក្រុងសង្កស្សតាមជណ្តើរកែវត្រង់កណ្តាល ខ្ញុំមិនបានឃើញក្នុងកាលមុន វៀរលែងនូវការឃើញនេះ ។ ហេតុនោះ (លោកពោលថា) ក្នុងកាលមុន អំពីកាលនេះ ខ្ញុំមិនបានឃើញ ។

ពាក្យថា ព្រះសារីបុត្តមានអាយុ (ពោល) ថាដូច្នេះ ត្រង់ពាក្យថា ដូច្នេះ ជាពាក្យតបទ ភ្ជាប់បទ បំពេញបទ ប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះ នុ៎ះគឺជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជា ពាក្យគោរព (ពាក្យថា មានអាយុ នុ៎ះជាពាក្យប្រកបដោយសេចក្តីគោរពកោតក្រែង) ។ ពាក្យថា ព្រះសារីបុត្ត គឺជាឈ្មោះ ជាការរាប់ ជាពាក្យសំគាល់ ជាបញ្ញត្តិ ជាពាក្យហៅ ជានាម ជានាមកម្ម ជានាមបញ្ញត្តិ ជាសំដី ជាគ្រឿងបញ្ជាក់ ជាគ្រឿងប្រកាសរបស់ព្រះថេរនោះ ហេតុនោះ (លោកពោលថា) ព្រះសារីបុត្ត មានអាយុ ពោលដូច្នេះ ។

ពាក្យថា ទាំងមិនបានឮ អំពីសំណាក់អ្នកណាមួយទេ ត្រង់ពាក្យថា មិនជាពាក្យហាមឃាត់ ។ ពាក្យថា ទាំងជាពាក្យតបទ ភ្ជាប់បទ បំពេញបទ ប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា ទាំងនុ៎ះ គឺជាលំដាប់បទ ។ ពាក្យថា អ្នកណាមួយ គឺអ្នកណាមួយ ទោះក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សុទ្ទៈក្តី គ្រហស្ថក្តី បព្វជិតក្តី ទេវតាក្តី មនុស្សក្តី ហេតុនោះ (លោកពោលថា) ទាំងមិនបានឮអំពីសំណាក់អ្នកណាមួយទេ ។

ពាក្យថា ព្រះសាស្តាមានព្រះសូរសៀងពីរោះយ៉ាងនេះ អធិប្បាយថា ព្រះអង្គមានព្រះសូរសៀងពីរោះ សូរសៀងទន់ផ្អែម សូរសៀងគួរជាទីស្រឡាញ់ សូរសៀងជាទីគាប់ចិត្ត សូរសៀងពីរោះដូចសំឡេងសត្វករវិក យ៉ាងនេះ ។ ព្រះសូរសៀងដែលផ្សាយចេញចាកព្រះឱស្ឋរបស់ព្រះមានព្រះភាគនោះ ប្រកបដោយអង្គ ៨ គឺក្បោះក្បាយ ១ គប្បីដឹងបានដោយងាយ ១ ទន់ពីរោះ ១ ស្រួលស្តាប់ ១ មូល ១ មិនបែកព្រែក ១ ក្រអួន ១ លាន់រំពង ១ ។ កាលណា ព្រះមានព្រះភាគអង្គនោះ ទ្រង់ញុំាងបរិស័ទឱ្យដឹងដោយព្រះសូរសៀង ព្រះសូរសៀង ព្រះមានព្រះភាគអង្គនោះ មិនខ្ចាយចេញទៅខាងក្រៅអំពីបរិស័ទ ។ ព្រះមានព្រះភាគអង្គនោះ មានព្រះសូរសៀងដូចជាសំឡេងព្រហ្ម មានព្រះសូរសៀងដូចជាសំឡេងសត្វករវិក ហេតុនោះ លោកពោលថា ព្រះមានព្រះភាគ មានព្រះសូរសៀងពីរោះ យ៉ាងនេះ ។ ពាក្យថា ព្រះសាស្តា គឺព្រះមានព្រះភាគជាអ្នកនាំពួក ។ នាយពួកញុំាងពួកទាំងឡាយឱ្យឆ្លងផ្លូវលំបាក គឺឱ្យឆ្លងផ្លូវលំបាក គឺចោរ ឱ្យឆ្លងផ្លូវលំបាកគឺម្រឹគសាហាវ ឱ្យឆ្លងផ្លូវលំបាកគឺការអត់ឃ្លាន ឱ្យឆ្លង

ឱ្យឆ្លងឡើង ឱ្យឆ្លងចេញ ឱ្យឆ្លងផុតផ្លូវលំបាកគឺការមិនមានទឹក ឱ្យបានដល់ទីក្សេម យ៉ាងណាមិញ ព្រះមានព្រះភាគជាអ្នកនាំពួក តែងញុំាងពួកសត្វឱ្យឆ្លងផ្លូវលំបាក គឺឱ្យឆ្លងផ្លូវលំបាកគឺជាតិ ឱ្យឆ្លងផ្លូវលំបាកគឺជរា ឱ្យឆ្លងផ្លូវលំបាកគឺព្យាធិ ឱ្យឆ្លងផ្លូវលំបាក គឺមរណៈ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ឱ្យឆ្លងផ្លូវលំបាកគឺរាគៈ ឱ្យឆ្លងផ្លូវលំបាកគឺទោសៈ មោហៈ មានះ ទិដ្ឋិ ឱ្យឆ្លងឱ្យឆ្លងឡើង ឱ្យឆ្លងចេញ ឱ្យឆ្លងផុតនូវសេចក្ដីសាំញ៉ាំគឺកិលេស ឱ្យដល់ទីក្សេមគឺអមតនិព្វានក៏យ៉ាងនេះដែរ ហេតុនោះ ព្រះមានព្រះភាគជា អ្នកនាំពួកយ៉ាងនេះខ្លះ ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់ទូន្មាន ណែនាំ ប្រៀនប្រដៅឱ្យស្គាល់ ឱ្យចាក់ធ្លុះ ឱ្យសំឡឹងមើល ឱ្យជ្រះថ្លា ហេតុនោះ ព្រះមានព្រះភាគជាអ្នកនាំពួក យ៉ាងនេះខ្លះ ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់ធ្វើមគ្គ ដែលមិនទាន់កើត ឱ្យកើតឡើង ទ្រង់ធ្វើមគ្គដែលមិនទាន់កើតឱ្យកើតព្រម ទ្រង់ប្រាប់មគ្គដែលមិនទាន់បានប្រាប់ ជាអ្នកដឹងនូវមគ្គជ្រាបច្បាស់នូវមគ្គ ឈ្លាសក្នុងមគ្គ។ ឯពួកសាវ័ក ឥឡូវនេះ ជាអ្នកដើរតាមមគ្គ ជាអ្នកប្រកបតាមក្រោយ ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថា ជាអ្នកនាំពួក យ៉ាងនេះខ្លះ (លោក ពោលថា) ព្រះសាស្ដា មានព្រះសូរសៀងពីរោះ យ៉ាងនេះឯង ។

ពាក្យថា ចុះចាកឋានតុសិត មកកាន់ពួក អធិប្បាយថា ព្រះមានព្រះភាគចុះចាកកាយតុសិត ស្ដេចមកកាន់ផ្ទៃមាតា ទាំងមានស្មារតីដឹងច្បាស់ ហេតុនោះលោកហៅថា តុសិត ។ ពួកទេវតាទាំងនោះ ជាអ្នកត្រេកអរ ត្រេកអរព្រមពេញចិត្ត មានបីតិនិងសោមនស្ស ព្រះសាស្ដាចុះចាកឋានតុសិត ទេវលោក មក

កាន់ពួក ហេតុនោះ (លោកពោលថា) ចុះចាកឋានតុសិត មកកាន់ពួក យ៉ាងនេះខ្លះ ។ មួយវិញទៀត ព្រះអរហន្តទាំងឡាយ លោកពោលថា តុសិត ។ ព្រះអរហន្តទាំងនោះ ជាអ្នកត្រេកអរ ត្រេកអរព្រមពេញចិត្ត រីករាយ មានបីតិនិងសោមនស្ស ព្រះមានព្រះភាគ ស្តេចមកកាន់ពួកព្រះអរហន្តទាំងឡាយ ហេតុនោះ (លោកពោលថា) ចុះចាកឋានតុសិត មកកាន់ពួក យ៉ាងនេះខ្លះ ។ ព្រះមានព្រះភាគឈ្មោះថា មានពួក ព្រោះមានពួក ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក ព្រោះជាអាចារ្យនៃពួក ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក ព្រោះជាសាស្តានៃពួក ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក ព្រោះទ្រង់រក្សាពួក ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក ព្រោះទ្រង់ទូន្មានពួក ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក ព្រោះទ្រង់ប្រៀនប្រដៅពួក ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក ព្រោះទ្រង់អង់អាចចូលទៅរកពួក ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក ព្រោះតែងស្តាប់ដោយគោរព (នូវពាក្យ) នៃព្រះមានព្រះភាគនោះ ផ្ទៀងសោតៈស្តាប់ដំកល់ទុកនូវចិត្តដើម្បីដឹង ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក ព្រោះទ្រង់ញុំាងពួក ឱ្យក្រោកចេញអំពីអកុសលធម៌ ហើយឱ្យតាំងនៅក្នុងកុសលធម៌ ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួករបស់ពួកនៃភិក្ខុ ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួករបស់ពួកនៃភិក្ខុនី ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួករបស់ពួកនៃឧបាសក ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួករបស់ពួកនៃឧបាសិកា ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួករបស់ពួកនៃព្រះរាជា ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួករបស់ពួកនៃក្សត្ររបស់ពួក

នៃព្រាហ្មណ៍ របស់ពួកនៃវេស្សៈ របស់ពួកនៃសុទ្ទៈ របស់ពួកនៃទេវតា របស់ពួកនៃព្រហ្ម ។ ព្រះមានព្រះភាគ មានសង្ឃ មានគណៈ ជាគណាចារ្យ បានស្តេចមកចូលទៅជិត ចូលទៅជិតព្រម បានដល់នូវសង្កស្សនគរ ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគចុះចាកឋានតុសិតមកកាន់ពួក ។ ហេតុនោះ ព្រះសារីបុត្តត្ថេរ ពោលថា

(ព្រះសារីបុត្តមានអាយុ ពោលដូច្នេះថា) ក្នុងកាលមុនអំពីកាលនេះ ខ្ញុំមិនបានឃើញ ទាំងមិនបានឮ (អំពីសំណាក់) អ្នកណាមួយទេ ព្រះសាស្តា មានព្រះសូរសៀងពីរោះ យ៉ាងនេះ ទ្រង់ចុះចាកឋានតុសិត មកកាន់ពួក ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ប្រាកដដល់លោក ព្រមទាំងទេវលោក ទ្រង់កំចាត់បង់នូវងងឹត ទាំងពួង តែមួយអង្គឯង បានដល់នូវសេចក្តីត្រេកអរ ។

ពាក្យថាដល់លោក ព្រមទាំងទេវលោក គឺដល់លោក ព្រមទាំងទេវលោក ព្រមទាំងមារលោក ព្រមទាំងព្រហ្មលោក ដល់ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំង មនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហេតុនោះ (លោកពោលថា) ដល់លោក ព្រមទាំងទេវលោក ។

ពាក្យថា ទ្រង់មានចក្ខុ ប្រាកដ អធិប្បាយថា ពួកទេវតាឃើញព្រះមានព្រះភាគ កាលគង់លើថ្មបណ្ឌុកម្ពល ក្រោមម្លប់បារិច្ឆត្តព្រឹក្ស នាឋានតាវត្តិង្ស ទ្រង់សំដែងធម៌ យ៉ាងណា ពួកមនុស្សក៏រមែង ឃើញយ៉ាងនោះ ។ មនុស្សទាំងឡាយឃើញយ៉ាងណា ពួកទេវតាឃើញយ៉ាងនោះ ។ ព្រះមានព្រះភាគ ប្រាកដដល់មនុស្សយ៉ាងណា ប្រាកដដល់ពួកទេវតាយ៉ាងនោះ ហេតុនោះ (លោកពោល

ថា) មានចក្ខុប្រាកដ យ៉ាងនេះខ្លះ ។ មួយទៀត ពួកសមណព្រាហ្មណ៍ដ៏ចម្រើនទុំះ ដែលមានចិត្តមិនទាន់ទូន្មានទេ ប្រាកដដោយភេទនៃអ្នកមានចិត្តទូន្មាន មានចិត្តមិនទាន់រម្ងាប់ទេ ប្រាកដដោយភេទនៃអ្នកមានចិត្តរម្ងាប់ មានចិត្តមិនទាន់ស្ងប់ស្ងាត់ទេ ប្រាកដដោយភេទនៃអ្នកមានចិត្តស្ងប់ស្ងាត់ មិនទាន់មានទុក្ខរលត់ទេ ប្រាកដ ដោយភេទនៃអ្នកមានទុក្ខរលត់ យ៉ាងណាមិញ ។

ពួកសមណព្រាហ្មណ៍ដែលមានបរិវារហែហម មិនមានសេចក្តីបរិសុទ្ធខាងក្នុងមានលំអខាងក្រៅ ត្រេចទៅក្នុងលោក ដូចជាកុណ្ឌលដែលធ្វើអំពីដីស្អិត មានសភាពដ៏សមគួរ ឬ ដូចជាមាសកៈទង់ដែងដែលក្រឡៃមាស (យ៉ាងណាមិញ) ។

ចំណែកព្រះមានព្រះភាគ មិនប្រាកដយ៉ាងនោះទេ ។ ព្រះមានព្រះភាគទ្រង់មានព្រះទ័យទូន្មានហើយ ប្រាកដដោយភេទនៃអ្នកមានចិត្តទូន្មាន ទ្រង់មានព្រះទ័យរម្ងាប់ហើយ ប្រាកដដោយភេទនៃអ្នកមានចិត្តរម្ងាប់ ទ្រង់មានព្រះទ័យរម្ងាប់ហើយ ប្រាកដដោយភេទនៃអ្នកមានចិត្តស្ងប់រម្ងាប់ ទ្រង់មានទុក្ខរលត់ហើយ ប្រាកដដោយភេទនៃអ្នកមានទុក្ខរលត់ហើយ ដោយពិតប្រាកដទៀងទាត់មិនប្រែប្រួល មិនវិបរិតពិតមែន ។ មួយទៀត ព្រះពុទ្ធទាំងឡាយ មានព្រះភាគមានព្រះឥរិយាបថមិនបានញាប់ញ័រ សឹងបរិបូរណ៍ដោយសេចក្តីប្រាថ្នា ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគ មានចក្ខុប្រាកដយ៉ាងនេះខ្លះ ។ មួយទៀត ព្រះមានព្រះភាគ ព្រះអង្គមានកិត្តិសព្ទដ៏បរិសុទ្ធ មានកិត្តិសព្ទនឹងសេចក្តីសរសើរដ៏ពោរពេញក្នុងភពនៃនាគផង ក្នុងភពនៃគ្រុឌផង ក្នុងភពនៃយក្ខផង ក្នុងភពនៃអសុរផង ក្នុងភពនៃគន្ធព្វផង ក្នុងភពនៃមហារាជផង ក្នុងភពនៃព្រះឥន្ទផង ក្នុង

ភពនៃព្រហ្មផង គឺថា ព្រះអង្គមានកិត្តិសព្ទនិងសេចក្ដីសរសើរ ប្រាកដបែបនេះផង ប្រាកដបែបនោះផង លើសលប់ជាងនោះផង ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគ មានចក្ខុប្រាកដ យ៉ាងនេះខ្លះ ។ មួយទៀត ព្រះមានព្រះភាគ ព្រះអង្គប្រកបដោយកំឡាំង ១០ តែងប្រាកដជាក់លាក់ដោយវេសារជ្ជញ្ញាណ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ តេជៈ ១ ពលៈ ១ គុណ ១ វីរិយៈ ១ បញ្ញា ១ ។ សប្បុរសទាំងឡាយ រមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមវន្ត អសប្បុរសទាំងឡាយមិនប្រាកដ ក្នុងទីឆ្ងាយនោះបានទេ ដូចជាសរដែលគេបាញ់ទៅក្នុងពេលយប់ ។ ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគ មានចក្ខុប្រាកដ យ៉ាងនេះខ្លះ ។

ពាក្យថា ទ្រង់មានចក្ខុ សេចក្ដីថា ព្រះមានព្រះភាគ មានចក្ខុដោយចក្ខុ ៥ គឺ មានចក្ខុដោយមំសចក្ខុ ១ មានចក្ខុដោយទិព្វចក្ខុ ១ មានចក្ខុដោយបញ្ញាចក្ខុ ១ មានចក្ខុដោយពុទ្ធចក្ខុ ១ មានចក្ខុ ដោយសមន្តចក្ខុ ១ ។

ព្រះមានព្រះភាគ មានចក្ខុដោយមំសចក្ខុ តើដូចម្ដេច ។ ក្នុងមំសចក្ខុរបស់ព្រះមានព្រះភាគ មានសម្បុរ ៥ គឺ សម្បុរខៀវ ១ សម្បុរលឿង ១ សម្បុរក្រហម ១ សម្បុរខ្មៅ ១ សម្បុរស ១ ។ រោមព្រះនេត្ររបស់ព្រះមានព្រះភាគតាំងនៅទ្រង់ទីណា ទីនោះមានសម្បុរខៀវ ខៀវស្រងាត់ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាកណ្ណិការ ។ រណ្ដៅព្រះនេត្រទាំងពីរខាងរបស់ព្រះមានព្រះភាគ មានសម្បុរ ក្រហម ក្រហមឆ្អៅ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងអណ្ដើកមាស ។ ត្រង់កណ្ដាល មានសម្បុរខ្មៅ ខ្មៅស្រិល មិនមានសៅហ្មង

យ៉ាងស្និទ្ធ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្លែផ្កាំ ។ ក្រៅអំពីនោះ មាន សម្បុរស សសុទ្ធ សក្បុះ សត្រសុះ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាយព្រឹក ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញជុំវិញចម្ងាយ ១ យោជន៍ ទាំងយប់ទាំងថ្ងៃ ដោយព្រះមំសចក្ខុតាមប្រក្រតីនោះ ដែលកើតអំពីសុចរិតកម្មក្នុងកាលមុនរាប់ទាំងអត្តភាពផង ។ ទោះបីងងឹតប្រកបដោយអង្គ ៤ គឺ ព្រះអាទិត្យអស្តង្គត ១ ថ្ងៃឧបោសថជាចំណែកខាងរនោច ១ ដងព្រៃជិតស្ទិប ១ ភ្លៀងធំខុសកាលតាំងឡើង ១ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញជុំវិញចម្ងាយ ១ យោជន៍ ក្នុងទីងងឹតប្រកបដោយអង្គ ៤ សូម្បីមានសភាពយ៉ាងនេះ ។ ព្រះអង្គមិនមានជញ្ជាំង ឬ សន្ទះទ្វារ កំផែង ឬ ភ្នំ គុម្ពឈើ ឬ វល្លិ ជាគ្រឿងរាំងនូវកិរិយាឃើញរូបទាំងឡាយទេ ។ បើទុកជាគេដាក់គ្រាប់ល្ង ១គ្រាប់ ក្នុងរទេះពេញដោយល្ង ធ្វើឱ្យជាគ្រឿងចំណាំ ក៏នៅតែព្រះមានព្រះភាគ ទ្រង់រើសយកគ្រាប់ល្ងនោះបានវិញដដែល ។ ព្រះមំសចក្ខុ ជាប្រក្រតីរបស់ព្រះមានព្រះភាគបរិសុទ្ធយ៉ាងនេះឯង ។ ព្រះមានព្រះភាគ មានចក្ខុដោយមំសចក្ខុ យ៉ាងនេះ ។

ព្រះមានព្រះភាគ មានចក្ខុដោយទិព្វចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគទ្រង់មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងផុតចក្ខុរបស់មនុស្ស ទ្រង់ទតឃើញពួកសត្វ កំពុងច្យុត កំពុងកើតជាសត្វថោកទាប ឧត្តម មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានដំណើរល្អ មានដំណើរអាក្រក់ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ ពួកសត្វដ៏ចម្រើនទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត តិះដៀលព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ កាន់

យកអំពើនៃមិច្ឆាទិដ្ឋិ ពួកសត្វនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ ក៏ទៅកើតក្នុងអបាយទុគ្គតិ វិនិបាតនរក ម្យ៉ាងទៀត ពួកសត្វដ៏ចម្រើននេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀលព្រះអរិយៈ ជាសម្មាទិដ្ឋិ កាន់យកអំពើនៃសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ ក៏ទៅកើតក្នុងសុគតិសួគ៌ ទេវលោក ព្រះមានព្រះភាគទ្រង់មានចក្ខុ ដូចជាទិព្វដ៏បរិសុទ្ធ កន្លងផុតចក្ខុរបស់មនុស្ស ទ្រង់ឃើញពួកសត្វដែលកំពុងច្យុត កំពុងកើតជាសត្វថោកទាបឧត្តម មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានដំណើរល្អ មានដំណើរអាក្រក់ ទ្រង់ជ្រាបនូវពួកសត្វដែលអន្ទោលទៅតាមកម្ម យ៉ាងនេះ ។ មួយទៀត ព្រះមានព្រះភាគ កាលបើចង់ឃើញគប្បីឃើញលោកធាតុ ១ ខ្លះ ឃើញលោកធាតុ ២ ខ្លះ ឃើញលោកធាតុ ៣ ខ្លះ ឃើញលោកធាតុ ៤ ខ្លះ ឃើញលោកធាតុ ៥ ខ្លះ ឃើញលោកធាតុ ១០ ខ្លះ ឃើញលោកធាតុ ២០ ខ្លះ ឃើញលោកធាតុ ៣០ ខ្លះ ឃើញលោកធាតុ ៤០ ខ្លះ ឃើញលោកធាតុ ៥០ ខ្លះ ឃើញលោកធាតុតូច ១ ពាន់ខ្លះ ឃើញលោកធាតុជាកណ្តាល ១ពាន់ ២ ជាន់ខ្លះ (១លាន) ឃើញលោកធាតុ ១ ពាន់ ៣ជាន់ខ្លះ (១០០កោដិ) ឃើញលោកធាតុច្រើនពាន់ខ្លះ ។ ព្រះមានព្រះភាគ អង្គនោះទ្រង់ប្រាថ្នាត្រឹមណា គប្បីទតឃើញត្រឹមនោះ ។ ទិព្វចក្ខុរបស់ព្រះមានព្រះភាគបរិសុទ្ធ យ៉ាងនេះ ។ ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ដោយទិព្វចក្ខុយ៉ាងនេះ ។

ព្រះមានព្រះភាគ មានចក្ខុដោយបញ្ញាចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ មានបញ្ញាច្រើន មានបញ្ញាក្រាស់ មានបញ្ញារីករាយ មានបញ្ញារហ័ស មាន

បញ្ញាក្លាហាន មានបញ្ញាទំលាយបង់នូវកិលេស ឈ្លាសក្នុងប្រភេទនៃបញ្ញា មានញាណបែកធ្លាយ បានសម្រេចបដិសម្ភិទា បានសម្រេចចតុវេសារជ្ជញ្ញាណ ទ្រទ្រង់នូវកម្លាំង ១០ ជាបុរសដ៏ប្រសើរ ជាសីហបុរស ជានាគបុរសជាអាជញ្ញបុរស ជាបុរសអ្នកនាំនូវធុរៈ មានញាណមិនមានទីបំផុត មានតេជៈមិនមានទីបំផុត មានយសមិនមានទីបំផុត ស្តុកស្តម្ភ មាំមួន មានទ្រព្យ ទ្រង់ទូន្មាន ណែនាំប្រៀនប្រដៅឱ្យស្គាល់ ឱ្យចាក់ធ្លុះ ឱ្យប្រាថ្នា ឱ្យជ្រះថ្លា ។ ព្រោះព្រះមានព្រះភាគអង្គនោះ ទ្រង់ញ៉ាំងមគ្គដែលមិនទាន់កើត ឱ្យកើតឡើង ទ្រង់ញ៉ាំងមគ្គដែលមិនទាន់កើតឡើងព្រម ឱ្យកើតឡើងព្រម ទ្រង់ប្រាប់មគ្គដែលមិនទាន់បានប្រាប់ ជាអ្នកដឹងនូវមគ្គ ឈ្លាសវៃក្នុងមគ្គ ។ ឯពួកសាវ័កក្នុងកាលឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវ មកតាមក្រោយ ។ ព្រោះថា ព្រះមានព្រះភាគនោះ ទ្រង់ជ្រាបហេតុដែលគួរជ្រាប ទ្រង់ឃើញហេតុដែលគួរឃើញ ទ្រង់មានចក្ខុ មានធម៌ មានញាណ មានភាពដ៏ប្រសើរទ្រង់ពោលសំដែងបង្អោននូវប្រយោជន៍ជាអ្នកឱ្យនូវព្រះនិព្វាន ជាម្ចាស់ហេតុធម៌ ជាព្រះតថាគត ។ ហេតុណាមួយ ដែលព្រះមានព្រះភាគនោះ មិនជ្រាប មិនឃើញ មិនជាក់ច្បាស់ មិនធ្វើឱ្យប្រាកដ មិនពាល់ត្រូវដោយបញ្ញា មិនដែលមានទេ ។ ធម៌ទាំងអស់រាប់ទាំងអតីត អនាគត បច្ចុប្បន្ន រមែងមកកាន់គន្លងចំមុខព្រះញាណនៃព្រះពុទ្ធដ៏មានព្រះភាគ ដោយអាការៈទាំងពួង ។ ឈ្មោះថាវត្ថុណាមួយដែលត្រូវយល់ ត្រូវដឹងប្រយោជន៍ខ្លួនក្តី ប្រយោជន៍អ្នកដ៏ទៃក្តី ប្រយោជន៍ទាំងពីរក្តី ប្រយោជន៍ជាបច្ចុប្បន្នក្តី ប្រយោជន៍ក្នុងលោកខាងមុខក្តី ប្រយោជន៍រាក់ក្តី ប្រយោជន៍ជ្រៅក្តី ប្រយោជន៍លាក់ក្តី

ប្រយោជន៍កំបាំងក្តី ប្រយោជន៍ដែលត្រូវណែនាំក្តី ប្រយោជន៍ដែលបាននាំចេញស្រាប់ហើយក្តី ប្រយោជន៍មិនមានទោសក្តី ប្រយោជន៍មិនមានកិលេសក្តី ប្រយោជន៍ដ៏ផូរផង់ក្តី ប្រយោជន៍សំខាន់ក្តី ទាំងអស់នោះ រមែងប្រព្រឹត្តទៅខាងក្នុងនៃពុទ្ធញ្ញាណ ។ ព្រះពុទ្ធមានព្រះភាគ មានព្រះញាណ មិនទើសទាក់ក្នុងអតីត មានព្រះញាណមិនទើសទាក់ក្នុងអនាគត មានព្រះញាណមិនទើសទាក់ក្នុងបច្ចុប្បន្ន ។ កាយកម្មទាំងអស់ ប្រព្រឹត្តទៅតាមព្រះញាណរបស់ព្រះពុទ្ធ មានព្រះភាគ វចីកម្មទាំងអស់ មនោកម្មទាំងអស់ ប្រព្រឹត្តទៅតាមព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ។ ហេតុដែលត្រូវដឹងមានត្រឹមណា ព្រះញាណក៏មានត្រឹមនោះ ព្រះញាណមានត្រឹមណា ហេតុដែលត្រូវដឹងក៏មានត្រឹមនោះ ព្រះញាណមានហេតុដែលត្រូវដឹងជាទីបំផុត ហេតុដែលត្រូវដឹងក៏មានញាណជាទីបំផុត ព្រះញាណមិនប្រព្រឹត្តកន្លង ហេតុដែលត្រូវដឹងគន្លងដែលត្រូវដឹង ប្រព្រឹត្តកន្លងព្រះញាណក៏មិនមានធម៌ទាំងនោះ រមែងឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ ផ្ទៃស្មុគ្រទាំងពីរដែលស្និទ្ធស្នាលគ្នាល្អ ផ្ទៃស្មុគ្រខាងក្រោម មិនប្រព្រឹត្តហួសផ្ទៃស្មុគ្រខាងលើ ផ្ទៃស្មុគ្រខាងលើមិនហួសផ្ទៃស្មុគ្រខាងក្រោម ផ្ទៃស្មុគ្រទាំងពីរ រមែងឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា យ៉ាងណាមិញ ហេតុដែលត្រូវដឹងមានត្រឹមណា ព្រះញាណក៏មានត្រឹមនោះ ព្រះញាណមានត្រឹមណា ហេតុដែលត្រូវដឹងក៏មានត្រឹមនោះ ព្រះញាណ មានហេតុដែលត្រូវដឹងជាទីបំផុត ហេតុដែលត្រូវដឹងក៏មានព្រះញាណជាទីបំផុត ព្រះញាណមិនប្រព្រឹត្តកន្លង ហេតុដែលត្រូវដឹងគន្លងដែលត្រូវដឹង ប្រព្រឹត្តកន្លង ព្រះញាណក៏មិនមានធម៌ទាំងនោះ រមែងតាំងនៅក្នុងទី

បំផុតនៃគ្នានឹងគ្នា ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ប្រព្រឹត្តទៅក្នុងធមិទាំងពួង ។ ធមិទាំងពួង ជាប់ដោយការពិចារណា ជាប់ដោយសេចក្តីប្រាថ្នា ជាប់ដោយការធ្វើទុកក្នុងចិត្ត ជាប់ដោយចិត្តុប្បាទនៃព្រះពុទ្ធមានព្រះភាគ ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ប្រព្រឹត្តទៅក្នុងពួកសត្វទាំងពួង ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបអធ្យាស្រ័យ ជ្រាបអនុស័យ ជ្រាបចរិត ជ្រាបនូវអធិមុត្តិនៃសត្វទាំងពួង ជ្រាបច្បាស់នូវសត្វទាំងឡាយ ដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយ ក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការៈល្អ មានអាការៈអាក្រក់ ឱ្យដឹងបានដោយងាយ ឱ្យដឹងបានដោយកម្រ ជាសត្វគួរនិងមិនគួរត្រាស់ដឹង ។ លោកព្រមទាំងទេវលោក ព្រមទាំងមារ ព្រមទាំងព្រហ្មពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស រមែងប្រព្រឹត្តទៅក្នុងពុទ្ធញ្ញាណ ។ ហ្វូងត្រីនិងអណ្តើកណានីមួយ ដោយហោចទៅរាប់តាំងពីត្រី ឈ្មោះ តិមិ និងត្រីឈ្មោះ តិមិង្គលៈ ប្រព្រឹត្តទៅក្នុងខាងក្នុងមហាសមុទ្រ យ៉ាងណា លោកព្រមទាំងទេវលោក ព្រមទាំងមារ ព្រមទាំងព្រហ្ម ពួកសត្វ ព្រមទាំង សមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក៏ប្រព្រឹត្តទៅខាងក្នុងពុទ្ធញ្ញាណក៏ យ៉ាងនោះឯង ។ ពួកបក្សីណាមួយ ដោយហោចទៅរាប់តាំងពីគ្រុឌឈ្មោះវេនតេយ្យ ប្រព្រឹត្តទៅក្នុងប្រទេសនៃអាកាស យ៉ាងណា ពួកជនណាមានបញ្ញាស្មើនឹងព្រះសារីបុត្ត សូម្បីជនទាំងនោះ ក៏ប្រព្រឹត្តទៅក្នុងប្រទេសនៃពុទ្ធញ្ញាណ យ៉ាងនោះឯង ។ ពុទ្ធញ្ញាណផ្សាយគ្រប់នូវបញ្ញានៃទេវតា និង មនុស្សទាំងឡាយហើយឋិតនៅ ។ ពួកជនណាមួយ

ជាខត្តិយបណ្ឌិតក្តី ព្រាហ្មណ៏បណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី ជាបណ្ឌិតមានប្រាជ្ញាល្អិត មានបរប្បវាទធ្វើហើយ មានសភាពដូចជាខ្នាន់ធ្នូអ្នកបាញ់រោមកន្ទុយ អាចទំលាយនូវទិដ្ឋិទាំងឡាយដោយប្រាជ្ញាបាន ពួកជនទាំងនោះក៏តាក់តែងរៀបចំនូវបញ្ហា ហើយចូលទៅសួរព្រះតថាគត ។ បញ្ហាទាំងនោះព្រះមានព្រះភាគ ទ្រង់សំដែងទាំងដោះស្រាយហើយ ជាប្រស្នាដែលព្រះមានព្រះភាគគួរសំដែងចេញនូវហេតុទាំងជាប្រស្នាដែលព្រះអង្គគួរបញ្ឈប់ទុក ។ ជនទាំងនោះ នាំគ្នាចុះចូលព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់រុងរឿងក្នុងទីប្រជុំនោះ ដោយបញ្ញា ព្រះមានព្រះភាគ មានចក្ខុដោយបញ្ញាចក្ខុយ៉ាងនេះ ។

ព្រះមានព្រះភាគ មានចក្ខុ ដោយពុទ្ធចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលសត្វលោក ដោយពុទ្ធចក្ខុ បានឃើញនូវសត្វទាំងឡាយមានធូលីស្រាលស្តើងក្នុងភ្នែក មានធូលីក្រាស់ក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការៈល្អ មានអាការៈអាក្រក់ ជាសត្វឱ្យដឹងបានដោយងាយឱ្យដឹងបានដោយកម្រនូវសត្វពួកខ្លះ ជាអ្នកឃើញទោសក្នុងបរលោកថា គួរខ្លាច ។ ដូចជលជាតពួកខ្លះ គឺព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ក្នុងត្រពាំងព្រលិតក្តី ក្នុងត្រពាំងឈូកក្រហមក្តី ក្នុងត្រពាំង ឈូកសក្តី ដុះក្នុងទឹក ចម្រើនក្នុងទឹក លូតតាមទឹក លិចចុះខាងក្នុងដែលទឹកចិញ្ចឹមហើយ ផ្កាជលជាតពួកខ្លះ គឺព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះក្នុងទឹក ចម្រើនក្នុងទឹក ឋិតនៅស្មើនឹងទឹក ជលជាតពួកខ្លះ គឺ ព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះក្នុងទឹក ចម្រើនក្នុងទឹក ឋិតផុត

ពីទឹក មិនទទឹកដោយទឹក យ៉ាងណា ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ទតឃើញនូវសត្វទាំងឡាយ ដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការៈល្អ មានអាការៈអាក្រក់ ជាសត្វឱ្យដឹងបានដោយងាយ ឱ្យដឹងបានដោយកម្រនូវសត្វពួកខ្លះ ជាអ្នកឃើញទោសក្នុងបរលោកថា គួរខ្លាច ក៏យ៉ាងនោះឯង ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា បុគ្គលនេះជារាគចរិត នេះជាទោសចរិត នេះជាមោហចរិត នេះជាវិតក្កចរិត នេះជាសទ្ធាចរិត នេះជាញាណចរិត ។ ព្រះមានព្រះភាគ ទ្រង់សំដែងអសុភកថាដល់បុគ្គលជារាគចរិត ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់មេត្តាភាវនាដល់បុគ្គលជាទោសចរិត ។ ព្រះមានព្រះភាគ ទ្រង់ញ៉ាំងបុគ្គលជាមោហចរិត ឱ្យតាំងនៅក្នុងឧទ្ទេស (ការរៀនបាលី) ក្នុងបរិបុច្ឆា (ការរៀនអដ្ឋកថា) ក្នុងការស្តាប់ធម៌តាមកាល ក្នុងការសន្ទនាគ្នាទៅវិញទៅមកនូវធម៌តាមកាល ក្នុងការនៅជាមួយនឹងគ្រូ ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់អានាបានស្សតិដល់បុគ្គលជាវិតក្កចរិត ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់និមិត្តដែលគួរជ្រះថ្លា គឺការត្រាស់ដឹងដ៏ប្រពៃនៃព្រះពុទ្ធ ការទ្រទ្រង់ល្អនៃព្រះធម៌ សេចក្តីប្រតិបត្តិល្អនៃព្រះសង្ឃ នឹងសីលទាំងឡាយសម្រាប់ខ្លួនដល់បុគ្គលជាសទ្ធាចរិត ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់នូវវិបស្សនានិមិត្ត គឺអាការៈមិនទៀង អាការៈ ជាទុក្ខ អាការៈមិនមែនខ្លួនដល់បុគ្គលជាញាណចរិត ។ បុគ្គលឈរលើកំពូលភ្នំថ្ម គប្បីឃើញប្រជុំជនដោយជុំវិញ យ៉ាងណាមិញ បពិត្រព្រះអង្គមានប្រាជ្ញាល្អ មានសមន្តចក្ខុ ព្រះអង្គមានសេចក្តីសោកទៅប្រាសហើយ សូមទ្រង់យាងឡើងកាន់

ប្រាសាទគឺធម៌ ហើយទតមើលប្រជុំជន ដែលខ្វល់ដោយសេចក្ដីសោក ត្រូវជាតិ និងជរាគ្របសង្កត់ ក៏យ៉ាងនោះឯង ។ ព្រះមានព្រះភាគ មានចក្ខុដោយពុទ្ធចក្ខុយ៉ាងនេះ ។

ព្រះមានព្រះភាគ មានចក្ខុដោយសមន្តចក្ខុ តើដូចម្ដេច ។ ព្រះសព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគ ទ្រង់ចូល ចូលព្រមទៅជិត ជិតព្រម ដល់ ដល់ព្រម ប្រកបដោយព្រះ សព្វញ្ញុតញ្ញាណ ។

ហេតុនីមួយក្នុងលោកនេះ ដែលព្រះមានព្រះភាគ ទ្រង់មិនឃើញ ឬ ថា មិនទ្រង់ជ្រាប មិនគួរជ្រាប មិនមានទេ ហេតុណា ដែលត្រូវដឹង ព្រះមានព្រះភាគ ទ្រង់ជ្រាបហេតុនោះទាំងអស់ ព្រោះហេតុនោះ ព្រះតថាគតទើបឈ្មោះថា សមន្តចក្ខុ ។

ព្រះមានព្រះភាគ មានចក្ខុដោយសមន្តចក្ខុ យ៉ាងនេះ ហេតុនោះ (លោកពោលថា) ព្រះមាន ព្រះភាគ មានចក្ខុប្រាកដ ។

ពាក្យថា កំចាត់បង់នូវងងឹតទាំងពួង គឺទ្រង់បន្សាត់លះបង់ បន្ទោបង់ ធ្វើឱ្យវិនាស មិនឱ្យដល់នូវភាវៈ មិនមានបែបភាពនូវងងឹតគឺរាគៈ ងងឹតគឺទោសៈ ងងឹតគឺមោហៈ ងងឹតគឺមានះ ងងឹតគឺទិដ្ឋិ ងងឹត គឺកិលេស ងងឹតគឺទុច្ចរិត គ្រឿងធ្វើឱ្យងងឹត គ្រឿងធ្វើមិនឱ្យមានបញ្ញាចក្ខុ គ្រឿងធ្វើមិនឱ្យមានញាណ ជាគ្រឿងរលត់បញ្ញា ជាចំណែកនៃការបៀតបៀន ដែលមិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ហេតុនោះ (លោកពោលថា) កំចាត់បង់នូវងងឹតទាំងពួង ។

ពាក្យថា ដល់នូវការត្រេកអរតែមួយព្រះអង្គឯង អធិប្បាយថា ព្រះមាន

ព្រះភាគ មួយព្រះអង្គឯង ដោយចំណែកបព្វជ្ជា មួយព្រះអង្គឯងដោយសេចក្ដីថា មិនមានបុគ្គលជាទីពីរ មួយព្រះអង្គឯង ដោយអត្ថថា លះបង់តណ្ហា មួយព្រះអង្គឯង ព្រោះព្រះអង្គប្រាសចាករាគៈដោយចំណែកមួយ ព្រោះព្រះអង្គ ប្រាសចាកទោសៈដោយចំណែកមួយ មួយព្រះអង្គឯង ព្រោះព្រះអង្គប្រាសចាកមោហៈដោយចំណែកមួយ មួយព្រះអង្គឯង ព្រោះព្រះអង្គមិនមានកិលេសដោយចំណែកមួយ មួយព្រះអង្គឯង ព្រោះព្រះអង្គយាង ទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង មួយព្រះអង្គឯង ព្រោះព្រះអង្គតែម្នាក់ឯង ទ្រង់ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិ ហេតុនោះ (លោកពោលថា) តែមួយព្រះអង្គឯង ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ដោយចំណែកបព្វជ្ជានោះ តើដូចម្ដេច ។ ព្រះមានព្រះភាគ កាលនៅជាកំលោះនៅឡើយ មានព្រះកេសាខ្មៅស្រិល ប្រកបដោយវ័យកំពុងចម្រើន គឺបឋមវ័យ កាលដែលព្រះមាតាបិតា ទ្រង់មិនពេញព្រះទ័យ (នឹងការទ្រង់ផ្នួស) ដែលមានព្រះភក្ត្រជោកទៅដោយទឹកព្រះនេត្រ ទ្រង់ព្រះកន្សែងសោយសោកហើយ ទ្រង់ក៏លះបង់ពួកញាតិ កាត់យសបលិពោធទាំងអស់ កាត់បុត្តទារបលិពោធ កាត់ញាតិបលិពោធ កាត់មិត្តាមច្ចបលិពោធ កាត់សន្និធិបលិពោធ ហើយកោរសក់និងពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួសដល់នូវភាពមិនមានការកង្វល់ ត្រាច់ទៅ ប្រព្រឹត្តទៅ ចរទៅ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាព ឱ្យប្រព្រឹត្តទៅមួយអង្គឯង ព្រះមានព្រះភាគ ឈ្មោះថា មួយព្រះអង្គឯង ដោយចំណែកបព្វជ្ជា យ៉ាងនេះ ។

ព្រះមានព្រះភាគ មួយអង្គឯង ដោយសេចក្តីថា មិនមានបុគ្គលជាទីពីរ តើដូចម្តេច ។ ព្រះមានព្រះភាគនោះ កាលទ្រង់ព្រះផ្នួស ហើយយ៉ាងនេះ តែមួយព្រះអង្គឯង ទ្រង់អាស្រ័យសេនាសនៈស្ងាត់ ដែលតាំងនៅក្នុងព្រៃតូចធំ មានសំឡេងតិច មានគឹកកងតិច ប្រាសចាកសំដីមនុស្សអ្នកដើរទៅមក សមគួរដល់ការកំបាំងអំពីពួកមនុស្ស គួរជាទីលាក់ខ្លួនពួនសម្ងំបាន ព្រះមានព្រះភាគអង្គនោះ យាងទៅមួយអង្គឯង ឈរមួយអង្គឯង គង់នៅមួយអង្គឯង សម្រេចការផ្ទំមួយអង្គឯង ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត្រ មួយអង្គឯង ចៀសចេញទៅមួយអង្គឯង គង់នៅក្នុងទីស្ងាត់មួយអង្គឯង អធិដ្ឋានទីចង្ក្រម មួយអង្គឯង ត្រាច់ទៅ ប្រព្រឹត្តទៅ ចរទៅ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅមួយអង្គឯង ព្រះមានព្រះភាគ ឈ្មោះថា មួយព្រះអង្គឯង ដោយសេចក្តីថា មិនមានបុគ្គលជាទីពីរ យ៉ាងនេះ ។

ព្រះមានព្រះភាគ មួយអង្គឯង ដោយសេចក្តីថាលះបង់តណ្ហានោះ តើដូចម្តេច ។ ព្រះមានព្រះភាគអង្គនោះ មួយព្រះអង្គឯង មិនមានបុគ្គលជាទីពីរ យ៉ាងនេះហើយ ព្រះអង្គមិនមានសេចក្តីប្រហែស មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានព្រះទ័យបញ្ជូនទៅកាន់ព្រះនិព្វាន ទ្រង់គង់នៅក្រោមដើមពោធិព្រឹក្ស ទៀបឆ្នេរស្ទឹងនេរញ្ជរា តាំងទុកនូវមហាបធាន កំចាត់បង់នូវមារដែលមិនលែងជនឱ្យរួច ព្រមទាំងសេនាជាផៅពង្សនៃអ្នកប្រហែល ហើយលះបង់ បន្ទោបង់ ធ្វើឱ្យវិនាស ធ្វើមិនឱ្យមានបែបភាពនូវតណ្ហាដែលជាបណ្តាញ ជាគ្រឿងហូរទៅជាប់នៅក្នុងអារម្មណ៍ផ្សេងៗ ។

បុរសដែលមានតណ្ហាជាទីពីរ រមែងអន្ទោលទៅអស់កាលជាយូរអង្វែង មិនប្រព្រឹត្តកន្លងនូវសំសារវដ្ត ជាភាពមានប្រការយ៉ាងនេះ ជាភាពមានប្រការដទៃ ភិក្ខុដឹងនូវទោសនុ៎ះ ហើយគប្បីជាអ្នកប្រាសចាកតណ្ហា មិនមានការប្រកាន់ មានស្មារតី វៀរនូវតណ្ហា ដែលជាដែនកើតទុក្ខ ។

ព្រះមានព្រះភាគ ឈ្មោះថា មួយព្រះអង្គឯង ដោយសេចក្តីថា លះបង់តណ្ហា យ៉ាងនេះ ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះព្រះអង្គប្រាសចាករាគៈដោយចំណែកមួយ តើដូចម្តេច ។ ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះព្រះអង្គប្រាសចាករាគៈដោយចំណែកមួយ ព្រោះលះបង់រាគៈហើយ ។ ព្រះមានព្រះភាគមួយអង្គឯង ព្រោះប្រាសចាកទោសៈដោយចំណែកមួយ ព្រោះលះបង់ ទោសៈហើយ ។ ព្រះមានព្រះភាគមួយអង្គឯង ព្រោះប្រាសចាកមោហៈដោយចំណែកមួយ ព្រោះលះបង់មោហៈហើយ ។ ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះមិនមានកិលេសដោយចំណែកមួយ ព្រោះលះបង់នូវកិលេសទាំងឡាយហើយ ។

ព្រះមានព្រះភាគ មួយអង្គឯង ព្រោះស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង តើដូចម្តេច ។ ដែលហៅថា ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង (នោះ) សំដៅយកសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។

ព្រះមានព្រះភាគ មានប្រក្រតីឃើញនូវទីបំផុតនៃធមិជាគ្រឿង អស់ទៅនៃជាតិ មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ ទ្រង់ជ្រាបច្បាស់នូវផ្លូវជា

ទីទៅនៃបុគ្គលម្នាក់ឯង ជនទាំងឡាយក្នុងកាលមុន បានឆ្លងហើយតាមផ្លូវនុ៎ះ ជនទាំងឡាយបម្រុងនឹងឆ្លង ទាំងជនទាំងឡាយកំពុងឆ្លងនូវឱឃៈ (ក៏ឆ្លងតាមផ្លូវនុ៎ះ) ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះស្ដេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង យ៉ាងនេះ ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះព្រះអង្គតែម្នាក់ឯង ទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិ តើដូចម្ដេច ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ធម្មវិចយៈ សម្ពោជ្ឈង្គ វិមំសា វិបស្សនា សម្មាទិដ្ឋិ ក្នុងមគ្គ ៤ លោកហៅថា ពោធិ ។ ដោយសារពោធិញ្ញាណនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ដឹងថា សង្ខារទាំងពួងមិនទៀង ត្រាស់ដឹងថា សង្ខារទាំងពួងជាទុក្ខ ត្រាស់ដឹងថា ធម៌ទាំងពួងជាអនត្តា ត្រាស់ដឹងថា សង្ខារទាំងឡាយមានអវិជ្ជាជាបច្ច័យ ។បេ។ ត្រាស់ដឹងថា ជរាមរណៈមានជាតិជាបច្ច័យត្រាស់ដឹងថា សេចក្ដីរលត់នៃសង្ខារព្រោះរលត់អវិជ្ជា ។បេ។ ត្រាស់ដឹងថា ការរលត់នៃជរាមរណៈ ព្រោះរលត់ជាតិ ត្រាស់ដឹងថា នេះទុក្ខ ត្រាស់ដឹងថា នេះទុក្ខសមុទ័យ ត្រាស់ដឹងថា នេះទុក្ខនិរោធ ត្រាស់ដឹងថា នេះទុក្ខនិរោធគាមិនីបដិបទា ត្រាស់ដឹងថានេះអាសវៈ ត្រាស់ដឹងថា នេះអាសវសមុទ័យ ត្រាស់ដឹងថា នេះអាសវនិរោធ ត្រាស់ដឹងថា នេះអាសវនិរោធគាមិនីបដិបទា ត្រាស់ដឹងថា ធម៌ទាំងនេះ គប្បីដឹង ត្រាស់ដឹងថា ធម៌ទាំងនេះត្រូវកំណត់ ត្រាស់ដឹងថា ធម៌ទាំងនេះត្រូវលះបង់ ត្រាស់ដឹងថា ធម៌ ទាំងនេះត្រូវចម្រើន ត្រាស់ដឹងថា ធម៌ទាំងនេះត្រូវធ្វើឱ្យជាក់ច្បាស់ ត្រាស់ដឹង

ថា ហេតុដែលនាំឱ្យកើតឡើងផង នូវសេចក្តីអស់ផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចោលផងនៃផស្សាយតនៈ ៦ ត្រាស់ដឹងថានូវហេតុ ដែលនាំឱ្យកើតឡើងផងនូវសេចក្តីអស់ផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចោលផង នៃឧបាទានក្ខន្ធ ៥ ត្រាស់ដឹងនូវហេតុដែលនាំឱ្យកើតឡើងផងនូវសេចក្តីអស់ផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចោលផងនៃមហាភូតរូប ៤ ត្រាស់ដឹងថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ។ មួយទៀត ធម្មជាតណាមួយដែលព្រះមានព្រះភាគគប្បីជ្រាប គប្បីជ្រាបចំពោះ គប្បីជ្រាបព្រម គប្បីត្រាស់ដឹង គប្បីពាល់ត្រូវ គប្បីធ្វើឱ្យជាក់ច្បាស់ ព្រះមានព្រះភាគ ក៏ទ្រង់ជ្រាបជ្រាបតាមលំដាប់ ជ្រាបចំពោះ ជ្រាបព្រម ជ្រាបដោយប្រពៃ ត្រាស់ដឹងបានចំពោះ ពាល់ត្រូវ ធ្វើឱ្យជាក់ច្បាស់នូវធម្មជាតទាំងអស់នោះ ដោយពោធិញ្ញាណនោះ ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះព្រះអង្គតែមួយព្រះអង្គឯងត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិ យ៉ាងនេះ ។

ពាក្យថា សេចក្តីត្រេកអរក្នុងបទថា បានដល់នូវសេចក្តីត្រេកអរ មានសេចក្តីថា ព្រះមានព្រះភាគ ដល់សម្រេច ពាល់ត្រូវ ធ្វើឱ្យជាក់ច្បាស់នូវសេចក្តីត្រេកអរក្នុងនេក្ខម្មៈ នូវសេចក្តីត្រេកអរក្នុងបរិវេក នូវសេចក្តីត្រេកអរក្នុងការស្ងប់រម្ងាប់នូវសេចក្តីត្រេកអរក្នុងសម្ពោធិហេតុនោះ (លោកពោលថា) បានដល់នូវសេចក្តីត្រេកអរ មួយព្រះអង្គឯង ។ ហេតុនោះ ព្រះសារីបុត្តត្ថេរ ពោលថា ៖

ព្រះមានព្រះភាគ មានចក្ខុប្រាកដដល់លោក ព្រមទាំងទេវលោក

ទ្រង់កំចាត់បង់នូវងងឹតទាំងពួងតែមួយអង្គឯង បានដល់នូវសេចក្តីត្រេកអរ ។

ពាក្យថា ព្រះអង្គមិនអាស្រ័យ អធិប្បាយថា គ្រឿងអាស្រ័យមាន ២ គ្រឿងអាស្រ័យគឺតណ្ហា ១ គ្រឿងអាស្រ័យគឺទិដ្ឋិ ១ ។

គ្រឿងអាស្រ័យគឺតណ្ហា តើដូចម្តេច ។ បុគ្គលប្រកាន់វត្ថុដែលខ្លួនធ្វើឱ្យជាសីមា ធ្វើឱ្យជាព្រំ ធ្វើឱ្យជាប្រទល់ដែន ធ្វើឱ្យជាទីបំផុត កាន់កាប់ ប្រកាន់ដោយចំណែកតណ្ហា ទាំងអម្បាលម៉ានថា នេះរបស់អញ នុ៎ះរបស់អញ ប៉ុណ្ណេះរបស់អញ អម្បាលម៉ាននេះរបស់អញ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ កំរាលគ្រឿងដណ្តប់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោល សេះញីស្រែ ចម្ការ ប្រាក់ មាស ស្រុកនិគម រាជធានី ដែន ជនបទ ឃ្លាំង និង ជង្រុករបស់អញ សូម្បីការប្រកាន់នូវផែនដីធំ ទាំងមូលដោយអំណាចតណ្ហា ការប្រែប្រួលនៃតណ្ហា ១០៨ ទាំងអម្បាលម៉ាន នេះគ្រឿងអាស្រ័យ គឺតណ្ហា ។

គ្រឿងអាស្រ័យគឺ ទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិកទិដ្ឋិមានវត្ថុ ១០ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃស្បាតគឺ ទិដ្ឋិ ផ្លូវ លំបាកគឺទិដ្ឋិ ធម្មជាតជំទាស់គឺទិដ្ឋិ ធម្មជាតញ្ញាក់ញ្ញាក់គឺទិដ្ឋិ គ្រឿងចងក្រៀក គឺទិដ្ឋិ កំណាន់ កំណាន់ស៊ប់សួន ការប្រកាន់មាំ ការស្ទាបអង្អែល ផ្លូវគួរខ្ពើម ផ្លូវខុស សភាពខុស ទីដូចជាកំពង់ កំណាន់ដោយការស្វះស្វែងរក ផ្សេងៗ កំណាន់ផ្ទុយ កំណាន់ប្រែប្រួល កំណាន់ខុស កំណាន់ថា មែនក្នុងវត្ថុដែលមិនមែន ទិដ្ឋិ ៦២ ទាំងអម្បាលម៉ាន នេះ គ្រឿងអាស្រ័យគឺទិដ្ឋិ ។

ព្រះពុទ្ធមានព្រះភាគ លះបង់គ្រឿងអាស្រ័យ គឺតណ្ហារលាស់ចោល គ្រឿង

អាស្រ័យគឺទិដ្ឋិហើយ ។ ព្រោះលះបង់គ្រឿងអាស្រ័យគឺតណ្ហា រលាស់ចោលគ្រឿងអាស្រ័យគឺទិដ្ឋិ ព្រះមានព្រះភាគ មិនអាស្រ័យចក្ខុ មិនអាស្រ័យ សោតៈ ឃានៈ ជិវ្ហា កាយ ចិត្ត មិនអាស្រ័យ មិនស្អិត មិនចូលទៅជិត មិនជក់ ចិត្ត មិនចុះចិត្ត ស្ទុះចេញ ខ្ជាតចេញ ឃ្លាតចេញ ប្រាសចេញ ចាករូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ត្រកូល ពួក អាវាស លាភ យស សេចក្ដីសរសើរ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភាព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព ជាអតីត អនាគត បច្ចុប្បន្ន ធម៌ទាំងឡាយដែលខ្លួនឃើញ ឮ ប៉ះពាល់ ឬ គប្បីដឹងមានព្រះទ័យសម្រេចសម្រាន្តនៅ ហេតុនោះ (លោកពោលថា) ព្រះពុទ្ធអង្គនេះ ព្រះអង្គមិនអាស្រ័យ ។

ពាក្យថា ទ្រង់នឹងធឹង អធិប្បាយថា ព្រះមានព្រះភាគ ទ្រង់នឹងធឹងដោយអាការ ៥ គឺ ទ្រង់នឹងធឹងក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ១ ទ្រង់នឹងធឹងព្រោះព្រះអង្គបានលះ ១ ទ្រង់នឹងធឹងព្រោះព្រះអង្គ បានឆ្លង ១ ទ្រង់នឹងធឹងព្រោះព្រះអង្គបានរួច ១ ទ្រង់នឹងធឹងព្រោះការសំដែងចេញនូវគុណនោះ ១ ។

ព្រះមានព្រះភាគទ្រង់នឹងធឹងក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ តើដូចម្ដេច។ ព្រះមានព្រះភាគ ទ្រង់នឹងធឹងក្នុងលាភផង ទ្រង់នឹងធឹងក្នុងការមិនមានលាភផង ទ្រង់នឹងធឹងក្នុងយសផង ទ្រង់នឹងធឹងក្នុងការមិនមានយសផង ទ្រង់នឹងធឹងក្នុងសេចក្ដីសរសើរផង ទ្រង់នឹងធឹងក្នុងនិន្ទាផង ទ្រង់នឹងធឹងក្នុងសុខផង ទ្រង់នឹងធឹងក្នុងទុក្ខផង ។ បើពួកជនគប្បីលាបព្រះពាហាម្ខាងដោយគ្រឿង

ក្រអូប គប្បីច្រាស់ ព្រះពាហាម្ខាងដោយកាំបិតព្រា ។ តម្រេកក្នុងការលាប ដោយគ្រឿងក្រអូបឯណោះមិនមាន សេចក្ដីថ្នាំងថ្នាក់ ក្នុងការច្រាស់ដោយ កាំបិតព្រាឯណោះមិនមាន ។ ព្រះមានព្រះភាគលះស្រឡះនូវសេចក្ដីស្រឡាញ់ ស្អិត និងសេចក្ដីថ្នាំងថ្នាក់កន្លងផុតនូវសេចក្ដីកាន់ជើង និងសេចក្ដីផ្ញាញ់ផ្ញាល់ កន្លងផុតស្រឡះនូវសេចក្ដីត្រូវចិត្ត និងសេចក្ដីសុខចិត្ត ។ ព្រះមានព្រះភាគ ទ្រង់ នឹងធឹងក្នុងឥដ្ឋារម្មណ៍ និង អនិដ្ឋារម្មណ៍ យ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះព្រះអង្គបានលះ តើដូចម្ដេច ។ ព្រះ មានព្រះភាគ ទ្រង់បានលះ ខ្ជាក់លែង កំចាត់ លះបង់រាគៈ ។ ទ្រង់បានលះ ខ្ជាក់លែង កំចាត់ លះបង់ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្ដីក្រវល់ក្រវាយទាំងអស់ ការ អន្ទះអន្ទែងទាំងអស់ ការក្ដៅក្រហាយទាំងអស់ អភិសង្ខារជាអកុសលទាំង អស់ ។ ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះព្រះអង្គបានលះ យ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះទ្រង់បានឆ្លង តើដូចម្ដេច ។ ព្រះ មានព្រះភាគ ទ្រង់បានឆ្លង កាមោឃៈ ឆ្លងភវោឃៈ ឆ្លងទិដ្ឋោឃៈ ឆ្លងអវិជ្ជោឃៈ ឆ្លង ឆ្លងផុត ឆ្លងរួច កន្លង កន្លងដោយប្រពៃ រំលងនូវផ្លូវសង្សារ ទាំងអស់ ។ ព្រះអង្គគង់នៅក្នុងអរិយវាស ប្រព្រឹត្តចរណៈដើរហួសផ្លូវឆ្ងាយ គឺ សង្សារដល់នូវទិស គឺ (ព្រះនិព្វាន) ដល់នូវទីបំផុត (អនុបាទិសេសនិព្វាន) រក្សា ព្រហ្មចរិយៈដល់នូវទិដ្ឋិដ៏ឧត្ដម ចម្រើនមគ្គ លះបង់កិលេស ចាក់ធ្លុះព្រះអរហត្ត

ផល ដែលមិនកំរើក ធ្វើឱ្យច្បាស់លាស់នូវនិរោធ ។ ព្រះអង្គ កំណត់ដឹងទុក្ខ លះបង់សមុទយៈ ចម្រើនមគ្គ ធ្វើឱ្យច្បាស់លាស់នូវនិរោធ ត្រាស់ដឹង ធម៌ដែលត្រូវត្រាស់ដឹង កំណត់ធម៌ ដែលត្រូវកំណត់ដឹង លះបង់ធម៌ដែលត្រូវលះបង់ ចម្រើនធម៌ដែលត្រូវចម្រើន ធ្វើឱ្យច្បាស់លាស់នូវធម៌ដែលត្រូវធ្វើឱ្យច្បាស់លាស់ ។ ព្រះអង្គដកគន្លឹះទ្វារ គឺអវិជ្ជា កំចាត់បង់ស្នាមភ្លោះ គឺកម្មាភិសង្ខារ ដកសសរខឿន គឺតណ្ហា មិនមានសន្ទះទ្វារ គឺឱរម្ភាគិយ សំយោជនៈ ជាបុគ្គលបរិសុទ្ធ ទំលាក់ទង់ជ័យ គឺមានះ ហើយដាក់ភារៈ គឺខន្ធជាដើម ប្រាសចាកយោគៈ និងកិលេស លះស្រឡះនូវអង្គ ៥ គឺនីវរណៈ ប្រកបអង្គ ៦ គឺឧបេក្ខា មានការឃុំគ្រងយ៉ាងឯក គឺសតិ មានអបស្សេនធម៌ ៤ បន្ទោបង់ បច្ចេកសច្ចៈ មានការស្វែងរកគ្រប់យ៉ាងលះចោល ហើយដោយប្រពៃ មានសង្កប្បៈមិនល្អក់ រម្ងាប់កាយសង្ខារ មានចិត្តរួចស្រឡះដោយល្អ មានបញ្ញារួចស្រឡះដោយល្អ មានគុណដ៏បរិបូរណ៍ អប់រំព្រហ្មចរិយៈ ជាបុរសដ៏ខ្ពង់ខ្ពស់ ជាបុរសដ៏ក្រៃលែង ដល់ហើយនូវកិរិយាបាននូវអមតៈ ។ ព្រះអង្គឈប់កពូន ឈប់ កំចាត់កំចាយ ឈ្មោះថា ទ្រង់នឹងនួនព្រោះកំចាត់កំចាយ (កិលេស) ព្រះអង្គឈប់លះបង់ឈប់ប្រកាន់មាំ ឈ្មោះថា ទ្រង់នឹងនួន ព្រោះលះបង់ ព្រះអង្គឈប់ចាក់ស្រេះ ឈប់ក្រអឺតក្រអោង ឈ្មោះថា ទ្រង់នឹងនួន ព្រោះមិនចាក់ស្រេះ ព្រះអង្គឈប់រំលត់ ឈប់បង្កាត់ ឈ្មោះថា ទ្រង់នឹងនួន ព្រោះរំលត់ ឈ្មោះថា ទ្រង់នឹងនួន ព្រោះប្រកបដោយ អសេក្ខសីលក្ខន្ធ ឈ្មោះថា ទ្រង់នឹងនួន ព្រោះប្រកបដោយអសេក្ខសមាធិក្ខន្ធ ឈ្មោះថា ទ្រង់នឹងនួន ព្រោះប្រកបដោយអសេក្ខបញ្ញាខន្ធ ឈ្មោះថា ទ្រង់នឹងនួន ព្រោះប្រកប

ដោយ អសេក្ខវិមុត្តិក្ខន្ធ ឈ្មោះថា ទ្រង់នឹងនួន ព្រោះប្រកបដោយ អសេក្ខវិមុត្តិ-ញ្ញាណទស្សនក្ខន្ធ ឈ្មោះថា ទ្រង់នឹងនួន ព្រោះដឹងអរិយសច្ច ឈ្មោះថា ទ្រង់នឹងនួន ព្រោះកន្លង (តណ្ហាជាគ្រឿងញាប់ញ័រ) យ៉ាងនេះ ឈ្មោះថា ទ្រង់នឹងនួន ព្រោះរំលត់ភ្លើងគឺកិលេស ឈ្មោះថា ទ្រង់នឹងនួន ព្រោះមិនមាន ការត្រឡប់វិញ ឈ្មោះថា ទ្រង់នឹងនួន ព្រោះចាប់កំពូល (គឺជំនះ) បាន ឈ្មោះថា ទ្រង់នឹងនួន ព្រោះការសេពចំពោះនូវការរួច ឈ្មោះថា ទ្រង់នឹងនួន ព្រោះមេត្តាដ៏បរិសុទ្ធ ឈ្មោះថា ទ្រង់នឹងនួន ព្រោះករុណាដ៏បរិសុទ្ធ ឈ្មោះថា ទ្រង់នឹងនួន ព្រោះមុទិតាដ៏បរិសុទ្ធ ឈ្មោះថា ទ្រង់នឹងនួន ព្រោះឧបេក្ខាដ៏បរិសុទ្ធ ឈ្មោះថា ទ្រង់នឹងនួន ព្រោះឧបេក្ខាដ៏បរិសុទ្ធយ៉ាងដាច់ខាត ឈ្មោះថា ទ្រង់នឹងនួន ព្រោះបរិសុទ្ធមិនមានតណ្ហា ទិដ្ឋិមានះ ឈ្មោះថា ទ្រង់នឹងនួន ព្រោះទ្រង់រួចស្រឡះ (ចាកកិលេស) ឈ្មោះថា ទ្រង់នឹងនួន ព្រោះជាអ្នកសន្តោស ឈ្មោះថា ទ្រង់នឹងនួនក្នុងទីបំផុតខន្ធ ឈ្មោះថា ទ្រង់នឹងនួនក្នុងទីបំផុតធាតុ ឈ្មោះថា ទ្រង់នឹងនួនក្នុងទីបំផុតអាយតនៈ ឈ្មោះថា ទ្រង់នឹងនួនក្នុងទីបំផុតគតិ ឈ្មោះថា ទ្រង់នឹងនួនក្នុងទីបំផុតឧបបត្តិ ឈ្មោះថា ទ្រង់នឹងនួនក្នុងទីបំផុតបដិសន្ធិ ឈ្មោះថា ទ្រង់នឹងនួនក្នុងទីបំផុតភព ឈ្មោះថា ទ្រង់នឹងនួនក្នុងទីបំផុតសង្សារ ឈ្មោះថា ទ្រង់នឹងនួនក្នុងទីបំផុតវដ្តៈ ឈ្មោះថា ទ្រង់នឹងនួនក្នុងភពចុងបង្អស់ ឈ្មោះថា ទ្រង់នឹងនួនក្នុងសរីរៈចុងបង្អស់ គឺទ្រទ្រង់នូវសរីរៈចុងបង្អស់ រីចេញនូវដំណើរទៅកាន់ភពថ្មី ។

នេះជាភពចុងបង្អស់របស់ព្រះអង្គ នេះជាសរីរៈក្រោយបង្អស់របស់ព្រះអង្គ

ព្រះអង្គមិនមាន ជាតិ មរណៈ សង្សារ និងភពថ្មីទៀតទេ ។

ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះបានឆ្លងយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះបានរួច តើដូចម្ដេច ។ ព្រះហឫទ័យរបស់ព្រះមានព្រះភាគរួច រួចស្រឡះ រួចផុតចាករាគៈ ។ ព្រះហឫទ័យរួច រួចស្រឡះ រួចផុតចាកទោសៈ ។ ព្រះហឫទ័យរួច រួចស្រឡះ រួចផុតចាកមោហៈ ។ ព្រះហឫទ័យរួច រួចស្រឡះ រួចផុតចាកកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្ដីក្រវល់ក្រវាយទាំងពួង សេចក្ដីអន្ទះអន្ទែងទាំងពួង សេចក្ដីក្ដៅក្រហាយទាំងពួង អភិសង្ខារជាអកុសលទាំងពួង ។ ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះបានរួច យ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះ តើដូចម្ដេច ។ ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើសីលមានទ្រង់ក៏មានសីល ។ ទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើសទ្ធាមាន ទ្រង់ក៏មានសទ្ធា ។ ទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើវិរិយៈមាន ទ្រង់ក៏មានវីរិយៈ ទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើសតិមាន ទ្រង់ក៏មានសតិ ។ ទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើសមាធិមាន ទ្រង់ក៏តាំងព្រះហឫទ័យខ្ជាប់ ។ ទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើបញ្ញាមាន ទ្រង់ក៏មានបញ្ញា ។ ទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះ

ថា កាលបើ វិជ្ជាមាន ទ្រង់ក៏មានត្រៃវិជ្ជា ។ ទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើអភិញ្ញាមាន ទ្រង់ក៏មានអភិញ្ញា ៦ ។ ទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើពលៈមានទ្រង់ក៏មានពលៈ ១០។ ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះ យ៉ាងនេះ ហេតុនោះ (លោកពោលថា) ចំពោះព្រះពុទ្ធអង្គនោះ ព្រះអង្គមិនអាស្រ័យ ទ្រង់នឹងធឹង ។

អធិប្បាយពាក្យថា ព្រះអង្គមិនកុហក ព្រះអង្គជាមេពួក ទ្រង់យាងមក ត្រង់ពាក្យថា មិនកុហក សេចក្ដីថា វត្ថុនៃការកុហកមាន ៣ គឺវត្ថុនៃការកុហក ចំណែកខាងការសេពបច្ច័យ ១ វត្ថុ នៃការកុហក ចំណែកខាងឥរិយាបថ ១ វត្ថុនៃការកុហក ចំណែកខាងការពោលក្នុងទីជិត ១ ។ល។ វត្ថុនៃការកុហក ទាំង ៣ នេះ ព្រះពុទ្ធមានជោគបានលះបង់ ក្បួលក្របែល រំលត់រំលាយ រំសាយ រំសោះ ធ្វើមិនគួរឱ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ព្រះពុទ្ធឈ្មោះថា ព្រះអង្គមិនកុហក ។

អធិប្បាយពាក្យថា ព្រះអង្គជាមេពួក ទ្រង់យាងមក ត្រង់ពាក្យថា ព្រះអង្គ ជាមេពួក គឺព្រះមានព្រះភាគជាមេពួក ។ ព្រះមានព្រះភាគ ឈ្មោះ ថា មេពួក ព្រោះជាអាចារ្យរបស់ពួក ។ ឈ្មោះថា មេពួក ព្រោះជាគ្រូរបស់ពួក ។ ឈ្មោះថា មេពួក ព្រោះគ្រប់គ្រងពួក ។ ឈ្មោះថា មេពួក ព្រោះទូន្មានពួក ។ ឈ្មោះថា មេពួក ព្រោះប្រដៅប្រដៅពួក ។ ឈ្មោះថា មេពួក ព្រោះក្សៀវក្លាចូលទៅកាន់ ពួក ។ ឈ្មោះថា មេពួក ព្រោះពួកប្រាថ្នាដើម្បីស្ដាប់ ផ្សៀងសោតៈ

ដំកល់ចិត្ត ដើម្បីដឹង (ព្រះពុទ្ធដីកា) របស់ព្រះអង្គ ។ ឈ្មោះថា មេពួក ព្រោះញ៉ាំងពួកឱ្យ ចេញចាកអកុសលហើយ ឱ្យតាំងនៅមាំក្នុងកុសល ។ ឈ្មោះថា មេពួករបស់ពួកភិក្ខុ ។ ឈ្មោះថា មេពួក របស់ពួកភិក្ខុនី ។ ឈ្មោះថា មេពួករបស់ពួកឧបាសក ។ ឈ្មោះថា មេពួករបស់ពួកឧបាសិកា ។ ឈ្មោះថា មេពួករបស់ពួកព្រះរាជា ។ ឈ្មោះថា មេពួករបស់ពួកក្សត្រិយ៍ ។ ឈ្មោះថា មេពួករបស់ពួកសុទ្ទៈ ។ ឈ្មោះថា មេពួករបស់ពួកព្រហ្ម ។ ឈ្មោះថា មេពួក របស់ពួកទេវតា ។ ទ្រង់មានក្រុម មានពួកជាអាចារ្យរបស់ពួក យាងមកហើយ ចូលមកជិតហើយ ចូលមកជិតព្រម ដល់ព្រមហើយនូវសង្គស្សនគរ ហេតុនោះ (លោកពោលថា) ព្រះអង្គមិនកុហក ព្រះអង្គជាមេពួក ទ្រង់យាងមកយ៉ាងនេះ ។

- (ព្រះនាមថា ព្រះមានព្រះភាគ ដោយអត្ថដូចម្តេច ?)
- ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់កាច់បង់រាគៈ ។
- ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់កាច់បង់ទោសៈ ។
- ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់កាច់បង់មោហៈ ។
- ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់កាច់បង់មានះ ។
- ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់កាច់បង់ទិដ្ឋិ ។
- ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់កាច់បង់បន្លាគឺកាមគុណ ។
- ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់កាច់បង់កិលេស ។
- ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់ចែក ញែករំលែកនូវធម្មរតនៈ ។
- ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់ធ្វើនូវទីបំផុតនៃភព ។

- ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បានចម្រើនកាយ គឺរូបនិងនាម ។
- ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បានចម្រើនសីល ព្រោះទ្រង់បានចម្រើនចិត្ត ព្រោះទ្រង់បានចម្រើនប្រាជ្ញា ។
- មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់បានគប់រកព្រៃតូចនិងព្រៃធំ ជាសេនាសនៈស្ងាត់ មានសម្លេងតិច មានការគឹកកងតិច ប្រាសចាកខ្យល់កាយនៃជន គួរដល់អំពើស្ងាត់របស់មនុស្ស សមគួរដល់កិរិយាពួនសម្ងំ ។
- មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យទ្រង់មានភាគនៃចីវរ បិណ្ឌបាត សេនាសនៈ និង គិលានប្បច្ចយភេសជ្ជបរិក្ខារ ។
- មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត និង អធិប្បញ្ញា ។
- មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃឈាន ៤ អប្បមញ្ញា ៤ និង អរូបសមាបត្តិ ៤ ។
- មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃវិមោក្ខ ៨ អភិភាយតនៈ ៨ និងអនុបុព្វវិហារសមាបត្តិ ៩ ។
- មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគ នៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិសមាធិ និង អសុភសមាបត្តិ ។
- មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥

ពោជ្ឈង្គៈ ៧ និងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។

- មួយវិញទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃតថាគតពលៈ ១០ វេសារជ្ជញ្ញាណ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ និងពុទ្ធធម៌ ៦ ។
- ព្រះនាមថា ព្រះមានព្រះភាគនេះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកមិត្តនិងអាមាត្យថ្វាយ មិនមែនពួកញាតិសាលោហិតថ្វាយ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយ មិនមែនពួកទេវតាថ្វាយទេ ឯព្រះនាមថា ព្រះមានព្រះភាគនេះ មានក្នុងទីបំផុតនៃវិមោក្ខរបស់ព្រះពុទ្ធទាំងឡាយ ទ្រង់មានជោគ ការបញ្ញត្តិថាព្រះមានព្រះភាគនេះ (កើត) ដោយការធ្វើឱ្យជាក់ច្បាស់ ព្រមទាំងការបាននូវសព្វញ្ញុតញ្ញាណ ទៀបគល់ ពោធិព្រឹក្ស ហេតុនោះ (ទើបមានពាក្យថា) ព្រះមានព្រះភាគ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា ៖

> ភិក្ខុមានស្មារតី មានចិត្តផុតស្រឡះល្អ គប្បីបន្ទោបង់
> នូវសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ទាំងនុះចេញ ភិក្ខុនោះ
> កាលពិចារណាធម៌ ដោយប្រពៃតាមកាលគួរ ភិក្ខុ
> នោះ នឹងជាអ្នកមានចិត្តខ្ពស់ឯក កំចាត់បង់នូវងងឹត
> បាន ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះ ។

ចប់ អធិប្បាយពាក្យថា ព្រះមានព្រះភាគ

បិដកលេខ ៦៦ ទំព័រ ២១២

## ២៣ អធិប្បាយពាក្យថា ព្រះពុទ្ធ ព្រះនាមថាព្រះពុទ្ធ

ពាក្យថា ព្រះពុទ្ធ បានដល់ ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងឯង មិនមានបុគ្គលជាអាចារ្យ បានត្រាស់ដឹងដោយព្រះអង្គឯង នូវសច្ចៈទាំងឡាយ ក្នុងធមិទាំងឡាយ ដែលព្រះអង្គមិនធ្លាប់ឮហើយ ក្នុងកាលមុន ទាំងបានដល់នូវសព្វញ្ញុតញ្ញាណ ក្នុងសច្ចៈទាំងនោះ និងភាវៈស្ទាត់ក្នុងពលៈទាំងឡាយ ។

- ព្រះនាមថា ព្រះពុទ្ធ ដោយអត្ថដូចម្តេច?
- ព្រះនាមថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ត្រាស់ដឹងសច្ចៈទាំងឡាយ ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ញុំាងពពួកសត្វឱ្យត្រាស់ដឹង ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះព្រះអង្គដឹងធមិទាំងពួង ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះព្រះអង្គឃើញធមិទាំងពួង ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះព្រះអង្គដឹងច្បាស់ ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះព្រះអង្គរីកហើយ ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះគេពោលថា ព្រះអង្គមានអាសវៈអស់ហើយ ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះគេពោលថា ព្រះអង្គមានឧបក្កិលេសចេញហើយ ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាករាគៈដោយចំណែកមួយ ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកទោសៈដោយចំណែកមួយ ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកមោហៈដោយចំណែកមួយ ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះហេតុទ្រង់មានកិលេសចេញហើយ ដោយចំណែកមួយ ។

- ព្រះនាមថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ទៅហើយកាន់ផ្លូវ ជាទីទៅនៃបុគ្គលម្នាក់ឯង ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ជាបុគ្គលឯក ត្រាស់ដឹងចំពោះសម្មាសម្ពោធិញ្ញាណ មិនមាន គុណជាតិដទៃក្រៃលែងជាង ។
- ព្រះនាមថា ព្រះពុទ្ធ ព្រោះទ្រង់កំចាត់បង់សេចក្តីល្ងង់ ព្រោះការបាននូវប្រាជ្ញា ។
- ព្រះនាមថា ព្រះពុទ្ធនុ៎ះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកមិត្រ និងអាមាត្យថ្វាយ មិនមែនពួកញាតិនិងសាលោហិតថ្វាយ មិនមែនពួកសមណព្រាហ្មណ៏ថ្វាយ មិនមែនពួកទេវតាថ្វាយទេ ព្រះនាមថា ព្រះពុទ្ធនុ៎ះរបស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ ជាព្រះនាម កើតក្នុងទីបំផុតនៃវិមោក្ខបញ្ញត្តិថា ព្រះពុទ្ធនេះ កើតព្រោះការត្រាស់ដឹង ព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្សហេតុនោះ លោកពោលថា ព្រះពុទ្ធ ។

ចប់ អធិប្បាយពាក្យថាព្រះពុទ្ធ ព្រះនាមថាព្រះពុទ្ធ

(បិដកលេខ៦៨ទំព័រ១០៦)

# ២៤ មហាបុរិសលក្ខណៈ៣២ ប្រការ

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងវេលានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ឆ្លើយតបព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ មហាបុរសប្រកបដោយមហាបុរិសលក្ខណៈ៣២ប្រការនេះ មហាបុរស (នោះ) រមែងមានគតិ ២ យ៉ាង មិនមែនក្រៅពី ២ យ៉ាង នេះទេ គឺ បើមហាបុរសនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ មានជ័យជំនះផ្សាយអំណាចរហូតដល់ផែនដីដែលមានមហាសមុទ្រទាំង ៤ ព័ទ្ធជុំវិញ ទ្រង់ដល់នូវភាវៈជាអ្នកមានជនបទដ៏មាំមួន ទ្រង់ប្រកបដោយរតនៈ ៧ ប្រការ ឯរតនៈ ៧ប្រការ នៃស្តេចចក្រពត្តិនោះ គឺចក្ករតនៈ ១ ហត្ថិរតនៈ ១ អស្សរតនៈ ១ មណិរតនៈ១ ឥត្ថីរតនៈ[៨] ១ គហបតិរតនៈ[៩] ១ បរិនាយករតនៈ[១០] ១ រួមត្រូវជា ៧ ប្រការ ។ ព្រះរាជបុត្ររបស់ស្តេចចក្រពត្តិនោះ ក៏មានចំនួនច្រើន

---

៨ អដ្ឋកថា ថាបានដល់ស្រីដែលនាំមកនូវសេចក្តីសុខដ៏វិសេស ដល់ស្តេចចក្រពត្តិ ដែលគេនាំអំពីមទ្ទរាជត្រកូល ឬ ឧត្តរកុរុទ្វីប មកថ្វាយ ឱ្យតាំងជាអគ្គមហេសី ។

៩ អដ្ឋកថា ក្នុងមហាសុទស្សនសូត្រថា បានដល់ពួកអ្នកមានភោគសម្បត្តិច្រើន ។

១០ ព្រះរាជបុត្រច្បងដែលមានប្រាជ្ញាឈ្លាសវៃ អាចស្គាល់ចិត្តរបស់ស្តេចចក្រពត្តិ ជាអ្នកចាត់ចែងកិច្ចការគ្រប់ជំពូកថ្វាយស្តេចចក្រពត្តិបាន

ពាន់ ច្រើនតែជាអ្នកក្លៀវក្លា មានរូបសណ្ឋាន ជាអ្នកអង់អាច អាចញាំញីនូវសេនារបស់ស្ដេចឯទៀតបាន ។ ព្រះអង្គប្រាបប្រាមគ្រប់គ្រងនូវផែនដីនេះ ដែលមានសាគរជាទីបំផុតឱ្យជាផែនដីឥតមានគោល ឥតមាននិមិត្ត ឥតមានបន្លា គឺចោរឡើយ ជាផែនដីស្ដុកស្ដម្ភមាំមួន ក្សេមក្សាន្ត ឥតមានឧបទ្រព ឥតមានទីពួនរបស់ចោរ ដោយធម៌ដ៏ស្មើគឺសីល ៥ មិនបាច់ពឹងអាជ្ញា មិនបាច់ពឹងគ្រឿងសស្ត្រាវុធឡើយ បើមហាបុរសនោះចេញចាកគេហដ្ឋានទៅ ទ្រង់ព្រះផ្នួសហើយនឹងបានត្រាស់ជាអរហន្តសម្មាសម្ពុទ្ធ ក្នុងលោកមានដម្បូល គឺកិលេសបើកចេញហើយ ។ ម្នាលភិក្ខុទាំងឡាយ មហាបុរសប្រកបដោយ មហាបុរិសលក្ខណៈ ៣២ ប្រការនោះ តើដូចម្ដេចខ្លះ ទើបបានជាមានគតិ ២ យ៉ាង មិនមែនក្រៅពី ២ យ៉ាងនេះឡើយ គឺបើមហាបុរសនៅគ្រប់គ្រងគេហដ្ឋាននឹងបានជាស្ដេចចក្រពត្តិ ។ សេចក្ដីបំព្រួញ ។ បើមហាបុរសចេញចាកគេហដ្ឋានទៅទ្រង់ព្រះផ្នួស នឹងបានត្រាស់ជាអរហន្ត សម្មាសម្ពុទ្ធក្នុងលោក មានដម្បូល គឺកិលេសបើកចេញហើយ ។ ម្នាលភិក្ខុទាំងឡាយ មហាបុរស ក្នុងលោកនេះ មានព្រះបាទប្រតិស្ឋានល្អ គឺមានផ្ទៃព្រះបាទទាំងគូរាបស្មើសព្វអន្លើ ។ ម្នាលភិក្ខុទាំងឡាយ មហាបុរសមានព្រះបាទប្រតិស្ឋានល្អ ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯងជា មហាបុរិសលក្ខណៈរបស់មហាបុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀតត្រង់ផ្ទៃព្រះបាទទាំងគូខាងក្រោមរបស់មហាបុរស មានរូបចក្រកើតឡើង ប្រកបដោយខ្នងកង់ និង ដុំព្រមទាំងកាំ ១០០០ មានចន្លោះស្មើ គ្នាគ្រប់អន្លើ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ផ្ទៃព្រះបាទទាំងគូ ខាងក្រោមរបស់មហាបុរស មាន

រូបចក្រ កើតឡើងប្រកបដោយខ្នងកង់និងដុំ ព្រមទាំងកាំ១000 មានចន្លោះស្មើគ្នាគ្រប់អន្លើ ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯង ជាមហាបុរិសលក្ខណៈរបស់មហាបុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាបុរសមានព្រះបណ្ហិ គឺ កែងវែង ។ មានព្រះអង្គុលិ គឺម្រាមព្រះហស្ត និង ម្រាមព្រះបាទវែងៗ ។ មានផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទដ៏ទន់ល្មើយ ។ មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទប្រទាក់ដោយក្រឡាដូចសំណាញ់ ។ មានព្រះបាទដូចជា អណ្តែតឡើងខាងលើ ។ មានព្រះជង្ឃាគឺស្នងរៀវមូល ត្រសូលស្រដៀងនឹងស្នងសត្វទ្រាយ ។ កាលបើទ្រង់ឈរ មិនបាច់ឱនព្រះអង្គចុះ អាចស្ទាបអង្អែលព្រះជាណុ គឺជង្គង់ដោយផ្ទៃព្រះហស្តទាំងពីរបាន ។ មានព្រះអង្គាវយវៈដែលត្រូវលាក់កំបាំងដោយសំពត់ ឋិតនៅក្នុងស្រោម ។ មានស្បែក សម្បុរថ្លៃលឿងភ្លឺអន្លង់ ដូចជាសម្បុរនៃមាស ។ មានព្រះឆវីសម្បុរថ្ងៃល្អិត ផូរផង់រលីងស្រិលរអិល ធូលីធ្លាក់មកមិនជាប់ព្រះកាយ ។ មានព្រះលោមា តែ ១ សរសៃៗ គឺ ក្នុងរណ្តៅរោម ១ មានរោម ១ ។ មានព្រះលោមាមានចុង-ងឡើងលើព្រះលោមា ដែលដុះឡើងហើយមាន ចុងឡើងលើ ជាទក្ខិណាវដ្ត វិលវង់ព័ទ្ធពេនទៅខាងស្តាំ មានសម្បុរខៀវ ដូចជាសម្បុរនៃផ្កាអញ្ចន្ទកួច មូលដូចជាកុណ្ឌល ។ មានព្រះកាយត្រង់ដូចជាកាយនៃព្រហ្ម ។ មានព្រះមំសៈ គឺសាច់ ៧ អន្លើពេញបរិបូណ៌ ។ មានព្រះកាយ ពាក់កណ្តាលខាងលើដូចជាកាយនៃរាជសីហ៍ ។ មានព្រះបិដ្ឋិ គឺខ្នងដ៏ពេញបរិបូណ៌ ។ មានទ្រង់ទ្រាយព្រះកាយ ដូចជាបរិមណ្ឌលនៃដើមជ្រៃ កាយរបស់មហាបុរសប្រវែងណា ព្យាមរបស់មហាបុរសក៏ប្រវែង

នោះដែរ គឺមានកាយនឹងព្យាមស្មើគ្នា ។ មានព្រះសូរងមូលសម ។ មានព្រះប្រសាទគឺសរសៃល្អិតឆ្មារដ៏លើសលែងសម្រាប់ទទួលរសអាហារ ។ មានព្រះហនុកា (ចង្កា) ដូចជាចង្កានៃរាជសីហ៍ ។ មានព្រះទន្ត ៤០ គត់ ។ មានព្រះទន្តរាបស្មើ ។ មានព្រះទន្តជិតស្និទ្ធល្អ ។ មានព្រះទាឋា គឺចង្កូម (ទាំង ៤) សស្អាត ។ មានព្រះជិវ្ហាដ៏ធំវែង ។ មានព្រះសូរស័ព្ទ ដូចជា សំឡេងនៃព្រហ្ម ។ កាលបើបញ្ចេញវាចាលាន់ឮពីរោះ ដូចជាសំឡេងនៃសត្វករវិក ។ មានព្រះនេត្រខៀវស្រស់ ។ មានដួងព្រះនេត្រ ដូចជាភ្នែកនៃ (កូន) គោ ។ មានព្រះឧណ្ណាលោម គឺរោម ប្រជុំចិញ្ចើមដុះត្រង់ចន្លោះនៃព្រះភមុកា (ចិញ្ចើម) មានពណ៌សក្បុសទន់ល្មើយដូចជាសំឡី ។ ម្នាលភិក្ខុទាំងឡាយ មហាបុរសដែលមានព្រះឧណ្ណាលោមដុះត្រង់ចន្លោះនៃព្រះភមុកា មានពណ៌សក្បុស ទន់ល្មើយដូចជាសំឡី ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯង ជាមហាបុរិសលក្ខណៈរបស់មហាបុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាបុរសមានព្រះសិរ្សហាក់ដូចជាប្រដាប់ដោយក្បាំងមកុដស្រេចស្រាប់ ។ ម្នាលភិក្ខុទាំងឡាយ មហាបុរសដែលមានព្រះសិរ្ស ហាក់ដូចជាប្រដាប់ដោយក្បាំងមកុដស្រេចស្រាប់ ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯង ជាមហាបុរិសលក្ខណៈរបស់មហាបុរស ។ ម្នាលភិក្ខុទាំងឡាយ មហាបុរសប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ ប្រការនេះឯង ទើបបានជាមានគតិជា ២ យ៉ាង មិនមែនក្រៅអំពី ២ យ៉ាងនេះឡើយ គឺបើមហាបុរសនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ សេចក្តីបំព្រួញ ។ បើទ្រង់ចេញចាកគេហដ្ឋាន ទៅ

ទ្រង់ព្រះផ្នួស នឹងបានត្រាស់ជា ព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដម្បូល គឺកិលេសបើកចេញហើយ ។ ម្នាលភិក្ខុទាំងឡាយ ពួកឥសីជាខាងក្រៅ (អ្នូតថា) តែងចេះចាំ មហាបុរិសលក្ខណៈរបស់មហាបុរសទាំង ៣២ ប្រការនេះឯង តែឥសីទាំងនោះឥតដឹងសោះ ។ ព្រោះមហាបុរសបានធ្វើនូវកម្មនេះ ។ បេ ។ ទើបបាននូវលក្ខណៈនេះ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកបានសមាទានមាំមួនក្នុងកុសលធម៌ទាំងឡាយ គឺជាអ្នកសមាទានជាប់មិនដាច់ក្នុងកាយសុចរិត វចីសុចរិត មនោសុចរិត ការបរិច្ចាគទាន ការសមាទានសីល ការរក្សាឧបោសថ វត្តដែលត្រូវធ្វើចំពោះមាតា វត្តដែលត្រូវធ្វើចំពោះបិតា វត្តដែលត្រូវធ្វើចំពោះសមណៈ វត្តដែលត្រូវធ្វើចំពោះព្រាហ្មណ៍ វត្តដែលត្រូវធ្វើចំពោះជន ដែលជាច្បងក្នុងត្រកូល និងក្នុងពួកធម៌ជាកុសលដ៏ក្រៃលែងឯទៀតៗ ។ ព្រះតថាគតនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ ក៏បានទៅកើតក្នុងសុគតិសួគ៌ទេវលោក ព្រោះហេតុតែកុសលកម្ម ដែលមហាបុរសបានធ្វើសន្សំបណ្ដុះឱ្យធំទូលាយហើយនោះ ។ ព្រះតថាគតនោះតែងគ្របសង្កត់ពួកទេវតាឯទៀតក្នុងឋានសួគ៌នោះ ដោយហេតុ ១០ ប្រការ គឺ អាយុទិព្យ១ សម្បុរទិព្យ ១ សុខទិព្យ១ យសទិព្យ១ ភាពជាធំដ៏ជាទិព្យ១ រូបទិព្យ១ សំឡេងទិព្យ១ ក្លិនទិព្យ១ រសទិព្យ១ សម្ផស្សទិព្យ១ ។ លុះព្រះតថាគតច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ ។

ព្រះតថាគតមានជើងប្រតិស្ឋានល្អ ដាក់ជើងលើផែនដីក៏ស្មើ លើកឡើងក៏ស្មើ គឺបាតជើងជិតស៊ប់ នឹងផែនដីសព្វផ្ទៃជើង ។ ព្រះតថាគតនោះ ប្រកបហើយដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្ដេចចក្រពត្តិប្រកបដោយធមិជាស្ដេចទ្រង់ធមិ មានជ័យជំនះផ្សាយអំណាចរហូតដល់ផែនដីដែលមានមហាសមុទ្រទាំង ៤ ព័ទ្ធជុំវិញ និងដល់នូវភាពជាអ្នកមាន ជនបទដ៏មាំមួន ប្រកបដោយរតន៍ ទាំង ៧ ប្រការ ។ រតន៍ ៧ ប្រការរបស់ស្ដេចចក្រពត្តិនោះ គឺ ចក្ករតន៍ ១ ហត្ថិរតន៍១ អស្សរតន៍១ មណិរតន៍១ ឥត្ថិរតន៍១ គហបតិរតន៍១ បរិនាយករតន៍១ រួមត្រូវជា ៧ ប្រការ ។ ព្រះរាជបុត្ររបស់ស្ដេចចក្រពត្តិនោះក៏មានចំនួនច្រើនពាន់ ច្រើនតែជាអ្នកក្លៀវក្លា មានរូបសណ្ឋានជាអ្នកអង់អាច អាចញាំញីនូវសេនារបស់ស្ដេចឯទៀតបាន ។ ស្ដេចចក្រពត្តិនោះប្រាបប្រាមគ្រប់គ្រងផែនដីនេះ ដែលមានសាគរជាទីបំផុតឱ្យជាផែនដី ឥតមានគោល ឥតមាននិមិត្ត ឥតមានបន្លា គឺចោរឡើយ ជាផែនដីស្តុកស្តម្ភ មាំមួនក្សេមក្សាន្ត ឥតមានឧបទ្រព ឥតមានទីពួនរបស់ចោរ ដោយធមិស្មើ គឺសីល ៥ មិនបាច់ពឹងអាជ្ញា មិនបាច់ពឹងគ្រឿងសស្ត្រាវុធឡើយ កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់អ្វីនឹងបានជាអ្នកមិនតក់ស្លុត ដោយមនុស្សណាមួយជាសឹកសត្រូវជាបច្ចាមិត្ត កាលបើព្រះតថាគត នៅសោយរាជ្យនឹងបានរបស់នេះឯង ។ បើចេញចាកគេហដ្ឋានទៅបួសនឹងបានត្រាស់ជាអរហន្តសម្មាសម្ពុទ្ធ ក្នុងលោកមានដម្បូល គឺកិលេសបើកចេញហើយ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ បាននូវរបស់អ្វីទើបជាអ្នកមិនតក់ស្លុតដោយសឹកសត្រូវ បច្ចាមិត្តខាង

ក្នុង ឬខាងក្រៅ គឺរាគៈក្តី ទោសៈក្តី មោហៈក្តី សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយក្តីក្នុងលោក (នេះ) ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ បានរបស់នេះឯង ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកបាននាំមកនូវសេចក្តីសុខឱ្យដល់ជនច្រើននាក់ផង ជាអ្នកកំចាត់បង់នូវភ័យ គឺ សេចក្តីភ្ញាក់ផ្អើល និងសេចក្តីតក់ស្លុតផង ជាអ្នកចាត់ចែងនូវការរក្សាការពារគ្រប់គ្រងប្រកបដោយធមិផង បានឱ្យទានព្រមទាំងបរិវារ (របស់ទាន[១១] ផង) ។ ព្រះតថាគតនោះ លុះបែកធ្លាយរាងកាយខាងមុខ អំពីសេចក្តីស្លាប់ ក៏បានទៅកើតក្នុងសុគតិសួគ៌ទេវលោក ព្រោះកុសលកម្មដែលព្រះតថាគតបានធ្វើសន្សំបណ្តុះបណ្តាលឱ្យធំទូលាយនោះឯង ។ ព្រះតថាគត តែងគ្របសង្កត់នូវទេវតាឯទៀត ក្នុងឋានសួគ៌នោះ ដោយហេតុ ១០ ប្រការ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺត្រង់ផ្ទៃជើងទាំងគូខាងក្រោម មានរូបចក្រប្រកបដោយខ្នងកង់ និងដុំ ព្រមទាំងកាំ ១000 មាន ចន្លោះស្មើគ្នាគ្រប់អន្លើ ។

ម្នាលភិក្ខុទាំងឡាយ កាលតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានលះបង់បាណាតិបាត វៀរ

---

[១១] អដ្ឋកថា ថាបរិវាររបស់ទានមាន ១០ ប្រការគឺ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប គ្រែ ឬ តាំងលំនៅ ប្រទីប និងប្រេង ។

ស្រឡះចាកបាណាតិបាត ជាអ្នកដាក់ចុះនូវអាជ្ញា និងគ្រឿងសស្ត្រាវុធ មានសេចក្តីខ្មាសបាប មានចិត្តអាសូរករុណា តែងអនុគ្រោះសព្វសត្វ ដោយប្រយោជន៍ ។ ព្រះតថាគតនោះ ព្រោះបានធ្វើនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះមកកាន់អត្តភាព ជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំង ៣ នេះ គឺជាអ្នកមានកែងជើងវែង ១ មានម្រាមដៃនិងម្រាមជើងវែងៗ ១ មានកាយត្រង់ដូចជាកាយព្រហ្ម ១ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុនកើតជាមនុស្សក្នុងកាលមុនជាអ្នកឱ្យនូវខាទនីយភោជនីយាហារមានរសជាតិដ៏ថ្លៃថ្លា ព្រមទាំងទឹក (៨ប្រការ) ដែលគួរភ្លក្ស គួរលិទ្ធ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកុសលកម្មនោះ ។បេ។ លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈក៏បានទៅកើតក្នុងសុគតិសួគ៌ទេវលោក ។បេ។ លុះព្រះតថាគត នោះច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានសាច់ដ៏ពេញ ក្នុងទីទាំង ៧ អន្លើ គឺ សាច់ពេញត្រង់ខ្នងដៃទាំងពីរ សាច់ពេញត្រង់ខ្នង ជើងទាំងពីរ សាច់ពេញត្រង់ចង្កួយស្មាទាំងពីរ សាច់ពេញត្រង់ ក ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានសង្គ្រោះដល់ពពួកជនដោយសង្គហវត្ថុ ៤ ប្រការ គឺទាន ១ ពាក្យជាទី ស្រឡាញ់ ១ ការប្រព្រឹត្តដែលជាប្រយោជន៍ ១ ការតាំងខ្លួនស្មើ គឺមិនប្រកាន់ខ្លួន១ ។ ព្រះតថាគតនោះ លុះ

បែកធ្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ ក៏បានទៅកើតក្នុងសុគតិសួគ៌ ទេវលោក ព្រោះកុសលកម្មដែលព្រះតថាគតបានធ្វើសន្សំបណ្ដុះបណ្ដាលឱ្យធំទូលាយនោះឯង ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានផ្ទៃដៃ និង ផ្ទៃជើងទន់ល្វន់ (ដូចជាសំឡីដែលគេថ្ពេចអស់ ១០០ ដង) ១ មានផ្ទៃដៃ និងផ្ទៃជើង ប្រទាក់ដោយក្រឡាដូចជាសំណាញ់ ១ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានពោលពាក្យប្រកបដោយប្រយោជន៍ ទាំងប្រកបដោយធម៌ បានពន្យល់ជនច្រើននាក់ តែងនាំមកនូវប្រយោជន៍នឹងសេចក្ដីសុខឱ្យដល់សត្វទាំងឡាយ ជាអ្នកបូជានូវធម្មទាន ។ ព្រោះកុសលកម្ម ដែលព្រះតថាគតបានធ្វើសន្សំឱ្យធំទូលាយហើយនោះ ព្រះតថាគតនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានកជើង ដូចជាអណ្ដែតឡើងខាងលើ១ មានចុងរោមងឡើងលើ១ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានបង្ហាញនូវសិល្បសាស្ត្រ (ថោកទាបនិងសិល្បសាស្ត្រឧត្ដម) ផង នូវវិជ្ជា (ច្រើនប្រការ មានវិជ្ជាស្ដោះពស់ជាដើម) ផង នូវចរណៈ គឺសីល ៥ សីល ៨ ឬសីល១០ ឬ បាតិមោក្ខសំវរសីលផង នូវការងារផង ដោយយកចិត្តទុកដាក់ដោយតាំងចិត្តថា ធ្វើដូចម្ដេចហ្ន៎

ពួកជននេះ បានចេះដឹងឆាប់ បានទទួលសេចក្ដីប្រតិបត្តិឆាប់ កុំឱ្យលំបាកអស់កាលជាយូរអង្វែងឡើយ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានស្នែង រៀវមូលត្រសូលស្រដៀងនឹងស្នែងសត្វទ្រាយ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកចូលទៅរកសមណព្រាហ្មណ៍ ហើយសាកសួរថា បពិត្រលោកដ៏ចម្រើនអំពើដូចម្ដេចជាកុសល អំពើដូចម្ដេចជាអកុសល អំពើដូចម្ដេចដែលប្រកបដោយទោស អំពើដូចម្ដេចដែលមិនប្រកបដោយទោស អំពើដូចម្ដេចគួរសេព អំពើដូចម្ដេចមិនគួរសេព អំពើដូចម្ដេចដែលខ្ញុំធ្វើហើយ ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខអស់កាលយូរអង្វែងមួយទៀត អំពើដូចម្ដេចដែលខ្ញុំធ្វើហើយ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ អស់កាលយូរអង្វែង ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកសាងនូវកុសលកម្ម ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានឆវី (សម្បុរថ្ងៃ) ដ៏ល្អិតផូរផង់ រលីងស្រិល រអិលធូលីធ្លាក់មក ត្រូវមិនជាប់កាយ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកមិនមានសេចក្ដីក្រោធ មិនច្រើនដោយសេចក្ដីចង្អៀតចង្អល់ចិត្ត សូម្បីជនច្រើននាក់ នាំគ្នាស្ដីថា ឱ្យក៏

មិនឈឺចិត្ត មិនក្រោធ មិនចងកំហឹងទុក មិនដម្កល់ទុកនូវសេចក្តីក្រោធ ទាំងមិនបានធ្វើនូវសេចក្តីក្រោធ នូវការប្រទូស្ត និងសេចក្តីតូចចិត្តឱ្យប្រាកដឡើង (ដោយកាយវិការ ឬ វចីវិការ) ឡើយ ព្រះតថាគត ជាអ្នកបានឱ្យនូវកម្រាល និងសម្ពត់ដណ្តប់មានសាច់ល្អិតទន់ល្ហៃ គឺសម្ពត់ធ្វើពីសម្បក ឈើមានសាច់ម៉ដ្ឋ សម្ពត់ធ្វើពីកប្បាសមានសាច់ម៉ដ្ឋ សម្ពត់ធ្វើពីសូត្រមានសាច់ម៉ដ្ឋ សម្ពត់ធ្វើពីរោមសត្វមានសាច់ម៉ដ្ឋ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានពណ៌សម្បុរ (លឿងភ្លឺបំព្រង) ដូចជាសម្បុរនៃមាស និងមានស្បែកជិតស្និទ្ធល្អដូចជាមាស ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានរាប់អាននូវញាតិមិត្តសំឡាញ់ស្និទ្ធស្នាល ដែលព្រាត់ប្រាសនិរាស បាត់មុខយូរហើយផង ជាអ្នករាប់អានមាតាព្រមទាំងកូនផង រាប់អាននូវកូនព្រមទាំងមាតាផង រាប់អានបិតាព្រមទាំងកូនផង រាប់អានកូនព្រមទាំងបិតាផង រាប់អានបិតាព្រមទាំងបងប្អូនប្រុស រាប់អានបងប្អូនប្រុស ព្រមទាំងបងប្អូនស្រីផង រាប់អានបងប្អូនស្រីព្រមទាំងបងប្អូនប្រុសផង ហើយជាអ្នកត្រេកអរក្រៃលែង ព្រោះបានធ្វើគេឱ្យព្រមព្រៀងគ្នាផង ។ ព្រះតថាគតនោះ ព្រោះបានធ្វើនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានអង្គាវយវៈ ដែលត្រូវលាក់ឱ្យ

កំបាំងដោយសម្ពត់ ឋិតនៅក្នុងស្រោម (ដូចជាអង្គជាតនៃដំរី) ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានពិចារណានូវការសង្គ្រោះមហាជន តែងស្គាល់ស្មើ[១២] គឺស្គាល់ថា អ្នកនេះ ស្មើនឹងអ្នកនោះ ស្គាល់ដោយខ្លួនឯង[១៣] ស្គាល់បុរស[១៤] ស្គាល់គុណវិសេសរបស់បុរសថា បុរសនេះគួរទទួលនូវទាននិងគ្រឿងសក្ការៈនេះ បុរសនេះគួរទទួលនូវទាននិងគ្រឿងសក្ការៈនេះ (លុះស្គាល់ដូច្នោះហើយ) ក៏បានធ្វើនូវប្រយោជន៍ប្លែកៗគ្នា តម្រូវទៅតាមគុណវិសេសរបស់បុរសជាន់នោះៗ ។ ព្រះតថាគតនោះ ព្រោះបានធ្វើកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះមកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានបរិមណ្ឌល (នៃកាយ) ដូចជាបរិមណ្ឌលនៃដើមជ្រៃ ១ កាលបើឈរមិនបាច់ឱនខ្លួនចុះ អាចស្ទាបពាល់ជង្គង់ដោយដៃទាំងពីរបាន ១ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នា

---

[១២] ពាក្យថា ស្គាល់ស្មើនោះ គឺស្គាល់ថា ជននេះមានគុណស្មើនឹងជននោះ ហើយស្រុះស្រួលទទួលបុរសនោះតាមវិធីដែលត្រូវទទួល ។ដីកា។

[១៣] ពាក្យថា ស្គាល់ដោយខ្លួនឯង គឺស្គាល់ដោយមិនចាំបាច់ អ្នកឯទៀតមកពន្យល់ឡើយ ។

[១៤] ពាក្យថា ស្គាល់បុរសនោះ គឺស្គាល់ពិតប្រាកដថា បុរសនេះជាន់ខ្ពស់ បុរសនេះជាន់កណ្តាល បុរសនេះជាន់ទាប ។ដីកា ។

នូវប្រយោជន៏ ប្រាថ្នានូវសេចក្តីសុខ ប្រាថ្នាសេចក្តីក្សេមក្សាន្តចាកយោគៈ ដល់ពួកជនច្រើនថា ធ្វើដូចម្តេចជនទាំងនេះនឹងបានចម្រើនដោយសទ្ធា ចម្រើនដោយសីល ចម្រើនដោយសុតៈ ចម្រើនដោយវុឌ្ឍិ ចម្រើនដោយចាគៈ ចម្រើនដោយលោកិយធម៌ ចម្រើនដោយប្រាជ្ញា ចម្រើនដោយទ្រព្យនិងធញ្ញាហារ ចម្រើនដោយស្រែ និងចំការ ចម្រើនដោយសត្វជើងពីរ និងសត្វជើង ៤ ចម្រើនដោយកូននិង ប្រពន្ធ ចម្រើនដោយពួកបុរស ជាទាសៈនិងកម្មករ ចម្រើនដោយពួកញាតិចម្រើន ដោយពួកមិត្ត ចម្រើនដោយពួកផៅពង្ស ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះមកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំង ៣នេះ គឺមានចំណែកកន្លះកាយខាងលើស្រដៀងនឹងចំណែកកន្លះកាយនៃរាជសីហ៍ ១ មានខ្នងពេញស្មើ ឥតមានចង្អូរផត ខ្នងត្រង់កណ្តាល ១ មានកមូលសម ១ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកមិនបៀតបៀនសត្វទាំងឡាយ ដោយដៃ ឬ ដុំដី ឬក៏ដំបង គ្រឿងសស្ត្រាវុធឡើយ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះគឺជាអ្នកមានប្រសាទ គឺសរសៃល្អិត ឆ្ការដ៏លើសលែងសម្រាប់ទទួលរសអាហារឯប្រសាទសម្រាប់ទទួលរសអាហាររបស់ព្រះតថាគតនោះ មានចុង-ងឡើងលើប្រជុំស្រោបត្រង់-ក សម្រាប់ទទួលរសអាហារ ជ្រួតជ្រាបផ្សព្វផ្សាយស្មោះស្មើ

ត្ថា (សព្វសពិង្គកាយ) ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកមិនសំឡក់មើល (ដោយទោសចិត្ត) មិនមៀងមើលដោយចុងភ្នែក មិនលបសំឡក់គេ (ដោយស្អប់) ជាអ្នកមានចិត្តស្មោះត្រង់ រមិលមើលត្រង់ពេញភ្នែក ជាអ្នកសំឡឹងមើលជនច្រើនដោយចក្ខុគួរឱ្យស្រឡាញ់ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកុសលកម្មនោះ ។ល។ លុះព្រះតថាគតនោះច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានភ្នែកខៀវស្រស់ ១ មានកែវភ្នែក ស្រដៀងនឹងកែវភ្នែកកូនគោ ១ ។

ព្រះមំសចក្ខុជាប្រក្រតីរបស់ព្រះមានព្រះភាគ ក្នុងមំសចក្ខុរបស់ព្រះមានព្រះភាគ មានសម្បុរ ៥ គឺ សម្បុរខៀវ ១ សម្បុរលឿង១ សម្បុរក្រហម១ សម្បុរខ្មៅ ១ សម្បុរស១ ។ រោមព្រះនេត្រឋិតនៅត្រង់ទីណា ទីនោះមានសម្បុរខៀវ ខៀវល្អគួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាត្រគៀត ។ ទីក្រៅអំពីនោះ មានសម្បុរលឿង លឿងល្អដូចសម្បុរមាស គួរជ្រះថ្លា គួររមិលមើលស្រដៀងនឹងផ្កាកណ្ណិការ ។ រណ្តៅព្រះនេត្រទាំងពីរខាងរបស់ព្រះមានព្រះភាគ មានសម្បុរក្រហម ក្រហមល្អគួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងអណ្តើកមាស ។ ត្រង់កណ្តាលមានសម្បុរខ្មៅ ខ្មៅល្អ មិនមានសៅហ្មង យ៉ាងស្និទ្ធគួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្លែផ្តាំ ។ ក្រៅអំពីនោះ មានសម្បុរសសល្អ សស្រស់ សសុទ្ធ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាយព្រឹក ។ ព្រះ

មានព្រះភាគ ទ្រង់ទតឃើញជុំវិញចម្ងាយ ១ យោជន៍ ទាំងយប់ទាំងថ្ងៃ ដោយព្រះមំសចក្ខុ តាមប្រក្រតីនោះ ដែលរាប់ចូលក្នុងអត្តភាព កើតអំពីសុចរិតកម្មក្នុងកាលមុន ។ ទោះបីងងឹតប្រកបដោយអង្គ ៤ គឺព្រះអាទិត្យ អស្តង្គត ១ ថ្ងៃឧបោសថ ខាងកាឡបក្ខ ១ ដង ព្រៃដែលញឹក ១ អាកាសមេឃដ៏ធំតាំងឡើង ១ ព្រះមានព្រះភាគ ទ្រង់ទតឃើញជុំវិញចម្ងាយ ១ យោជន៍ ក្នុងទីងងឹតប្រកបដោយអង្គ ៤ សូម្បីមានសភាពយ៉ាងនេះ ។ មិនមានជញ្ជាំង សន្ទះទ្វារ កំពែងភ្នំ គុម្ពឈើ វល្លិ ជាគ្រឿងរារាំង ដើម្បីឃើញរូបទាំងឡាយទេ ។ បើទុកជាគេដាក់គ្រាប់ល្ង ១ គ្រាប់ ក្នុងរទេះពេញដោយល្ង ធ្វើឱ្យមានគ្រឿងចំណាំ ក៏នូវតែព្រះមានព្រះភាគ ទ្រង់រើសយកគ្រាប់ល្ងនោះបានវិញដដែល ។ ព្រះមំសចក្ខុជាប្រក្រតីរបស់ព្រះមានព្រះភាគបរិសុទ្ធយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាចម្បងរបស់ជនច្រើនក្នុងកុសលធម៌ទាំងឡាយ ជាប្រធានរបស់ជនច្រើន ក្នុងកាយសុចរិត វចីសុចរិត មនោសុចរិត ការបរិច្ចាគទាន សមាទានសីល កិរិយារក្សា ឧបោសថ វត្តដែលត្រូវ ធ្វើចំពោះមាតា វត្តដែលត្រូវធ្វើចំពោះបិតា វត្តដែលត្រូវធ្វើចំពោះសមណៈ វត្តដែលត្រូវធ្វើចំពោះព្រាហ្មណ៍ វត្តដែលត្រូវធ្វើចំពោះជន ដែលជាច្បងក្នុង ត្រកូល និងក្នុងពួកកុសលធម៌ដ៏ក្រៃលែងឯទៀតៗ ។ ព្រះតថាគតនោះព្រោះ បានធ្វើកុសលកម្មនោះ ។បេ។ លុះព្រះតថាគត ច្យុតចាកឋានសួគ៌នោះមកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺ ជាអ្នក

មានសីសៈ ដូចជាប្រដាប់ដោយក្បាំងស្រេចស្រាប់ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកលះបង់នូវមុសាវាទ វៀរស្រឡះហើយចាកមុសាវាទ ជាអ្នកនិយាយតែពាក្យពិត បញ្ចេញតែពាក្យពិត ជាអ្នកទៀងត្រង់ និយាយពាក្យគួរឱ្យគេជឿ ជាអ្នកមិនពោលបំភ្លាត់សត្វលោកឡើយ ។ ព្រះតថាគតនោះ ព្រោះបានធ្វើកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិស លក្ខណៈទាំងពីរនេះ គឺជាអ្នកមានរោមក្នុងរណ្ដៅមួយៗតែមួយសរសៃៗ (រាល់រណ្ដៅទាំងអស់) ១ មានរោមប្រជុំចិញ្ចើមដុះត្រង់ចន្លោះ ចិញ្ចើមមានពណ៌សក្បុសទន់ល្វន់ ដូចជាសំឡី ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកលះបង់នូវវាចាស៊កសៀត វៀរស្រឡះហើយចាកវាចាស៊កសៀត ជាអ្នកឮពាក្យអំពីជនឯនេះ មិននាំទៅប្រាប់ជនឯនោះ ដើម្បីបំបែកជនទាំងពីរចំណែកនេះឡើយ ឬបានឮពាក្យអំពីជននោះ មិននាំមកប្រាប់ជនឯនេះ ដើម្បីបំបែកជនឯនោះឡើយ ជាអ្នកផ្សះផ្សានូវជនដែលបាក់បែកគ្នាហើយ ជាអ្នកទំនុកបម្រុងនូវពួកជនដែលព្រមព្រៀងគ្នា ជាអ្នករីករាយនឹងការព្រមព្រៀង ត្រេកអរនឹងការព្រមព្រៀងគ្នា ពេញចិត្តនឹងការព្រមព្រៀងគ្នា និងពោលតែវាចាដែលធ្វើឱ្យកើតសេចក្ដីព្រមព្រៀងគ្នា ។ ព្រះតថាគតនោះ ព្រោះបានធ្វើកុសលកម្មនោះ ។ បេ។ លុះព្រះតថាគតច្យុត

ចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានធ្មេញ ៤០ គត់ ១ មានធ្មេញជិតស្និទ្ធល្អ ១ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានលះបង់នូវផរុសវាចា វៀរស្រឡះហើយចាកផរុសវាចា ជាអ្នកនិយាយ តែពាក្យដែលឥតទោស ពាក្យដែលជាសុខដល់ត្រចៀកគេ គួរឱ្យស្រឡាញ់ គួរឱ្យតាំងទុកក្នុងហឫទ័យ ជាសំដីអ្នកក្រុង ទាំងជាទីស្រឡាញ់នៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកសាងនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានអណ្តាតវែង ១ មានសូរសព្ទ សំឡេងក្រាងក្រអៅ ដូចជាសំឡេងព្រហ្ម កាលបើបញ្ចេញវាចាលាន់ឮពីរោះ ដូចជាសំឡេងសត្វករវិក ១ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកលះបង់នូវសម្ផប្បលាបៈ (ពាក្យរោយរាយ) វៀរស្រឡះហើយចាកសម្ផប្បលាបៈ ជាអ្នកពោលតាមកាលគួរ ពោលតែពាក្យពិត ពោលពាក្យប្រកបដោយហេតុ ពោលពាក្យប្រកបដោយផល ពោលពាក្យទូន្មាន ពោលពាក្យដែលគួរឱ្យអ្នកផងដឹកល់ទុកក្នុងហឫទ័យ ជាពាក្យប្រកបដោយគ្រឿងអាង មានទីបំផុតប្រកបដោយប្រយោជន៍ត្រូវតាមកាល ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំនូវកុសលកម្មនោះ ។បេ។

លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានចង្កាមានសណ្ឋាន ដូចជាចង្កានៃរាជសីហ៍ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន បានលះបង់នូវមិច្ឆាជីវៈ (ការចិញ្ចឹមជីវិតខុស) ចិញ្ចឹមជីវិតដោយសម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ) ជាអ្នកបានវៀរចាកការបញ្ឆោត ឬ បន្លំដោយជញ្ជីង បញ្ឆោតដោយមាស បញ្ឆោតដោយរង្វាល់ រង្វាស់ បង្ខុសបំភាន់ បញ្ឆោតបោកប្រាសនិងបន្លំដោយរបស់បួម វៀរចាកកិរិយាកាត់នូវអវយវៈ មានដៃជាដើម សម្លាប់ ចង ធ្វើមនុស្សឱ្យវង្វេងផ្លូវ ប្លន់ កំហែងយកទ្រព្យ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកសាងកុសលកម្មនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏បានទៅកើត ក្នុងឋានសុគតិសួគ៌ទេវលោក ។ ព្រះតថាគតនោះ គ្របសង្កត់នូវទេវតាឯទៀត ក្នុងឋានសួគ៌នោះ ដោយហេតុ ១០ ប្រការ គឺអាយុទិព្យ ១ សម្បុរទិព្យ ១ យសទិព្យ ១ សុខទិព្យ ១ អធិបតីទិព្យ ១ រូបទិព្យ ១ សំឡេងទិព្យ ១ ក្លិនទិព្យ ១ រសទិព្យ ១ សម្ផស្សទិព្យ ១ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងឡាយពីរនេះ គឺជាអ្នកមានធ្មេញជិតស្និទ្ធល្អ ១ មានចង្កូម (ទាំង៤) សស្អាត ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈទាំងពីរនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិប្រកបដោយធម៌ សោយរាជ្យដោយធម៌ មាន

ជ័យជំនះផ្សាយរាជអំណាចរហូតដល់ផែនដីដែលមានសមុទ្រទាំង ៤ ព័ទ្ធជុំវិញ ទ្រង់ដល់នូវភាពជាអ្នកមាំមួន ក្នុងជនបទប្រកបដោយរតនៈ ៧ ប្រការ ។ រតនៈ ៧ ប្រការនេះ របស់ស្ដេចនោះ គឺ ចក្ករតនៈ ១ ហត្ថិរតនៈ ១ អស្សរតនៈ ១ មណិរតនៈ ១ ឥត្ថីរតនៈ ១ គហបតិរតនៈ ១ បរិនាយករតនៈ ១ រួមត្រូវជា ៧ ប្រការ ។ បុត្ររបស់ស្ដេចចក្រពត្តិនោះ ក៏មានចំនួនច្រើនពាន់ សុទ្ធសឹងតែជាអ្នកក្លៀវក្លា មានរូបសណ្ឋានជាអ្នកក្លៀវក្លា អាចញាំញីនូវសេនារបស់ស្ដេចឯទៀតបាន ។ ទ្រង់ប្រាបប្រាមគ្រប់គ្រងនូវផែនដីនេះដែលមានសាគរជាទីបំផុត ឱ្យជាផែនដីឥតមានគោល ឥតមាននិមិត្ត ឥតមានបន្លាគឺចោរឡើយ ជាផែនដីស្ដុកស្ដម្ភ មាំមួន ក្សេមក្សាន្ត ឥតមានឧបទ្រព ឥតមានទីពួនរបស់ចោរ ដោយធម៌ដ៏ស្មើ មិនបាច់ពឹងអាជ្ញា មិនបាច់ពឹងគ្រឿងសស្ត្រាវុធឡើយ កាលបើនៅជាស្ដេច និងបានរបស់អ្វី គឺនឹងបានជាអ្នកមានបរិវារស្អាតបាត ឯបរិវារស្អាតបាតរបស់ស្ដេចចក្រពត្តិនោះ គឺពួកព្រាហ្មណ៍គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកមហាមាត្រ សេនាមានអង្គ ៤ អ្នករក្សាទ្វារ អាមាត្យ បរិស័ទ ស្ដេចចំណុះ អ្នកមានភោគសម្បត្តិនិងព្រះរាជកុមារ កាលបើនៅជាស្ដេចនឹងបានរបស់នេះឯង ។ បើព្រះតថាគត ចេញចាកគេហដ្ឋានទៅបួស នឹងបានត្រាស់ជាអរហន្តសម្មាសម្ពុទ្ធក្នុងលោក (នេះ) មានដម្បូលគឺរាគាទិក្កិលេស បើកចេញហើយ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានបរិវារស្អាតបាត ឯបរិវារស្អាតបាតរបស់តថាគតនោះ គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាលបើព្រះតថាគត បាន

ត្រាស់ជា ព្រះពុទ្ធ នឹងបានរបស់នេះឯង ។

លុះព្រះមានព្រះភាគបានសំដែងលក្ខណៈសូត្រនេះចប់ហើយ ។ ពួកភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ មហាបុរិសលក្ខណៈ៣២ ប្រការ

បិដកលេខ១៩ ទំព័រ ១

# ២៥ ឥរិយាបថរបស់ព្រះសម្ពុទ្ធ

កិត្តិសព្ទនៃព្រះគោតមដ៏ចម្រើននោះ ខ្ចរខ្ចាយសុះសាយទៅមានប្រការដូច្នេះ

ព្រះគោតមដ៏ចម្រើននោះ កាលដែលទ្រង់ពុទ្ធដំណើរទៅ រមែងទ្រង់ឈានព្រះបាទខាងស្ដាំទៅជាមុន ព្រះអង្គលើកជំហានព្រះបាទមិនឆ្ងាយពេក ដាក់ព្រះបាទមិនជិតពេក ព្រះអង្គទ្រង់ពុទ្ធដំណើរទៅមិនរហ័សពេក ទ្រង់ពុទ្ធដំណើរទៅមិនយឺតពេក ទ្រង់ពុទ្ធដំណើរទៅ មិនទង្គិចព្រះជានុដោយព្រះជានុ ទ្រង់ពុទ្ធដំណើរទៅមិនទង្គិចព្រះគោប្ផកៈ (កែងជើង) ដោយព្រះគោប្ផកៈ ព្រះគោតមនោះ កាលដែលទ្រង់ពុទ្ធដំណើរទៅមិនលើកព្រះឩរូ (ភ្លៅ) ទៅខាងមុខ មិនសណ្ដូកព្រះឩរូ មកខាងក្រោយ មិនធ្វើព្រះឩរូឱ្យ ជាប់រឹងស្ទូក មិនកែក្រាយព្រះឩ ,រូព្រះគោតមដ៏ចម្រើននោះ កាលដែលទ្រង់ពុទ្ធដំណើរទៅមានព្រះកាយខាងលើ រឹងប៉ឹងមិនបានកំរើក មិនទ្រង់ពុទ្ធដំណើរទៅដោយកំឡាំងព្រះកាយឡើយ ព្រះ គោតមដ៏ចម្រើននោះ កាលដែលទតព្រះនេត្រក្រឡេកមើល រមែងក្រឡេកមើល ទៅដោយទាំងកាយព្រះអង្គមិនបានងើយទតទៅខាងលើ មិនបានឈ្ងោកទត ទៅខាងក្រោម ទ្រង់ពុទ្ធដំណើរទៅមិនក្រឡេកទតទិសផ្សេងៗ ទ្រង់ក្រឡេកទតទៅតែប្រមាណមួយជួរនឹម[១៥] ប៉ុន្តែឯញាណទស្សនៈដែលមិនមានអ្វីរាំងរារបស់

[១៥] មួយជួរនឹមនោះ ប្រមាណ ៩ ចំអាម (អដ្ឋកថា) ។

ព្រះគោតមនោះ រមែងមានលើសលុបជាងមួយជួរនឹមនោះឯង ។ ព្រះគោតមនោះ កាលដែលចូលទៅកាន់ចន្លោះផ្ទះ មិនដកព្រះកាយឡើងលើ មិនបន្ទន់ព្រះកាយចុះក្រោម មិនទប់ទល់ព្រះកាយឱ្យរឹង មិនគ្រលែងព្រះកាយ ។ ព្រះគោតមនោះ ទ្រង់បែរព្រះកាយមិនឆ្ងាយពេក មិនជិតពេកអំពីអាសនៈ ទ្រង់គង់លើអាសនៈ មិនយកបាតព្រះហស្តច្រត់អាសនៈ មិនផ្អែកព្រះកាយទៅលើអាសនៈ ។ ព្រះគោតមនោះ កាលដែលទ្រង់គង់ក្នុងចន្លោះផ្ទះ មិនរពឹសព្រះហស្ត មិនរពឹសព្រះបាទា មិនគង់លើកព្រះជានុតម្រួតលើព្រះជានុ មិនគង់លើកព្រះគោប្ផកៈតម្រួតលើព្រះគោប្ផកៈ មិនគង់យកបាតព្រះហស្តទល់ព្រះហនុកៈ ។ ព្រះគោតមនោះ កាលដែលទ្រង់គង់ក្នុងចន្លោះផ្ទះ តែងមិនរំភើប មិនញាប់ញ័រ មិនរន្ធត់ មិនតក់ស្លុត ព្រះអង្គជាបុគ្គលមិនរំភើបផង មិនញាប់ញ័រផង មិនរន្ធត់ផង មិនតក់ស្លុតផង ប្រាសចាកសេចក្តីព្រឺរោមផង មានព្រះហឫទ័យបែរទៅរកសេចក្តីស្ងាត់ ។ កាលដែលព្រះអង្គទ្រង់ទទួលបាយ មិនលើកបាត្រឡើងឱ្យខ្ពស់ពេក មិនដាក់បាត្រឱ្យទាបពេក មិនទប់ទល់បាត្រឱ្យរឹង មិនគ្រលែងបាត្រ ។ ព្រះអង្គទ្រង់ទទួលបាយ មិនឱ្យតិចពេក មិនឱ្យច្រើនពេក ។ មួយទៀត ព្រះគោតមដ៏ចម្រើននោះ ទ្រង់ទទួលម្ហូបហើយ ទ្រង់សោយភត្តដោយល្មម ប្រមាណដល់ម្ហូប[១៦] មិនសោយម្ហូបឱ្យលើសលប់ពំនូតភត្ត ឬ មិនសោយភត្តឱ្យលើសលប់ម្ហូបឡើយ ។ ព្រះគោតមដ៏ចម្រើននោះ

[១៦] បរិភោគអាហារឱ្យមានបាយជាភាគទី៤ គឺចំនួនម្ហូប ៣ ភាគ បាយ ១ ភាគ ជាភាគទី ៤ នេះជាកំណត់យ៉ាងច្រើនបំផុត ។ (អដ្ឋកថា) ។

ទ្រង់គ្រលៀវពំនូតភត្តក្នុងព្រះឱស្ឋកំណត់ត្រឹមពីរបីដង ហើយទ្រង់លេបទៅ ។ ឯសាច់ភត្តបន្ទិចបន្តួច ដែលមិនទាន់ល្អិត ក៏មិនចូលទៅកាន់ព្រះកាយរបស់ព្រះអង្គឡើយ ។ លុះតែមិនសល់សាច់ភត្តបន្តិចបន្តួច នៅក្នុងព្រះឱស្ឋព្រះអង្គ ។ ទើបព្រះអង្គបង្អោននូវពំនូតភត្តដទៃទៀតឱ្យចូលទៅ ។ ព្រះគោតមដ៏ចម្រើននោះ ទ្រង់សោយអាហារ ទ្រង់ឆ្ងាញ់ពិសាតែរសអាហារប៉ុណ្ណោះ មិនបានឆ្ងាញ់ពិសា ព្រោះតម្រេកក្នុងរសអាហារឡើយ ។ ព្រះគោតមដ៏ចម្រើននោះ ទ្រង់សោយអាហារប្រកបដោយអង្គ ៨ គឺទ្រង់សោយដើម្បីនឹងលេង ក៏ទេ ដើម្បីនឹងឱ្យកើតសេចក្តីស្រវឹងក៏ទេ ដើម្បីនឹងប្រដាប់រាងកាយក៏ទេ ដើម្បី នឹងស្អិតស្អាងរាងកាយក៏ទេ ដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុំាង ជីវិតិន្ទ្រិយឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចារ្យ ទ្រង់ពិចារណាថា អាត្មាអញនឹងកំចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានចេញផង និងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណមិនឱ្យកើត ឡើងបានផង កិរិយាប្រព្រឹត្តទៅ (នៃឥរិយាបថទាំង ៤) ក្តី សេចក្តីមិនមាន ទោស (មានមិនប្រអូសកាយ មិនច្រអូសចិត្តជាដើម) ក្តី កិរិយានៅសប្បាយក្តី នឹងមានដល់អាត្មាអញ ។ លុះព្រះអង្គសោយរួចហើយ កាលដែលទ្រង់ទទួលទឹកលាងបាត្រ មិនលើកបាត្រឡើងឱ្យខ្ពស់ពេក មិនដាក់បាត្រឱ្យទាបពេក មិនទប់ទល់បាត្រឱ្យរឹង មិនបានគ្រវែងបាត្រ ។ ព្រះអង្គទ្រង់ទទួលទឹកលាងបាត្រ មិនឱ្យតិចពេក មិនឱ្យច្រើនពេក ។ ព្រះអង្គលាងបាត្រ មិនធ្វើឱ្យឮសូរខ្លូកខ្លូក

ទ្រង់លាងបាត្រមិនបង្វិលបាត្រឱ្យវិលជុំវិញ មិនដាក់បាត្រលើផែនដី ហើយលាងព្រះហស្តឡើយ ។ កាលដែលលាងព្រះហស្តហើយស្រេច បាត្រក៏លាងហើយស្រេច កាលដែលលាងបាត្រហើយស្រេច ព្រះហស្តក៏លាងហើយស្រេចដែរ ។ ព្រះអង្គទ្រង់ចាក់ ទឹកលាងបាត្រក្នុងទីមិនឆ្ងាយពេក មិនជិតពេក ទ្រង់មិនបាចសាចផ្តេសផ្តាសឡើយ ។ លុះព្រះអង្គ សោយរួចហើយ មិនដាក់បាត្រលើផែនដី ទ្រង់ទុកបាត្រក្នុងទីមិនឆ្ងាយពេក មិនជិតពេក ព្រះអង្គមិនមែនជាមិនត្រូវការដោយបាត្រទេ ទាំងទ្រង់រក្សាបាត្រ មិនឱ្យហួសវេលា ។ លុះព្រះអង្គសោយរួចហើយ ទ្រង់គង់ស្ងៀមមួយស្របក់ ។ ព្រះអង្គមិនញ៉ាំងកាលនៃមនុស្ស អ្នកត្រូវការដោយអនុមោទនាឱ្យកន្លងហួសទៅឡើយ ។ លុះព្រះអង្គសោយរួចហើយទ្រង់អនុមោទនា មិនតិះដៀលភត្តនោះ មិនប្រាថ្នានូវភត្តដទៃទៀតឡើយ ។ ព្រះអង្គទ្រង់ ញ៉ាំងបរិស័ទនោះឱ្យឃើញច្បាស់ ឱ្យកាន់យក ឱ្យអាចហ៊ានឱ្យរីករាយ ដោយធម្មីកថា ដោយពិត ។ លុះព្រះអង្គទ្រង់ញ៉ាំងបរិស័ទនោះឱ្យឃើញច្បាស់ ឱ្យកាន់យក ឱ្យអាចហ៊ាន ឱ្យរីករាយ ដោយធម្មីកថាហើយក៏ក្រោកអំពីអាសនៈចេញទៅ ។ ព្រះអង្គទ្រង់ស្តេចទៅមិនបានលឿនពេក មិនបានយឺតពេក ទ្រង់ស្តេចទៅមិនប្រាថ្នានឹងឃ្លាតឆ្ងាយអំពីបរិស័ទឡើយ ។ ចីវរក្នុងកាយរបស់ព្រះគោតមដ៏ចម្រើននោះ មិនឡើងលើពេក មិនចុះក្រោមពេក[១៧] មិនទទឹកស្អិតជាប់នៅក្នុងកាយដោយញើសក្អែល ទាំងមិនរបូតចាកកាយឡើយ ។

[១៧] ភិក្ខុដែលឃ្លុំចីវរឱ្យឡើងលើដរាបដល់ទល់នឹងឆ្អឹងចង្កា ហៅថា ឡើងលើពេក ។ ភិក្ខុដែលឃ្លុំចីវរ ឱ្យចុះក្រោមដរាប ដល់កជើងហៅថា ចុះក្រោមពេក ។

ខ្យល់[១៨] ក៏មិនបកសើយចីវរអំពីកាយរបស់ព្រះគោតមដ៏ចម្រើននោះ ។ ធូលីនិងក្អែល ក៏មិនជិតជាប់នៅក្នុងកាយរបស់ព្រះគោតមដ៏ចម្រើននោះ ។ ព្រះគោតមនោះ ស្ដេចទៅកាន់អារាម ទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ លុះគង់រួចហើយ ទ្រង់លាងព្រះបាទ ។ ព្រះគោតមដ៏ចម្រើននោះ ទ្រង់មិនបានខ្វល់ខ្វាយក្នុងការប្រកបគ្រឿងប្រដាប់ព្រះបាទទេ ។ លុះព្រះអង្គទ្រង់លាងព្រះបាទរួចហើយ ក៏គង់ផ្គត់ព្រះភ្នែនតម្កល់កាយឱ្យត្រង់ ផ្ចង់ស្មារតីឱ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។ ព្រះអង្គមិនទ្រង់ ព្រះតម្រិះដើម្បីបៀតបៀនខ្លួនឯង មិនទ្រង់ព្រះតម្រិះ ដើម្បីបៀតបៀនអ្នកដទៃ មិនទ្រង់ព្រះតម្រិះ ដើម្បីបៀតបៀន ទាំងពីរខាង ។ ព្រះគោតមដ៏ចម្រើននោះ ទ្រង់គង់ត្រិះរិះតែអំពីប្រយោជន៍នៃសត្វលោកទាំងអស់ គឺប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃ ឬប្រយោជន៍ទាំងពីរខាង ។ ព្រះអង្គស្ដេចទៅកាន់អារាម ទ្រង់សំដែងធម៌ក្នុងកណ្ដាលបរិស័ទ មិនបានលើកបញ្ជោរបរិស័ទនោះ មិនបានតិះដៀលបរិស័ទនោះ ទ្រង់ញុំាងបរិស័ទនោះឱ្យឃើញច្បាស់ ឱ្យកាន់យក ឱ្យអាចហ៊ាន ឱ្យរីករាយ ដោយធម្មីកថាតាមពិត ។ ព្រះគោតមដ៏ចម្រើននោះ ទ្រង់មានព្រះសូរសេង[១៩] ប្រកបដោយអង្គ ៨ លាន់ចេញអំពីព្រះឱស្ឋ គឺព្រះសូរសៀងជ្រះស្រឡះ ១ ញុំាងបុគ្គលឱ្យដឹងសេចក្ដីច្បាស់ ១ ទន់ពីរោះ ១ គួរស្ដាប់ ១ ណែន ១ មិនរាត់រាយគឺព្រះសូរសៀងមូល ១ ក្រអួន ១ កងរំពង ១ ។ ព្រះគោតមដ៏ចម្រើន ទ្រង់ញុំាងបរិស័ទ ឱ្យដឹងច្បាស់

---

[១៨] ទុកជាខ្យល់កំបុតត្បូង ក៏មិនអាចបក់ឱ្យកក្រើកបានដែរ ។ អដ្ឋកថា ។

[១៩] សូរសេង គឺសូរសំឡេង សៀមយកទៅប្រើក្លាយជាសូរសៀង ។

ដោយព្រះសូរសៀង យ៉ាងណា ព្រះសូរសៀង របស់ព្រះគោតមនោះ ក៏មិនផ្សាយចេញទៅខាងក្រៅអំពីបរិស័ទ យ៉ាងនោះ ។ ឯពួកបរិស័ទទាំងនោះ លុះព្រះគោតមដ៏ចម្រើននោះ ឱ្យឃើញច្បាស់ ឱ្យកាន់យក ឱ្យអាចហ៊ាន ឱ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ រមិលមើលមិនបាន លះបង់ (នូវសេចក្តីសរសើរអំពីធម្មកថា) ហើយចៀសចេញទៅដោយពាក្យថា ម្នាលគ្នាយើង យើងបានឃើញព្រះគោតមដ៏ចម្រើននោះ កំពុងស្តេចទៅ យើងបានឃើញព្រះគោតម ទ្រង់ឈរ យើងបានឃើញព្រះគោតម ទ្រង់ចូលទៅកាន់ចន្លោះផ្ទះ យើងបានឃើញព្រះគោតមគង់ស្ងៀមក្នុងចន្លោះផ្ទះ យើងបានឃើញព្រះគោតមកំពុងសោយក្នុងចន្លោះផ្ទះ យើងបានឃើញព្រះគោតម សោយរួចហើយ ទ្រង់គង់ស្ងៀម យើងបានឃើញព្រះគោតម សោយរួចហើយ ទ្រង់អនុមោទនា យើងបានឃើញព្រះគោតម ស្តេចមកកាន់អារាម យើងបានឃើញព្រះគោតមស្តេចទៅកាន់អារាមគង់ស្ងៀមយើងបានឃើញ ព្រះគោតមស្តេចទៅកាន់អារាម ទ្រង់សំដែងធម៌ក្នុងកណ្តាលបរិស័ទ ព្រះគោតម ដ៏ចម្រើននោះប្រាកដដូច្នេះផងប្រាកដ ដូច្នេះផងក្រៃលែងជាងនោះទៅទៀតផង ។

ចប់ ឥរិយាបថរបស់ព្រះពុទ្ធ

បិដកលេខ២៥ ទំព័រ ១១

## ២៦ បុព្វកម្មបិលោតិ នាម ពុទ្ធាបទាន

ព្រះលោកនាយក មានភិក្ខុសង្ឃច្រើនចោមរោម ទ្រង់គង់លើផ្ទៃនៃថ្ម ជាទីរីករាយ ជិតស្រះ អនោតត្ត រុងរឿងដោយរតនៈផ្សេងៗ ក្នុងចន្លោះនៃព្រៃ មានក្លិនផ្កាផ្សេងៗ ទ្រង់ព្យាករណ៍នូវបុព្វកម្មរបស់ព្រះអង្គ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវអំពើរបស់តថាគត ដែលបានធ្វើទុកមកហើយ ដូចតទៅនេះ តថាគតបានឃើញនូវភិក្ខុមួយរូបនៅក្នុងព្រៃ ហើយបានប្រគេនកំណាត់សំពត់ ។ ក្នុងកាលនោះ តថាគតបានប្រាថ្នាជាព្រះសម្ពុទ្ធ ជាដំបូងដើម្បីការត្រាស់ដឹង ឯសេចក្តីប្រាថ្នានោះ ក៏ឱ្យផលក្នុងការបានត្រាស់ជាព្រះពុទ្ធ ដោយអំណាចនៃបិលោតិកម្ម ។ ក្នុងកាលមុន តថាគតកើតជានាយគោបាល កៀងមេគោទៅកាន់ទីគោចរ បានឃើញមេគោកំពុងផឹកទឹកល្អក់ ហើយដេញចេញ ។ ដោយវិបាកនៃកម្មនោះ ក្នុងបច្ឆិមភពនេះ តថាគត ស្រេកទឹក ហើយមិនបានផឹកដូចសេចក្តីប្រាថ្នា ។ កាលភពមុន ក្នុងជាតិដទៃ តថាគតជាអ្នកលេង ឈ្មោះបុនាលិ បានពោលបង្កាច់នូវព្រះបច្ចេកពុទ្ធ ព្រះនាមសុរភិ ព្រះអង្គជាបុគ្គលមិនប្រទូស្តឡើយ ។ ដោយវិបាកនៃកម្មនោះ តថាគតអន្ទោលទៅក្នុងនរក អស់កាលដ៏យូររងទុក្ខវេទនា អស់ពាន់នៃឆ្នាំដ៏ច្រើន ។ ដោយ

សំណល់នៃកម្មនោះ ក្នុងបច្ឆិមភពនេះ តថាគត បាននូវការពោលបង្កាច់ ព្រោះហេតុនៃនាងសុន្ទរិកា ។ មួយទៀត តថាគតពោលបង្កាច់សាវ័កឈ្មោះនន្ទៈរបស់ព្រះពុទ្ធ ទ្រង់គ្រប់សង្កត់នូវសត្វលោកទាំងពួង តថាគតបានអន្ទោលទៅក្នុងនរកអស់កាលដ៏យូរ ព្រោះការពោលបង្កាច់នូវសាវ័កនោះ ។ តថាគតបានអន្ទោលទៅក្នុងនរក អស់កាលដ៏យូរចំនួនមួយហ្មឺនឆ្នាំ លុះតថាគត បានមកជាមនុស្សក៏បាននូវការពោលបង្កាច់ជាច្រើន ។ ដោយសំណល់នៃកម្មនោះ នាងចិញ្ចាមានវិកាមកពោលបង្កាច់តថាគត ក្នុងប្រជុំជនដោយពាក្យមិនពិត។ តថាគតកើតជាព្រាហ្មណ៍ តែងជាអ្នកចេះមន្ត មានគេធ្វើសក្ការបូជា បង្ហាញមន្តដល់មាណព ៥០០ នាក់ក្នុងព្រៃធំ ។ ឥសីភិមៈ បានអភិញ្ញា ៥ មានឫទ្ធិច្រើន មកក្នុងទីនោះ តថាគតបានឃើញឥសីនោះ លោកជាអ្នកមិនប្រទូស្ត និមន្តមកក៏បានពោលបង្កាច់ ។ លំដាប់នោះ តថាគតនិយាយនឹងពួកសិស្សថា ឥសីនេះ ជាអ្នកបរិភោគកាម ។ កាលតថាគតនិយាយប្រាប់ ឯពួកមាណព ក៏បានរីករាយតាម ។ លំដាប់នោះមាណពទាំងអស់ ត្រាច់ទៅសូមក្នុងត្រកូលតូចធំ និយាយប្រាប់មហាជនថា ឥសីនេះជាអ្នកបរិភោគកាម ដោយវិបាកនៃកម្មនោះ ភិក្ខុទាំងអស់ចំនួន ៥០០ នេះ ក៏បាននូវការពោលបង្កាច់ ព្រោះហេតុនៃនាងសុន្ទរិកា ។ កាលភពមុន តថាគតសម្លាប់បងប្រុសម្នាក់ មានមាតាផ្សេងគ្នា ព្រោះហេតុនៃទ្រព្យ ហើយបោះចោលទៅក្នុងជ្រោះភ្នំឱ្យប៉ះនឹងថ្ម ។ ដោយវិបាកនៃកម្មនោះ ទេវទត្តបានប្រមៀលថ្ម ដុំថ្មក៏រមៀលមកប៉ះអង្គុដ្ឋបាទ (មេជើង) នៃតថាគត ។ កាលពីជាតិមុន តថាគតជាទារក កំពុងលេងក្នុងផ្លូវធំ បានឃើញព្រះបច្ចេកពុទ្ធ ក៏ដុត

ព្រៃទាំងមូលក្បែរផ្លូវ ។ ដោយវិបាកនៃកម្មនោះ ក្នុងបច្ឆិមភពនេះ ទេវទត្តក៏ប្រើខ្មាន់ធ្នូ ឱ្យសម្លាប់តថាគត ។ កាលពីជាតិមុន តថាគតកើតជាហ្មដំរី បានបរដំរីបំព្រៃព្រះបច្ចេកមុនីដ៏ឧត្តម ព្រះអង្គកំពុងត្រេចទៅដើម្បីបិណ្ឌបាត ។ ដោយវិបាកនៃកម្មនោះ ដំរីនាឡាគីរីចុះប្រេងកាច ចូលមកព្រៃតថាគត ក្នុងគិរិព្វជបុរីដ៏ប្រសើរ (រាជគហៈ) ។ តថាគតកើតជាស្តេច ឈ្មោះបត្តិកៈ បានយកលំពែងសម្លាប់បុរសទាំងឡាយ ដោយវិបាកនៃកម្មនោះ តថាគតឆេះក្នុងភ្លើងនរកដ៏ក្លាខ្លាំង ។ ដោយសំណល់នៃកម្មនោះ ក្នុងកាលឥឡូវនេះ កម្មវិបាកនោះ ក៏ធ្វើឱ្យរបកស្បែកជើងទាំងអស់របស់តថាគត ព្រោះថាកម្មនៅមិនទាន់វិនាស ។ តថាគត កើតជាទារកនៃព្រានត្រី ក្នុងកេវដ្តគ្រាម បានឃើញពួកជនអ្នកសម្លាប់ត្រី ក៏កើតសោមនស្ស ។ ដោយវិបាកនៃកម្មនោះ ស្តេចវិដដុភៈសម្លាប់ពួកសាក្យៈ ក្នុងកាលណា ទុក្ខក្នុងក្បាលក៏មានដល់តថាគត (ក្នុងកាលនោះ) ព្រោះពួកសាក្យត្រូវគេសម្លាប់ ។ តថាគតបានពោលផ្តន្ទា នូវពួកសាវ័កក្នុងសាសនានៃព្រះពុទ្ធព្រះនាម បុស្សៈថា ចូរលោកទាំងឡាយទំពាស៊ីបរិភោគនូវបាយដំណើបចុះ កុំបរិភោគនូវបាយស្រូវសាលីឡើយ ។ ដោយវិបាកនៃកម្មនោះ ក្នុងកាលនោះ តថាគតនៅក្នុងស្រុកវេរញ្ជា ព្រាហ្មណ៍និមន្តឱ្យឆាន់តែបាយដំណើបអស់ ៣ ខែ ។ តថាគតបានហាមឃាត់កូនអ្នកចំបាប់ ក្នុងកាលដែលគ្មានព្រះពុទ្ធត្រាស់ ដោយវិបាកនៃកម្មនោះ ជម្ងឺខ្នងក៏កើតឡើងដល់តថាគត ។ តថាគតកើតជាពេទ្យ បានដាក់ថ្នាំបញ្ចុះសេដ្ឋីបុត្ត ដោយវិបាកនៃកម្មនោះ ជម្ងឺចុះឈាមក៏កើតឡើងដល់តថាគត ។ ក្នុងភពមួយនោះ តថាគតកើតជាជោតិបាល បានផ្ចាញ់ផ្ចាល់

ព្រះសុគត ព្រះនាមកស្សបៈថា ព្រោះអ្វីក៏ថា ត្រាស់ដឹងពោធិញ្ញាណជាទីផ្លូវផង់ គេរកបាន ដោយកម្រក្រៃលែង ។ ដោយវិបាកនៃកម្មនោះ តថាគតប្រព្រឹត្ត ទុក្ករកិរិយាជាច្រើន ក្នុងឧរុវេលាប្រទេសអស់ ៦ វស្សា ទើបបានត្រាស់ដឹងឡើង ។ តថាគតមិនបាននូវពោធិញ្ញាណដ៏ឧត្តមដោយផ្លូវនុ៎ះទេ តថាគតហេតុតែបុព្វកម្ម នោះដាស់តឿន ក៏ស្វែងរកតាមផ្លូវខុស ។ តថាគត មានបុណ្យ និង បាបអស់ រលីងហើយ បានវៀរបង់នូវកំដៅទាំងពួង មិនមានសេចក្តីសោក មិនមានសេចក្តី ចង្អៀតចង្អល់ មិនមានអាសវៈ នឹងបរិនិព្វាន ។ ព្រះជិនស្រី ទ្រង់ដល់នូវអភិញ្ញា និងពលៈទាំងពួង បានព្យាករណ៏ដោយសេចក្តីពិស្តារ ដល់ភិក្ខុសង្ឃជិតមហាស្រះ ឈ្មោះអនោតត្តៈ ដូចរៀបរាប់មកនេះឯង ។

បានឮថា ព្រះមានព្រះភាគ បានសំដែងនូវពុទ្ធាបទាន ឈ្មោះបុព្វកម្ម បិលោតិ ជាធម្មបរិយាយ ដែលជាបុព្វចរិតរបស់ព្រះអង្គ ដោយប្រការដូច្នេះ ។

ចប់ បុព្វកម្មបិលោតិ នាម ពុទ្ធាបទាន ។

(បិដកលេខ ៧៤ ទំព័រ ១២៤)

## ២៧ ព្រះមានព្រះភាគទ្រង់ដាក់ព្រះជន្ម និងបរិនិព្វាន

(បិដកលេខ១៦ទំព័រ ២១៥)

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅ ទ្រង់បិណ្ឌបាត ក្នុងក្រុងវេសាលី លុះទ្រង់ត្រេចទៅបិណ្ឌបាត ក្នុងក្រុងវេសាលីហើយ ត្រឡប់អំពីបិណ្ឌបាតក្នុងវេលាខាងក្រោយភត្តហើយ

ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកកាន់យកនិសីទនៈ[២០] ទៅ យើងនឹងចូលទៅសំរាកក្នុងវេលាថ្ងៃ ឯបាវាលចេតិយ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏កាន់និសីទនៈទៅតាម១ខាងក្រោយព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគស្តេចចូលទៅកាន់បាវាលចេតិយ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលព្រះអានន្ទ ក្រាលថ្វាយ ។ ចំណែកខាងព្រះអានន្ទមានអាយុ ក៏ក្រាបថ្វាយ បង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទ មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូល ដូច្នេះថា ម្នាលអានន្ទ ក្រុងវេសាលីជាទីគួរត្រេកអរ ឧទេនចេតិយជាទីគួរត្រេកអរ គោតមកចេតិយជាទីគួរត្រេកអរ សត្តម្ពចេតិយជាទីគួរត្រេកអរ ពហុបុត្តចេតិយជាទីគួរត្រេកអរ សារន្ទទចេតិយជាទីគួរត្រេកអរ បាវាលចេតិយជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើរឿយ១ហើយ ធ្វើឱ្យដូចជាយានហើយ ធ្វើឱ្យជាទីនៅហើយ បានតាំងទុករឿយ១ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បុគ្គលនោះ បើប្រាថ្នានឹងស្ថិតនៅ គប្បីស្ថិតនៅអស់ ១ អាយុកប្ប[២១] ឬលើសជាង ១ អាយុ កប្បក៏បាន ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ ព្រះតថាគត

---

[២០] ១អដ្ឋកថា និសីទនៈក្នុងទីនេះគឺចម្មខណ្ឌ ។

[២១] កំណត់អាយុរបស់មនុស្សដែលពេញគ្រប់គ្រាន់តាមកាលតាមសម័យ ហៅថា អាយុកប្បដូចក្នុងសម័យព្រះពុទ្ធជាម្ចាស់យើងនេះ អាយុកប្បកំណត់ ១ រយឆ្នាំ ។

បានចម្រើនហើយ បានធ្វើរឿយៗ ហើយ បានធ្វើឱ្យដូចជាយានហើយ ធ្វើឱ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់ ១ អាយុកប្ប ឬ លើសជាង ១ អាយុកប្បក៏បាន ។ ទុកជាព្រះមានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱភាសជាឱឡារិក យ៉ាងនេះហើយ ព្រះអានន្ទ មានអាយុ ក៏មិនអាចនឹង យល់សេចក្តីច្បាស់លាស់បាន មិនបានអារាធនា ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់ ១ អាយុកប្ប សូមព្រះសុគតឋិតនៅអស់ ១ អាយុកប្ប ដើម្បីប្រយោជន៏ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៏ ដើម្បីសេចក្តីសុខដល់ពួកទេវតានិងមនុស្ស ដូច្នេះសោះ ព្រោះមារចូលមកជ្រែកគំនិត ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលជាគម្រប់ ២ ដងផង ។ ល។ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូល នឹងព្រះអានន្ទ មានអាយុជាគម្រប់ ៣ ដងផងថា ម្នាលអានន្ទ ក្រុងវេសាលីជាទីគួរត្រេកអរ ឧទេនចេតិយជាទីគួរត្រេកអរ គោតមកចេតិយជាទីគួរត្រេកអរ សត្តម្ពចេតិយជាទីគួរត្រេកអរ ពហុបុត្តចេតិយជាទីគួរត្រេកអរ សារន្ទទចេតិយជាទីគួរត្រេកអរ បាវាលចេតិយជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើរឿយៗហើយ ធ្វើឱ្យដូចជាយានហើយ ធ្វើឱ្យជាទីនៅហើយ បានតាំងទុករឿយៗហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បុគ្គលនោះ បើប្រាថ្នានឹងស្ថិតនៅ គប្បីស្ថិត

នៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ ព្រះតថាគត បានចម្រើនហើយ បានធ្វើរឿយៗ ហើយ បានធ្វើឱ្យដូចជាយានហើយ ធ្វើឱ្យជាទីនៅហើយ បានតាំងទុករឿយៗហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ បើប្រាថ្នានឹងឋិតនៅគប្បីឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន ។ ទុកជាព្រះមានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱភាសជាឱឡារិក យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏នៅតែមិនអាចនឹងយល់សេចក្តីច្បាស់លាស់បានឡើយ ហើយមិនបានអារាធនា ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគឋិតនៅអស់ ១ អាយុកប្ប សូមព្រះសុគតឋិតនៅអស់ ១ អាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សដូច្នេះឡើយ ព្រោះមារចូលមកជ្រែកគំនិត ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ អ្នកចូរទៅចុះ អ្នកចូរដឹងនូវកាលដែលគួរនឹងទៅក្នុងកាលឥឡូវនេះចុះ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូល ព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ រួចក៏ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយអង្គុយទៀបគល់ឈើមួយ ក្នុងទីមិនឆ្ងាយ ។

កាលបើព្រះអានន្ទមានអាយុ ចេញទៅហើយមិនយូរប៉ុន្មាន គ្រានោះក្រុងមារមានចិត្តបាប ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ

បានឋិតនៅក្នុងទីដ៏សមគួរ ។ លុះក្រុងមារមានចិត្តបាប ឋិតនៅក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ បរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគបានត្រាស់វាចានេះហើយថា នែមារមានចិត្តបាប ពួកភិក្ខុជាសាវ័ករបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រង់ធម៌ បដិបត្តិធម៌សមគួរដល់ធម៌ប្រតិបត្តិដ៏សមគួរប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្ដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឱ្យងាយបាន ទាំងមិនទាន់បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឱ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អតាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យ ដរាបណាទេ តថាគត នឹងមិនទាន់បរិនិព្វានដរាបនោះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើនឥឡូវនេះ ពួកភិក្ខុជាសាវ័ករបស់ព្រះមានព្រះភាគ បានឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្ដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឱ្យងាយបានហើយ ទាំងសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឱ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យបានហើយ បពិត្រព្រះមានព្រះភាគដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគបរិនិព្វានទៅ សូម

ព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះមានព្រះភាគបាន ត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ពួកភិក្ខុនីជាសាវិកាបស់តថាគត ដែលឈ្លាសវាងវៃ ។ល។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគ បានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ពួកឧបាសកជាសាវ័ករបស់តថាគតដែលឈ្លាសវាងវៃ ។ល។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគបានត្រាស់វាចានេះហើយថា នែមារមានចិត្តបាប ពួកឧបាសិកាជាសាវិការបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រង់ធម៌ បដិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់សម្ដែងបញ្ញត្ត តាំងទុក បើក ចែក ធ្វើឱ្យងាយបាន ទាំងមិនទាន់បានសង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឱ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យ ដរាបណាទេ តថាគតក៏នឹងមិនទាន់បរិនិព្វាន ដរាបនោះដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើនឥឡូវនេះ ពួកឧបាសិកាជាសាវិការបស់ព្រះមានព្រះភាគ បានឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ ហើយ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្ដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឱ្យងាយបានហើយ ទាំងសង្កត់សង្កិននូវបរប្បវាទ ដែល

កើតឡើងហើយ ឱ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ តាមពាក្យដែលសម ហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យបានហើយ បពិត្រព្រះមានព្រះ ភាគដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគបរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះមានព្រះភាគដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹង បរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះមានព្រះភាគដ៏ចម្រើន មួយ ទៀត ព្រះមានព្រះភាគ បានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា និងមិនទាន់ពេញបរិបូណ៌ ដរាបណា មួយទៀត ពួកទេវតានិងមនុស្សមិនទាន់ចេះសំដែងបានដោយប្រពៃ ដរាបណា តថាគតនឹងមិនទាន់បរិនិព្វាន ដរាបនោះដូច្នេះ បពិត្រព្រះមានព្រះភាគដ៏ចម្រើន ឥឡូវនេះ ព្រហ្មចារ្យរបស់ព្រះមានព្រះភាគនេះខ្ជាប់ខ្ជួនហើយ បានចម្រើន ហើយ បានផ្សាយទៅសព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ ហើយ ពួកទេវតានិងមនុស្សចេះសម្ដែងបានដោយល្អហើយ បពិត្រព្រះអង្គដ៏ ចម្រើន ឥឡូវនេះសូមព្រះមានព្រះភាគបរិនិព្វានទៅ សូមព្រះសុគត បរិនិព្វាន ទៅ បពិត្រព្រះមានព្រះភាគដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ ព្រះមានព្រះភាគហើយ ។

កាលបើក្រុងមារ ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគក៏បាន ត្រាស់ ភាសិតនេះទៅនឹងក្រុងមារមានចិត្តបាបថា

**អប្បោស្សុក្កោ ត្វំ បាបិម ហោហិ ន ចិរំ តថាគតស្ស បរិនិព្វានំ**

**ភវិស្សតិ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតិ ។**

ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វាន របស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគត នឹងបរិនិព្វានហើយ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានសតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារ [illegible] ព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារហើយ ក៏កក្រើកផែនដីយ៉ាងធំ គួរឱ្យភ្លូកភ្លឹក ព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវដំណើរនោះហើយ ក៏បន្លឺនូវឧទាននេះ ក្នុងវេលានោះថា ÷

**តុលមតុលញ្ច សម្ភវំ ភវសង្ខារមវស្សជិ មុនិ**
**អជ្ឈត្តរតោ សមាហិតោ អភិន្ទិ កវចមិវត្តសម្ភវំ**

ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញនូវព្រះនិព្វានដែលមានគុណថ្លឹងមិនបានផង នូវភពផង ទ្រង់លះបង់នូវសង្ខារដែលនាំសត្វទៅកាន់ភពផង ទ្រង់ត្រេកអរក្នុងអារម្មណ៍ខាងក្នុង (ដោយពិចារណាវិបស្សនា) មានព្រះ ហឫទ័យតាំងមាំហើយ(ដោយអំណាចសមថៈ) ផង ទ្រង់បានទំលាយនូវបណ្តាញ គឺ កិលេសដែលកើតមាននៅក្នុងខ្លួនដូចជាក្រោះ ។

លំដាប់នោះ ព្រះអានន្ទមានអាយុមានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ហេតុជាអស្ចារ្យពេកណាស់ អើហ្ន៎ ហេតុចំឡែកពេកណាស់ ការកក្រើកផែនដី

នេះជាយ៉ាងធំ ការកក្រើកផែនដីនេះធំណាស់តើគួរឱ្យ ភ្លូកភ្លឹក ឱ្យព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង មានហេតុដូចម្តេច មានបច្ច័យដូចម្តេចហ្ន៎ ដែលនាំឱ្យកក្រើកផែនដីជាយ៉ាងធំម្លេះ ។ ទើបព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានហេតុជាអស្ចារ្យ បពិត្រព្រះអង្គដ៏ចម្រើន មានហេតុដ៏ប្លែក បពិត្រព្រះអង្គដ៏ចម្រើន ការកក្រើកផែនដីនេះជាយ៉ាងធំ បពិត្រព្រះអង្គដ៏ចម្រើន ការកក្រើកផែនដីនេះធំពេកណាស់ គួរឱ្យភ្លូកភ្លឹក ឱ្យព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង បពិត្រព្រះអង្គដ៏ចម្រើន មានហេតុដូចម្តេច មានបច្ច័យដូចម្តេចហ្ន៎ ដែលនាំឱ្យកក្រើកផែនដី យ៉ាងធំម្លេះ ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ ឯហេតុបច្ច័យដែលនាំឱ្យផែនដីកក្រើកមាន ៨ យ៉ាង ។ ហេតុបច្ច័យទាំង ៨ យ៉ាងតើដូចម្តេចខ្លះ ។

ម្នាលអានន្ទ មហាប្រឹថពីនេះ ប្រតិស្ឋាននៅលើទឹក ឯទឹកប្រតិស្ឋាននៅលើខ្យល់ ខ្យល់ប្រតិស្ឋាន នៅលើអាកាស ម្នាលអានន្ទ សម័យដែលមានខ្យល់ធំបក់ ខ្យល់ធំដែលបក់នោះ រមែងធ្វើទឹកឱ្យកក្រើក ឯទឹកដែលកក្រើកមកហើយ ក៏ធ្វើផែនដីឱ្យកក្រើកដែរ នេះជាហេតុ ជាបច្ច័យទី ១ ដែលនាំឱ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ សមណៈក្តី ព្រាហ្មណ៍ក្តី ដែលមានឫទ្ធិដល់នូវការស្ទាត់ជំនាញក្នុងចិត្ត ឬ ទេវតាដែលមានឫទ្ធិធំ មានអានុភាពធំ បុគ្គលនោះ បានចម្រើន

បបរីសញ្ញាឱ្យមានកម្លាំងតិច ចម្រើនអបោសញ្ញាឱ្យ មានកម្លាំងច្រើន បុគ្គល នោះ រមែងធ្វើផែនដីនេះ ឱ្យកក្រើកញាប់ញ័របាន នេះជាហេតុ ជាបច្ច័យទី ២ ដែលនាំឱ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ មួយទៀត កាលណាព្រះពោធិសត្វច្យុតចាកពួកទេវតា ដែល ឋិតនៅក្នុងឋានតុសិត មានសតិនិងសម្បជញ្ញៈ យាងចុះកាន់ព្រះមាតុឧទរ ក្នុង កាលនោះ ផែនដីនេះតែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៣ ដែលនាំឱ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះពោធិសត្វ មានសតិ និង សម្បជញ្ញៈទ្រង់ប្រសូតចាកព្រះមាតុឧទរ ក្នុងកាលនោះ ផែនដីនេះតែងកក្រើក រំពើករំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៤ ដែលនាំឱ្យកក្រើកផែនដីជា យ៉ាងធំ ។

ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគត ត្រាស់ដឹងនូវអនុត្តរ សម្មាសម្ពោធិញ្ញាណ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំពើករំភើប ញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៥ ដែលនាំឱ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ មួយទៀត កាលណាដែលតថាគត ញ៉ាំងអនុត្តរធម្មចក្រឱ្យ ប្រព្រឹត្តទៅ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំពើករំភើបញាប់ញ័រ នេះជា ហេតុ ជាបច្ច័យទី ៦ ដែលនាំឱ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ មួយទៀត កាលណាដែលតថាគតមានសតិនិងសម្បជញ្ញៈ ដាក់ចុះនូវអាយុសង្ខារ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំពើករំភើបញាប់ ញ័រ

នេះជាហេតុ ជាបច្ច័យទី ៧ ដែលនាំឱ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ មួយទៀត កាលដែលព្រះតថាគត បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំពើករំភើបញ្ជាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៨ ដែលនាំឱ្យកក្រើកផែនដីជាយ៉ាងធំ។ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យដែលនាំឱ្យកក្រើកផែនដីជាយ៉ាងធំមាន ៨ យ៉ាងនេះឯង ។

ម្នាលអានន្ទ សម័យមួយ តថាគតបានត្រាស់ជាដំបូង បានគង់នៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេសឯណោះ ។ ម្នាលអានន្ទ គ្រានោះឯង ក្រុងមារមានចិត្តបាប ចូលទៅរកតថាគត លុះចូលទៅដល់ហើយ បានឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលអានន្ទ លុះក្រុងមារមានចិត្តបាបឋិតនៅក្នុងទីដ៏សមគួរហើយ បាននិយាយយ៉ាងនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ ម្នាលអានន្ទ កាលបើក្រុងមារបាននិយាយយ៉ាងនេះហើយ តថាគត ក៏បានពោលពាក្យនេះទៅក្រុងមារ មានចិត្តបាបថា ម្នាលមារមានចិត្តបាប ពួកភិក្ខុជាសាវ័ករបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រង់ធម៌ បដិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួនហើយ ប្រាប់សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឱ្យងាយបាន ទាំងមិនទាន់បានសង្កត់

សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឱ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ ប្រកបដោយបាដិហារ្យបាន ដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ។ ម្នាលមារមានចិត្តបាប ពួកភិក្ខុនីជាសាវិការបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រង់ធម៌ បដិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់បានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឱ្យងាយបាន ទាំងមិនទាន់បានសង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឱ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យ ដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ។ ម្នាលមារមានចិត្តបាប ពួកឧបាសក ជាសាវ័ករបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រង់ធម៌ បដិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឱ្យងាយបាន ទាំងមិនទាន់បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឱ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យ ដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វាន ដរាបនោះ ។ ម្នាលមារមានចិត្តបាប ពួកឧបាសិកាជាសាវិការបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រង់ធម៌ បដិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈ

នៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឱ្យងាយបាន ទាំងមិនទាន់បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឱ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យ ដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វាន ដរាបនោះ ។

ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួនមិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា ទាំងមិនទាន់ពេញបរិបូណ៌ ដរាបណា មួយទៀត ពួកទេវតា និងមនុស្សមិនទាន់ចេះសម្តែងបានដោយប្រពៃ ដរាបណាទេ តថាគតក៏មិនទាន់បរិនិព្វាន ដរាបនោះ ។ ម្នាលអានន្ទ ថ្ងៃនេះក្រុងមារមានចិត្តបាប បានចូលមករកតថាគត ក្នុងបាវាលចេតិយអម្បាញ់មិញនេះឯង បានឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលអានន្ទ លុះមារមានចិត្តបាប បានឋិតនៅក្នុងទីដ៏សមគួរហើយ ក៏បានពោលពាក្យនេះនឹងតថាគតថាបពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះមានព្រះភាគបានត្រាស់ព្រះវាចានេះថា ម្នាលមារមានចិត្តបាប ពួកភិក្ខុជាសាវ័ករបស់តថាគតនៅមិនទាន់មាន ដរាបណាទេ តថាគតក៏មិនទាន់បរិនិព្វានដរាបនោះ ។ ពួកភិក្ខុនី ជាសាវិការបស់តថាគត មិនទាន់មានដរាបណា ។ ពួកឧបាសកជាសាវ័ករបស់តថាគត នៅមិនទាន់មានដរាបណា ។ ពួកសាវិការបស់តថាគត នៅមិនទាន់មានដរាបណា ។ ព្រហ្មចារ្យរបស់តថាគត នៅមិនទាន់ ខ្ជាប់ខ្ជួន មិនទាន់

ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា ទាំងមិនទាន់ពេញបរិបូណ៌ ដរាបណា មួយទៀត ពួកទេវតានិងមនុស្សមិនទាន់ ចេះសម្តែងបានដោយប្រពៃ ដរាបណា (តថាគតក៏មិនទាន់បរិនិព្វានដរាបនោះ) បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រហ្មចារ្យរបស់ព្រះមានព្រះភាគ បានខ្ជាប់ខ្ជួនហើយ បានចម្រើនហើយ បានផ្សាយទៅសព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ហើយ ពួកទេវតានិងមនុស្សចេះសម្តែងបានដោយល្អហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ ។ ម្នាលអានន្ទ កាលបើក្រុងមារ និយាយយ៉ាងនេះហើយ តថាគតក៏បានពោលពាក្យនេះ ទៅនឹងក្រុងមារមានចិត្តបាបថា ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគតមិនយូរប៉ុន្មានទេ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វាន ហើយម្នាលអានន្ទក្នុងថ្ងៃនេះ តថាគតមានសតិសម្បជញ្ញៈ បានដាក់អាយុសង្ខារ ក្នុងបាវាលចេតិយអម្បាញ់មិញនេះឯង ។ កាលបើព្រះមានព្រះភាគ មានពុទ្ធតម្រាស់យ៉ាងនេះហើយ អានន្ទមានអាយុ ក៏បានក្រាបបង្គំទូលឃាត់ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និង មនុស្សទាំងឡាយ ។

ម្នាលអានន្ទ ឥឡូវនេះ កុំឡើយអ្នកកុំអង្វរតថាគតឡើយ ម្នាលអានន្ទ ឥឡូវនេះ មិនមែនជាកាលគួរនឹងអារាធនាតថាគតទេ ។ ព្រះអានន្ទមានអាយុ បានក្រាបបង្គំទូលជាគំរប់ពីរដងផង ។ល។ ព្រះអានន្ទមានអាយុ បានក្រាបបង្គំទូលព្រះមានព្រះភាគ ជាគម្រប់បីដងផងដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលអានន្ទ អ្នកជឿពោធិញ្ញាណរបស់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿ ។ ម្នាលអានន្ទ កាលបើអ្នកជឿដែរ ហេតុអ្វីក៏អ្នកនៅតែទទូចតថាគត ដល់ទៅបីដង ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធដីកានេះ ខ្ញុំព្រះអង្គបានស្តាប់ ក្នុងទីចំពោះព្រះភក្រ្ត បានត្រងរងក្នុងទីចំពោះព្រះភក្រ្តថា ម្នាលអានន្ទ ឥទ្ធិបាទ ទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើរឿយៗហើយ ធ្វើឱ្យដូចជាយានហើយ ធ្វើឱ្យជាទីនៅហើយ បានតាំងទុករឿយៗហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បុគ្គលនោះ បើប្រាថ្នានឹងស្ថិតនៅ គប្បីស្ថិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ ព្រះតថាគត បានចម្រើនហើយ បានធ្វើរឿយៗហើយ បានធ្វើឱ្យដូចជាយានហើយ ធ្វើឱ្យជាទីនៅហើយ បានតាំងទុករឿយៗហើយបានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ បើប្រាថ្នានឹងឋិតនៅ គប្បី

ឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន ។ ម្នាលអានន្ទ អ្នកជឿទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿ ។ ម្នាលអានន្ទ ហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ព្រោះតថាគត បានធ្វើនិមិត្តជាឱឡារិក បានធ្វើឱភាសយ៉ាងឱឡារិកនេះហើយ អ្នកនៅតែមិន យល់សេចក្តីច្បាស់លាស់បាន មិនអារាធនាតថាគតថា សូមព្រះមានព្រះភាគ ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ឋិតនៅអស់មួយអាយុកប្ប ដើម្បី ប្រយោជន៏ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់ សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៏ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ដូច្នេះសោះ ម្នាលអានន្ទ បើអ្នកអារាធនា តថាគត តថាគតគប្បីឃាត់ វាចារបស់អ្នកត្រឹមតែពីរលើក តែដល់ទៅបីលើក តថាគត គប្បីទទួល ម្នាលអានន្ទ ព្រោះហេតុនោះ នេះជាអំពើទាស់របស់អ្នក ហើយនេះ ជាកំហុសរបស់អ្នកហើយ ។

(សម្តេចព្រះអនាវរណញ្ញាណ ជាកំពូលលើអស់អ្នកប្រាជ្ញព្រះអង្គជាអ្នក ធ្វើនូវប្រយោជន៏ ដោយកិរិយាឈ្លាសក្នុងឧបាយនៃសេចក្តីករុណាអាណិតអាសូរ ដល់សព្វសត្វ មិនមានចំពោះមុខ ។ ទ្រង់ជ្រាបច្បាស់នូវហេតុ.....។ ទ្រង់ធ្វើនូវ និមិត្តជាឱឡារិក បានធ្វើនូវឱភាសជាឱឡារិកចំពោះព្រះអានន្ទ ចំនួន ១៦ លើក ។ ដែលមាននៅក្នុងទីនោះៗគឺ÷)

ម្នាលអានន្ទ សម័យមួយ តថាគតគង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុង រាជគ្រឹះនោះឯង ១ ។

តថាគតនៅក្នុងគោតមនិគ្រោធ ជិតក្រុងរាជគ្រឹះនោះឯង ១ ។

តថាគតនៅជិតជ្រោះជាទីទម្លាក់នូវចោរ ទៀបក្រុងរាជគ្រឹះនោះឯង១ ។

តថាគតនៅក្នុងសត្តបណ្ណគុហា (គុហាដែលសន្ធតដោយដើមសត្តបណ្ណព្រឹក្ស) ខាងភ្នំវេភារៈជិត ក្រុងរាជគ្រឹះនោះឯង ១ ។

តថាគតនៅក្នុងកាឡសិលា (ថ្មខ្មៅ) ខាងភ្នំឥសិគិលិ ទៀបក្រុងរាជគ្រឹះនោះឯង ១ ។

តថាគតនៅក្នុងសប្បសោណ្ឌិកបព្ភារៈ (ញូកមានត្រពាំងទឹកជាទីនៅនៃពស់) ក្នុងសីតវ័ន (ព្រៃត្រជាក់) ទៀបក្រុងរាជគ្រឹះនោះឯង ១ ។

តថាគតនៅក្នុងតបោទារាម (អារាមជិតស្ទឹងឈ្មោះតបោទា) ជិតក្រុងរាជគ្រឹះ នោះឯង ១ ។

តថាគតនៅក្នុងវេឡុវ័នកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះនោះឯង១ ។

តថាគតនៅក្នុងជីវកម្ពវ័នជិតក្រុងរាជគ្រឹះនោះឯង ១ ។

តថាគតនៅក្នុងមទ្ទកុច្ឆិមិគទាយវ័ន ជិតក្រុងរាជគ្រឹះនោះឯង ១ ។

តថាគតនៅក្នុងឧទេនចេតិយទៀបក្រុងវេសាលីនោះឯង ១ ។

តថាគតនៅក្នុងគោតមកចេតិយ ទៀបក្រុងវេសាលីនោះឯង ១ ។

តថាគតនៅក្នុងសត្តម្ពចេតិយ ជិតក្រុងវេសាលីនោះឯង ១ ។

តថាគតនៅក្នុងពហុបុត្តចេតិយ ជិតក្រុងវេសាលីនោះឯង ១ ។

តថាគតនៅក្នុងសារន្ទទចេតិយ ជិតក្រុងវេសាលីនោះឯង ១ ។

ម្នាលអានន្ទ ក្នុងកាលឥឡូវនេះ តថាគតនៅក្នុងបាវាលចេតិយ ១។ ក្នុង

ថ្ងៃ(១៥ កើត ពេញបូណ៌មី ខែមាឃ ឆ្នាំម្សាញ់) នេះបានប្រាប់អ្នកថា ម្នាល អានន្ទ ក្រុងរាជគ្រឹះជាទីគួរត្រេកអរ ភ្នំគិជ្ឈកូដជាទីគួរត្រេកអរ គោតមនិគ្រោធ ជាទីគួរត្រេកអរ ជ្រោះជាទីទម្លាក់នូវចោរជាទីគួរត្រេកអរ សត្តបណ្ណគុហា ខាងភ្នំវេភារៈជាទីគួរត្រេកអរ កាឡសិលាខាងភ្នំឥសិគិលិជាទីគួរត្រេកអរ សត្តម្ពចេតិយជាទីគួរត្រេកអរ ពហុបុត្តចេតិយជាទីគួរត្រេកអរ សារន្ទទចេតិយជាទីគួរត្រេកអរ បាវាលចេតិយជាទីគួរត្រេកអរ ម្នាលអានន្ទ តថាគត នៅក្នុងទីអម្បាល នោះក្តី ក្នុងទីនេះក្តី តថាគតបានប្រាប់អ្នក (ដូចៗគ្នា) ថា ឥទ្ធិបាទ ទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើឱ្យច្រើនហើយ បានធ្វើឱ្យដូចជាយាន ហើយបានធ្វើឱ្យជាទីនៅហើយបានតាំងទុករឿយៗហើយ បានសន្សំទុក បានប្រារព្ធដោយល្អ ហើយបុគ្គលនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ។ ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើឱ្យច្រើនហើយ បានធ្វើឱ្យដូចជាយានហើយ បានធ្វើឱ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បើតថាគតប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ម្នាលអានន្ទ កាលបើតថាគតធ្វើនិមិត្តជាឱឡារិក ធ្វើឱភាសជាឱឡារិក យ៉ាងនេះ ហើយក៏អ្នកនៅតែមិនអាចនឹងយល់សេចក្តីច្បាស់លាស់បាន មិនអាចអារាធនាតថាគតថា សូមព្រះមានព្រះភាគ ទ្រង់ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគតទ្រង់ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន

ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើនដល់ទេវតានិងមនុស្សទាំងឡាយ ដូច្នេះសោះ ម្នាលអានន្ទ បើអ្នកអារាធនាតថាគត។ គប្បីឃាត់ពាក្យអ្នកត្រឹមតែពីរដងប៉ុណ្ណោះ គង់នឹងទទួលអារាធនា ក្នុងវារៈជាគម្រប់បីដងមិនខាន ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ម្នាលអានន្ទ ក្រែងតថាគត ប្រាប់អ្នកជាមុនហើយ យ៉ាងនេះថា សេចក្ដីព្រាត់ប្រាស សេចក្ដីវិនាស សេចក្ដីប្រែប្រួលចាកសត្វនិងសង្ខារជាទីស្រឡាញ់ជាទីពេញចិត្តទាំងអស់ តែងមានជាធម្មតា ម្នាលអានន្ទព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្ដីទៀងទាត់ មិនព្រាត់ប្រាសក្នុងខន្ធប្រវត្តិនេះអំពីទីណា ធម្មជាតណា កើតឡើងហើយ មានហើយ សង្ខារតាក់តែងហើយ តែងមានសេចក្ដីវិនាសទៅជាធម្មតា ធម្មជាតនោះឯងបុគ្គលនឹងពោលឃាត់ថា កុំវិនាសដូច្នេះ (ដោយហេតុណា) ហេតុនុ៎ះ មិនមានឡើយ ។ ម្នាលអានន្ទ មួយទៀត ធម្មជាតណា ដែលតថាគតទាត់ចោលហើយ ខ្ជាក់ចោលហើយ ជម្រុះចោលហើយ លះបង់ចោលហើយ បន្សាត់ចោលហើយ អាយុសង្ខារតថាគតដាក់ចុះហើយ វាចារបស់តថាគតពោលដោយពិតថា បរិនិព្វាននៃតថាគតមិនយូរប៉ុន្មានឡើយកន្លង ៣ ខែអំពីថ្ងៃនេះទៅ តថាគត នឹងបរិនិព្វានហើយ តថាគតនឹងត្រឡប់មកកាន់ធម្មជាតនោះវិញទៀត ព្រោះហេតុនៃជីវិតប៉ុណ្ណោះ (ដោយហេតុណា) ហេតុនុ៎ះ មិនមានឡើយ ម្នាលអានន្ទ មក យើងនឹងទៅកាន់កូដាគារសាលា នាមហាវ័ន ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

(ចន្លោះពេល ៣ ខែ ដែលព្រះមានព្រះភាគទ្រង់ដាក់អាយុសង្ខារ ក្នុងបាវាលចេតិយ ទល់គ្នានឹងថ្ងៃដែលព្រះអង្គទ្រង់បរិនិព្វាន ព្រះអង្គទ្រង់យាងនិងគង់តាមពុទ្ធអធ្យាស្រ័យ) ។

ព្រះសុគតសាស្តា ទ្រង់យាងទៅកាន់កូដាគារសាលា នាមហាវ័ន លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយធម៌នេះ គប្បីតាំងនៅអស់កាលយូរអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយធម៌នេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយមានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឱ្យសំរេចដោយសេចក្តីមិនប្រមាទចុះ បរិនិព្វាននឹងមានដល់តថាគត មិនយូរប៉ុន្មានឡើយ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ ព្រះមានព្រះភាគលុះទ្រង់មានព្រះបន្ទូលដូច្នេះហើយ ក៏ទ្រង់មានព្រះបន្ទូលដូច្នេះ តទៅទៀតថា ÷

**ទហរាបិ ច យេ វុឌ្ឍា　　　យេ ពាលា យេ ច បណ្ឌិតា**
**អឌ្ឍា ចេវ ទលិទ្ទា ច　　　សព្វេ មច្ចុបរាយនា ។**

ពួកជនណា១ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ ។

**យថាបិ កុម្ភការស្ស    កតំ មត្តិកភាជនំ**
**ខុទ្ទកញ្ច មហន្តញ្ច    យញ្ច បក្កំ យញ្ច អាមកំ**
**សព្វំ ភេទបរិយន្តំ    ឯវំ មច្ចាន ជីវិតំ ។**

ភាជន៍ដីដែលស្មូនឆ្នាំង ធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ ទាំងអស់នោះ មានកិរិយា បែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។

ព្រះសាស្តាទ្រង់មានព្រះបន្ទូលដូច្នេះតទៅទៀតថា ÷

**បរិបក្កោ វយោ មយ្ហំ    បរិត្តំ មម ជីវិតំ**
**បហាយ វោ គមិស្សាមិ    កតំ មេ សរណមត្តនោ ។**

វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់តថាគតមានប្រមាណតិច តថាគតនឹងលះបង់អ្នកទាំងឡាយហើយទៅ ឯទីពឹងចំពោះខ្លួន តថាគតបានធ្វើ ទុកហើយ ។

**អប្បមត្តា សតីមន្តោ    សុសីលា ហោថ ភិក្ខវោ**
**សុសមាហិតសង្កប្បា    សចិត្តមនុរក្ខថ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់នឹងល្អ ចូររក្សាចិត្តរបស់ខ្លួនឱ្យរឿយៗចុះ ។

**យោ ឥមស្មឹ ធម្មវិនយេ    អប្បមត្តោ វិហរិស្សតិ**
**បហាយ ជាតិសំសារំ    ទុក្ខស្សន្តំ ករិស្សតិ ។**

ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម្មវិន័យនេះ (ភិក្ខុនោះ) នឹង

លះបង់ជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក

បានមិនខាន ។

ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរចូលទៅបិណ្ឌបាត ក្នុងក្រុងវេសាលី លុះស្តេចទ្រង់ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ទ្រង់ងាកក្រឡេកមើលនូវក្រុងវេសាលី ដូចជាដំរីដែលក្រឡេកបែរមើល (នូវទីខាងក្រោយ) ហើយត្រាស់នឹងព្រះអានន្ទ ដូច្នេះថា ម្នាលអានន្ទ តថាគតឃើញក្រុងវេសាលីម្តងនេះ ជាបច្ឆិមទស្សនៈ (ការឃើញទីបំផុត) ។ ម្នាលអានន្ទ មកយើងនឹងទៅភណ្ឌគ្រាម ។ ព្រះសុគតជាសាស្តា ទ្រង់មានព្រះបន្ទូលថា ធម៌ទាំងនេះ គឺ សីល សមាធិ បញ្ញា និង វិមុត្តដ៏ប្រសើរ ព្រះគោតមព្រះអង្គមានយសបានត្រាស់ដឹងហើយ ព្រះពុទ្ធទ្រង់ត្រាស់ដឹងយ៉ាងនេះហើយ ទើបសំដែងធម៌ប្រាប់ចំពោះភិក្ខុទាំងឡាយ ព្រះសាស្តាមានចក្ខុទ្រង់ធ្វើនូវព្រះនិព្វានជាទីបំផុត នៃកងទុក្ខទ្រង់បរិនិព្វានហើយ ។ ម្នាលអានន្ទ មក យើងនឹងទៅកាន់ហត្ថិគ្រាម អម្ពគ្រាម ជម្ពុគ្រាម និងភោគនគរ ។ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងនន្ទចេតិយ ជិតភោគនគរនោះ ។

គ្រានោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងភោគនគរ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ស្តេចទ្រង់យាងទៅកាន់ក្រុងបាវា ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអម្ពវ័ន (ព្រៃស្វាយ) របស់នាយចុន្ទកម្មារបុត្រ (កូនជាងមាស) ទៀបក្រុងបាវានោះ ។

នាយចុន្ទកម្មារបុត្ត បានឮដំណឹងថា ព្រះមានព្រះភាគស្តេចមកដល់ក្រុង

បាវ៉ា ឥឡូវនេះ ទ្រង់គង់នៅក្នុងអម្ពវ័នរបស់អគ្នាអញ ទៀបក្រុងបាវ៉ា ។ គ្រានោះ នាយចុន្ទកម្មារបុត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាយចុន្ទកម្មារបុត្ត អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគក៏ទ្រង់ឱ្យឃើញច្បាស់ ឱ្យកាន់យក ឱ្យអាចហ៊ាន ឱ្យរីករាយ ដោយធម្មីកថា ។ លំដាប់នោះ នាយចុន្ទកម្មារបុត្ត កាលដែលព្រះមានព្រះភាគ ទ្រង់ឱ្យឃើញច្បាស់ ឱ្យកាន់យក ឱ្យអាចហ៊ាន ឱ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ក៏ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព លុះនាយចុន្ទកម្មារបុត្ត បានដឹងច្បាស់ថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តហើយក៏ក្រោកចាកទីអង្គុយថ្វាយបង្គំព្រះមានព្រះភាគធ្វើប្រទក្សិណហើយចេញទៅ ។ លុះកន្លងរាត្រីនោះទៅហើយ ទើបនាយចុន្ទកម្មារបុត្ត ក៏ឱ្យគេចាត់ចែងខាទនីយភោជនីយាហារ មានរសដ៏ឆ្ងាញ់ ពិសា ព្រមទាំងសូករមទ្ទវៈ[២២] ដ៏ច្រើន ក្នុងផ្ទះរបស់ខ្លួនហើយ ឱ្យគេទៅក្រាបទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលគួរហើយ ភត្តសំរេចហើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ

---

[២២] ពាក្យថា សូករមទ្ទវៈ បានដល់សាច់ជ្រូកដែលគេចិញ្ច្រាំ ឱ្យល្អិតល្អន់ហើយចំអិនដោយល្អ ។ មួយទៀតថា សូករមទ្ទវៈនេះ ជាឈ្មោះរបស់ភោជន ដែលគេតាក់តែងត្រូវតាមតម្រា នៃម្ហូបមានរសឆ្ងាញ់ ។ អដ្ឋកថា ។

ក្នុងបុព្វណ្ហសម័យ (ថ្ងៃ ១៥កើត ពេញបូណ៌មី ខែ វិសាខ ឆ្នាំ ម្សាញ់) ហើយស្តេចចូលទៅកាន់លំនៅរបស់នាយចុន្ទកម្មារបុត្ត ជាមួយនឹងភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់រួចហើយ ក៏ត្រាស់នឹងនាយចុន្ទកម្មារបុត្តថា ម្នាលនាយចុន្ទៈ សូករមទ្ទវៈណាដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសតថាគត ដោយសូករមទ្ទវៈនោះចុះ ឯខាទនីយភោជនីយាហារដទៃណា ដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសភិក្ខុសង្ឃដោយ ខាទនីយភោជនីយាហារនោះចុះ ។ នាយចុន្ទកម្មារបុត្ត ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ករុណាព្រះអង្គ ហើយក៏អង្គាសព្រះមានព្រះភាគ ដោយសូករមទ្ទវៈ ដែលខ្លួនតាក់តែងហើយ អង្គាសភិក្ខុសង្ឃដោយខាទនីយភោជនីយាហារដទៃ ដែលខ្លួនតាក់តែងហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងនាយចុន្ទកម្មារបុត្តថា ម្នាលនាយចុន្ទៈ សូករមទ្ទវៈណាដែលអ្នកនៅសល់ អ្នកចូរកប់នូវសូករមទ្ទវៈនោះ ក្នុងរណ្តៅទៅ ម្នាលនាយចុន្ទៈ ក្នុងលោក (នេះ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស តថាគតមិនឃើញបុគ្គលណាមួយ ដែលបរិភោគនូវសូករមទ្ទវៈនោះហើយ សូករមទ្ទវៈនោះ គប្បីដល់នូវកិរិយារលួយទៅដោយល្អឡើយ វៀរលែងតែតថាគតចេញ ។ នាយចុន្ទកម្មារបុត្ត ទទួលព្រះបន្ទូល ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏កប់នូវសូករមទ្ទវៈដែលនៅសល់នោះក្នុងរណ្តៅ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយ

អង្គុយក្នុងទីសមគួរ ។ លុះនាយចុន្ទកម្មារបុត្ត អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ឱ្យឃើញច្បាស់ ឱ្យកាន់យក ឱ្យអាចហ៊ាន ឱ្យរីករាយ ដោយធម្មីកថា ហើយក៏ក្រោកចាកអាសនៈស្តេចចេញទៅ ។ លុះព្រះមានព្រះភាគទ្រង់ឆាន់ភត្តរបស់នាយចុន្ទកម្មារបុត្តរួចហើយ ព្រះអាពាធដ៏ខ្លាំងក៏កើតឡើង វេទនាដ៏ក្លៀវក្លា កើតអំពីលោហិតប្បក្ខន្ទិកាពាធ (អាពាធចុះព្រះលោហិត) ជិតនឹងដល់នូវមរណៈ ក៏ប្រព្រឹត្តទៅ ។ បានឮថា ព្រះមានព្រះភាគ មានព្រះសតិនិងសម្បជញ្ញៈមិនបានលំបាក ទ្រង់អត់សង្កត់នូវវេទនានោះបាន ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មកយើងនឹងទៅកាន់ក្រុងកុសិនារា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ខ្ញុំបានឮថា ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់សោយភត្ត របស់នាយចុន្ទកម្មារបុត្ត ហើយមានព្រះអាពាធ ជាទំងន់ ជិតនឹងមរណៈ ។ ព្យាធិដ៏ក្លាកើតដល់ព្រះសាស្តា ដែលសោយភត្ត ដោយសូករមទ្ទវៈ ព្រះមានព្រះភាគ ទ្រង់មានអាពាធ ចុះព្រះលោហិតរឿយៗ ទើបមានព្រះពុទ្ធដីកាថា តថាគតនឹងទៅកាន់ក្រុងកុសិនារា ។ (គាថាទាំងនេះ ព្រះសង្គីតិកាចារ្យទាំងឡាយសំដែងហើយក្នុងកាលធ្វើសង្គីតិ) ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជៀសចេញអំពីផ្លូវ ហើយទ្រង់ចូលទៅកាន់ម្លប់ឈើមួយដើម លុះចូលដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកក្រាលសង្ឃាដី មានជាន់ ៤ ឱ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតល្ហិតល្ហៃណាស់ តថាគតអង្គុយសិន ។ ព្រះអានន្ទមានអាយុ

ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ក្រាលសង្ឃាដី មានជាន់ ៤ ថ្នាយ ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈដែលព្រះអានន្ទក្រាលថ្វាយ ។ លុះព្រះមានព្រះភាគទ្រង់គង់រួចហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹកមកឱ្យតថាគត ដោយឆាប់ ម្នាលអានន្ទ តថាគត ស្រេកទឹកណាស់ តថាគតនឹងឆាន់ទឹកបន្តិច ។ ព្រះមានព្រះភាគ មានព្រះបន្ទូលដូច្នេះគ្រប់បីដង ទើបព្រះអានន្ទមានអាយុ ក៏ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ករុណាព្រះអង្គ ហើយក៏កាន់បាត្រដើរទៅកាន់ស្ទឹង ។

គ្រានោះ ព្រះអានន្ទក៏ដងទឹកដោយបាត្រ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះជាអស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះចំឡែកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ស្ទឹងតូចដែលកង់រទេះកិនល្អក់រីកវរកំពុងហូរមកនោះ កាលដែលខ្ញុំព្រះអង្គចូលទៅដល់ហើយ ក៏ត្រឡប់ទៅជាទឹករងថ្លា មិនល្អក់ហូរមកវិញ ព្រោះព្រះអង្គមានឫទ្ធិធំ មានអានុភាពធំ សូមព្រះមានព្រះភាគ ទ្រង់សោយព្រះសុទ្ធរស សូមព្រះសុគតទ្រង់សោយសុទ្ធរស ។ លំដាប់នោះ ព្រះមានព្រះភាគក៏ទ្រង់សោយព្រះសុទ្ធរសរួចហើយ ។

សម័យនោះឯង មល្លបុត្ត (ព្រះរាជបុត្តនៃមល្លក្សត្រ) ព្រះនាមបុក្កុសៈ ចូលគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយក្រាបទូលសន្ទនា និងស្តាប់ព្រះធម៌ ។ល។ ហើយមានចិត្ត

ត្រេកអររីករាយ ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាសរណៈចាប់ផ្ដើមអំពីថ្ងៃនេះតទៅ សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថា ជាឧបាសកដល់នូវសរណគមន៍ស្មើដោយជីវិត ។ បុក្កុសមល្លបុត្តថ្វាយនូវសំពត់មានសាច់ម៉ដ្ឋ ១ គូ មានសម្បុរដូចមាសសិង្គី (ចំពោះព្រះសាស្ដា) ព្រះសាស្ដាដែលព្រះអានន្ទនោះថ្វាយឱ្យទ្រង់សាដកហើយ ក៏មានសម្បុរដូចព្រះចន្ទល្អរុងរឿង ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្ដេចចូលទៅកាន់ស្ទឹងកកុធៈ ព្រមទាំងភិក្ខុសង្ឃជាច្រើន លុះចូលទៅដល់ហើយ ទ្រង់ស្ដេចចុះកាន់ស្ទឹងកកុធៈ ស្រង់ផងសោយផង ហើយស្ដេចត្រឡប់ឡើងវិញ ក៏ចូលទៅរកអម្ពវ័ន លុះចូលទៅដល់ហើយ ទ្រង់ត្រាស់ហៅព្រះចុន្ទកៈមានអាយុថា ម្នាលចុន្ទកៈ ចូរអ្នកក្រាលសង្ឃាដី មានជាន់ ៤ ឱ្យតថាគតដោយឆាប់ ម្នាលចុន្ទកៈ តថាគតល្ហិតល្ហៃណាស់ តថាគតនឹងសឹង ។ ព្រះចុន្ទកៈមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ក្រាលសង្ឃាដី មាន ជាន់ ៤ ថ្វាយ ។ ទើបព្រះមានព្រះភាគ ទ្រង់សំរេចសីហសេយ្យា ផ្អៀងទៅខាងស្ដាំ ទ្រង់យកព្រះបាទឆ្វេងត្រួតលើព្រះបាទស្ដាំ ទ្រង់មានព្រះសតិនិងព្រះសម្បជញ្ញៈ ធ្វើទុកក្នុងព្រះទ័យនូវឧដ្ឋានសញ្ញា (សេចក្ដីសំគាល់ថា នឹងក្រោកឡើងវិញ) ។ ឯព្រះចុន្ទកៈមានអាយុ ក៏អង្គុយចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ក្នុងទីនោះឯង ។ គ្រានោះ ព្រះមានព្រះភាគ បានត្រាស់ហៅព្រះអានន្ទ មានអាយុមកថា ម្នាលអានន្ទ

បើមានបុគ្គលណាមួយ ញ៉ាំងសេចក្តីក្តៅក្រហាយស្តាយក្រោយ ឱ្យកើតឡើងដល់ចុន្ទកម្មារបុត្តថា ម្នាលអាវុសោចុន្ទៈ អ្នកពេញហៅជាមនុស្ស ឥតលាភ អត្តភាពជាមនុស្សក៏អ្នកបានដោយអាក្រក់ ព្រោះព្រះតថាគត សោយបច្ឆិមបិណ្ឌបាតរបស់អ្នកហើយទ្រង់បរិនិព្វាន ម្នាលអានន្ទ អ្នកគប្បីបន្ទោបង់សេចក្តីក្តៅក្រហាយស្តាយក្រោយ របស់ចុន្ទកម្មារបុត្តយ៉ាងនេះថា ម្នាលអាវុសោចុន្ទៈ អ្នកពេញហៅជាមនុស្សមានលាភ អត្តភាព ជាមនុស្សក៏អ្នកបានដោយប្រពៃហើយ ព្រោះថាព្រះតថាគត ទ្រង់សោយបច្ឆិម បិណ្ឌបាតរបស់អ្នកហើយ ទ្រង់បរិនិព្វាន ម្នាលអាវុសោចុន្ទៈ ពាក្យនេះ យើងបានស្តាប់ បានទទួលចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ដូច្នេះថា ចង្ហាន់បិណ្ឌបាតទាំងពីរនេះមានផលស្មើ១គ្នា មានវិបាកស្មើ១គ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ក្រៃលែងជាងចង្ហាន់បិណ្ឌបាតដទៃ ។ ចង្ហាន់បិណ្ឌបាតទាំងពីរ តើដូចម្តេច ។ គឺព្រះតថាគត ទ្រង់សោយចង្ហាន់បិណ្ឌបាតណាហើយ ទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ១ ព្រះតថាគត ទ្រង់សោយចង្ហាន់បិណ្ឌបាតណាហើយ ទ្រង់បរិនិព្វានដោយអនុបាទិសេស និព្វានធាតុ ១ ចង្ហាន់បិណ្ឌបាតទាំងពីរនេះឯង មានផលស្មើ ១ គ្នាមានវិបាកស្មើ១គ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ក្រៃលែងជាងចង្ហាន់បិណ្ឌបាតដទៃ បុញ្ញកម្មដែលញ៉ាំងអាយុឱ្យប្រព្រឹត្តទៅ ចុន្ទកម្មារបុត្តមានអាយុ ក៏បានសន្សំហើយ បុញ្ញកម្មដែលញ៉ាំងសម្បុរឱ្យប្រព្រឹត្តទៅ ចុន្ទកម្មារបុត្តមានអាយុ ក៏បានសន្សំហើយ បុញ្ញកម្មដែលញ៉ាំងសេចក្តីសុខឱ្យប្រព្រឹត្តទៅ ។ល។ ញ៉ាំងយសឱ្យប្រព្រឹត្តទៅ ។ល។ ញ៉ាំងឋានសួគ៌

ឱ្យប្រព្រឹត្តទៅ ។ល។ ញុំាំងភារៈជាធំឱ្យប្រព្រឹត្តទៅ ចុន្ទមានអាយុក៏បានសន្សំហើយ ម្នាលអានន្ទ អ្នកគប្បីបន្ទោបង់សេចក្តីក្តៅក្រហាយ ស្តាយក្រោយរបស់ចុន្ទកម្មារបុត្ត យ៉ាងនេះឯង ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនេះហើយ ទ្រង់បន្លឺនូវឧទានគាថានេះ ក្នុងវេលានោះថា ÷

**ទទតោ បុញ្ញំ បវឌ្ឍតិ សំយមតោ វេរំ ន វីយតិ**
**កុសលោ វ ជហាតិ បាបកំ រាគទោសមោហក្ខយា និព្វុតោ**

បុណ្យ រមែងចម្រើនដល់អ្នកឱ្យទាន វេរាមិនចម្រើនដល់បុគ្គលអ្នកសង្រួមបុគ្គលអ្នកឈ្លាស(បរិបូណ៌ដោយញាណ) រមែងលះបង់នូវអំពើលាមកបាន បុគ្គលនោះ ក៏បរិនិព្វាន ព្រោះអស់រាគៈ ទោសៈ មោហៈ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទ មានអាយុមកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ត្រើយខាងនាយនៃស្ទឹងហិរញ្ញវតី ហើយចូលទៅកាន់សាលវ័នរបស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ត្រើយខាងនាយនៃស្ទឹងហិរញ្ញវតី នឹងចូលទៅកាន់សាលវ័នរបស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា ព្រមទាំងភិក្ខុសង្ឃជាច្រើន លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នករៀបចំគ្រែ ឱ្យមានក្បាលដំណេកបែរទៅកាន់ទិសខាងជើង ក្នុងចន្លោះនៃដើមសាលព្រឹក្សទាំងគូ ឱ្យតថាគត

ដោយឆាប់ ម្នាលអានន្ទ តថាគតមានកាយល្ហិតល្ហៃណាស់ តថាគតនឹងសឹង ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយរៀបចំគ្រែ ឱ្យមានក្បាលដំណេក បែរទៅទិសខាងជើង ក្នុងចន្លោះដើម សាលព្រឹក្សទាំងគូថ្វាយ គ្រានោះព្រះមានព្រះភាគ មានព្រះសតិសម្បជញ្ញៈ ទ្រង់ សំរេចសីហសេយ្យា ផ្ទៀងទៅខាងស្តាំ ទ្រង់យកព្រះបាទឆ្វេង តម្រួតលើព្រះ បាទស្តាំ ។

ព្រះមានព្រះភាគទ្រង់ដាក់ព្រះជន្ម និងបរិនិព្វាន

សម័យនោះឯង សាលព្រឹក្សទាំងគូ ក៏មានផ្ការីកស្គុះស្គាយទាំងអស់ (តាំងពីគល់ដល់ចុង) ដោយអកាលបុប្ផ (ផ្កាពុំជូកាល) សាលព្រឹក្សទាំងគូនោះ ក៏រោយរាយ បាចសាច (នូវផ្កា) លើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត សូម្បីមន្ទារវបុស្ស (ផ្កាមន្ទារវៈ) ជាទិព្វ ក៏ធ្លាក់ចុះមកអំពីអាកាស ផ្កាទាំងនោះ ក៏រោយរាយ បាចសាចលើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត ។ ទាំង លម្អិតខ្លឹមចន្ទន៍ជាទិព្វ ក៏ធ្លាក់ចុះ មកអំពីអាកាស សម្អិតទាំងនោះ ក៏រោយរាយ បាចសាច លើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត ។ ទាំងតូរ្យតន្ត្រីជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាព្រះតថាគត ។ ទាំងចម្រៀងជាទិព្វ ក៏លាន់ឮ ឯអាកាស ដើម្បីបូជាព្រះតថាគត ។

គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងព្រះអានន្ទ ថា ÷

**យោ កោចិ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិ បដិបន្នោ អនុធម្មចារី**

ម្នាលអានន្ទ បុគ្គលឯណាមួយ គឺភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី

ជាអ្នកប្រតិបត្តិធម៌វិន័យ តាមសមគួរដល់ធម៌វិន័យ ជាអ្នកប្រតិបត្តិដោយសេចក្ដីគោរពកោតក្រែងដល់ធម៌វិន័យ ប្រព្រឹត្តតាមធម៌វិន័យជាប្រក្រតី ។

**សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ**

**បូជេតិ បរមាយ បូជាយ បដិបត្តិ បូជាយ**

បុគ្គលទាំងអស់នោះឈ្មោះថា ធ្វើសក្ការៈ នឹងតថាគត ធ្វើនូវសេចក្ដីគោរព តថាគតរាប់អាននូវតថាគត បូជានូវតថាគត ដោយបដិបត្តិបូជាជាបូជាយ៉ាងក្រៃលែង ។

គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ប្រសិនបើអ្នកទាំងឡាយ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ពាក្យប្រៀនប្រដៅដែលមានគ្រូប្រព្រឹត្តកន្លងទៅហើយ គ្រូរបស់យើង ឈ្មោះថា មិនមានឡើយ ម្នាលអានន្ទ សេចក្ដីនេះ អ្នកកុំចូលចិត្តយ៉ាងនេះឡើយ ម្នាលអានន្ទ ធម៌ណាក្ដី វិន័យណាក្ដី ដែលតថាគតសំដែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណើះតតអំពីតថាគតទៅ ធម៌និងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ ម្នាលអានន្ទ ក៏ក្នុងកាលសព្វថ្ងៃនេះ ពួកភិក្ខុ ហៅគ្នា នឹងគ្នាដោយពាក្យថា អាវុសោ អំណើះតតអំពីតថាគតទៅ អ្នកទាំងឡាយកុំហៅយ៉ាងនេះទៀតឡើយ ម្នាលអានន្ទភិក្ខុចាស់ជាង ត្រូវហៅភិក្ខុខ្ចីជាង ដោយនាមក៏បាន ដោយគោត្តក៏បាន ដោយពាក្យថា អាវុសោក៏បានចំណែកភិក្ខុខ្ចីជាង ត្រូវហៅភិក្ខុចាស់ជាងថា ភន្តេ ក៏បាន ថា អាយស្មា ក៏បាន ។

គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា៖

**ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ** ។ ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់ អ្នកទាំងឡាយឱ្យបានដឹងសង្ខារទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចទាំងពួងឱ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ ។

ព្រះមានព្រះភាគទ្រង់ដាក់ព្រះជន្មនឹងបរិនិព្វាន

**អយំ តថាគតស្ស បច្ឆិមា វាចា** នេះជាបច្ឆិមវាចា របស់ព្រះតថាគត ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចូលកាន់បឋមជ្ឈាន ចេញពីបឋមជ្ឈានហើយចូលកាន់ទុតិយជ្ឈាន ចេញអំពីទុតិយជ្ឈាន ហើយចូលកាន់តតិយជ្ឈាន ចេញអំពីតតិយជ្ឈាន ហើយចូលកាន់ចតុត្ថជ្ឈាន ចេញអំពីចតុត្ថជ្ឈាន ហើយចូលកាន់អាកាសានញ្ចាយតនសមាបត្តិ ចេញអំពីអាកាសានញ្ចាយតនសមាបត្តិហើយ ចូលកាន់វិញ្ញាណញ្ចាយតនសមាបត្តិ ចេញអំពី វិញ្ញាណញ្ចាយតនសមាបត្តិហើយចូលកាន់អាកិញ្ចញ្ញាយតនសមាបត្តិ ចេញអំពីអាកិញ្ចញ្ញាយតនសមាបត្តិហើយ ចូលកាន់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ចេញអំពីនេវសញ្ញានាសញ្ញា-យតនសមាបត្តិហើយ ចូលកាន់សញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញានិងវេទនា) ។

គ្រានោះ ព្រះអានន្ទ មានអាយុ ពោលទៅព្រះអនុរុទ្ធមានអាយុ ដូច្នេះថាបពិត្រព្រះអនុរុទ្ធដ៏ចម្រើន ព្រះមានព្រះភាគបរិនិព្វានហើយឬ ។ ព្រះអនុរុទ្ធតបថា ម្នាលអាវុសោអានន្ទ ព្រះមានព្រះភាគ មិនទាន់បរិនិព្វានទេ ព្រះអង្គ ទ្រង់ចូលកាន់សញ្ញាវេទយិតនិរោធ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ហើយ ថយមកចូលកាន់នេវសញ្ញានាសញ្ញាយតនសមាបត្តិវិញ ចេញអំពីនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ថយមកចូលកាន់អាកិញ្ចញ្ញាយតនសមាបត្តិវិញ ចេញអំពីអាកិញ្ចញ្ញាយតនសមាបត្តិ ហើយថយមកចូលកាន់វិញ្ញាណញ្ចាយតនសមាបត្តិវិញ ចេញអំពីវិញ្ញាណញ្ចាយតនសមាបត្តិហើយ ថយចូលមកកាន់អាកាសានញ្ចាយតនសមាបត្តិវិញ ចេញអំពីអាកាសានញ្ចាយតន-សមាបត្តិហើយ ថយមកចូលកាន់ចតុត្ថជ្ឈានវិញ ចេញអំពីចតុត្ថជ្ឈានហើយ ចូលមកកាន់តតិយជ្ឈានវិញ ចេញអំពីតតិយជ្ឈានហើយ ថយមកចូលកាន់ទុតិយជ្ឈានវិញ ចេញអំពីទុតិយជ្ឈានហើយ ថយមកចូលកាន់បឋមជ្ឈានវិញ ចេញអំពីបឋមជ្ឈានហើយ ក៏ចូលកាន់ទុតិយជ្ឈានទៀត ចេញអំពីទុតិយជ្ឈានហើយក៏ចូលកាន់តតិយជ្ឈានទៀត ចេញអំពីតតិយជ្ឈានហើយ ក៏ចូលចតុត្ថជ្ឈានទៀត ។ លុះព្រះមានព្រះភាគ ទ្រង់ចេញចាកចតុត្ថជ្ឈានហើយ ក៏ទ្រង់បរិនិព្វានក្នុងចន្លោះនោះ ។

កាលព្រះមានព្រះភាគ បរិនិព្វានហើយ ការកក្រើកនៃផែនដីធំ គួរស្ញើមគួរព្រឺរោម ក៏កើតមាន ទាំងផ្គរ ក៏លាន់ឮ គគ្រឹកគគ្រេង ព្រមនឹងការបរិនិព្វាន ។

កាលព្រះមានព្រះភាគ បរិនិព្វានហើយ សហម្បតិព្រហ្មក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វាន ថា:

**សព្វេ វ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ**
**យត្ថ ឯតាទិសោ សត្ថា លោកេ អប្បដិបុគ្គលោ**

**តថាគតោ ពលប្បត្តោ សម្ពុទ្ធោ បរិនិព្វុតោ ។**

ព្រះសាស្តា ដែលឥតបុគ្គលប្រៀបស្មើ ប្រាកដដូច្នោះ ព្រះតថាគតជាសម្ពុទ្ធ បរិបូរណ៍ហើយ ដោយកម្លាំង ទ្រង់បរិនិព្វានហើយ ក្នុងលោកណា ពួកសត្វទាំងអស់ មុខជានឹងដាក់ចុះនូវរាងកាយ ក្នុងលោក(នោះ) មិនខានឡើយ ។

ព្រះមានព្រះភាគទ្រង់ជាព្រះជន្មនៃបរិនិព្វាន

កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះឥន្ទ្រជាធំជាងទេវតា ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា :

**អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ**
**ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។**

សង្ខារទាំងឡាយ មិនទៀងហ្ន៎ មានកិរិយាកើតឡើងនិងការសូន្យទៅជាធម្មតា លុះកើតឡើងហើយក៏រលត់ទៅវិញកិរិយារម្ងាប់នូវសង្ខារទាំងឡាយនោះ ទើបនាំមកនូវសេចក្តីសុខ ។

កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះអនុរុទ្ធមានអាយុ ក៏ពោលនូវគាថានេះ ព្រមនឹងការ បរិនិព្វានថា :

**នាហុ អស្សាសបស្សាសោ ឋិតចិត្តស្ស តាទិនោ**
**អនេជោ សន្តិមារព្ភ យំ កាលមករី មុនិ ។**
**អសល្លីនេន ចិត្តេន វេទនំ អជ្ឈវាសយិ**
**បជ្ជោតស្សេវ និព្វានំ វិមោក្ខោ ចេតសោ អហូ ។**

ព្រះមុនីនាថអង្គណា ដែលមិនមានតណ្ហា ទ្រង់ប្រារព្ធនូវ

អនុបាទិសេសនិព្វានហើយ ទ្រង់ធ្វើមរណកាល អស្សាសៈ
បស្សាសៈ នៃព្រះមុនីនាថ ជាតាទិបុគ្គល ដែលមានព្រះទ័យ
ខ្ជាប់ខ្ជួននោះ មិនមានហើយ ។ ព្រះមុនីនាថ ទ្រង់អត់សង្កត់
វេទនាបានដោយចិត្តមិនរួញរា សេចក្ដីរលត់នៃចិត្តក៏កើតមាន
បីដូចជាការលត់នៃប្រទីប ។

កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះអានន្ទមានអាយុ ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា :

**តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ**
**សព្វាការវរូបេតេ សម្ពុទ្ធេ បរិនិព្វុតេ ។**

កាលដែលព្រះសម្ពុទ្ធ ប្រកបដោយហេតុ ប្រសើរទាំងពួងទ្រង់
បរិនិព្វានហើយ សេចក្ដីញាប់ញ័រក្តី សេចក្ដីព្រឺរោមក្ដី ក៏កើត
មានប្រាកដ ។

## ២៨ ធាតុភាជនីយកថា

ព្រះមហាគោតម ជាព្រះជិនស្រីប្រសើរ ទ្រង់និព្វានក្នុងនគរកុសិនារា ព្រះធាតុផ្សាយទៅក្នុងប្រទេសនោះ តាមចំណែក គឺព្រះធាតុមួយចំណែក បានទៅព្រះបាទអជាតសត្តុ មួយចំណែកបានទៅក្រុងវេសាលី មួយចំណែកបានទៅក្រុងកបិលព័ស្តុ មួយចំណែកបានទៅដែនអល្លកប្បកៈ មួយចំណែកបានទៅ ក្រុងរាមគ្រាម មួយចំណែកបានទៅវេលដ្ឋទីបកៈ មួយចំណែកបានទៅក្រុងបាវេយ្យកមល្លៈ ឯព្រះធាតុ មួយចំណែកទៀតបានទៅអ្នកក្រុងកុសិនារា ។

ព្រាហ្មណ៍ឈ្មោះទោណៈ បានធ្វើស្តូបបញ្ចុះតុម្ព(នាឡិ) ពួកមោរិយជន មានចិត្តជ្រះថ្លា បានធ្វើស្តូបបញ្ចុះព្រះអង្គារ (ធ្យូង)។ ព្រះស្តូបបញ្ចុះព្រះសារីរិកធាតុមាន ៨ បើរាប់តុម្ពចេតិយមួយផងជា ៩ បើគិតទាំងព្រះស្តូបបញ្ចុះ ព្រះអង្គារមួយទៀត ត្រូវជា ១០ ដែលមហាជនស្ថាបនាទុកក្នុងកាលនោះ ។

ព្រះចង្កូម ១ តម្កល់ក្នុងឋានត្រៃត្រិង្ស ព្រះចង្កូម ១ តម្កល់ក្នុងនាគបុរី ព្រះចង្កូម ១ តម្កល់នៅក្នុងដែនគន្ធារៈ ព្រះចង្កូម ១ តម្កល់ក្នុងដែនកាលិង្គរាជ។ ព្រះទន្តទាំង ៤០ គត់ ព្រះកេសា និង ព្រះលោមាទាំងអស់ ពួកទេវតារៀងខ្លួនបាននាំទៅមួយៗកាន់ចក្រវាឡទីទៃៗ ។ បាត្រ ឈើច្រត់ និង ចីវររបស់ព្រះមានព្រះភាគ តម្កល់ទុកនៅក្នុងដែនវជិរៈ ស្បង់តម្កល់ទុកនៅក្នុងផ្ទះនៃត្រកូល គ្រឿងកម្រាល តម្កល់ទុកនៅក្នុងក្រុងឈ្មោះសិលៈ ។ ធម្មក្រក និង កាយពន្ធ(វត្ថពន្ធចង្កេះ) តម្កល់ទុកនៅក្នុងក្រុង បាដលីបុត្រ ឧទកសាដក តម្កល់ទុកនៅក្នុងក្រុងចម្បា ព្រះឧណ្ណាលោម(រោមចិញ្ចើម) តម្កល់ទុកនៅក្នុងដែនកោសល ។ សំពត់កាសាវៈ តម្កល់ទុកនៅក្នុងព្រហ្មលោក ឆ្នួតតម្កល់ទុកនៅក្នុងឋានត្រៃត្រិង្ស ស្នាមព្រះបាទដ៏ប្រសើរ ដែលមិនបាត់ទៅ តម្កល់ទុកលើថ្មសំពត់និសីទនៈ តម្កល់ទុកក្នុងអវន្តិជនបទ គ្រឿងកម្រាល តម្កល់ទុកក្នុងដែនឈ្មោះទេវៈ ក្នុងកាលនោះ ។ កាលនោះ ដែកភ្លើងតម្កល់ទុកក្នុងក្រុងមិថិលា តម្រងទឹក តម្កល់ទុកក្នុងដែនវិទេហៈ កាំបិតកោរ និងបំពង់ម្ជុល តម្កល់ទុកនៅក្នុងឥន្ទបត្តបុរី ។ កាលនោះ គ្រឿងបរិក្ខារដ៏សេសទាំងឡាយ តម្កល់ទុកក្នុងជនបទជាទីបំផុត ពួកមនុស្សតែងបូជាចំពោះគ្រឿងបរិក្ខារទាំងឡាយ ដែលព្រះ

មុនីទ្រង់ប្រើប្រាស់ ការផ្សាយទៅនៃព្រះធាតុរបស់ព្រះមហេសី ព្រះនាមគោតម ក្នុងកាលនោះ ជាប្រពៃណីពីបូរាណ (នៃព្រះពុទ្ធទាំងឡាយ) សម្រាប់ទុកអនុគ្រោះស្រោចស្រង់សត្វទាំងឡាយជាខាងក្រោយ ។

ព្រះសម្ពុទ្ធទាំងឡាយអង្គនោះ ៧ ព្រមទាំងសាវ័ក មានគុណប្រមាណមិនបានបន្លឺនូវសីហនាថ គឺព្រះសទ្ធម្ម មានសន្តានមិនកំរើក បុគ្គលចូលទៅរកបានដោយកម្រ សម្តែងនូវឫទ្ធិដូចការធ្លាក់ចុះនូវផ្លេកបន្ទោរ ទ្រង់នៅគប់ភ្លើង គឺព្រះធម៌ ហើយញុំាងមហាជនឱ្យឆ្លង ដ៏រុងរឿងដូចជាផ្កាយដុះកន្ទុយ ទ្រង់ធ្វើស្ពាន គឺព្រះធម៌ឱ្យមាំ ដើម្បីចម្លងនូវជនទាំងឡាយដ៏សេស ដែលកំពុងដើរទៅ ដើម្បីឆ្លងនូវខ្សែទឹកគឺសង្សារ សាសនារបស់ព្រះពុទ្ធនោះ ៧ ដ៏វិចិត្រដោយព្រះអរហន្តទាំងឡាយ ដូចជារលកក្នុងសាគរ ឬដូចជាផ្កាយក្នុងអាកាស ទ្រង់សំដែងរស្មីធ្វើសាសនាមិនឱ្យមានមន្ទិល ដូចព្រះចន្ទកាលរុងរឿងឰដ៏អាកាស ទ្រង់សំដែងពន្លឺភ្លឺត្រចះ ហើយញុំាងសាវ័ក ឱ្យសាយភាយទៅ ទ្រង់ក្រសាលដោយសមាបត្តិដ៏ប្រសើរ ព្រះអង្គទ្រង់ស្រោយនូវចំណងនៃទេវតា និងមនុស្សជាច្រើន ទាំងប្រាប់ផ្លូវត្រូវផ្លូវខុស ចំពោះបុថុជ្ជនដ៏សេសទៀតផង ទ្រង់បង្ករភ្លៀងគឺព្រះធម៌ ស្រោចស្រង់ផ្សើមពួកមនុស្សព្រមទាំងទេវតា ធ្វើឱ្យដល់នូវសភាពក្សេមក្សាន្ត ទ្រង់សំដែងពន្លឺហើយបង្ហាញឧបាយ ជាទីទៅកាន់ព្រះនិព្វានឈ្មោះអមតៈ ទ្រង់សោយនូវយសដ៏ឧត្តម ប្រសើររុងរឿងដូចគំនរភ្លើង ហើយបរិនិព្វាន ។ ព្រះជិនស្រីទាំងឡាយនោះ ព្រមទាំងសាវ័កទាំងឡាយ ទ្រង់បរិនិព្វានហើយ ដូចជាភ្លៀង(ដែលបាត់ទៅ) ព្រោះខ្យល់ ដូចទឹកសន្សើម (អស់ទៅ) ព្រោះព្រះអាទិត្យ ឬដូច

ងងឹត (អស់ទៅ) ព្រោះប្រទីប ព្រះសិរីរៈដ៏បរិបូណ៌ដោយអនុព្យញ្ជនៈ មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ទ្រង់បាត់បង់សូន្យទាំងអស់ ឱ! សង្ខារទាំងពួងជារបស់ទទេ ទទេតើ ព្រះជិនស្រីសម្ពុទ្ធ ព្រមទាំងសាវ័កទាំងឡាយនោះ ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់បរិនិព្វាន ។ ទាំងព្រះស្តូប ព្រះចេតិយ ព្រះជិនធាតុ ក៏សាបសូន្យទៅ នឹងសាបសូន្យទៅគ្មានសល់ ។

ចប់ ធាតុភាជនីយកថា

បិដកលេខ ៧៧ ទំព័រ ២៣៦

## ២៩ អនាគតទសវង្ស

រឿងអនាគតទសវង្ស ដែលខ្ញុំព្រះករុណា អាត្មាភាព ប្រមូលរៀបរៀងមកនេះ មិនមាននៅក្នុងគម្ពីរព្រះត្រៃបិដកទេ គឺខ្ញុំស្រង់ចេញអំពីសៀវភៅអនាគតទសវង្សរបស់ព្រះគ្រូ (សមាធិញាណ **មាស-គុន**) ដែលលោកប្រមូលរៀបរៀងពីគម្ពីរនានាមានសាស្ត្រាស្លឹករិត និងសៀវភៅខ្មែរយើងជាច្រើន ។

គម្ពីរអនាគតទសវង្ស លោកពោលថា ជាស្នាដៃរបស់ព្រះមហាកស្សបត្ថេរៈ នៅឥណ្ឌាខាងត្បូង សរសេរជាប្រព័ន្ធដោយគាថារហូត ១៤២ គាថា ពណ៌នាអនាគតទសវង្សក្នុងព.ស. ប្រមាណ ១៧០៣-១៧៧៣ ។ នៅលង្កាទ្វីប ជាស្នាដៃរបស់ព្រះឧបតិស្សត្ថេរ លោករៀបជាអត្ថបទថា អនាគតទសវង្ស ប្រែជាភាសាសីហឡបោះពុម្ពផ្សាយក្នុងលង្កា ព.ស. ២៤៩៦ ។

កម្រងរឿងនេះ ខ្ញុំមិនបានស្រង់យកសេចក្តីបទដើមទាំងស្រុងទេ គ្រាន់តែសរសេរជាសេចក្តី សង្ខេបល្មមស្តាប់បាន មិនឱ្យខូចលំនាំរឿង ។ ដើម្បីបំពេញ

សេចក្ដីជ្រះថ្លាដល់ពុទ្ធបរិស័ទ អ្នកអានបានបុណ្យកុសល ឱ្យរីងរិតតែចម្រើនឡើងថែមទៀត ។ ដែលមានលំនាំរឿងពីទី១ ដល់ទី ១០ ដូចតទៅ÷

## រឿងព្រះសិរិអារ្យមេត្រីយ៍ទី ១

សម័យមួយ សម្ដេចព្រះសារពេជ្ញ ស្ដេចទ្រង់ អាស្រ័យនូវនគរសាវត្ថីកាលគង់នៅក្នុងបុព្វារាម ដែលព្រះនាងវិសាខាសាងថ្វាយ ។ គ្រានោះ ព្រះអង្គទ្រង់ប្រារព្ធ ព្រះអជិតត្ថេរបរមពុទ្ធង្កូរអរិយមេត្រីយ៍ ឱ្យជាហេតុ ព្រះលោកជេដ្ឋទ្រង់ត្រាស់សំដែងធម៌ទេសនានូវរឿងព្រះពោធិសត្វ ១០ ព្រះអង្គ ដែលត្រាស់ដឹងជាអង្គព្រះសម្មាសម្ពុទ្ធក្នុងកាលជាអនាគត ។

ព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ ទ្រង់ត្រាស់ថា÷

ម្នាលសារីបុត្ត ព្រះអរិយមេត្រីយ៍សម្មាសម្ពុទ្ធ ដែលបានត្រាស់ដឹងក្នុងភទ្ទកប្បនេះ ព្រះអង្គសាងបារមី ជាវីរិយាធិកគ្រាន់តែនឹកក្នុងព្រះទ័យ ២៨ អសង្ខេយ្យ ទ្រង់បញ្ចេញវាចាប្រាថ្នា ឱ្យបានត្រាស់ជាព្រះពុទ្ធ ៣៦ អសង្ខេយ្យ

ទ្រង់បញ្ចេញវាចា ព្រមទាំងកាយ ១៦ អសង្ខេយ្យ ១សែនកប្ប ទើបបានត្រាស់ជាព្រះពុទ្ធ ។

គ្រានោះក្រុងពារាណសី ផ្លាស់ជានគរឈ្មោះ កេតុមតី ស្តេចចក្រពត្តិឈ្មោះសង្ខចក្រ គ្រប់គ្រងរាជ្យសម្បត្តិ ក្នុងកាលនោះ បរោហិតរបស់ស្តេចចក្រពត្តិ មាននាមប្រាកដថា សុព្រហ្មជាព្រាហ្មណ៍ មានយសធំ ភរិយារបស់បរោហិតនោះ មាននាមប្រាកដថា ព្រហ្មវតី ។ គ្រានោះព្រះអរិយមេត្រីយ៍ពោធិសត្វ ដែលពួកទេវតាអារាធនាហើយក៏ចុតិអំពីឋានតុសិត មកបដិសន្ធិក្នុងផ្ទៃនៃនាងព្រហ្មវតីនោះ ក្នុងវេលាជិតភ្លឺ នាថ្ងៃឧបោសថ ពេញបូណ៌មី ខែអាសាឍ ក្នុងសម័យនោះ ស្តេចមហារាជទាំង ៤ ជាអ្នករក្សាគភ៌ ។

គ្រប់ទសមាស (១០ខែ)ហើយ ព្រះពោធិសត្វក៏ប្រសូតចាកផ្ទៃព្រះមាតាក្នុងគ្រានោះ សកលជម្ពូទ្វីបនឹងប្រាកដ និម្មិតធំតូច ៣២ ប្រការ ក្នុងចក្រវាឡទាំង អស់មានក្លិនក្រអូបសាយទៅ ។ ព្រះពោធិសត្វ មានប្រាសាទ ៣ ខ្នង គឺប្រាសាទ ទី១ ឈ្មោះសិរិវឌ្ឍនៈ ប្រាសាទ ទី២ ឈ្មោះ សិទ្ធត្ថៈ ប្រាសាទទី៣ឈ្មោះ ចន្ទកៈ ប្រាសាទ ទាំង៣នោះ ប្រកបដោយសួស្តី សព្វទិនទិវារាត្រី ។ ព្រះពោធិសត្វនោះ មានស្រីស្នំ ១ សែន គាល់បំរើអគ្គមហេសីជាប្រធានរបស់ស្រីស្នំទាំងនោះ ទ្រង់ព្រះនាមថា ចន្ទមុខី ។ បុត្ររបស់ព្រះពោធិសត្វមានព្រះនាមថា ព្រហ្មវឌ្ឍនកុមារ ។ ព្រះពោធិសត្វ ទ្រង់មានព្រះជន្ម ៨ ពាន់ឆ្នាំ ស្តេចទ្រង់យាងឡើងរថទៅកាន់ឱទ្យាន ទ្រង់ទតព្រះនេត្រឃើញ និម្មិតទាំង ៤ ប្រការគឺ មនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងអ្នកបួស ទ្រង់កើតព្រះញាណដែល

មានសេចក្តី សង្វេគជាអារម្មណ៏ ទ្រង់ពេញព្រះទ័យ ក្នុងភាពជាអ្នកបួស ស្តេច ត្រឡប់មកវិញ ឡើងកាន់ប្រាសាទ ទ្រង់បង្អោនព្រះទ័យក្នុងភាពជាអ្នកបួស ។ ខណៈនោះ ប្រាសាទរបស់ព្រះពោធិសត្វ ដែលសម្រេចហើយដោយកែវក៏អណ្តែត ចាកផ្ទៃ ផែនដីឡើងកាន់អាកាស គួរនាដូចស្តេចហង្សមាស បាននាំព្រះពោធិសត្វ ព្រមទាំងបរិវារឡើងកាន់អាកាស ។ ក្នុងកាលនោះ ពួកទេវតាមួយម៉ឺន ចក្រវាឡ ក៏នាំយកផ្កាឈើ ជាទិព្វមកបូជា ។

ព្រះរាជា ៨ ម៉ឺន ៤ ពាន់អង្គ អ្នកនិគម និងជនបទក៏នាំគ្នាកាន់យក គ្រឿងក្រអូប ឬ ផ្កាឈើមកបូជា ។ ស្តេចអសុររាជ ចាំរក្សាប្រាសាទ ។ ស្តេច នាគរាជកាន់យកកែវមណីមកបូជា ។ ស្តេចគ្រុឌកាន់យកកែវប្រដាប់ក ស្តេច គន្ធព្វទាំងឡាយ ក៏ធ្វើសក្ការៈបូជាដោយតូរ្យតន្ត្រីផ្សេង១ដល់ព្រះពោធិសត្វ ។ ស្តេចចក្រពត្តិ ព្រមទាំងស្រីស្នំ និងបរិវារបានប្រថាប់ឈរក្នុងសំណាក់ព្រះ ពោធិសត្វ ។ ដោយព្រះបរមរាជានុភាព និងដោយអានុភាពព្រះមហាសត្វ មហាជនគ្រប់ជំពូក ប្រាថ្នាភាពជាបព្វជិត ក៏អណ្តែតឡើងទៅក្នុងអាកាស ព្រម ជាមួយព្រះពោធិសត្វក្នុងកាលនោះ មហាព្រហ្មកាន់ឆត្រ ៦០ យោជន៏ មកបាំង ថ្វាយព្រះពោធិសត្វ ។ ស្តេចសក្កទេវរាជក៏ទ្រង់ផ្លុំវិជ័យយុត្តស័ង្ខថ្វាយព្រះពោធិ សត្វ ។ ស្តេចសុយាម ក៏ទ្រង់បក់ផ្លិត វាលវីជនីបូជា ។ ស្តេចសន្តុសិត ក៏ទ្រង់ កាន់យកផ្លិតធាងត្នោតកែវមុនីថ្វាយ ។ បញ្ចសិខៈទេវគន្ធព្វឈរដេញពិនកែវ ពៃទូរ្យមានពណ៌លឿងថ្វាយ ។ ស្តេចមហារាជទាំង ៤ មានដៃកាន់ព្រះខាន់ ប្រថាប់ឈរលោមព័ទ្ធក្នុងទិសទាំង ៤ ។ ពួកទេវតា មនុស្ស គន្ធព្វ យក្ស នាគ

និងត្រុឌ លោមព័ទ្ធទាំងសងខាង គឺខាងមុខនិងខាងក្រោយ ទៅជាមួយព្រះពោធិសត្វនោះ ។ ព្រះពោធិសត្វ ដែលបរិស័ទ ទាំងទេវតា និងមនុស្សជាដើម ដែលបរិបូណ៌ដោយយសសិរីយ៉ាងនោះ ជាបរិវារអណ្តែតទៅកាន់អាកាស ឈានចុះកាន់ទីពោធិមណ្ឌល ។ ខណៈនោះមហាព្រហ្មបាននាំបរិក្ខារ ៨ ដែលសម្រេចដោយឫទ្ធិ បង្អោនមកថ្វាយព្រះពោធិសត្វ ។

លំដាប់នោះព្រះមហាសត្វ ប្រើព្រះខាន់កាត់ព្រះមូលី បោះទៅក្នុងអាកាស ទ្រង់ទទួលបរិក្ខារ ៨ អំពីហត្ថារបស់ព្រហ្មហើយទ្រង់ផ្នួស ទ្រង់បំពេញព្យាយាមធំរហូត ៧ ថ្ងៃ ។ មនុស្សទាំងឡាយចេញបួស តាមព្រះមហាសត្វយ៉ាងប្រើត្រឹង ព្រះសិអារ្យមេត្រីយ៍ទី ១

មានដើមខ្ទឹងជាឈើត្រាស់ដឹង កំពស់ ១២០ ហត្ថ មានមែក ៤ មែកនីមួយៗប្រវែង ១២០ ហត្ថ អំពីគល់ដល់ចុង ២៤០ ហត្ថ ។

ក្នុងវេលាល្ងាចព្រះពោធិសត្វ ស្តេចឡើងកាន់ពោធិមណ្ឌល ប្រថាប់លើអបរាជិតបល្ល័ង្ក ក្នុងបឋមយាម ទ្រង់បានបុព្វេនិវាសញ្ញាណ ក្នុងមជ្ឈិមយាមទ្រង់ជម្រះទិព្វចក្ខុញ្ញាណក្នុងបច្ឆិមយាម ទ្រង់ពិចារណានូវបច្ចយាការ ១២ ប្រការ ត្រឡប់ទៅត្រឡប់មក ទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ក្នុងបច្ចូសសម័យនោះឯង ទ្រង់ជាព្រះពុទ្ធ ទ្រង់ញ៉ាំងមនុស្ស ១ សែនកោដិ ឱ្យផឹកទឹកអម្រិតទេវតា រាប់ចំនួន មិនបានត្រាស់ដឹងធម៌ ។

ក៏ព្រះមានព្រះភាគអង្គនេះ ទ្រង់មានព្រះវរកាយកំពស់ ៨៨ ហត្ថ រាប់ពីផ្ទៃព្រះបាទដល់ព្រះជានុ ២២ហត្ថ រាប់ពីព្រះជានុដល់ព្រះនាភិ ២២ ហត្ថ រាប់ពី

ព្រះនាភិដល់ព្រះអក្ខៈទាំងពីរ ២២ហត្ថ រាប់ពីព្រះអក្ខៈដល់ព្រះសិរ ទីបំផុត ព្រះឧណ្ហីស ២២ ហត្ថ ស្មើគ្នាទាំង ៤ចំណែក ទំហំព្រះអង្គ ២៥ ហត្ថ ។

ក៏ព្រះឆព្វណ្ណរង្សី បានផ្សាយចេញទៅអំពីព្រះវរកាយរបស់ព្រះមានព្រះភាគអង្គនោះ ដូចខ្សែទឹកហូរអំពីឆ្នាំងមាស គ្របដណ្ដប់ពន្លឺរបស់ព្រះចន្ទ និង ព្រះអាទិត្យ ផ្សាយទៅក្នុង១ម៉ឺនចក្រវាឡ ពន្លឺភ្លឺស្វាង អស់កាលជានិច្ច មនុស្សទាំងឡាយមិនអាចកំណត់ពេលថ្ងៃ និង ពេលយប់បាន, រស្មីរបស់ព្រះពុទ្ធតាំងនៅក្នុងលោក អស់កាលជានិច្ច មនុស្សទាំងឡាយដឹងថា នេះជាពេលល្ងាច ជាវេលាដែលព្រះអាទិត្យអស្តង្គត ដោយសម្លេងសត្វបក្សីយំ ក្នុងវេលាមកកាន់សំបុក និងដោយចុងត្របកផ្កាឈូក និង ចុងត្របកផ្កាឈើរួមក្ដោប មនុស្សទាំងឡាយដឹងថានេះជាពេលព្រឹក ជាវេលាដែលព្រះអាទិត្យចែងចាំងរស្មី ដោយសម្លេងសត្វបក្សីហើរចេញទៅស្វែងរកស៊ី និងដោយចុងត្របកផ្កាឈូក និងដោយចុងត្របកផ្កាឈើរីកចេញ ។ លំដាប់នោះផ្កាឈូកធំៗ មានត្របកខាងក្រៅ ៣០ហត្ថ ត្របកខាងក្នុង ២៥ ហត្ថ កេសរ ២០ ហត្ថ រង្វង់ក្ដិប ១៦ ហត្ថ លំអងកេសរផ្សាយទៅក្នុងអាកាសផ្កាឈូកទាំងនោះ ជ្រែកផែនដីដុះឡើងទទួលព្រះបាទ ដែលទ្រង់យាងទៅគ្រប់ៗ ជំហានរបស់ព្រះពុទ្ធអង្គនោះ ។ មនុស្សទាំងឡាយ មិនបាច់ធ្វើស្រែ ចំការ មិនបាច់ប្រកបអាជីវកម្ម មិនមានរោគាបៀតបៀន មិនមានភ័យ បរិបូណ៌ដោយសេចក្ដីសុខ មានពុទ្ធានុស្សតិ បរិភោគស្រូវសាលី ដែលជាភោជនាហារ កើតដោយពុទ្ធានុភាព ស្លៀកដណ្ដប់សំពត់ អាវ គ្រឿងអភរណៈ ចិញ្ចឹមជីវិត ។ កាលព្រះមានព្រះភាគអង្គនោះ ទ្រង់សំដែងធម្មចក្ក ទេវតា និង

មនុស្សប្រមាណ ៣០ កោដិ បានត្រាស់ដឹងធម៌ ។

ម្នាលសារីបុត្ត ការបំពេញអភិនីហារបារមីយ៉ាងសំខាន់បំផុតរបស់ព្រះអរិយមេត្រីយ៍ កាលដែលបានជួបនឹងព្រះសម្ពុទ្ធទ្រង់ព្រះនាមសិរីមតៈ ។ សេចក្ដីថា ក្នុងកាលនោះ ព្រះអង្គបានជាស្ដេចចក្រពត្តិ ទ្រង់ព្រះនាមថា (សង្ខចក្រ) ។ ថ្ងៃមួយ ព្រះអង្គគង់នៅក្រោមស្វេតច្ឆត្រ ទ្រង់រំពឹងថា ប្រសិនបើអ្នកណា ប្រាប់ដំណឹងថា ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃកើតឡើងហើយ អាត្មាអញនឹងលះរាជ្យសម្បត្តិដល់អ្នកនោះ គ្រានោះមានកុលបុត្រកំសត់ម្នាក់ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ទ្រង់ព្រះនាមសិរីមតៈ បានបព្វជ្ជាជាសាមណេរ ឯមាតានៃសាមណេរនោះជាទាសីរបស់អ្នកដទៃ ឈ្មោះហើយសាមណេរនោះ ខំស្វែងរកទ្រព្យដើម្បីលោះលាមាតា និមន្តរហូតទៅដល់ឥន្ទបត្តនគរ ហេតុតែអ្នកស្រុកទាំងឡាយមិនស្គាល់ភេទ បព្វជិត ស្មានថាជាយក្ស ឬ មារក៏នាំគ្នាកាន់គ្រឿងសាស្ត្រាវុធចាំការពារខ្លួនគ្រប់ៗគ្នា ខ្លះក៏ដេញកាប់ពីក្រោយ ។ ឯសាមណេរភ័យតក់ស្លុតរន្ធត់ខ្លាំងក៏រត់ទៅឈរចំពោះព្រះភ័ក្ត្រ ព្រះរាជាក្នុងព្រះរាជវាំង ។ ព្រះមហាក្សត្រ ទ្រង់ទតឃើញ ទ្រង់មានព្រះឱង្ការថា អ្នកឈ្មោះអ្វី? ថ្វាយព្រះពរ អាត្មាភាពឈ្មោះសាមណេរ ។ ដូចម្ដេចទៅដែលហៅថាសាមណេរ? ថ្វាយព្រះពរដែលហៅថាសាមណេរ ព្រោះអាត្មាភាពមិនធ្វើបាបខាងក្រៅ ហើយប្រឹងតែធ្វើកុសល ឱ្យកើតឡើងខាងក្នុងសន្ដាន ។

ចុះពាក្យថា សាមណេរ អ្នកណាឱ្យលោក? ថ្វាយព្រះពរអាចារ្យរបស់អាត្មាភាព ។ អាចារ្យរបស់លោកឈ្មោះអ្វី? ថ្វាយព្រះពរឈ្មោះ ថាភិក្ខុ ។ ចុះ

អាចារ្យឈ្មោះថាភិក្ខុ ដោយហេតុអ្វី? ថ្វាយព្រះពរ អាចារ្យរបស់អាត្មាភាពឈ្មោះថា ភិក្ខុ ជាសង្ឃរតនៈ ព្រោះរករតនៈដទៃមកប្រៀបផ្ទឹមត្រឹមគ្មាន ។ ព្រះអង្គទ្រង់ព្រះសណ្ដាប់ ហើយក៏ទ្រង់ជ្រាបថា ព្រះសង្ឃពិតជាកើតប្រត្យក្សក្នុងលោកហើយ ទ្រង់មានព្រះទ័យសោមនស្សពន់ពេក ទើបទ្រង់ព្រះចិន្តាថា អាត្មានឹងចុះទៅកាន់ទីជិតសាមណេរ បីតិបណ្ដាលព្រះអង្គឱ្យអណ្ដែតចុះមកចំពោះមុខសាមណេរ ជ្រះថ្លាក្នុងសង្ឃរតនៈ ស្រាប់តែផ្កាឈ្យូកផុសឡើងមកទ្រព្រះបាទព្រះរាជាអង្គនោះ ។ ស្ដេចប្រណមហត្ថាទូលសួរសាមណេរថា ចុះសង្ឃរតនៈ អ្នកណាឱ្យនាម? ថ្វាយព្រះពរ ព្រះពុទ្ធអង្គ ទ្រង់ព្រះនាមសិរីមតៈជាពុទ្ធរតនៈ ទ្រង់ប្រទាន ។ ស្ដេចទ្រង់ព្រះសណ្ដាប់ហើយ ក៏ដល់នូវវិសញ្ញីដួលសន្លប់ភ្លាម លុះមានព្រះស្មារតីឡើងវិញហើយ ទើបទូលសួរថា ព្រះអង្គ ទ្រង់គង់នៅទីណា? ថ្វាយព្រះពរ ព្រះអង្គទ្រង់គង់នៅបុព្វារាមក្នុងឧត្តរទិស រាប់ពីនគរឥន្ទបត្តនេះ ទៅចម្ងាយ ១៦យោជន៏ ។ ព្រះមហាក្សត្រិយ៏ទ្រង់ព្រះសណ្ដាប់ ហើយទូលសាមណេរថា បពិត្រសាមណេរ បើព្រះសព្វញ្ញុពុទ្ធគង់ក្នុងទីណា ខ្ញុំព្រះករុណានឹងទៅក្នុងទីនោះ ហើយព្រះបាទសង្ខចក្រ ស្ដេចមិនអើពើនឹងរាជសម្បត្តិ ទ្រង់ចង់ជួបតែព្រះពុទ្ធប៉ុណ្ណោះ ទើបទ្រង់មានបន្ទូលឱ្យសាមណេរ ចាកសិក្ខាបទ ទ្រង់ប្រគល់រាជសម្បត្តិ ឱ្យដល់បណ្ឌិតសាមណេរសោយរាជ្យជាស្ដេចក្នុងឥន្ទបត្តមហានគរតទៅ ។ ព្រះអង្គយាងទៅតែមួយព្រះអង្គឯងមានព្រះភ័ក្ត្រឆ្ពោះទៅបុព្វារាម ។ ហេតុតែព្រះអង្គ ជាសុខុមជាតិ មានព្រះអង្គទន់ល្វន់ គ្រាន់តែស្ដេចយាងតាមមាគ៌ាប៉ុណ្ណោះ ដោយព្រះបាទាទទេ

ព្រះអង្គ ក៏ដល់នូវអាការៈពោរពង ព្រះលោហិតហូរស្រក់ចុះអំពីព្រះបាទទាំងគូ លុះព្រះអង្គយាងដោយព្រះបាទពុំរួច ក៏នៅតែមិនប្រថាប់ ស្តេចទ្រង់យាងទៅដោយព្រះជានុ គឺវារទៅបន្តិចម្តងៗ យាងតាមផ្លូវដែលបណ្ឌិតសាមណេរនោះពន្យល់ មិនព្រមលះបង់សេចក្តីព្យាយាមឡើយ ។ លុះថ្ងៃទី ៤ ព្រះហត្ថា ឆ្វេង-ស្តាំ និងព្រះជានុឆ្វេង-ស្តាំបែកហូរព្រះលោហិតទៅទៀត ស្តេចវារទៅពុំរួចឡើយ ក៏ទ្រាលផ្ទាល់ព្រះឱរាលូនបន្តិចម្តងៗ វេទនាក្នុងព្រះឱរាខ្លាំង ស្តេចក៏យកពុទ្ធគុណមកជាអារម្មណ៍ ប្រឹងអត់សង្កត់ទុក្ខវេទនា មិនអាឡោះអាល័យកាយរបស់ព្រះអង្គឡើយ ។

គ្រានោះព្រះពុទ្ធសិរីមតះ ព្រះអង្គប្រកបដោយមហាករុណាទិគុណពិចារណាមើលសត្វលោកដោយសព្វញ្ញុតញ្ញាណក៏បានជ្រាបថាព្រះបាទ សង្ខចក្រខំប្រឹងព្យាយាមយាងមកឱ្យជួបតថាគត យ៉ាងឧក្រិដ្ឋ ស្តេចនេះមិនថោកថយពិតជាពុទ្ធង្កូរបណ្តូលសារពេជ្ជ មានវង្សជាមួយតថាគតដែរ បើតថាគត មិនទៅសង្គ្រោះទេ ឃើញថាមិនបាន ទើបព្រះអង្គនិម្មិតព្រះកាយជាមាណពឡើងបររថសំដៅតាមមាគ៌ាឆ្ពោះ ព្រះភ័ក្ត្រទៅរកព្រះបាទសង្ខចក្រ លុះដល់ហើយទ្រង់មានព្រះបន្ទូលថា អ្នកណាមកដេក កណ្តាលផ្លូវរថ ចូរអ្នកក្រោកចេញឱ្យឆាប់ព្រះពោធិសត្វសង្ខចក្រ ឆ្លើយតបថា ម្នាលសារថី ហេតុអ្វីបានជាអ្នកដេញយើងឱ្យចេញ យើងមានគុណព្រះពុទ្ធ ជាអារម្មណ៍ គួរតែអ្នកឯងបរសេះចៀសខ្ញុំវិញទើបគួរ បើអ្នកមិនព្រមទេ ចូរអ្នកបរសេះលើខ្នងខ្ញុំចុះ យើងមិនចៀសអ្នកឯងឡើយ ។ គ្រានោះ ព្រះសព្វញ្ញូត្រាស់សួរថា អ្នកប្រាថ្នា ទៅទីណា? យើងចង់

ទៅកាន់សំណាក់ព្រះសម្ពុទ្ធ បើដូច្នេះ ចូរអ្នកក្រោកឡើងជិះទៅជាមួយនឹងយើង យើងនឹងនាំអ្នកទៅឱ្យដល់ ។

គ្រានោះ ព្រះសព្វញ្ញុពុទ្ធ ទ្រង់ញាក់អស្សពាហ៍ចូលទៅជិត ទើបព្រះពោធិសត្វតម្រង់កាយយ៉ាងស្រួល ហើយឡើងគង់លើរថ ព្រះសព្វញ្ញូបំបែររថតាមផ្លូវទៅកាន់បុព្វារាម ។ ដល់ពាក់កណ្ដាលផ្លូវ សម្ដេចអម្រិន្ទ្រា និងនាងសុជាតា នាំភោជនាហារ និងទឹកទិព្វមកថ្វាយ ហើយនិម្មិតភេទជាបុរស មកឈរចាំមុខរថ ហើយស្រែកហៅថា នែសារថី! អ្នកឯងស្រេកទឹក ឃ្លានបាយឬទេ បើឃ្លានយើងឱ្យ! នាយ សារថីតបថា យើងមិនត្រូវការទេ តែសូមអ្នកឱ្យមកចុះ យើងនឹងឱ្យដល់ បុរសម្នាក់នេះបរិភោគ ត្បិតគ្នាលំបាកណាស់ អម្រិន្ទ្រាធិរាជ ក៏ថ្វាយភោជនាហារដល់ព្រះអង្គ ។ ព្រះអង្គក៏ប្រទានដល់ពោធិសត្វ ។ ព្រះសង្ខចក្រទ្រង់សោយហើយដ៏រាបណា ឱជារសអាហារទិព្វ ទើបបំបាត់ទុក្ខវេទនាក្នុងព្រះកាយអស់ ។ ព្រះសព្វញ្ញុពុទ្ធជានាយសារថី នាំព្រះពោធិសត្វ ទៅជិតបុព្វារាមវិហារ ទើបស្ដេចទៅគង់លើពុទ្ធាសនៈវិញដដែល ។

ឯមហាបុរសយាងចុះពីរថស្ដេចចូលទៅកាន់វិហារ ទតឃើញទ្វត្តឹសមហាបុរិសលក្ខណៈ និងអសីត្យានុព្យញ្ជនៈព្រមទាំងរស្មីដ៏ឱភាស ស្ដេចក៏ដល់នូវវិសញ្ញីបាត់ស្មារតីសន្លប់ដួលចុះក្នុងទីនោះ ។ ព្រះសព្វញ្ញុពុទ្ធត្រាស់ថា នែមហាបុរស ! តថាគតនៅក្នុងទីនេះទេតើ ព្រះពោធិសត្វបានឮព្រះបន្ទូល ហើយក៏មានស្មារតីឡើងជ្រះថ្លាហួសប្រៀប ស្ដេចឱនសិរសាថ្វាយបង្គំ ហើយគង់នៅក្នុងទីដ៏

សមគួរ ទើបក្រាបទូល ព្រះពុទ្ធអង្គ សូមឱ្យសម្ដែងព្រះធម៌ទេសនា ។ ព្រះសព្វញ្ញុពុទ្ធទ្រង់សម្ដែងអនុបុព្វីកថា រួចស្ដេចពណ៌នាអំពីគុណព្រះនិព្វានថា វិសេសវិសាលធំមិទាំងពួង គឺព្រះនិព្វានជាបរមសុខគ្មានអ្វីប្រៀបស្មើបាន ទ្រង់មានព្រះសូរសៀងពីរោះដូចជាសម្លេងសត្វករវិក និងសម្លេងមហាព្រហ្ម ។ ព្រះមហាបុរសរតនី ទ្រង់ឃាត់ បានជាទ្រង់ឃាត់ព្រោះទ្រង់គ្មានអ្វីបូជា ទើបក្រាបទូលថា ព្រះអង្គទ្រង់ប្រទានធម៌ ទេសនាដល់ខ្ញុំព្រះអង្គអំពីអមតមហានិព្វាន ខ្ញុំព្រះអង្គគ្មានអ្វីបូជាព្រះអង្គសោះ បើដូច្នោះ ខ្ញុំព្រះអង្គ នឹងកាត់ព្រះសិរសាធ្វើសក្ការៈបូជា ទូលដូច្នេះរួចហើយ ទើបទ្រង់អធិដ្ឋានថា សូមឱ្យក្រចករបស់ខ្ញុំព្រះអង្គមុតដូចព្រះខ័នពេជ្រ ។ មនោប្រណិធានក៏បានដូចអធិដ្ឋានមែន ព្រះអង្គកាត់ព្រះសិរសាដាក់លើព្រះហស្ត ទើបក្រាបទូល សូមព្រះអង្គយាងទៅកាន់និព្វានមុនចុះ ខ្ញុំព្រះអង្គនឹងទៅក្រោយ ដោយតេជះ ខ្ញុំព្រះអង្គកាត់សិរសាថ្វាយឥឡូវនេះ សូមឱ្យខ្ញុំព្រះអង្គបាននូវសព្វញ្ញុតញ្ញាណ លុះផុតវាចាក៏ទីវង្គត់ទៅ បានទៅកើតក្នុងតុសិត ។ ម្នាលសារីបុត្ត ព្រះសិអារ្យមេត្រីយ៍ ស្ដេចបានត្រាស់មានព្រះកាយកំពស់ ៨៨ ហត្ថនេះ ដោយផលដែលបូជាព្រះសិរសា ។ ដែលមានរស្មីភ្លឺទាំងយប់ទាំងថ្ងៃ ដោយផលដែលព្រះអង្គ ខំប្រឹងព្យាយាម ស្ដេចទៅតាមផ្លូវ ទ្រង់បំណងឱ្យជួបនឹងព្រះពុទ្ធ ដរាបដល់ព្រះលោហិតហូរចេញតាមព្រះបាទព្រះជង្ឃ និងតាមព្រះឱរានោះឯង ។ រស្មីដែលផ្សាយចេញទៅរហូតដល់ព្រហ្មលោកទៅក្រោម ដល់អវិចីនរកនេះ ដោយផលដែលព្រះអង្គបានកាត់ព្រះសិរសាធ្វើសក្ការៈបូជាធម៌ទេសនា ក្នុងសាសនាព្រះពុទ្ធសិរីមតៈ មានដើម

កល្បព្រឹក្សកើតឡើង ៤ ដើម ឱ្យសម្រេចសេចក្តីប្រាថ្នាទាំងពួង ដោយផលដែលព្រះអង្គយាងទៅតាមផ្លូវឆ្ងាយ ទ្រង់ចង់ជួបនឹងព្រះពុទ្ធអង្គលុះអស់រយៈមួយសប្តាហ៍ទើបបានជួប ។

ម្នាលសារីបុត្ត ជនណាបានឃើញរូបកាយតថាគត ឬ អ្នកណាបានជួបសាសនាតថាគតហើយ
ខំធ្វើទានរក្សាសីលចម្រើនភាវនាប្រាថ្នាចង់ជួបនឹងសាសនា
ព្រះអរិយមេត្រីយ៍នោះ មុខតែបានជួបពុំខានឡើយ ។

ហេតុនោះបណ្ឌិតទាំងឡាយចូរខំធ្វើទានរក្សាសីល ចម្រើនមេត្តាភាវនាដើម្បីនឹងឈោងយកព្រះនិព្វានទៅខាងមុខ ។ រតនបល្ល័ង្ករបស់ព្រះអរិយមេត្រីយ៍ ៥៣ហត្ថ ព្រះជន្ម ៨ម៉ឺនឆ្នាំ កើតក្នុងត្រកូល ព្រាហ្មណ៍ ព្យាយាមអស់ ៧ ថ្ងៃ បានត្រាស់ដឹងព្រះរស្មីរាប់មិនបាន ។ ព្រះអគ្គសាវ័កខាងស្តាំ ឈ្មោះអសោកត្ថេរ អគ្គសាវ័កខាងឆ្វេងឈ្មោះ ជិនមិត្តត្ថេរ ឧបដ្ឋាកឈ្មោះ វិជិយ្យកត្ថេរ អគ្គសាវិកាឈ្មោះ នាង បូរម្មាថេរី អគ្គសាវិកា ឆ្វេងឈ្មោះ សមន្ទាថេរី ។

ចប់ រឿងអរិយមេត្រីយ៍សម្មាសម្ពុទ្ធ

## រឿងព្រះរាមសម្មាសម្ពុទ្ធទី ២

កាលសាសនា ព្រះអរិយមេត្រីយ៍ វិនាសទៅហើយ ភ្លើងនឹងឆេះដែនដីកាលភទ្ទកប្បកន្លងទៅហើយ មានសុញ្ញកប្បកើតឡើងជាបន្តបន្ទាប់ចំនួនមួយអសង្ខេយ្យផែនដី គ្មានព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង ស្តេចចក្រពត្តិឡើយ លុះ

កប្បនោះវិនាសទៅហើយ ។ ទើបមានផែនដីមួយជាថ្មីទៀត ឈ្មោះថា មណ្ឌកប្ប ។ ក្នុងកប្បនេះមាន ព្រះសម្ពុទ្ធពីរព្រះអង្គត្រាស់ដឹងឡើងក្នុងលោក គឺ ព្រះរាម សម្មាសម្ពុទ្ធ ១ ព្រះធម្មរាជាសម្មាសម្ពុទ្ធ ១ ។ ព្រះរាមសម្មាសម្ពុទ្ធ ឧប្បត្តិឡើងមុនក្នុងសាសនា ព្រះសមណគោតមសម្មាសម្ពុទ្ធ ព្រះអង្គជារាមរាជ ពោធិសត្វ ព្រះអង្គសាងបារមីជាវិរិយាធិក ព្រះអង្គមានកំពស់ ៨០ ហត្ថ មាន ដើមចន្ទន៏ ជាមហាពោធិ មានរស្មីភ្លឺព្នដ៏អាកាសជានិច្ច មនុស្សកាលនោះចិញ្ចឹម ជីវិតបានសុខ សប្បាយដោយសារដើមកប្បព្រឹក្ស ជាទីកើតនៃវត្ថុគ្រប់យ៉ាង ដោយតេជានុភាពនៃព្រះពុទ្ធ ។

ក្នុងសាសនាព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមកស្សប ។ ព្រះរាមពោធិសត្វ មកកើតក្នុងត្រកូល ព្រាហ្មណ៏ មាននាមថា នារទមាណព បានបំពេញបារមីជា កំពូល "បរមត្ថបារមី" កាលនារទមាណព បានជួបនឹងព្រះកស្សបសម្មាសម្ពុទ្ធ មានសេចក្តីសោមនស្សគិតថា អញនឹងធ្វើសក្ការៈបូជា អញមិនស្តាយជីវិតឡើយ លុះគិតដូច្នោះហើយ ក៏យកសំពត់ពីរផ្ទត់ជ្រលក់ប្រេងក្រអូប ហើយរុំព័ទ្ធសរីរ ទាំងមូល ទើបអុជភ្លើងជាប្រទីបបូជា ហើយតាំងសត្យាប្រណិធានប្រាថ្នាថា "បពិត្រព្រះអង្គ អវយវៈតូចធំដែលខ្ញុំព្រះអង្គ បានធ្វើសក្ការៈបូជាថ្វាយ ដូច្នេះ សូមជាបច្ច័យឱ្យខ្ញុំបានសព្វញ្ញុតញ្ញាណ" ទើបព្រះកស្សបសម្មាសម្ពុទ្ធ ទ្រង់ ព្យាករណ៏ថា នៃមាណព ! ភទ្ទកប្បនេះ វិនាសទៅហើយ មានផែនដីដុះឡើងថ្មី ទៀតហៅថា សុញ្ញកប្ប ផែនដីនោះវិនាសទៅជាបន្តបន្ទាប់អស់១ អសង្ខេយ្យ ផែនដីទៀត ទើបកើតមណ្ឌកប្បខាងមុខ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធទ្រង់

ព្រះនាមថា "ព្រះរាមសម្ពុទ្ធ" ។

ឯនារទមាណព លុះដុតកាយជាប្រទីតាំងជាសក្ការៈបូជាថ្វាយ ព្រះកស្សបសម្ពុទ្ធហើយក៏រលត់ខន្ធ ទៅកើតក្នុងតុសិតទេវលោក ។ ដោយផលនៃការបូជានេះ ទើបបានជាសព្វញ្ញុពុទ្ធ ព្រះអង្គមានព្រះកាយ កំពស់ ៨០ ហត្ថ មានព្រះជន្ម ៩ ម៉ឺនឆ្នាំ ជាកំណត់ មានព្រះរស្មីចែងចាំង ទាំងយប់ទាំងថ្ងៃជានិច្ច លើស លប់លើពន្លឺព្រះអាទិត្យ និងព្រះចន្ទបាន ។

(ចប់ រឿងព្រះរាមសម្មាសម្ពុទ្ធ)

## រឿងព្រះធម្មរាជាសម្មាសម្ពុទ្ធទី ៣

កាលសាសនារបស់ព្រះរាមសម្មាសម្ពុទ្ធសាបសូន្យហើយ ទើបព្រះបាទបសេនទិកោសល ពោធិសត្វ ចុះមកត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធ មាននាមប្រាកដថា ព្រះធម្មរាជាសម្មាសម្ពុទ្ធ ព្រះអង្គ ទ្រង់បំពេញបារមីជាវីរិយាធិក មាន ព្រះកាយកំពស់ ១៦ ហត្ថ មានដើមខ្លឹងជាមហាពោធិ បើព្រះអង្គយាងទៅទីណា មានផ្កាឈូកមាសពីរផុសមកទទួលព្រះបាទទាំងគូរ ឯផ្កាឈូកនោះទំហំប៉ុន កង់រាជរថ ។ កាលនោះ មនុស្សទាំងឡាយ មិនបាច់រកស៊ីចិញ្ចឹមជីវិតដោយកិច្ចការអ្វីមួយឡើយ រស់នៅជាសុខសប្បាយ ដោយសារដើមកប្បព្រឹក្សមួយដើម ឱ្យបានសម្រេចប្រយោជន៍គ្រប់យ៉ាង។ កប្បព្រឹក្សកើតឡើង ដោយបុណ្យ បារមីរបស់ព្រះអង្គ ។

ក្នុងសាសនានៃព្រះកោនាគមនសម្មាសម្ពុទ្ធ ព្រះបាទបសេនទិកោសល នេះ កើតជាមាណពម្នាក់ ឈ្មោះ សុទ្ធមាណព បានបំពេញបារមីជាកំពូលមួយ ឈ្មោះថា បរមត្ថបារមី ។ មាណពនោះបានថែរក្សាស្រះឈូកមួយ រាល់ព្រឹក គាត់តែងបេះផ្កាឈូកពីរ៧ទៅលក់ចិញ្ចឹមជីវិតរាល់ថ្ងៃ ។ សម័យមួយ មាណព បេះផ្កាឈូកប្រយោជន៍ដើម្បីលក់ ស្រាប់តែព្រះកោនាគមនសម្ពុទ្ធ ទ្រង់គោចរ បិណ្ឌបាត បានទតព្រះនេត្រ មកទ្រង់ពិចារណាជ្រាបថា "សុទ្ធមាណពនេះ នឹង បានត្រាស់ជាព្រះពុទ្ធដូចតថាគតដែរ ឥឡូវនេះ គួរតែតថាគតនឹងព្យាករណ៍ មាណពនេះ ថាជាព្រះសម្មាសម្ពុទ្ធ" ទ្រង់តម្រិះដូច្នេះហើយ ទើបទ្រង់ញញឹម ។ សុទ្ធមាណពឃើញដូច្នេះ ក៏ទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មិនជា ញាតិទេ ចុះហេតុអ្វីបានជាព្រះអង្គ ធ្វើដូចជាស្និទ្ធស្នាលម្ល៉េះ?" ។ ព្រះអង្គត្រាស់ ថា "ម្នាលសុទ្ធមាណព អ្នកមិនដឹងទេឬ ? ខ្លួនអ្នកនេះរួមបិតា ជាមួយនឹង តថាគត"។ សុទ្ធមាណពមានហឫទ័យសោមនស្ស ទើបទូលសួរថា ខ្ញុំព្រះអង្គជា ប្អូនពីកាលណា? ព្រះអង្គទ្រង់ញញឹមដូច្នេះទៀត ទ្រង់ត្រាស់ថា ម្នាលសុទ្ធ មាណព ក្នុងកាលយូរអង្វែងណាស់ទៅ មានកប្បមួយឈ្មោះមណ្ឌកប្បមាន ព្រះពុទ្ធត្រាស់ពីរអង្គ គឺព្រះរាមសព្វញ្ញុពុទ្ធត្រាស់មុន លុះសាសនានោះ កន្លងទៅ ទើបអ្នកមកត្រាស់ជាសព្វញ្ញុពុទ្ធ ព្រះនាមថា "ធម្មរាជា" ដ៏ប្រសើរ! ឥឡូវនេះ តថាគត ត្រាស់មុនអ្នកហើយ អ្នកនឹងត្រាស់ដឹងជាខាងក្រោយមិនខាន ហេតុនេះ បានជាតថាគតពោលថា "ខ្លួនអ្នក ជាប្អូនតថាគត" ។ សុទ្ធមាណពបានឮពុទ្ធ ព្យាករណ៍ ហើយជ្រះថ្លាពន់ប្រមាណ ក៏លះបង់អាយុជីវិតថ្វាយ ចំពោះព្រះអង្គ

មិនស្តាយឡើយ លើកយកផ្កាឈូកទាំងពីរថ្វាយ ហើយទូលថា សូមព្រះអង្គគង់លើផ្កាឈូកនេះ ។ ព្រះអង្គគង់ហើយដោយពុទ្ធានុភាព សុទ្ធមាណព ឃើញហើយកាន់តែជ្រះថ្លា ក៏យកសំពត់ពីរផ្ទត់បាំងជាដំបូល ថ្វាយដោយ បង្គោលដើមបបុស ៤ ដើម ការបូជានេះ ខ្ញុំព្រះអង្គមិនមានវត្ថុអ្វីដែលលើស ឡើយ សូមជាបច្ច័យឱ្យខ្ញុំព្រះអង្គបានពោធិញ្ញាណទៅអនាគតកុំបីខានឡើយ ។ ព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់ថា សេចក្តីប្រាថ្នារបស់អ្នកចូរបានសំរេចចុះ។ ព្រះធម្មរាជាសម្ពុទ្ធទ្រង់មានព្រះជន្ម ៥ ម៉ឺនឆ្នាំគត់ ទើបបរិនិព្វាន ។

ចប់ រឿងព្រះធម្មរាជាសម្ពុទ្ធ

## រឿងព្រះធម្មសាមីសម្មាសម្ពុទ្ធទី ៤

កាលសាសនារបស់ព្រះពុទ្ធរាម និងព្រះពុទ្ធធម្មរាជា វិនាសទៅ មណ្ឌកប្បនឹងត្រូវភ្លើងឆេះ តពីនេះ មានកប្បថ្មីឈ្មោះ សារកប្ប ព្រះអភិភូទេវរាជ ឬមារាធិរាជ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ទ្រង់ព្រះនាមថា ធម្មសាមី ។ ព្រះធម្មសាមីសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់សាងបារមីជាវិរិយាធិក មានព្រះកាយកំពស់ ៨០ ហត្ថ មានដើមរាំងជាពោធិព្រឹក្ស មានរស្មីរុងរឿង ដូចជាព្រះអាទិត្យ និងព្រះចន្ទរះចាកស្រទាប់មេឃ មានស្វេតច្ឆត្រ កំពស់ ៣ យោជន៍ផុសឡើងបាំងថ្វាយ ព្រះអង្គ គ្រប់តិរិយាបថដោយអំណាចអភិនីហារបារមីនៃព្រះអង្គ ទើបមានកំណប់មាស ១ធំ ឱ្យសម្រេចប្រយោជន៍ចិញ្ចឹមជីវិតជាសុខសប្បាយដល់មនុស្សទាំងឡាយ ។

មារាធិរាជ កាលកំពុងសាងបារមីនោះ មានបារមីមួយជាកំពូលនៃបារមី

ទាំងពួង គឺ បរមត្ថបារមី ទើបឱ្យសម្រេចនូវពុទ្ធសម្បត្តិទាំងពួង ។

ក្នុងអតីតជាតិ ព្រះធម្មសាមីសោយព្រះជាតិជាអាមាត្យ ឈ្មោះពោធិ ក្នុងសម័យនៃព្រះពុទ្ធ ព្រះនាមកស្សបះ ក្នុងកាលមួយព្រះពុទ្ធកស្សបះ ទ្រង់សោយផលសមាបត្តិ ខាងក្រោមដើមនិគ្រោធ ស្តេចចេញចាកផលសមាបត្តិ ប្រថាប់ក្នុងវត្តជេតពន ព្រះបាទកិង្កិស្សមហារាជ ទ្រង់ជ្រាបអានិសង្ស នៃផលសមាបត្តិ ទ្រង់មានប្រាថ្នានឹងថ្វាយទានដល់ព្រះពុទ្ធមុន បើមានអ្នកណាមួយហ៊ានថ្វាយទានមុនព្រះអង្គ អ្នកនោះនឹងទទួលរាជទណ្ឌ ហើយទ្រង់ឱ្យទាហានរក្សាការពារជុំវិញវត្តជេតពន ។ ពោធិអាមាត្យ ប្រាថ្នានឹងថ្វាយទានដល់ព្រះពុទ្ធមុន ទុកជារាជបុរសចាប់អញយកទៅថ្វាយ ព្រះ មហាក្សត្រ ព្រះនាមកិង្កិស្ស ស្តេចនឹងប្រហារជីវិត ព្រះសម្មាសម្ពុទ្ធទ្រង់សរសើរអាត្មាអញដោយសារព្យាយាម ក្នុងបុណ្យកុសល ជីវិតរបស់អាត្មាអញឈ្មោះថា ប្រសើរណាស់ ក៏ប្រាប់ប្រពន្ធកូនឱ្យចាត់ចែងទេយ្យទាន មានសំពត់និងភត្តយ៉ាងប្រណីត នាំមកកាន់វត្តជេតពន ត្រូវពួកអាមាត្យ និងរាជបុរសចាប់ខ្លួននាំទៅថ្វាយព្រះបាទកិង្កិស្ស មហារាជ ព្រះរាជាទ្រង់ក្រោធ បញ្ជាឱ្យនាំពោធិអាមាត្យ ទៅសម្លាប់ក្នុងព្រៃ ។

គ្រានោះ ព្រះកស្សបសម្មាសម្ពុទ្ធ ទ្រង់ជ្រាបហេតុដោយពុទ្ធញ្ញាណថា ពោធិអាមាត្យ នេះជាពោធិសត្វ មុខជាមរណៈក្នុងពេលនេះហើយ ត្រូវតថាគតទៅសង្គ្រោះក៏និម្មិតរូបនៃព្រះអង្គ ហាក់ដូចជាគង់នៅក្នុងវិហារដដែល ហើយព្រះអង្គទៅស្ថិតនៅចំពោះមុខព្រះពោធិសត្វសំដែងឫទ្ធិ មិនឱ្យឃាតករបុរសឃើញព្រះអង្គឡើយ ។ ពោធិអាមាត្យលុះឃើញព្រះពុទ្ធហើយ ក៏សោមនស្សជ្រះថ្លារកទីបំផុតគ្មាន ទើបយកគ្រឿងសក្ការចំណែកខ្លួន និងចំណែកប្រពន្ធមក

ថ្វាយព្រះអង្គ ដោយបញ្ចប្រតិស្ថានទូលថា "បពិត្រព្រះសម្ពុទ្ធដ៏ចម្រើន ដោយតេជះដែលខ្ញុំព្រះអង្គលះជីវិតថ្វាយក្នុងពេលនេះ ខ្ញុំព្រះអង្គសូមឱ្យបានសម្រេចពោធិញ្ញាណដូចព្រះអង្គក្នុងអនាគតកាល" ព្រះសាស្តាទ្រង់សង្គ្រោះ ក៏លូកព្រះហស្តទៅអង្អែលសិរសាព្រះពោធិសត្វ ហើយត្រាស់ថា "សូមឱ្យបានសេចក្តីសុខ ចូរឱ្យបានរួចចាកទុក្ខក្នុងវដ្តសង្សារ សូមឱ្យបានសម្រេចតាមសេចក្តីប្រាថ្នារបស់អ្នកគ្រប់យ៉ាង អ្នកនឹងបានត្រាស់ ជាសព្វញ្ញុពុទ្ធពុំខាន" ។ ព្រះអង្គទ្រង់ព្យាករណ៍ហើយទ្រង់យាងចុះទៅគន្ធកុដិ ស្តេចក៏ធ្វើភត្តកិច្ច ដោយបច្ច័យទេយ្យទាននៃព្រះពោធិសត្វ ។ ពោធិអាមាត្យត្រូវឃាតករសម្លាប់ហើយក៏បានទៅកើតក្នុងស្ថានសួគ៌ជាន់តុសិត ។

ព្រះធម្មសាមីសម្មាសម្ពុទ្ធ មានព្រះជន្ម ១សែនឆ្នាំ ទើបបរិនិព្វាន ។

ចប់ រឿងព្រះធម្មសាមីសម្ពុទ្ធ

## រឿងព្រះនារទសម្មាសម្ពុទ្ធទី ៥

កាលសាសនារបស់ព្រះធម្មសាមីកន្លងទៅហើយ សារកប្បកន្លងទៅហើយ សុញ្ញកប្បកើតឡើង កាលសុញ្ញកប្បកន្លងទៅ មណ្ឌកប្បបានកើតឡើងក្នុងមណ្ឌកប្បនោះ មានព្រះពុទ្ធ ២ ព្រះអង្គ គឺ ព្រះពុទ្ធនារទៈ ១ និងព្រះពុទ្ធរង្សីមុនី ១ ។

រាហូអសុរិន្ទនឹងបានត្រាស់ជាព្រះពុទ្ធមុន ទ្រង់ព្រះនាមថា ព្រះនារទៈព្រះនារទសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់សាងបារមីជាសទ្ធាធិកនឹកក្នុងព្រះទ័យប្រាថ្នាជាព្រះពុទ្ធ ១៤ អសង្ខេយ្យ ។ បញ្ចេញវាចា ១៨ អសង្ខេយ្យ ។ បញ្ចេញទាំងកាយវាចា ព្រមទាំងចិត្ត ៨ អសង្ខេយ្យ ១ សែនមហាកប្ប ។ ទើបបានត្រាស់

ជាព្រះពុទ្ធទ្រង់ព្រះនាមថា នារទៈ ព្រះអង្គទ្រង់មានព្រះកាយកំពស់ ១២០ ហត្ថ ព្រះជន្ម ១ ម៉ឺនឆ្នាំ មានដើមចន្ទន៍ជាមហាពោធិ មានរស្មីភ្លឺទាំងយប់ ទាំងថ្ងៃ រុងរឿងដូចផ្លេកបន្ទោរ ក្នុងស្រទាប់មេឃ មានរស្មីឆ្មៀលឆ្វាត់ជាមួយគ្នា ដូចជាផ្កាបទុមជាតិ ។ កាលរាហូអសុរិន្ទ ព្រះអង្គ បានត្រាស់ដឹងជា សព្វញ្ញុពុទ្ធហើយ មនុស្សទាំងឡាយប្រកបដោយរូបកាយពណ៌សម្បុរល្អ គួរជាទីនាំមកនូវសេចក្ដីស្នេហា ផែនដីមានឱជារស ៧ ប្រការ ពួកសត្វទាំងឡាយបានអាស្រ័យចិញ្ចឹមជីវិត ជាសុខសប្បាយ ។

រាហូអសុរិន្ទពោធិសត្វ បំពេញបារមីទាំងឡាយយ៉ាងហ្មត់ចត់សព្វកាល ក្នុងនោះបានបំពេញបរមត្ថ បារមីដ៏លើសលប់ជាងបារមីទាំងពួង ។

កាលកន្លងទៅហើយ ក្នុងសាសនាព្រះពុទ្ធកស្សបៈ រាហូអសុរិន្ទបានសោយរាជ្យជាមហាក្សត្រ ទ្រង់ព្រះនាមថា ព្រះបាទសិរីគុត្តមហារាជ ។ សម័យមួយ មានព្រាហ្មណ៍ ៨ នាក់ នាំគ្នាមកកាន់សំណាក់ព្រះបាទសិរីគុត្តមហារាជ ក្រាបទូលសូមព្រះរាជនគរ ។ ព្រះអង្គទ្រង់ប្រទានព្រះរាជនគរដល់ព្រាហ្មណ៍ទាំង ៨ នាក់ ហើយសាងអាស្រមលើកំពូលភ្នំ ស្ដេច ៤ ព្រះអង្គទ្រង់រក្សាសីលស្ថិតនៅក្នុងអាស្រមបទនោះ ។ មានយក្សមួយមកទូលសុំព្រះឱរស ព្រះធីតាជាអាហារ ព្រះសិរីគុត្តទ្រង់ព្រះរាជទាន ហើយតាំងសេចក្ដីប្រាថ្នា សូមឱ្យទាននេះចូរជាបច្ច័យឱ្យបានបន្លុះព្រះសព្វញ្ញុតញ្ញាណ គ្រានោះ ប្រថពីកំរើកញាប់ញ័រហាក់ដូចទ្រុឌទ្រោមចុះក្នុងកាលនោះ ។ យក្សទទួលព្រះរាជឱរសព្រះធីតា ទៅខាំកាត់បំពង់កហុតឈាម ទំពាស៊ីទាំងសាច់ និងឆ្អឹងជាអាហារ ។ ព្រះបាទសិរីគុត្ត ជាបិតា និងព្រះមាតាទ្រង់ទតដោយព្រះនេត្រ ឃើញឈាមកុមារទាំងពីរ

ហូរស្រក់ចុះមកអំពីមាត់យក្ស ។ ព្រះមហាក្សត្រទាំងពីរ ព្រះអង្គក៏មិនមានព្រះទ័យតក់ស្លុតញាប់ញ័រឡើយ ។ ទើបស្តេច ទ្រង់ប្រកាសដល់ពពួកទេវតាថា សូមទេវតាទាំងឡាយ ចូរមកត្រេកអរសោមនស្សរីករាយនឹងទានបារមីរបស់យើង ដែលជាទានដ៏ប្រសើរ ក្នុងកាលឥឡូវនេះចុះ ។

ព្រះមានព្រះភាគ ទ្រង់នាំអតីតទាននៃរាហូអសុរិន្ទបរមពោធិសត្វមកនិទានដូច្នេះហើយ ទើបមានព្រះបន្ទូលថា ម្នាលសារីបុត្តរាហូអសុរិន្ទ បានត្រាស់ដឹងជាសព្វញ្ញុតញ្ញាណ ទ្រង់ទូន្មានសត្វលោក គ្រប់ព្រះជន្ម ១ ម៉ឺនឆ្នាំ ទើបស្តេចចូលកាន់ព្រះនិព្វាន ។

ចប់ រឿងព្រះនារទសម្មាសម្ពុទ្ធ

# រឿងព្រះរង្សីមុនីសម្មាសម្ពុទ្ធទី ៦

កាលសាសនារបស់ព្រះនារទៈសម្មាសម្ពុទ្ធកន្លងទៅហើយ ក្នុងមណ្ឌកប្បដដែលនេះ សោណព្រាហ្មណ៍ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ទ្រង់ព្រះនាមថា ព្រះរង្សីមុនី ។

ព្រះរង្សីមុនីសម្មាសម្ពុទ្ធ ព្រះអង្គសាងបារមីជាវីរិយាធិក ទ្រង់មានព្រះកាយកំពស់ ៦០ ហត្ថ ព្រះជន្ម ៥ពាន់ឆ្នាំ មានដើមល្បៀបជាមហាពោធិ ព្រះអង្គប្រកបដោយរស្មីមានពណ៌ដូចជាមាស ឱភាស ដោយពណ៌រន្ទាលច្រាលឆ្អៅក្នុងវេលាទិវាជាប្រក្រតី លុះអស្តង្គតទៅ ព្រះរស្មីឱភាសដោយពណ៌លឿងស្រស់បំព្រង ដរាបដល់ព្រះអាទិត្យរះឡើង ព្រះអង្គតែងតែមានរស្មីបែបនេះជានិច្ចមិន

ដាច់ឡើយ ។ មហាជនទាំងឡាយណាកើតទាន់សាសនាព្រះរង្សីមុនីសម្ពុទ្ធនេះ តែងតែមានសម្បុរស្បែកដូចមាសស្ទើរ តែគ្មានញើសក្អែលឡើយ ការចិញ្ចឹមជីវិតជាប្រក្រតីមិនបាច់ធ្វើស្រែ ចំការ ឬ ក៏ជួញដូរឡើយ ។ ក្នុងកាលនេះ គ្រាន់តែមហាជនយកពូជកប្បាសទៅដាំលើដីក៏ដុះឡើងប្រកប ដោយផលានុផលជាសំពត់ អាវគ្រឿងស្លៀកដណ្តប់គ្មានខ្វះអ្វីឡើយ ។

ព្រះរង្សីមុនីសម្ពុទ្ធ ទ្រង់បានបំពេញបារមីទាំង ១០ មានទាន សីលជាដើម តែទ្រង់បំពេញបរមត្ថបារមីមួយជាកំពូលនៃបារមីទាំងពួង ទើបព្រះអង្គបានសម្រេចពុទ្ធសម្បត្តិទាំងឡាយ ។

ក្នុងអតីតកាលកន្លងទៅហើយ ព្រះពុទ្ធទ្រង់ព្រះនាមកកុសន្ធោ ត្រាស់ដឹងឡើងក្នុងលោកគ្រានោះ សោណព្រាហ្មណ៍បរមពោធិសត្វជាមាណព ឈ្មោះថា "មាឃមាណពមហានាវា" ជានាយសំពៅ គាត់ទៅជួញដំបូងចំណេញ ១ ភាគទៅជា ១០ ភាគ ទើបជញ្ជូនរបស់ទ្រព្យដាក់សំពៅត្រឡប់មកវិញ ដល់ពាក់កណ្តាលសមុទ្រ សំពៅក៏លិចទៅ ។ មាឃមាណពហែលឆ្លងសមុទ្ររួចមកផ្ទះវិញ គាត់ទៅជួញលើកទី ២ ទៀត បានចំណេញ ១ ភាគ ទៅជា ១០ ភាគទៀតត្រឡប់មកវិញដល់ផ្ទះបាន ៧ ថ្ងៃ ភ្លើងឆេះអស់ ទ្រព្យសម្បត្តិជាច្រើន ។ មាឃទៅជួញលើកទី៣ទៀត បានចំណេញ ១ ភាគទៅជា ១០ ភាគទៀត ជញ្ជូនទ្រព្យដាក់សំពៅមកវិញ គ្រានោះចោរ ចូលមកលួចយកទ្រព្យអស់ ។ គាត់ទៅជួញម្តងទៀតជាលើកទី ៤ បានចំណេញដូចមុន ហើយជញ្ជូនទ្រព្យយកមកផ្ទះ ។ ក្នុងកាលនោះ ព្រះមហាក្សត្រឱ្យរាជបុរសទៅកំហែងរឹបអូសជញ្ជូនយកទ្រព្យ

របស់មាសប្រាក់មក ដាក់ក្នុងរាជឃ្លាំងទាំងអស់ ។ ឯមហាពាណិជក៏ដល់នូវការក្ដៅក្រហាយអស់វារៈ ៤ លើក ស្វាមីភរិយាទាំងពីរនាក់ កើតលំបាកតោកយ៉ាកឈ្លោះប្រកែកទាស់ទែងគ្នា ។ មាណពជាស្វាមីបានសំពត់ កម្ពល ១ ផ្ទត់ និងមាស ១ សែនដំឡឹងចេញពីផ្ទះទៅឯនគរកោសម្ពី ។ មាណពពោធិសត្វតែងរក្សាសីលឧបោសថជាប្រក្រតី ។

គ្រានោះ ព្រះអគ្គសាវ័កនៃព្រះសម្ពុទ្ធកក្កុសន្ធៈ ទើបចេញពីផលសមាបត្តិក៏គិតថា អ្នកណាហ្ន៎! មានទុក្ខបៀតបៀនច្រើន ក៏ពិចារណាឃើញ "មាយមាណពបរមពោធិសត្វ មានទុក្ខច្រើនគួរតែអាត្មាអញប្រោសឱ្យកើតផលទិដ្ឋធម្មវេទនីក្នុងជាតិនេះចុះ" ។

អគ្គសាវ័កប្រដាប់ ស្បង់ បាត្រ និងចីវរ ហោះតាមអាកាសមកចុះត្រង់ពាក់កណ្ដាលនគរកោសម្ពី ទ្រង់ឈរប្រឡបផ្លូវល្មមមាណពឃើញ លុះមាណពដើរមកក៏បានឃើញមែន ទើបចូលទៅក្រាបថ្វាយបង្គំ ទូលសួរបពិត្រព្រះថេរៈដ៏ចម្រើន លោកម្ចាស់ត្រូវការវត្ថុអ្វីដែរឬ? "លោកមានថេរៈដីកាថា" ម្នាលមាណព អាត្មាភាពមកប្រយោជន៏ទទួលទេយ្យទានរបស់អ្នក ។ ឯមាណពឮហើយ ក៏មាន សទ្ធាជ្រះថ្លារីករាយខ្លាំងណាស់ ហាក់បីដូចជាបុរសកំសត់បានកំណប់មាសរាប់ ពាន់ដំឡឹង អរយ៉ាងណា សេចក្ដីត្រេកអរនោះក៏យ៉ាងនោះដែរ ។ មាណពក្រាប ទូលព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកជំនួញធំ បានទ្រព្យមកហើយអន្តរាយទៅវិញអស់ ៤ លើកហើយ ឥឡូវនេះខ្ញុំព្រះអង្គ សូមធ្វើ

ព្រះនិព្វានជាពាណិជ្ជកម្ម ញុំាងចិត្តឱ្យជ្រះថ្លា ធ្វើដំណើរទៅកាន់នគរកែវ ដើម្បីឱ្យបានលោកុត្តរ សម្បត្តិទៅអនាគត ។ ពោធិសត្វ មាណពបន្លឺវាចាហើយក៏កាន់យកមាស ១ ពាន់ដំឡឹង និងសំពត់កម្ពល ១ផ្ទត់ ថ្វាយព្រះថេរៈហើយ ដោយអំណាចនៃចិត្តជ្រះថ្លាក៏តាំងប្រណិធានថាសូមតេជៈនៃទាននេះ ចូរជាបច្ច័យឱ្យខ្ញុំព្រះអង្គបានសម្រេចសម្មាសម្ពោធិញ្ញាណ នាអនាគតកាលកុំបីខានឡើយ ។ ព្រះអគ្គសាវ័កមានថេរៈដីកាថា សេចក្តីតាំងសច្ចវាចាប្រាថ្នាយ៉ាងណា ក៏សូមឱ្យបានសម្រេចដល់អ្នកយ៉ាងនោះចុះ ។

កាលព្រះថេរៈនិមន្តទៅអាវាសវិញហើយ លំដាប់នោះដើមកប្បព្រឹក្ស ១ ដើមផុសឡើងក្នុងទីនោះ ជាប្រយោជន៏គ្រប់យ៉ាងដល់មាណព។ក៏អាស្រ័យនៅលើដើមកប្បព្រឹក្សនោះជាសុខសាន្ត ដូចជាទេវបុត្ត អាស្រ័យនៅក្នុងរុក្ខវិមានក៏ដូច្នោះដែរ

ព្រះវង្សមុនីសម្មាសម្ពុទ្ធទី ៦

គ្រានោះ ព្រះបាទកោសម្ពីស្តេចទ្រង់ព្រះរាជដំណើរចេញទៅជាមួយនឹងមហាជនទាំងឡាយ ជាបរិវារ ស្តេចគមនាការផ្ទៀងព្រះនេត្រទៅឃើញមាណពអង្គុយលើដើមកល្បព្រឹក្ស បីដូចជាវិមានទិព្វ ទើបព្រះបាទកោសម្ពីទ្រង់យាងចូលទៅជិត ក៏សំគាល់មាណពនោះថា "ដូចជាទេវតារក្សាដើមកល្បព្រឹក្ស" ស្តេចទ្រង់ពិរោធទ្រង់បង្គាប់ឱ្យបុរសទាំងឡាយ យកភ្លើងមកដុតទិព្វវិមាននោះចោល មានផ្កាបទុមជាតិផុសឡើង មកទទួលរងមាណពដើម្បីឱ្យអង្គុយនៅជាសុខសប្បាយ ។ ព្រះបាទកោសម្ពីទ្រង់ទត ឃើញអស្ចារ្យដូច្នោះ ទើបទ្រង់ក្រោធខឹងរឹងរឹតតែខ្លាំងឡើង ទ្រង់បង្គាប់រាជបុរសឱ្យចាប់នូវពោធិសត្វមកទម្លាក់ទឹកម្តងទៀត រាជ

បុរសក៏ធ្វើតាមព្រះរាជបង្គាប់ ។ គ្រានោះ ផ្កាបទុមជាតិក៏ផុសឡើងទ្រមាណពទុក មិនឱ្យអន្តរាយឡើង ។ ព្រះបាទកោសម្ពីឃើញ ដូច្នោះ ស្តេចមានព្រះបន្ទូលសួរថា "ម្នាលមាណពដ៏ចម្រើន ដើមកល្បព្រឹក្សនេះ បុគ្គលណាឱ្យអ្នក" ។ មាណព ទូលថា "បពិត្រមហារាជ ដើមឈើទិព្វនេះ ព្រះអគ្គសាវ័កជាម្ចាស់លោក ប្រទានដល់ទូលព្រះបង្គំ"។ ស្តេចត្រាស់ថា "បើដូច្នោះ អ្នកចូរទៅអារាធនា អគ្គសាវ័កឱ្យមកកាន់សំណាក់របស់យើង ទើបយើងជឿតាមពាក្យរបស់អ្នក" ។ គ្រានោះ មាណពក៏តាំងចិត្តអធិដ្ឋាន ដើម្បីផ្សងឱ្យលោក និមន្តមក ដោយវាចាថា "បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា អនុគ្រោះដល់ខ្ញុំព្រះករុណា សូម មេត្តានិមន្តមកកាន់សំណាក់ខ្ញុំព្រះករុណាក្នុងកាលឥឡូវនេះកុំខាន" ។ លុះផុត សត្យាធិដ្ឋានស្រេចហើយ ព្រះថេរៈក៏ជ្រាបច្បាស់ដោយ សោតទិព្វញ្ញាណក៏ហោះមកប្រតិស្ឋានក្នុងទីជិតនៃមាណព លោកមានថេរដីកាទៅកាន់ស្តេចកោសម្ពីថា "ថ្វាយព្រះពរ មហារាជ បើព្រះអង្គ ប្រទុស្តចំពោះព្រះពោធិសត្វ ជាពុទ្ធង្កូរបណ្តូលសារពេជ្ជតាញាណ ដែលនឹងត្រូវបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលនេះ ព្រះនគររបស់ព្រះអង្គ ទ្រុឌទ្រោមលិចលង់ទៅមិនខាន" ព្រះថេរៈពោលដូច្នេះហើយ ក៏ហោះទៅកាន់ទីរបស់ព្រះអង្គវិញ ។ ព្រះបាទកោសម្ពី បានទ្រង់សណ្តាប់ពាក្យរបស់ព្រះអគ្គសាវ័ក (មានថេរដីកាដូច្នោះ) ទ្រង់ក៏តក់ស្លុតរន្ធត់ភិតភ័យក្នុងព្រះទ័យ ក្រៃពេក ហើយត្រាស់នឹងពោធិសត្វថា "ម្នាលមាណពដ៏ចម្រើន! ទោសឯណាដែលយើងធ្វើហើយដល់អ្នក សូមអ្នកអភ័យទោសដល់

យើង" ។ មួយទៀតតាំងពីថ្ងៃនេះទៅ អ្នកចូលជាអនុជរបស់យើង ។ ចាប់តាំងពីថ្ងៃនោះមក ព្រះបាទកោសម្ពី ទ្រង់តាំងមាណព ជាអនុរាជរបស់ព្រះអង្គ ។

ព្រះសាស្តាជាម្ចាស់នៃយើង ទ្រង់នាំរឿងនិទានដូច្នេះហើយ ទ្រង់ត្រាស់នឹងព្រះសារីបុត្តថា៖ ម្នាលធម្មសេនាបតី មាណពនេះមានសម្បត្តិច្រើន លុះបានត្រាស់ជាព្រះពុទ្ធ ទ្រង់ព្រះនាមថា "រង្សីមុនីសម្ពុទ្ធ" មានពុទ្ធរស្មី និងសម្បត្តិបរិបូរណ៍ក្រៃពេក ។

ចប់ រឿងព្រះរង្សីមុនីសម្មាសម្ពុទ្ធទី ៦

## រឿងព្រះទេវទេពសម្មាសម្ពុទ្ធទី ៧

កាលព្រះសាសនារបស់ព្រះរង្សីមុនីកន្លងទៅហើយ មណ្ឌកប្បនោះក៏កន្លងទៅហើយ ផែនដីថ្មី កកើតឡើងបន្តមានឈ្មោះថា មណ្ឌកប្ប ដូចគ្នាក្នុងកប្បនោះមានព្រះពុទ្ធពីរព្រះអង្គត្រាស់ដឹងឡើង ក្នុងលោកគឺព្រះបរមពោធិសត្វ ព្រះនាមថា "សុភព្រាហ្មណ៍" ជាបុត្រនៃតោទេយ្យព្រាហ្មណ៍ បានត្រាស់ជាសព្វញ្ញុពុទ្ធទ្រង់ព្រះនាមថា "ទេវទេពសព្វញ្ញូ" ១ ព្រះពោធិសត្វទ្រង់ព្រះនាមតោទេយ្យព្រាហ្មណ៍ បានត្រាស់ជាសព្វញ្ញុពុទ្ធព្រះនាម "នរសីហសព្វញ្ញូ" ១ ព្រះពោធិសត្វ

ទាំងពីរព្រះអង្គនេះ ក្នុងសាសនាព្រះសម្ពុទ្ធសមណគោតមជា (ឪពុកនិងកូន) លុះបានត្រាស់ជាសព្វញ្ញុពុទ្ធ ក្នុងមណ្ឌកប្បជាមួយគ្នាទៀត ។

ព្រះទេវទេពសម្មាសម្ពុទ្ធ ព្រះអង្គបានត្រាស់ដឹងមុន ទ្រង់សាងបារមីជាវិរិយាធិក ទ្រង់មានព្រះកាយកំពស់ ៨០ ហត្ថ មានព្រះជន្ម ៨ ម៉ឺនឆ្នាំ មានដើមចម្បាជាមហាពោធិ មានរស្មីភ្លឺពាសពេញ ក្នុងលោកធាតុទាំងមូលរុងរឿងជានិច្ចឆព្វណ្ណរង្សី មានសណ្ឋានបីដូចជាផ្កាកណ្ណិការ មានពណ៌ស្រស់បំព្រង សូម្បីក្តៅនិងត្រជាក់ក៏ពុំសូវមានផង ។ ដោយពុទ្ធានុភាពនៃព្រះអង្គមានស្រូវសាលីដុះឡើង មានរសនិងក្លិនក្រអូបជាប្រក្រតី មនុស្សទាំងឡាយមិនបាច់ធ្វើស្រែ ចំការចិញ្ចឹមជីវិតដោយសារស្រូវសាលីនោះ មានដើមកល្បព្រឹក្សជាទីកើតនូវគ្រឿងប្រដាប់សម្រាប់តាក់តែងស្អិតស្អាងរាងកាយទៅតាមចិត្តប៉ង ប្រាថ្នាគ្រប់បែបកាលប្រដាប់តាក់តែងហើយ មានពណ៌សម្បុរដូចមាសជាប្រក្រតីស្រណុក សុខសប្បាយជានិរន្តរ ។ ក្នុងការបំពេញបារមីរបស់ព្រះសុភព្រាហ្មណ៍ពោធិសត្វ មានអភិនីហារបារមីជាកំពូលនៃបារមីទាំងពួង
ដែលអាចឱ្យបានសម្រេចនូវពុទ្ធសម្បត្តិ គ្រប់យ៉ាង ។

អតីតកាលកន្លងទៅហើយ សុភព្រាហ្មណ៍ពោធិសត្វបានកើតជាឆទ្ទន្តរាជអាស្រ័យនៅប្របឆ្នេរស្រះឆទ្ទន្ត នាព្រៃហិមពាន្តក្នុងសាសនាព្រះកោនាគមនសម្មាសម្ពុទ្ធ ។ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ជាអគ្គសាវ័កនៃព្រះពុទ្ធកោនាគមនៈលោកនិមន្តទៅបរិនិព្វានជិតឆ្នេរស្រះឆទ្ទន្ត ឯដំរីឆទ្ទន្តពោធិសត្វ បានទស្សនាការនូវព្រះសរីរកាយនៃព្រះអញ្ញាកោណ្ឌញ្ញត្ថេរអង្គ ព្រះខីណាស្រពដែលបរិនិព្វាន

ដូច្នេះហើយក៏ត្រិះរិះថា នេះជាភារដ៏ឧត្តមរបស់អញ ក៏មានព្រះទ័យសោមនស្ស ក្រៃពេក ទើបតាំងអធិដ្ឋានចិត្តថា យើងនឹងបូជាព្រះសរីរកាយនៃព្រះថេរៈក្នុង ទីនេះ ទើបព្រះអង្គស្រែកប្រកាសដល់ពពួកទេវតាទាំងឡាយថា បពិត្រទេវតា ដ៏ចម្រើនប្រសិនបើការកុសលឯណាដែលយើងបានធ្វើមកអំពីអត្តភាពមុន ក៏សូម ឱ្យកុសលនោះបណ្តាឱ្យរណារ (ទិព្វមួយ) ធ្លាក់ចុះក្នុងទីនេះ រណារទិព្វក៏អណ្តែត ធ្លាក់ចុះមកចំពោះព្រះភ័ក្ត្រព្រះពោធិសត្វភ្លាម ទើបឆទ្ទន្តរាជអារកាត់នូវភ្លុកទាំង ពីរដាច់ហើយយក ភ្លុកម្ខាងធ្វើកោដ្ឋ ភ្លុកម្ខាងទៀតធ្វើជារូបក្ងោក ដើម្បីធ្វើ ឈាបនកិច្ចនៃព្រះសរីរកាយរបស់ព្រះថេរៈ ។ ដោយអំណាចបុណ្យព្រះពោធិសត្វ សន្សំមកហើយ ទើបក្តៅដល់អាសនអម្រិន្ទ្រាធិរាជស្តេចបង្គាប់វិស្សុកម្ម ទេវបុត្ត ឱ្យចុះមកនិម្មិតសព្វសក្ការៈគ្រឿងធ្វើឈាបនកិច្ចរួចហើយ ស្តេចគជសា ដកយក [illegible] រួចធ្វើគ្រឿងសក្ការៈបូជា ពួកដំរីជាបរិវារទាំងឡាយ ៨ ម៉ឺន ៤ ពាន់ ចោមរោមធ្វើបុណ្យសម្ពោធគឹកកងគំរប់ ៧ ថ្ងៃ ទើបហើយ ។

ព្រះពោធិសត្វ ក៏នាំដំរីទាំង ៨ ម៉ឺន ៤ ពាន់ លើកព្រះសពចេញចាកកោដ្ឋ ហើយលើកឡើងដាក់ក្នុងរូបក្ងោក ទើបពោធិសត្វយកខ្លឹមចន្ទន៍ក្រហមដ៏មាន ក្លិនក្រអូបដាក់ចុះរៀបរយល្អហើយ ក៏តាំងព្រះទ័យនៅក្នុងកម្មដ្ឋាន ហើយស្តេច ក៏លើកព្រះសពដាក់លើសិរសា ទើបយកភ្លើងមកបូជាលើព្រះសិរសារបស់ខ្លួន ។ លុះតេជោធាតុឆេះឡើង ព្រះសរីរសពដែលតាំងនៅលើសិរសានៃព្រះពោធិសត្វ ក៏អណ្តែតត្រសែតទៅលើអាកាសវេហាស៍ ។ ព្រះអដ្ឋិធាតុក៏រោយធ្លាក់ចុះលើ

ផែនដីនៅទីនោះឯង ។ ទេវតាទាំងឡាយក៏ប្រតិស្ឋាន ព្រះចេតិយបញ្ចុះព្រះអដ្ឋិធាតុទុកបូជាក្នុងទីនោះតទៅ ។ ដោយតេជះដែលខ្ញុំបានអារភ្លុកទាំងពីរធ្វើសក្ការបូជាសពព្រះអគ្គសាវ័កជាម្ចាស់នេះ សូមជាបច្ច័យឱ្យបានសម្រេចសព្វញ្ញុតញ្ញាណ ( ក្នុងអតីតកុំបីឃ្លាតឡើយ ) ។

ព្រះសាស្តាជាម្ចាស់បញ្ចប់ពុទ្ធនិទានហើយ ក៏ត្រាស់ថា ម្នាលសារីបុត្តក្នុងសាសនាព្រះកោនាគមនៈនោះ សុភព្រាហ្មណ៍នេះ បានបំពេញបារមីដូច្នេះឯងហើយនឹងបានសម្រេចជាព្រះពុទ្ធមួយព្រះអង្គ ក្នុងអនាគតកាល ដោយពិតព្រះនាមទេវទេពសព្វញ្ញូដ៏ប្រសើរ ។

ចប់ រឿងព្រះទេវទេពសម្មាសម្ពុទ្ធ

# រឿងព្រះនរសីហសម្មាសម្ពុទ្ធទី ៨

កាលសាសនារបស់ព្រះទេវទេពសម្ពុទ្ធកន្លងទៅហើយ ក្នុងមណ្ឌកប្បនេះតោទេយ្យព្រាហ្មណ៍ នឹងបានត្រាស់ជាសព្វញ្ញុពុទ្ធ ព្រះនាមថា នរសីហៈ ។

ព្រះនរសីហៈសម្មាសម្ពុទ្ធ ព្រះអង្គសាងបារមីជាបញ្ញាធិក នឹកក្នុងព្រះទ័យ ៧ អសង្ខេយ្យ ទ្រង់បញ្ចេញវាចា ៩ អសង្ខេយ្យ ទ្រង់បញ្ចេញវាចាព្រមទាំងកាយនិងចិត្ត ៤ អសង្ខេយ្យ និង ១ សែនមហាកប្ប ទើបបានត្រាស់ជាព្រះពុទ្ធព្រះអង្គមានព្រះកាយកំពស់ ៦០ ហត្ថ មានព្រះជន្ម ៨ ម៉ឺនឆ្នាំ ជាកំណត់ មាន

ដើមច្រនៀងជាមហាពោធិ មានរស្មីភ្លឺរុងរឿង ក្នុងពេលថ្ងៃមានពន្លឺរស្មីដូចកែវមណីជោតិនៃស្ដេចចក្រ ក្នុងពេលរាត្រីមានពន្លឺរស្មីដូចមាសជាប្រក្រតី ដោយតេជានុភាពនៃព្រះនរសីហៈសម្មាសម្ពុទ្ធ ផែនដីកើតស្រូវសាលីក្រអូបប្រកបដោយឱជារសយ៉ាង ប្រណីតមានជាប្រក្រតី មនុស្សទាំងឡាយ ចិញ្ចឹមជីវិតដោយស្រូវសាលីនោះមិនបាច់ធ្វើស្រែ ចំការ លក់ដូរឡើយ មានដើមកល្បព្រឹក្សមួយដើមដុះឡើង បរិបូណ៌ដោយគ្រឿងអភរណៈ ស្បៀកពាក់ប្រដាប់តាក់តែងនិងរបស់ប្រើប្រាស់ផ្សេងៗ មនុស្សទាំងឡាយមានរូបល្អ មានពណ៌សម្បុរ ដូចមាសទោះបីមិនតាក់តែងកាយដោយគ្រឿងប្រដាប់ក៏នៅតែល្អជានិច្ច ទាំងសុខភាពក៏បរិបូណ៌ ។

ព្រះនរសីហៈសម្មាសម្ពុទ្ធ ព្រះអង្គបានបំពេញបារមីមួយជាកំពូលលើបារមីទាំងពួង គឺក្នុងចន្លោះសាសនារបស់ព្រះសម្ពុទ្ធព្រះនាមកស្សប និងតថាគត កាល

នោះតោទេយ្យព្រាហ្មណ៏បរមពោធិសត្វកើតជាពាណិជម្នាក់ឈ្មោះ "ចន្ទមាណព" ដើរលក់ទំនិញតាមនានាប្រទេស ក៏បានជួបនឹងព្រះបច្ចេកពុទ្ធមួយអង្គ កំពុងនិមន្តគោចរបិណ្ឌបាត្រ ចន្ទមាណពបានឃើញក៏មានសទ្ធាជ្រះថ្លា សោមនស្សទើបលើកសំពត់ កម្ពល ១ ផ្ទត់ និងមាស ១ សែនដំឡឹង បង្អោនជាទេយ្យធម៌ថ្វាយដល់ព្រះបច្ចេកពុទ្ធជាម្ចាស់ស្រេចហើយ ក៏តាំងប្រណិធានប្រាថ្នា បពិត្រព្រះជាម្ចាស់ដ៏ចម្រើន ដោយអំណាចផលនៃទាន ដែលខ្ញុំព្រះករុណាបានបូជាហើយនេះ សូមជាបច្ច័យឱ្យបានសម្រេចសព្វញ្ញុតញ្ញាណ (ក្នុងអនាគតកាល) ។

ព្រះមានព្រះភាគជាម្ចាស់ បញ្ចប់ពុទ្ធនិទានហើយ ទ្រង់ត្រាស់ថា ម្នាល

សេនាបតីសារីបុត្ត តោទេយ្យព្រាហ្មណ៍នេះនឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ ទ្រង់ព្រះនាមថា នរសីហសម្មាសម្ពុទ្ធ ។

ចប់ រឿងនរសីហសម្មាសម្ពុទ្ធ

# រឿងព្រះតិស្សសម្មាសម្ពុទ្ធទី ៩

កាលសាសនារបស់ព្រះនរសីហកន្លងទៅហើយ មណ្ឌកប្បក៏កន្លងទៅហើយ សុញ្ញកប្បបានកើតឡើងកាលសុញ្ញកប្បកន្លងផុតទៅទៀតទើបមណ្ឌកប្បកើតឡើងក្នុងមណ្ឌកប្បនោះ មានព្រះពុទ្ធពីរ ព្រះអង្គ គឺ ព្រះពុទ្ធតិស្ស ១ និងព្រះពុទ្ធសុមង្គល ១ ។

ព្រះពុទ្ធតិស្ស គឺដីរធនបាល ឬ ហៅថា នាឡាគិរីដែលភិក្ខុទេវទត្ត បង្គាប់ឱ្យព្រះបាទអជាតសត្តុរាជកុមារ លែងមកប្រាថ្នាដើម្បីសម្លាប់ព្រះតថាគតហ្នឹងឯង ។ ព្រះតិស្សសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់បារមី ជាវីរិយាធិក ព្រះអង្គមានព្រះកាយកំពស់ ៨០ ហត្ថ មានព្រះជន្ម ៨ម៉ឺនឆ្នាំ មានដើមជ្រៃជាមហាពោធិ មានរស្មីផ្សាយចេញទៅមានរបៀបច្រើនយ៉ាង គឺពុទ្ធរស្មីភ្លឺដូចអណ្ដាតភ្លើង ដែលឆេះឡើងក្នុងលោកធាតុ ១ ពុទ្ធរស្មីភ្លឺទាំងយប់ ទាំងថ្ងៃ១ ពុទ្ធរស្មីចេញអំពីព្រះកាយឆ្មៀលឆ្វាត់បែកជាពណ៌ផ្សេងៗគឺរស្មី ម្យ៉ាងជាវង់ទក្ខិណាវដ្ដ សដូចពណ៌នៃស័ង្ខ ១ ពុទ្ធរស្មីដង្គំចេញទៅដូចពណ៌នៃស្វេតច្ឆត្រ ១ ពុទ្ធរស្មីភ្លឺពណ៌ផ្លេក រហ័សរវិចដូចជាកន្ទុយទង់ ១ ពុទ្ធរស្មីចេញចាកព្រះឧណ្ណាលោម ហើយរុំព័ទ្ធ ព្រះអង្គដូចរំភាយនៃស្វេតច្ឆត្រមានពណ៌មួយពាន់ ១ ពុទ្ធរស្មីទាំងឡាយផ្សាយ ចេញចាកព្រះកាយហាក់ដូចជាសង្កាត់ជាជួរ ព័ន្ធព័ទ្ធព្រះអង្គគួរអស្ចារ្យក្រៃពេក ១ ។

ដោយតេជានុភាពនៃព្រះតិស្សសម្មាសម្ពុទ្ធ ដើមកល្បព្រឹក្សកើតឡើង ឱ្យសម្រេចប្រយោជន៍ដល់ពពួកមនុស្សទាំងឡាយ មានទាំងអាហារភោជន និង

គ្រឿងប្រដាប់គ្រប់ប្រការដែលគួរប្រាថ្នាមិនខ្វះឡើយ ។ មនុស្សទាំងឡាយ ចិញ្ចឹមជីវិតជាសុខសាន្ត ។

ដ៏វីរនាឡាគីរីបរមពោធិសត្វ បានបំពេញបារមីក្នុងសាសនា "ព្រះពុទ្ធកោនាគមនៈ" យ៉ាងក្រៃលែង លើសបារមីទាំងពួង ។

អតីតកាលកន្លងទៅហើយ ក្នុងសាសនាព្រះពុទ្ធកោនាគមនៈជាម្ចាស់ មានមហាក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាមថា ព្រះបាទធម្មរាជ សោយរាជ្យសម្បត្តិក្នុងចម្បាកនគរ ព្រះអង្គមានព្រះឱរស ៥ ព្រះអង្គ គឺដ៏វីរនាឡាគីរីបរមពោធិសត្វ សោយព្រះជាតិជាបុត្តទី ១ (បុត្តច្បង) មានព្រះនាមថា ធម្មសេនកុមារ និងបុត្តជាបន្តបន្ទាប់ ៤ ព្រះអង្គទៀត ជាគម្រប់ ៥ ព្រះអង្គ ។ បុត្តទាំងអស់មានវ័យល្មមសិក្សាហើយ ព្រះរាជាបញ្ជូនទៅរៀនឯនគរតក្កសិលា ជាមួយអាចារ្យទិសាបាមោក្ខ ព្រះរាជកុមារទាំង ៥ ព្រះអង្គរៀនវិជ្ជា នឹងអាចារ្យផ្សេងៗគ្នា រៀនចេះចប់ គ្រប់ព្រះអង្គហើយក៏ត្រឡប់មកព្រះនគរវិញ ចូលទៅក្រាបថ្វាយ បង្គំព្រះបិតាទូលពីវិជ្ជាសិល្បៈរៀងៗព្រះអង្គគឺ :

- ទី១ ធម្មសេនពោធិសត្វ ចេះវិជ្ជាដោះសារក្នុងអត្ថ គឺសីល និងទានជាសិល្បសាស្ត្រ
- ទី២ ភទ្ទកុមារ ចេះច្បាស់ខាងវិជ្ជាមានពិសជាសិល្បសាស្ត្រ
- ទី៣ រាមកុមារ ចេះច្បាស់ខាងវិជ្ជា ផ្កាភ្លើងជាសិល្បសាស្ត្រ
- ទី៤ បមាទកុមារ ចេះច្បាស់ខាងវិជ្ជា ជាងមាស និងរកមាស
- ទី៥ ធជកុមារ ចេះច្បាស់ខាងវិជ្ជាអសិរពិស និងប្រែកាយជាពស់

ព្រះរាជាទ្រង់ទស្សនាឃើញសិល្បសាស្ត្ររបស់រាជឱរសហើយ ទ្រង់មានសេចក្តីត្រេកអរណាស់ ទ្រង់ព្រះតម្រិះថាព្រះរាជឱរស មានវ័យចម្រើនហើយ គួរ ឱ្យរាជឱរសណាគ្រប់គ្រងរាជ្យសម្បត្តិបាន បើអញលើករាជ្យសម្បត្តិឱ្យរាជឱរស ណាមួយ រាជឱរសណាដែលមិនបាននោះមុខជានឹងច្បាំងដណ្តើមយករាជ្យមិនខាន បើដូច្នេះអញនឹងយកតាមពាក្យអ្នកនគរ បើអ្នកនគរពេញចិត្តនឹងសិល្បសាស្ត្រ ឱរសណា ឱរសនោះនឹងទទួលគ្រងរាជ្យសម្បត្តិ ។ ព្រះមហាក្សត្រធម្មរាជ ជាបិតា ទ្រង់ចាត់ចែងរាជបុរសឱ្យរៀបនាវាមួយ ដើម្បីសំដែងសិល្បសាស្ត្រឱ្យអ្នកនគរទាំងឡាយបានឃើញ ព្រះរាជឱរសទាំង ៥ ចុះសំពៅទៅសំដែងសិល្បៈ ព្រះឱរសប្អូនទាំង ៤ ព្រះអង្គត្រូវអស់ព្រះជន្មក្នុងពេលសំដែងសិល្បៈ គ្រានោះ ធម្មសេនពោធិសត្វ នៅសល់តែមួយអង្គឯង កាលនោះមានឥសី ៨ម៉ឺនអង្គ ហោះមកពីព្រៃហិមពាន្តមកកាន់នគរនោះ ទ្រង់គោចរបិណ្ឌបាត ធម្មសេនពោធិសត្វឃើញឥសីទាំងឡាយនោះហើយ ក្រាបថ្វាយបង្គំទូល សូមរៀនវិជ្ជា ចេះហោះតាមអាកាសបាន ឥសីទាំងឡាយមានសេចក្តីករុណា នាំធម្មសេនហោះទៅកាន់អាកាស ដោយឫទ្ធិសំដៅទៅកាន់បរមសាលានាព្រៃហិមពាន្ត ក៏បំបួសធម្មសេនជាឥសីរួចហើយចម្រើននូវកសិណ បរិកម្មភាវនាញុំាងអភិញ្ញា ៥ និងសមាបត្តិ ៨ ឱ្យកើតឡើង អាចហោះទៅតាមអាកាសបានស្ទាត់ជំនាញ តាមចិត្តប្រាថ្នា ធម្មសេនក៏ចូលទៅក្រាបថ្វាយបង្គំព្រះឥសីទាំងឡាយ សូមសំដែងសិល្បៈថ្វាយហើយ សូមលាឥសីចូលមកកាន់នគរ ដើម្បីជួបព្រះបិតាវិញ ឥសីទាំងឡាយបាន

[illegible] មានពុទ្ធដីកាថា (សាធុៗគ្រប់ៗព្រះអង្គ) ។ ធម្មសេនចម្រើនអភិញ្ញា ហោះទៅកណ្ដាលអាកាសសំដៅទៅកាន់ចម្បាកបុរី អ្នកនគរឃើញធម្មសេនហោះមកក៏មានការកោតសរសើរ តាបសធម្មសេនថា មានឫទ្ធានុភាពច្រើន ធម្មសេនចុះមកកាន់សំណាក់ព្រះបិតា គង់ក្នុងទីដ៏សមគួរ ។ ព្រះបាទ ធម្មរាជទតឃើញរាជបុត្ត ហើយពោលសរសើរប្រកបដោយទឹកចិត្តស្នេហាកើតឡើងក៏និមន្តឱ្យគង់នៅ រួចទ្រង់ត្រាស់សួររករាជបុត្ត ទាំង ៤ ព្រះអង្គទៀតថា : លោកម្ចាស់ ព្រះកនិដ្ឋាទាំងឡាយរបស់លោកម្ចាស់ទៅទីណា បានជាលោក ម្ចាស់និមន្តមកមួយអង្គឯង ធម្មសេនតាបស ថ្វាយសេចក្ដីថា បពិត្រមហារាជ ព្រះកនិដ្ឋាទាំង ៣ ព្រះអង្គ ប្រឹងសំដែងសិល្បៈផ្សេងៗលោតទៅក្នុងមហាសមុទ្រ ត្រីឆ្លាមមករទាំងឡាយខាំស៊ីជាអាហារក្ស័យជីវិតទាំងអស់ហើយឯរាជកនិដ្ឋាមួយព្រះអង្គទៀត ទៅដល់នគរដទៃ ក៏និម្មិតខ្លួនជាពស់ ពួកមហាជនភិតភ័យ ហើយក៏នាំគ្នាវាយប្រហារសុគតក្នុងទីនោះឯង ។

ព្រះបាទធម្មរាជ ទ្រង់បានសណ្ដាប់ពាក្យរាជបុត្តហើយ (មានបន្ទូលថា) បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គចាស់ហើយ ខ្ញុំព្រះអង្គនឹងថ្វាយរាជ្យដល់លោកម្ចាស់សូមលោកម្ចាស់សោយរាជ្យសម្បត្តិ តបវេណីតំណាងបិតា ។ ធម្មសេនឥសីទ្រង់សណ្ដាប់ ព្រះបន្ទូលព្រះបិតា ក៏ទទួលយល់ព្រមយកស្វេតច្ឆត្រសោយរាជ្យសម្បត្តិ កាលនោះព្រះពោធិសត្វដោះបរិក្ខារ ៨ ប្រការ (សម្រាប់អ្នកបួស) កាន់យកភេទគ្រឹហាវាស អធិដ្ឋានឱ្យបរិក្ខារទាំងឡាយ ទៅទីប្រជុំឥសីវិញ ។

ព្រះបាទធម្មរាជ ជាព្រះបិតារៀបចំអភិសេក ព្រះធម្មសេនរាជឱរសឱ្យទទួលសោយរាជ្យសម្បត្តិ នាំនាងលម្ពស្សាទេវីមកដំកល់ជាអគ្គមហេសីនៃព្រះពោធិសត្វ ក្នុងកាលនោះឯង ។ លំដាប់នោះ ព្រះបរមពោធិសត្វមហាបុរសរ័ត្នព្រះអង្គឡើង ព្រះនាមថា "ព្រះធម្មសេនរាជ" សោយរាជ្យសម្បត្តិជាមួយនឹងនាងលម្ពស្សាទេវី ។ ព្រះអង្គទ្រង់មានរាជបុត្តពីរព្រះអង្គ គឺបុត្រាមួយអង្គ បុត្រីមួយអង្គ ។

សម័យមួយ ព្រះបាទធម្មសេនរាជ ស្ដេចយាងទៅក្រសាលឆ្នេរស្ទឹង ជាមួយព្រះរាជទេវី និងរាជ បុត្រា បុត្រី ទាំង៤ព្រះអង្គ ព្រមដោយសេនាពួកពលជាច្រើនចោមរោមជាបរិវារ ស្ដេចយាងទៅប្រាថ្នា ស្រង់ទឹកស្ទឹង ។ កាលនោះមានយក្សមួយឃើញកុមារទាំងពីរប្រាថ្នាចង់ធ្វើជាអាហារ មិនអាចនឹងទប់ចិត្តបាន ក៏មកសំដែងកាយឱ្យប្រាកដចំពោះព្រះភ័ក្ត្រនៃព្រះមហាក្សត្រ ហើយទូលថា បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំប្រាថ្នាដើម្បីសូមព្រះរាជបុត្តទាំងពីររបស់ព្រះអង្គ (យកទៅបរិភោគ) បានជាទូលព្រះបង្គំ មកក្នុងទីនេះ បើព្រះអង្គមិនប្រទានឱ្យទេ ខ្ញុំព្រះអង្គនឹងដាច់អាហារស្លាប់ក្នុងទីនេះ ។ ព្រះធម្មសេនរាជសណ្ដាប់ពាក្យយក្សហើយមានព្រះបន្ទូលថា ម្នាលយក្សអ្នកមកចុះយើងនឹងឱ្យម្នាលយក្សដ៏ចម្រើន កូនទាំងពីររបស់យើង យើងស្រឡាញ់ណាស់មិនមែនជាទីស្អប់ឡើយ ប៉ុន្តែសម្ពោធិញ្ញាណជាទីស្រឡាញ់ក្រៃលែង ជាងនេះទៅទៀតដោយអំណាចបិយបុត្តទាននេះ សូមឱ្យខ្ញុំបានសម្រេចនូវពោធិញ្ញាណ តែម្យ៉ាងនាអនាគតកាល ព្រះអង្គតាំងប្រាថ្នាហើយក៏ទ្រង់ច្រូចទឹកលើបាតដៃស្ដាំយក្ស

ហើយព្រះតម្រាស់សុត្តាទាំងឡាយផ្តល់យក្សក្នុងកាលនោះឯង ។ ក្រឡាមហាប្រថពីកម្រើកញាប់ញ័រ ខ្ទរខ្ទារទាំងលោកធាតុក្នុងកាលនោះឯង ។

លំដាប់នោះ ព្រះធម្មសេនរាជ និងព្រះរាជទេវី ព្រមទាំងពួកពលបរិវារហែហមវិលត្រឡប់មកព្រះនគរវិញ ។ លុះជិតដល់ព្រះនគរហើយ ព្រះអង្គទតឃើញបុរសចាស់ម្នាក់ កំសត់ទុរគត អង្គុយសំកុកជាទុក្ខម្នាក់ឯង ទើបស្ដេចមានព្រះបន្ទូលថា ម្នាលជិនបុរស ហេតុអ្វីក៏អ្នកអង្គុយជាទុក្ខដូច្នេះ? បុរសចាស់ក្រាបថ្វាយបង្គំប្រណមទូលថា បពិត្រព្រះមហាក្សត្រដ៏ប្រសើរ ខ្ញុំព្រះអង្គជាមនុស្សទុរគត គ្មានទ្រព្យសម្បត្តិ គ្មានបុត្ត ភរិយាជាទីពឹង ទើបខ្ញុំព្រះអង្គអង្គុយនៅជាទុក្ខដូច្នេះ ។ ស្ដេចទ្រង់ព្រះតម្រិះថា បើដូច្នេះ គួរតែអញយកលម្ពស្សាទេវីអគ្គមហេសីឱ្យជាទានដល់បុរសនោះចុះ ហើយមានព្រះបន្ទូលថា ម្នាលបុរសចាស់ដ៏ចម្រើន! ចូរអ្នកមកកាន់សំណាក់យើង យើងនឹងឱ្យនាងលម្ពស្សាទេវីដល់អ្នក ទ្រង់មានព្រះបន្ទូលហើយក៏ចាប់ព្រះហស្តព្រះនាងទេវីដាក់លើដៃបុរសចាស់ ហើយច្រួចទឹកដាក់លើដៃបុរសចាស់ ទើបតាំងប្រណិធានថាៈ ដោយតេជះដែលយើងឱ្យនាងលម្ពស្សាទេវីជាទានដល់បុរសកំសត់ ក្នុងពេលនេះ សូមជាបច្ច័យឱ្យបានត្រាស់ជាសព្វញ្ញុតញ្ញាណទៅអនាគត ព្រះអង្គតាំងប្រណិធានហើយ ក៏កើតអស្ចារ្យ កំរើកផែនដីដូចមុន ។ គ្រានោះ បុរសចាស់ក្រាបថ្វាយបង្គំប្រណមទទួលព្រះនាងទេវីពីព្រះបរមពោធិសត្វ ហើយពោលនឹងនាងលម្ពស្សាថា ខ្ញុំជាមនុស្សចាស់ ម្យ៉ាងទៀតគ្មានសម្បត្តិអ្វីសោះ ធ្វើម្ដេចនាងទៅជាមួយខ្ញុំបាន ។ ព្រះធម្មសេនពោធិសត្វ ទ្រង់សណ្ដាប់ពាក្យបុរសចាស់ហើយ ទ្រង់ព្រះតម្រិះថា

អញនឹងលើករាជសម្បត្តិឱ្យបុរសចាស់នោះទៀត ខ្លួនអញនឹងទៅបួសជាឥសី ប្រសើរជាង ទើបមានបន្ទូលថា នែ! បុរសចាស់អ្នកមក យើងប្រទានរាជសម្បត្តិដល់អ្នក អ្នកចូរគ្រងរាជ្យសម្បត្តិនេះចុះ យើងឈប់ត្រូវការហើយ ។ ក៏ទ្រង់តាំងប្រណិធានប្រាថ្នាដូចមុន ក្រឡាមហាប្រថពីកក្រើកញាប់ញ័រទាំងលោកធាតុ ។

ព្រះពោធិសត្វទ្រង់តាំងអធិដ្ឋានថា សូមឱ្យបរិក្ខារទាំង ៨ ដ៏ចម្រើន ចូលមក កាន់សំណាក់យើង (ក្នុងកាលឥឡូវនេះកុំខាន) ។

គ្រានោះ អដ្ឋបរិក្ខារអណ្តែតមកហើយ ព្រះបរមពោធិសត្វទ្រង់គ្រឿងបរិក្ខារជាភេទឥសីស្រេចចម្រើនបរិកម្មភាវនាញុំាងអភិញ្ញាសមាបត្តិឱ្យកើតឡើង ហោះទៅកាន់អាកាសសំដៅព្រៃហិមពាន្តគង់នៅជាមួយឥសីទាំងឡាយ ។

សម័យមួយ ព្រះអរិយសាវ័ករបស់ព្រះកោនាគមនសម្មាសម្ពុទ្ធ មួយព្រះអង្គនិមន្តទៅកាន់សំណាក់ឥសី (នាព្រៃហិមពាន្ត) ឥសីទាំងឡាយ មានចិត្តជ្រះថ្លានឹងព្រះអរិយសាវ័ក ក្រាបថ្វាយបង្គំនមស្ការបូជា និមន្តឱ្យគង់នៅអស់រាត្រី ព្រឹកឡើង ព្រះឥសីធម្មសេនបរមពោធិសត្វ ក៏ហោះមកជាមួយព្រះអរិយសាវ័ក ទៅកាន់សំណាក់ព្រះកោនាគមនសម្មាសម្ពុទ្ធ លុះដល់ហើយ ធម្មសេនឥសី ចូលទៅក្រាបថ្វាយបង្គំ នមស្ការទៀបបាទមូលនៃព្រះកោនាគមនសម្មាសម្ពុទ្ធ ទើបអារាធនា ព្រះអង្គសំដែងធម៌ ព្រះពុទ្ធអង្គទ្រង់សំដែងធម៌ហើយ ទ្រង់មានព្រះបន្ទូលថាៈ ម្នាលធម្មសេនឥឡូវនេះ អ្នកសមគួរនឹងពិចារណារកធម៌ សម្រាប់ទៅ

កាន់ស្រុកកែវ គឺអមតមហានិព្វាន ទើបគួរដល់អ្នក ។ ព្រះធម្មសេនបរមពោធិសត្វ ទ្រង់ស្ដាប់ព្រះសម្មាសម្ពុទ្ធហើយ កើតសេចក្ដីប្រាថ្នា ទ្រង់ព្រះចិន្ដាថា អាត្មាអញកាត់ព្រះសិរសាធ្វើសក្ការៈបូជាព្រះធម៌ទេសនាក្នុងពេលនេះ ទើបអធិដ្ឋានថា សូមឱ្យក្រចករបស់អាត្មាអញមុត (ដូចព្រះខ័នពេជ្រ) ហើយលើក ហត្ថាឡើងកាត់ព្រះសិរសា ដាក់លើព្រះហស្ដធ្វើសក្ការៈបូជាហើយ ។ ទ្រង់ពោលសេចក្ដីប្រណិធានថា បពិត្រព្រះសព្វញ្ញូ ទ្រង់ព្រះនាមកោនាគមនសម្មាសម្ពុទ្ធ ព្រះអង្គបានត្រាស់ជាសព្វញ្ញូមុន (ខ្ញុំព្រះអង្គ) ដោយអំណាចនៃសីលទាន ដែលបានបំពេញមកហើយ សូមបានសម្រេចសព្វញ្ញុតញ្ញាណក្នុងបច្ឆាកាល ។ មួយចំណែកទៀតព្រះអង្គប្រកបដោយមហាករុណាគុណជាទីពឹងនៃសព្វសត្វ ព្រះអង្គបរិនិព្វានមុនចុះ ខ្ញុំព្រះអង្គនឹងជានាវាចម្លងសត្វហើយបរិព្វានក្នុងកាលជាខាងក្រោយ ។

ព្រះសាស្ដាជាម្ចាស់ ទ្រង់ពុទ្ធនិទានចប់ហើយ ទ្រង់ត្រាស់ថា ម្នាលសេនាបតីសារីបុត្ត ដំរីធនបាលបរមពោធិសត្វ (ដែលហៅថា នាឡាគិរី) បំពេញបារមីយ៉ាងនេះ ហ្នឹងបានសម្រេចជាព្រះពុទ្ធមួយព្រះអង្គ ទ្រង់ព្រះនាមថា តិស្សសព្វញ្ញូសាស្ដាចារ្យក្នុងកាលជាអនាគត ។

ចប់ រឿងព្រះតិស្សសម្មាសម្ពុទ្ធ

# រឿងព្រះសុមង្គលសម្មាសម្ពុទ្ធទី ១០

កាលសាសនារបស់ព្រះតិស្សសម្មាសម្ពុទ្ធកន្លងទៅហើយ ក្នុងមណ្ឌកប្បដដែលនោះ ដំរីបាលិលេយ្យបរមពោធិសត្វនឹងបានត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធក្នុងកាលជាអនាគត ទ្រង់ព្រះនាមថា សុមង្គលសម្មាសម្ពុទ្ធ ព្រះអង្គ ទ្រង់សាងបារមីជាវីរិយាធិក ទ្រង់មានព្រះកាយកំពស់ ៦០ ហត្ថ ទ្រង់មានព្រះជន្ម ១ សែន ឆ្នាំជាកំណត់ មានដើមខ្ទឹងជាទីត្រាស់ដឹង ព្រះសុមង្គលសម្ពុទ្ធ មានរស្មីភ្លឺចេញអំពី ព្រះអង្គក្នុងវេលាថ្ងៃដូចជាមាស ភ្លឺចេញមានរស្មីឱភាសប្រពៃ លុះដល់ពេលរាត្រី មានរស្មីចេញពីព្រះអង្គពណ៌ប្រាក់ ដោយអានុភាពនៃព្រះពុទ្ធដើមកល្បព្រឹក្សមួយដើម សម្រេចបានជាគ្រឿងឧបភោគ បរិភោគរបស់ប្រើប្រាស់មិនខ្វះ មនុស្សទាំងឡាយមិនបាច់ខ្វល់ខ្វាយធ្វើស្រែ ចំការ ជំនួញជួញប្រែឡើយនាំគ្នា ចិញ្ចឹមជីវិតអាស្រ័យកល្បព្រឹក្សនោះ មនុស្សទាំងឡាយមិនមានភិតភ័យសុខ កាយ សប្បាយចិត្តដូចទេវបុត្តស្ថិតក្នុងវិមាន ។

ព្រះសុមង្គលសម្មាសម្ពុទ្ធ សាងបារមីទាំង ១០ បរិបូណ៌ហើយ ប៉ុន្តែមានបារមីមួយប្រាកដជាងបារមីទាំងឡាយ អាចឱ្យសម្រេចនូវពុទ្ធសម្បត្តិទាំងពួង ។ ដំរីបាលិលេយ្យបរមពោធិសត្វ ដែលធ្លាប់បានបំរើព្រះតថាគត មួយវស្សានាព្រៃបាលិលេយ្យ ។ កាលពីខាងដើមនៃភទ្ទកប្បនេះ បានកើតជាស្តេចចក្រពត្រាធិរាជ ទ្រង់ព្រះនាមថា មហាបនាទបរមចក្រ សោយរាជ្យក្នុងសកលជម្ពូទ្វីប ព្រះអង្គប្រកបដោយ រតន៍ ៧ ប្រការគឺ ចក្ករតន៍ (ចក្កកែវ) ១ ហត្ថិរតន៍(ដំរីកែវ)

១ អស្សរតន៍ (សេះកែវ) ១ មណិរតន៍ (កែវមណីជោត) ១ ឥត្ថីរតន៍(ស្ត្រីកែវ) ១ បរិនាយករតន៍ (បរិនាយកកែវ) ១ គហបតិរតន៍ (គហបតីកែវ) ១ ជាគម្រប់ ៧ ។ ព្រះមហាបនាទបរមចក្រ ព្រះអង្គសោយរាជ្យសម្បត្តិក្នុងជម្ពូទ្វីបជា (ឥស្សរៈលើផែនដី) មានមហាសមុទ្រទាំងបួនជាទីបំផុត ព្រះអង្គទ្រង់គង់នៅ ជាសុខរហូតដល់ព្រះកក្កុសន្ធសម្មាសម្ពុទ្ធ ត្រាស់ដឹងឡើងក្នុងលោក ។

ព្រះមហាបនាទបរមចក្រ ព្រះអង្គទ្រង់បង្គាប់ឱ្យរតនៈដ៏ចម្រើនទាំង ៧ ប្រការរបស់ព្រះអង្គ ចេញទៅនាំយករតនៈផ្សេងៗ ដោយឡែកពីគ្នាមកថ្វាយព្រះអង្គ បានដូចព្រះបំណងហើយ ទើបព្រះអង្គទ្រង់ បង្គាប់គហបតីរតន៍ទៀតថា "ម្នាលគហបតិរតន៍ដ៏ចម្រើន ចូរអ្នកទៅសោឡសមហានគរ ហើយនាំយកកែវមណីមកឱ្យយើង" ។ គហបតីកែវ បានស្តាប់ព្រះបន្ទូលនៃព្រះបរមចក្រហើយ ក៏ហោះទៅកាន់សោឡស មហានគរ យ៉ាងរួសរាន់ ទៅដល់ហើយគហបតីកែវបានជួបព្រះកក្កុសន្ធសម្មាសម្ពុទ្ធ (ដែលប្រថាប់នៅក្នុងព្រះវិហារ) គហបតីកែវមិនស្គាល់ថា ជាព្រះពុទ្ធ ក៏ទូលថា : ម្នាលមាណពដ៏ចម្រើន ខ្លួនអ្នកជាអ្វី? ឈ្មោះ អ្វី? ដូចម្តេចបានជាមានរូបឆោមលោមពណ៌បរិសុទ្ធម្ល៉េះ? ព្រះមានព្រះភាគទ្រង់ ត្រាស់ថា "ម្នាលគហបតីកែវដ៏ចម្រើន! យើងមាននាមថាសាស្តាចារ្យ" គហបតី កែវសួរទៀតថា "ម្នាលមាណពដ៏ចម្រើន អ្នកមាននាមថាសាស្តាចារ្យដោយហេតុ អ្វី?" សម្តេចព្រះកក្កុសន្ធសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ម្នាលគហបតី តថាគត បាន នាមថាសាស្តានោះព្រោះប្រកបដោយអាចរិយគុណ ៣១ប្រការ គហបតីសួរ ទៀតថា ម្នាលមាណពដ៏ចម្រើន អាចរិយគុណ ៣១

ប្រការរបស់អ្នកដូចម្ដេច? ។

ព្រះសារពេជ្ញកក្កុសន្ធសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលគហបតីកែវដ៏ចំរើន! ឯអាចរិយ គុណនោះ គឺៈ ឥតិបិសោភគវាជាដើមជាគុណនៃតថាគតមានទូទៅ ក្នុងលោកទើបបានទ្រង់ព្រះនាមថាសាស្ដាប្រកបដោយអាចរិយគុណ៣១ប្រការ ។ គហបតីកែវបានស្គាល់ច្បាស់ថា ព្រះពុទ្ធដូច្នេះហើយ ទើបចារិកព្រះគុណទាំងនោះទុកក្នុងសុវណ្ណប័ដ ហើយអារាធនា ព្រះមានព្រះភាគឱ្យទ្រង់ត្រាស់សំដែងធមិ បានស្ដាប់សព្វគ្រប់ហើយក៏ចារិកព្រះរូបប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ និងកំពស់ ៦០ ហត្ថ និងលក្ខណៈដទៃទៀតទុកក្នុងផែនមាសទាំងពីរ ។ គហបតីកែវធ្វើនិវត្តនាការត្រឡប់មកកាន់សំណាក់ ព្រះ-បាទបរមចក្រថ្វាយផែន សុវណ្ណប័ដឱ្យទ្រង់ទតនូវព្រះកក្កុសន្ធសម្មាសម្ពុទ្ធ និងព្រះពុទ្ធគុណដែលចារិក ជាតួអក្ខរៈសព្វគ្រប់ និងទូលថ្វាយនូវសេចក្ដីប្រាស្រ័យសាកសួរព្រះសម្ពុទ្ធពិតប្រាកដហើយ ។ ព្រះបាទមហាបនាទបរមចក្រ ទ្រង់ជ្រាបហេតុការថា ព្រះសម្ពុទ្ធទ្រង់ប្រតិស្ថានឡើងក្នុងលោកហើយ ទ្រង់ព្រះកន្ទ្បែងអួលក្នុងហឫទ័យ ទ្រង់ព្រះវិសញ្ញីនៅក្នុងទីនោះអស់ ៣ លើក ទ្រង់មានព្រះស្មារតីហើយ ក៏ពោលសរសើរគុណគហបតីកែវដែលបាននាំដំណឹងមកថ្វាយយើង ជាវត្ថុប្រសើរលើសលប់ក្នុងលោក បើដូច្នេះ យើងនឹងតបគុណអ្នកដោយសម្បត្តិចក្រនេះវិញទើបគួរ ហើយព្រះអង្គទ្រង់ធ្វើពិធីអភិសេកគហបតីកែវឱ្យសោយរាជ្យសម្បត្តិជាស្ដេចចក្រពត្រាតទៅ ។ ចំណែកព្រះអង្គ ស្ដេចទ្រង់គមនាការទៅកាន់សំណាក់នៃ ព្រះកក្កុសន្ធសម្មាសម្ពុទ្ធតែមួយព្រះអង្គឯងរហូតដល់ដើមជ្រៃធំមួយ ទ្រង់ធ្វើអញ្ជលីបញ្ចង្គប្រតិស្ថានឆ្ពោះព្រះមានបុណ្យ

ទ្រង់ប្រកាសថា បពិត្រព្រះអង្គដ៏ចម្រើន! បីតិសោមនស្សរបស់ខ្ញុំព្រះអង្គពោរពេញក្នុងសន្តាន ខ្ញុំព្រះអង្គយកព្រះពុទ្ធដ៏មានបុណ្យ ជាទីពឹងស្មើដោយជីវិត ដោយតេជៈនៃសេចក្តីប្រាថ្នារបស់ខ្ញុំព្រះអង្គ សូមអដ្ឋបរិក្ខារទាំង ៨ ប្រការអណ្តែតមកកាន់សំណាក់របស់ខ្ញុំព្រះអង្គ ។ គ្រានោះ សម្តេចព្រះសព្វញ្ញុពុទ្ធព្រះអង្គទ្រង់ជ្រាបវារៈចិត្តនៃមហាបរមចក្រ ទ្រង់ប្រាថ្នាបព្វជ្ជា ដូច្នោះ ព្រះអង្គទ្រង់បញ្ជូនបរិក្ខារទាំង ៨ ឱ្យមកតាំងនៅ ចំពោះមុខមហាបរមចក្រ ក្នុងខណៈនោះដោយពុទ្ធានុភាព ។ លុះព្រះអង្គទ្រង់ទតឃើញ អដ្ឋបរិក្ខារអណ្តែតមកហើយ ស្តេចទ្រង់ទទួលអដ្ឋបរិក្ខារ លើកទូលលើព្រះសិរសា មានព្រះបន្ទូលថា ម្នាលបរិក្ខារដ៏ចម្រើន យើងអាស្រ័យនូវអ្នកទើបចេញចាកសង្សារទុក្ខបានហើយ ទ្រង់ផ្លាស់គ្រឿងរាជយសទ្រង់ប្រដាប់ស្បង់ចងវត្ថពន្ធចង្កេះ ចីពរ សង្ឃាដីស្រេច ហើយ ទ្រង់តាំងព្រះទ័យជាសមណៈ ហើយស្តេចទ្រង់ចម្រើនកម្មដ្ឋានក្នុងទីនោះ សមគួរហើយពិចារណានូវពុទ្ធគុណមានឥតិបិសោជាដើម ជាគ្រឿងញ៉ាំងឈានឱ្យកើតឡើង ស្តេចហោះទៅកាន់អាកាស ឆ្ពោះទៅកាន់សំណាក់ព្រះមុនីនាថដល់ហើយទ្រង់ទតឃើញ ព្រះរូបព្រះកក្កុសន្ធសម្មាសម្ពុទ្ធប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការនិងអនុព្យញ្ជនៈ ៨០ ល្អបរិបូណ៌គ្រប់ប្រការញ៉ាំងព្រះបីតិសោមនស្ស និងសេចក្តីជ្រះថ្លាជ្រួតជ្រាបសព្វសព៌ាង្គកាយហើយក៏ទ្រង់វិសញ្ញីក្នុងទីនោះ ព្រះដ៏ទ្រង់យស ទ្រង់យកឧទកវារី ប្រោះព្រំលើឱរា ។ ស្តេចមានព្រះស្មារតីឡើងនមស្ការ ក្រាបថ្វាយបង្គំទៀបបាទមូល ទូលអារាធនាសូមព្រះភគវា ស្តេចទ្រង់សម្តែងធម៌ទេសនា ។ គ្រានោះ ស្តេចព្រះកក្កុសន្ធសម្មាសម្ពុទ្ធ

ទ្រង់ប្រទានធមិទេសនាថា បពិត្រមហារាជបុរស ព្រះអង្គសូមពិចារណានូវសភាវធមិដែលនាំព្រះអង្គ ឱ្យទៅកាន់អមតមហានិព្វានចុះ ។

សម្តេចព្រះមហាបនាទបរមពុទ្ធង្កូរ បានទ្រង់សណ្តាប់សព្វក្រសែព្រះពុទ្ធដីកាត្រាស់ជាន័យសេចក្តីដូច្នេះ ទ្រង់មានព្រះបីតិជ្រួតជ្រាបសព្វសព៌ង្គកាយរបស់ព្រះអង្គ ក្នុងខណៈនោះ (ទើបទ្រង់អធិដ្ឋាន ព្រះនខាឱ្យមុតដូចព្រះខ័នពេជ្រស្រេច) ស្តេចទ្រង់កាត់ព្រះសិរសាដោយព្រះនខា ដាច់ចាកព្រះសូរងហើយធ្វើសក្ការៈបូជា ទៀបបាទមូលនៃសម្តេចព្រះពុទ្ធអង្គហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គ ទ្រង់ប្រោសពពួកសត្វទាំងឡាយមុនខ្ញុំព្រះអង្គ ដោយអំណាចនៃសីលទាននេះ ខ្ញុំព្រះអង្គសូមប្រណិធានជាព្រះពុទ្ធក្នុងបច្ឆាកាល បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអគ្គមុនីយាងទៅកាន់អមតមហានិព្វានមុនចុះ ខ្ញុំ ព្រះអង្គនឹងបានអមតមហានិព្វានក្រោយព្រះអង្គ ។

ព្រះសាស្តាចារ្យជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ព្រះបាទមហាបនាទបរមពោធិសត្វ ទ្រង់ធ្វើទានយ៉ាងនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ទ្រង់ព្រះនាមសុមង្គលសម្មាសម្ពុទ្ធ នាអនាគតពុំខានឡើយ ។ មនុស្សទាំងឡាយណាកាលបើមិនបានមគ្គផលវិសេសជាមួយព្រះពុទ្ធទាំងឡាយ ដែលកន្លងទៅហើយនោះគង់នឹងបានសម្រេចមគ្គផល ក្នុងសាសនាព្រះសុមង្គលសម្មាសម្ពុទ្ធ ដែលនឹងបាន ត្រាស់ដឹងក្នុងកាលជាអនាគត ។

ចប់ រឿងព្រះសុមង្គលសម្មាសម្ពុទ្ធ

រឿងអនាគតពុទ្ធវង្សទាំង ១០ ព្រះអង្គ

ចប់ដោយសេចក្តីសង្ខេប

# ៣០ តារាងពុទ្ធប្បកិណ្ណកកណ្ឌ

| ព្រះពុទ្ធ១៤ព្រះអង្គ | ព្រះពុទ្ធសមណគោតមទ្រង់ព្យាករណ៍ដល់ព្រះពុទ្ធ១០ព្រះអង្គនាអនាគត | កប្បទី |
|---|---|---|
| ភទ្ទកប្ប ៥ព្រះអង្គ | ( កកុសន្ធ កោនាគមន កស្សប គោតម ) មេត្តេយ្យ នាអនាគត | ១ |
| សុញ្ញកប្ប | ប្រមាណជា ១ អសង្ខេយ្យកប្បនេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| មណ្ឌកប្ប២ព្រះអង្គ | រាមៈ ធម្មរាជា | ២ |
| សារកប្ប ១ព្រះអង្គ | ធម្មសាមី | ៣ |
| សុញ្ញកប្ប | ១ កប្បនេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| មណ្ឌកប្ប២ព្រះអង្គ | នារទៈ រង្សីមុនី | ៤ |
| មណ្ឌកប្ប២ព្រះអង្គ | ទេវទេព នរសីហៈ | ៥ |
| សុញ្ញកប្ប | ១ កប្បនេះគ្មានព្រះពុទ្ធត្រាស់ដឹងទេ | |
| មណ្ឌកប្ប២ព្រះអង្គ | តិស្សៈ សុមង្គលៈ | ៦ |

# ៣១. បច្ចេកពុទ្ធាបទាន

សប្បុរសទាំងឡាយ ចូរស្តាប់បច្ចេកពុទ្ធាបទាន ដូចតទៅនេះចុះ

នតង្គៈ ជាអ្នកប្រាជ្ញ ជាបុត្រនៃនាងទេវីក្នុងដែនវេទេហៈ បានសួរព្រះតថាគត កាលគង់នៅក្នុងវត្តជេតពនថា ឮថា ព្រះបច្ចេកពុទ្ធទាំងឡាយ រមែងមាន តើព្រះបច្ចេកពុទ្ធជាអ្នកប្រាជ្ញទាំងនោះ រមែងកើតឡើងដោយហេតុដូចម្តេចខ្លះ ។ គ្រានោះ ព្រះសព្វញ្ញុពុទ្ធដ៏ប្រសើរ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ទ្រង់បែរទៅត្រាស់នឹងព្រះអានន្ទដ៏ចម្រើន ដោយព្រះសូរសៀងដ៏ពីរោះថា ៖

ពួកជនណា មានការកសាងបានធ្វើទុកហើយ ក្នុងសំណាក់នៃព្រះពុទ្ធទាំងពួង តែមិនទាន់បានមោក្ខធម៌ក្នុងសាសនានៃព្រះជិនស្រីទេ ។ ជនទាំងនោះ ជាអ្នកប្រាជ្ញ ជាអ្នកមានប្រាជ្ញាមុតថ្លា វៀរលែងតែព្រះពុទ្ធទាំងឡាយ រមែងបាននូវបច្ចេកពោធិញ្ញាណ ដោយប្រធាននៃសង្វេគនោះផង ដោយអារម្មណ៍ដ៏ស្តើងស្តួចនោះផង ក្នុងលោកទាំងមូល វៀរលែងតែតថាគតចេញ មិនមានបុគ្គលណាស្មើនឹងព្រះបច្ចេកពុទ្ធឡើយ តថាគតនឹងសម្តែងនូវគុណត្រឹមតែសង្ខេបនេះរបស់ព្រះបច្ចេកពុទ្ធទាំងឡាយនោះ (អ្នកទាំងឡាយចូរស្តាប់នូវគុណ) របស់ពួកព្រះបច្ចេកពុទ្ធ ជាមហាមុនីដោយប្រពៃចុះ ។ អ្នកទាំងឡាយ កាលប្រាថ្នានូវភេសជ្ជៈដ៏ប្រសើរផុតគឺព្រះនិព្វាន ចូរមានចិត្តជ្រះថ្លាទាំងអស់គ្នាស្តាប់នូវពាក្យដ៏ពីរោះដូចជា ទឹកឃ្មុំផ្អិតរបស់ព្រះមហាឥសីដែលត្រាស់ដឹងឯង ។ ព្រះបច្ចេកពុទ្ធទាំងឡាយដែលមកប្រជុំគ្នាមានព្យាករណ៍ មានទោស មានវត្ថុនៃសេចក្តីរសាយចិត្ត ទាំងមានហេតុដែលបានសម្រេចនូវពោធិញ្ញាណផ្សេងៗគ្នា ។ (ព្រះបច្ចេកពុទ្ធ

ទាំងនោះ) មានសេចក្តីសំគាល់ក្នុងការរសាយចិត្ត ក្នុងវត្ថុដែលប្រកបដោយរាគៈ មានចិត្តរសាយក្នុងលោក ដែលគេត្រេកត្រអាលលះបង់នូវបបញ្ចធម៌[២៣] និង កិលេសជាត ដែលញ៉ាំងសត្វឱ្យអន្ទះសា ហើយបានសម្រេចនូវពោធិញ្ញាណ ក្នុង ទីនោះឯង ។ បុគ្គលទម្លាក់ចោលនូវអាជ្ញាចំពោះសត្វទាំងពួង មិនបៀតបៀននូវ សត្វទាំងនោះ សូម្បីសត្វណាមួយទេ ទាំងជាអ្នកអនុគ្រោះចំពោះប្រយោជន៍ ដោយមេត្តាចិត្ត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលទម្លាក់ចោល នូវអាជ្ញាចំពោះពួកសត្វទាំងពួង មិនបៀតបៀនចំពោះសត្វទាំងនោះ សូម្បីសត្វ ណាមួយទេ មិនបានប្រាថ្នានូវបុត្រ (ទៅហើយ) តើនឹងប្រាថ្នានូវសម្លាញ់អំពី ណា គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ សេចក្តីស្រឡាញ់ របស់សត្វដែល នៅច្រឡូកច្រឡំគ្នារមែងមាន ឯសេចក្តីទុក្ខនេះមានឡើង ព្រោះអាស្រ័យសេចក្តី ស្រឡាញ់ បុគ្គលកាលឃើញទោស ដែលកើតអំពីសេចក្តីស្រឡាញ់ គប្បីប្រព្រឹត្ត តែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមានចិត្តជាប់ចំពាក់កាលអនុគ្រោះចំពោះ ពួកមិត្តនិងសំឡាញ់ រមែងញ៉ាំងប្រយោជន៍ឱ្យវិនាសបុគ្គល កាលឃើញនូវភ័យ ក្នុងសេចក្តីស្និទ្ធស្នាលនុ៎ះ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ សេចក្តី ស្រឡាញ់ ក្នុងបុត្រនិងភរិយា ដូចជាឬស្សីមានមែកចាក់កណ្តាញ់ បុគ្គលកាល មិនជាប់ចំពាក់ ដូចជាទំពាំងឬស្សី គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ម្រឹគក្នុងព្រៃ មិនជាប់ចំណង ដើរទៅរកចំណីតាមចំណង់បាន យ៉ាងណា វិញ្ញូជន

[២៣] បានដល់ធម៌ ៣ យ៉ាងគឺ រាគៈ ១ ទោសៈ ១ កិលេសទាំងអស់១ ដែលធ្វើដំណើរសត្វឱ្យយឺតយូរ ។ អដ្ឋកថា ។

កាលបើប្រាថ្នាសេរីភាព (យ៉ាងនោះ) គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ការហៅរក រមែងមានក្នុងកណ្តាលនៃសម្លាញ់ គឺក្នុងលំនៅ ក្នុងទីបំរើ ក្នុងការដើរ ក្នុងការត្រាច់ចារិក បុគ្គលកាលប្រាថ្នានូវសេរីភាព ដែលពួកជនពាលមិនប្រាថ្នា គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ល្បែង និងតម្រេករមែងមានក្នុងកណ្តាលនៃសម្លាញ់ ទាំងសេចក្តីស្រឡាញ់ដ៏ធំទូលាយ រមែងមានក្នុងបុត្រទាំងឡាយ បុគ្គលកាលខ្ពើមរអើម ចំពោះការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលជាអ្នកនៅជាសុខក្នុងទិសទាំង៤ មិនមានថ្នាំងថ្នាក់ចិត្ត ត្រេកអរក្នុងវត្ថុតាមមាន តាមបានជាអ្នកអត់ធន់ចំពោះអន្តរាយជាអ្នកមិនតក់ស្លុត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បព្វជិតពួកខ្លះ ឬ ពួកគ្រហស្ថ ដែលនៅគ្រប់គ្រងផ្ទះខ្លះ គេសង្គ្រោះបានដោយកម្រ បុគ្គលអ្នកមិនមានសេចក្តីខ្វល់ខ្វាយចំពោះពួកកូននៃបុគ្គលដទៃ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ វីរបុគ្គលលះបង់នូវវត្ថុទាំងឡាយជាគ្រឿងប្រាកដរបស់គ្រហស្ថ កាត់បង់នូវចំណងរបស់គ្រហស្ថទាំងឡាយ ដូចដើមរលួសផ្អុងជម្រុះស្លឹក គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បើបុគ្គលបានសម្លាញ់ជាអ្នកប្រាជ្ញ មានបញ្ញាខ្ជាប់ខ្ជួន ជាអ្នកប្រព្រឹត្តត្រូវគ្នា មានធម៌ជាគ្រឿងនៅដ៏ល្អ គប្បីជាអ្នកមានស្មារតីគ្របសង្កត់នូវអន្តរាយទាំងពួង ហើយមានចិត្តរីករាយប្រព្រឹត្តជាមួយសម្លាញ់នោះចុះ ។ បើបុគ្គលមិនបានសម្លាញ់ ជាអ្នកប្រាជ្ញមានបញ្ញាខ្ជាប់ខ្ជួន ជាអ្នកប្រព្រឹត្តត្រូវគ្នា មានធម៌ជាគ្រឿងនៅដ៏ល្អទេ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចព្រះរាជាទ្រង់ លះបង់នូវដែនដែលទ្រង់ឈ្នះហើយ ឬ ដូចដំរី

ឈ្មោះមាតង្គៈ (លះបង់នូវហ្វូង កាលត្រាច់ទៅ) ក្នុងព្រៃ ។ តាមពិត យើងសរសើរនូវការបរិបូណ៌ ដោយសម្លាញ់ហើយ តែបុគ្គលគួរគប់រកសម្លាញ់ដែលមានគុណប្រសើរជាងខ្លួន ឬ សម្លាញ់មានគុណស្មើនឹងខ្លួន បើរកមិនបានពួកសម្លាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគនូវចតុប្បច្ច័យ ដែលមិនមានទោស ហើយប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលឃើញនូវកងមាសទាំងពីរ ដែលកូនជាងមាសធ្វើសម្រេច ល្អហើយរណ្តំគ្នាត្រង់កដៃ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ឯការឆ្លើយឆ្លងដោយវាចាក្តី ការជាប់ចំពាក់ក្តី ជាមួយនឹងបុគ្គលគម្រប់ពីររបស់អញ ដូចកងមាសមួយគូមានយ៉ាងនុ៎ះ បុគ្គលកាលរំពឹងឃើញនូវភ័យនុ៎ះក្នុងកាលខាងមុខ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសផ្អែមជាទីរីករាយនៃចិត្ត រមែងញាំញីនូវចិត្តដោយសភាពដ៏ប្លែកៗ បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលឃើញនូវភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយថា នេះជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ ជាសរទាំងជាភ័យរបស់អញហើយគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលគ្របសង្កត់នូវសត្រូវទាំងអស់នុ៎ះ គឺត្រជាក់ ក្តៅ គម្លាន សម្រេក ខ្យល់ និងកំដៅថ្ងៃ របោម និងសត្វលូនហើយគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ដំរីមានខ្លួនសមរម្យ មាំមួនមានសម្បុរដូចផ្កាឈូក កាលលះបង់ហ្វូងហើយនៅក្នុងព្រៃគួរដល់អធ្យាស្រ័យយ៉ាងណា បុគ្គលគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស យ៉ាងនោះឯង ។ បុគ្គលបាននូវសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំងនៃ

បុគ្គលអ្នកត្រេកអរក្នុងពួកទេ បុគ្គលពិចារណានូវពាក្យនៃព្រះពុទ្ធ ជាអាទិច្ចពន្ធុ ហើយគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលកន្លងចម្រូងគឺទិដ្ឋិដល់នូវធម៌មិនទៀង គឺមគ្គទី១ មានមគ្គ (ដ៏សេស) បានហើយ មិនមានអ្នកដទៃដឹកនាំ ព្រោះដឹងថា អាត្មាអញមានញាណ កើតឡើងហើយគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមិនជាប់ចិត្ត (ក្នុងអាហារ) មិនកុហក មិនស្រេកឃ្លាន មិនលុបគុណគេ កំចាត់បង់មោហៈ ដូចជាទឹកចត់ មិនមានទីអាស្រ័យនៅ គឺតណ្ហាក្នុងលោកទាំងពួងហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលគប្បីវៀរស្រឡះនូវសម្លាញ់អាក្រក់ អ្នកមិនឃើញនូវសេចក្តីវិនាស អ្នកអាស្រ័យនៅក្នុងកម្មមិនស្មើ មិនគប្បីគប់រកនូវសម្លាញ់ ដែលជាប់ចំពាក់ដែលស្រវឹង (ក្នុងកាមគុណ) ដោយខ្លួនឯង គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលគប្បីគប់រកនូវបុគ្គលជាពហូសូត អ្នកទ្រទ្រង់ធម៌ អ្នកប្រកបដោយគុណដ៏ក្រៃលែង មានប្រាជ្ញាវាងវៃ បុគ្គលដឹងច្បាស់នូវប្រយោជន៍ទាំងឡាយ គួរបន្ទោបង់សេចក្តីសង្ស័យ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមិនអើពើ មិនអាឡោះអាល័យនូវល្បែងផង តម្រេកផង កាមសុខក្នុងលោកផង ជាអ្នកវៀរស្រឡះចាកគ្រឿងស្អិតស្អាង អ្នកពោលនូវពាក្យសច្ចៈ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលលះបង់នូវកាមទាំងឡាយតាមចំណែក គឺបុត្រ ភរិយា បិតាមាតា ទ្រព្យសម្បត្តិ ស្រូវ អង្ករ និងផៅពង្សហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ កាមគុណនេះ ជាគ្រឿងជាប់ចំពាក់ ឯសេចក្តីសុខក្នុងកាមនុ៎ះ មានប្រមាណតិច កាមគុណនុ៎ះ មានសេចក្តីត្រេកអរតិច បុគ្គលអ្នកមានគំនិត

ប្រាជ្ញា លុះដឹងច្បាស់ថាកាមគុណន៍ុះ ដូចជាដំបៅពកដូច្នេះ ហើយគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលទម្លាយនូវសំយោជនៈ ដូចត្រីក្នុងទឹកទម្លាយនូវសំណាញ់ មិនត្រឡប់មករកសំយោជនៈវិញ ដូចភ្លើងឆេះ (មិនត្រឡប់វិញ) គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គល មានចក្ខុដាក់ចុះ មានជើងមិនរពឹស ជាអ្នកគ្រប់គ្រងឥន្ទ្រិយ រក្សាចិត្តទុក (ដោយល្អ) មិនជោគជាំ មិនរោលរាល (ដោយកិលេស) គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលលះបង់នូវភេទគ្រហស្ថ ដូចដើមបារិច្ឆត្តព្រឹក្ស ដែលមានស្លឹកដាច់ហើយ មានសំពត់កាសាយៈ ចេញបួសហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមិនធ្វើនូវសេចក្តីប្រាថ្នា ក្នុងរសទាំងឡាយ ជាអ្នកមិនល្មោភ មិនចិញ្ចឹមនូវបុគ្គលដទៃ ជាអ្នកត្រាច់ទៅសព្វច្រក មិនជាប់ចិត្តក្នុងត្រកូលមួយៗ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលលះបង់នូវហេតុជាគ្រឿងរារាំង ៥ យ៉ាងរបស់ចិត្ត បន្ទោបង់នូវឧបក្កិលេសទាំងពួង ទាំងមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) កាត់បង់នូវទោសនៃសេចក្តីស្រឡាញ់ ហើយគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលធ្វើនូវសុខទុក្ខសោមនស្សនិងទោមនស្ស ក្នុងកាលមុនឱ្យនៅពីក្រោយខ្នងបាននូវឧបេក្ខាជាសមថៈដ៏ស្អាត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលប្រារព្ធព្យាយាម ដើម្បីដល់នូវព្រះនិព្វាន មានចិត្តមិនរួញរាមានការប្រព្រឹត្តមិនខ្ជិលច្រអូស មានសេចក្តីប្រឹងប្រែងដ៏មាំមួន ប្រកបដោយកម្លាំងកាយ និងកម្លាំងបញ្ញា ហើយគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលកាលមិនលះបង់នូវឈានដ៏ស្ងប់ស្ងាត់ (ចាកសត្វ និង សង្ខារ) ជាអ្នក

ប្រព្រឹត្តនូវធម៌ដ៏សមគួរក្នុងធម៌ទាំងឡាយអស់កាលជានិច្ច ពិចារណានូវទោសក្នុងភពទាំងឡាយ ហើយគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គល កាលប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិនប្រហែស មិនល្ងង់ មានការចេះដឹង មានស្មារតី មានធម៌ពិចារណា ហើយជាបុគ្គលទៀង មានសេចក្តីខ្មីឃ្មាត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលកាលមិនតក់ស្លុតក្នុងលក្ខណៈ មានមិនទៀងជាដើម ដូចសីហៈមិនតក់ស្លុតក្នុងសំឡេងទាំងឡាយ មិនជាប់ចំពាក់ក្នុងធម៌ទាំងឡាយមានខន្ធជាដើម ដូចខ្យល់មិនជាប់នឹងសំណាញ់ មិនប្រឡាក់ដោយលោភៈជាដើម ដូចស្លឹកឈូក មិនប្រឡាក់ដោយទឹក គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ សីហៈជាស្តេចសត្វ មានចង្កូមជាកម្លាំងប្រព្រឹត្តគ្របសង្កត់កំហែងនូវពួកម្រឹគយ៉ាងណា បុគ្គលគប់រកនូវសេនាសនៈដ៏ស្ងាត់ (មានព្រៃជាគ្រឿងអាង) ក៏យ៉ាងនោះដែរ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលកាលចម្រើននូវមេត្តា ឧបេក្ខា ករុណា និងមុទិតា ជាហេតុរួចហើយចាកកិលេសក្នុងកាលដ៏គួរមិនខឹងសម្បានឹងលោកទាំងពួង គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលលះបង់នូវរាគៈផង ទោសៈផង មោហៈផង ហើយទំលាយចេញនូវសំយោជនៈ មិនតក់ស្លុតក្នុងការអស់ទៅនៃជីវិតហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ពួកជនមានប្រយោជន៍ ជាហេតុទើបគប់រកផង បម្រើផងឯពួកមិត្តដែលឥតហេតុ គេរកបានដោយក្រក្នុងថ្ងៃនេះ ឯពួកមនុស្សអ្នកមានបញ្ញា ប្រាថ្នាប្រយោជន៍ផ្ទាល់ខ្លួនឈ្មោះថា ជាមនុស្សមិនស្អាត បុគ្គលគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ពួកព្រះបច្ចេកពុទ្ធ មានសីលបរិសុទ្ធ មានប្រាជ្ញា

បរិសុទ្ធល្អ មានចិត្តតម្កល់មាំប្រកបរឿយ ៗនូវព្យាយាមជាគ្រឿងភ្ញាក់រឭក អ្នកពិចារណានូវសង្ខារ ឃើញនូវធម៌ដ៏វិសេសដឹងច្បាស់នូវធម៌ដែលជាអង្គនៃមគ្គនិងពោជ្ឈង្គ ។ ពួកជនជាអ្នកប្រាជ្ញណាចម្រើននូវសុញ្ញតវិមោក្ខអប្បណិហិតវិមោក្ខនិង អនិមិត្តវិមោក្ខ ក្នុងសាសនានៃព្រះជិនស្រីហើយ តែមិនសម្រេចនូវភាពជាសាវ័កទេ ពួកជនជាអ្នកប្រាជ្ញនោះ គង់បានជាព្រះបច្ចេកពុទ្ធ ត្រាស់ដឹងឯង ។ ពួកជននោះ ជាអ្នកមានធម៌ដ៏ច្រើន មានធម្មកាយដ៏សម្បូណ៌ មានចិត្តជាធំ ឆ្លងនូវទុក្ខនិងឱឃៈទាំងពួង មានចិត្តខ្ពង់ខ្ពស់ផុត ជាអ្នកឃើញនូវប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វាន មានឧបមាដូចសីហៈ (តែងប្រព្រឹត្តតែម្នាក់ឯង) ដូចកុយរមាស ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ជាបុគ្គលមានឥន្រ្ទិយស្ងប់ មានចិត្តស្ងប់ស្ងាត់ មានចិត្តជាសមាធិ ប្រព្រឹត្តដោយប្រាជ្ញាចំពោះសត្វក្នុងទីបំផុតដែន ដូចប្រទីបឆ្លុះបំភ្លឺក្នុងលោកខាងមុខ និងលោកនេះ ជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ដល់ពួកសត្វ ។ ព្រះបច្ចេកពុទ្ធទាំងឡាយជាធំជាងជនលះកិលេសជាគ្រឿងរារាំងទាំងពួងហើយ ជាប្រទីបនៃលោក មានរស្មីដូចមាសដុំ ជាទក្ខិណេយ្យបុគ្គលដ៏ល្អរបស់សត្វលោក ដោយឥតសង្ស័យ ជាបុគ្គលសម្រេចដោយនិរោធសមាបត្តិជារឿយ ៗ ។ សុភាសិតរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ រមែងប្រព្រឹត្តទៅក្នុងមនុស្សលោក ព្រមទាំងទេវលោក ពួកជនពាលណាស្តាប់ហើយ តែមិនបានធ្វើតាមសុភាសិត មានសភាពដូច្នោះទេ ពួកជនពាលនោះឯង រមែងធ្លាក់ទៅរងទុក្ខទាំងឡាយរឿយ ៗ ។ សុភាសិតរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ផ្អែមល្ហែមដូចទឹកឃ្មុំផ្លិតដែលហូរចុះ ពួកជនណាបានស្តាប់ហើយ ប្រកបនូវសេចក្តីប្រតិបត្តិ

តាមយ៉ាងនោះ ពួកជននោះប្រកបដោយប្រាជ្ញា រមែងឃើញនូវសច្ចធម៌ ។ គាថាដ៏ខ្ពង់ខ្ពស់ណា ដែលព្រះបច្ចេកពុទ្ធទាំងឡាយជាអ្នកឈ្នះកិលេស សម្តែងហើយនោះ ព្រះសម្ពុទ្ធជាសីហៈក្នុងសក្យវង្ស ទ្រង់ខ្ពង់ខ្ពស់ជាងជន ទ្រង់ចេញបព្វជ្ជាហើយបានប្រកាសទុក ដើម្បីការដឹងច្បាស់នូវធម៌ ។ សុភាសិតទាំងនេះ ដែលព្រះបច្ចេកពុទ្ធទាំងនោះ សម្តែងផ្សេងៗគ្នា ដើម្បីអនុគ្រោះដល់សត្វលោក ព្រះសយម្ភូ ដូចជាសីហៈ ទ្រង់ប្រកាសទុកហើយ ដើម្បីញ៉ាំងសំវេគធម៌ សង្គហធម៌ និង ឧបាយប្រាជ្ញាឱ្យចម្រើនឡើង ។

ចប់ រឿងបច្ចេកពុទ្ធាបទាន ។

បិដក ៧២ ទំព័រ ១៦

# ពុទ្ធវចនសង្ខេប

# ចប់

# ព្រះនាមព្រះសង្ឃដែលមានសទ្ធាបរិច្ចាគប្រាក់បោះពុម្ពសៀវភៅនេះ

១ លោកម្ចាស់ អ៊ិត - សុជាតិ..........40000៛

២ លោកម្ចាស់ វ៉ែន - ណារ៉ា..........40000៛

៣ លោកម្ចាស់ ស៊ីម - ស៊ីសាមុត..........៣២000៛

៤ លោកម្ចាស់ សេង - រដ្ឋា..........២0000៛

៥ លោកម្ចាស់ វង - តុន..........២0000៛

៦ លោកម្ចាស់ បួន - វុន..........២0000៛

៧ លោកម្ចាស់ ស៊ឹង - ហ៊ុន..........១៦000៛

៨ លោកម្ចាស់ ស៊ីម - សុវណ្ណ..........១៦000៛

៩ លោកម្ចាស់ ម៉ន - សាមី..........១៦000៛

១0 លោកម្ចាស់ ឈឹម - ហ៊ាន..........១៦000៛

១១ លោកម្ចាស់ ពេជ្រ - សំអាត..........១៦000៛

១២ លោកម្ចាស់ ស៊ិន់ - សុភា..........១៦000៛

១៣ លោកម្ចាស់ សៀង - ហ៊ុន..........១៦000៛

១៤ លោកម្ចាស់ ហ៊ែល - ឡា..........១៦000៛

១៥ លោកម្ចាស់ អ៊ឹម - ឡឹម..........១៦000៛

១៦ លោកម្ចាស់ ប៊ឹម - សៃ..........១៦000៛

១៧ លោកម្ចាស់ មាស - កុសល..........១៦000៛

១៨ លោកម្ចាស់ សុទ្ធ - បឿន..........១៦000៛

១៩ លោកម្ចាស់ សេន - ដានី..........១៦000៛

២0 លោកម្ចាស់ សន - សែន..........១៦000៛

២១ លោកម្ចាស់ ម៉េង - រ៉ាវី.............................................................................១៦០០០៛

២២ លោកម្ចាស់ ប៊ិន - វិចិត្រ............................................................................១៦០០០៛

២៣ លោកម្ចាស់ វ៉ើន - សាវី...............................................................................១៦០០០៛

២៤ លោកម្ចាស់ ប្រាក់ - រតនា.........................................................................១៦០០០៛

២៥ លោកម្ចាស់ ឌឹម - វិក្កា...............................................................................១៦០០០៛

២៦ លោកម្ចាស់ ប៉ាង - រិន.................................................................................១៦០០០៛

២៧ លោកម្ចាស់ ញ៉ិប - បូរិន..............................................................................១៦០០០៛

២៨ លោកម្ចាស់ វី - ជាន.....................................................................................១៦០០០៛

២៩ លោកម្ចាស់ ហ៊ែល - វុធ...............................................................................១៦០០០៛

៣០ លោកម្ចាស់ ផុន - វីរៈ..................................................................................១៦០០០៛

៣១ លោកម្ចាស់ ចក់ - សាវើន............................................................................១៦០០០៛

៣២ លោកម្ចាស់ ឃុត - សុឃី...............................................................................១៦០០០៛

៣៣ លោកម្ចាស់ គឹម - ចាន់ណាត........................................................................១៦០០០៛

៣៤ លោកម្ចាស់ ថន - សុខឿន.............................................................................១៦០០០៛

៣៥ លោកម្ចាស់ វ៉ែត - ចាន់ដា.............................................................................១៦០០០៛

៣៦ លោកម្ចាស ឌិន - សារឹម ...............................................................................១៦០០០៛

៣៧ លោកម្ចាស់ ទុំ - សាលី ..................................................................................១៥០០០៛

៣៨ លោកម្ចាស់ មិត្ត - សុខរស់ ............................................................................១០០០០៛

៣៩ លោកម្ចាស់ ប៉ាវ - ស៊ីណាត...............................................................................៥០០០៛

៤០ លោកម្ចាស់ សួន - សារិទ្ធ.................................................................................៥០០០៛

## នាមពុទ្ធបរិស័ទដែលមានសទ្ធាបរិច្ចាគប្រាក់បោះពុម្ពសៀវភៅនេះ

១ លោកជំទាវ នួច - ស៊ីរដ្ឋា ព្រមទាំងបុត្រ.. ..................................១000000៛

២ ឯកឧត្តម ឃួន -ប្រូង លោកជំទាវ ឃួន -កល្យាណ បុត្រ ឃួន ប្រូង-ដារ៉ា និង ចៅ-ស្រី សុខ-អង់សេលីនណា...............................................................................១00 $

៣ ឧបាសក ចាន់ - យឿន ឧបាសិកា ព្រាបមុនី ព្រមទាំងបុត្រ......................១00 $

៤ លោក មាស - គឹមយ៉ាន អ្នកស្រី នង - សុខកែវបូរិន ព្រមទាំងបុត្រ........១១៥ $

៥ លោក ហេង - ប៊ុនហុង.........................................................................១00 $

៦ ឧបាសក សាំង - សេង និងភរិយា................................................... ៤0 $

៧ ឧបាសិកា ជុំ - ឆាយ ព្រមទាំងបុត្រ ..................................................២0 $

៨ ឧបាសិកា យាន - ចន្លី ព្រមទាំងប្អូននិងក្មួយ .........................................២0 $

៩ លោក ភោគ - ទីធិន ឧ.សិ. ទុយ - អ៊ាមខេង ...................................៥0000៛

១0 លោក ឈាន - សុភ័គ អ្នកស្រី យាន ថាវី ...........................................១0 $

១១ ឧបាសិកា ប៊ុន - ស្រីម៉ិច ..................................................................១0 $

១២ ឧបាសិកា ហុង - ចេង ឧបាសិកា ហុង - ម៉េង........................................១0 $

១៣ ឧបាសិកា គី - ហ៊ាង ព្រមទាំងបុត្រ.....................................................១0 $

១៤ សីលវតី គង់ - សុភា........................................................................៤0000៛

១៥ ឧបាសក ជា - តុន ព្រមទាំងបុត្រ ...............................................៣៥000៛

១៦ ឧបាសិកា គង់ - ម៉ារ៉ាឌី.......................................................................៥ $

១៧ ឧបាសិកា យី - អួយ ព្រមទាំងបុត្រ ......................................................៥ $

១៨ ឧបាសិកា មុំ - ឡៃ ព្រមទាំងបុត្រ .......................................................៥ $

១៩ ឧបាសិកា និត - អឿន ព្រមទាំងបុត្រ ...................................................៥ $

២0 ឧបាសិកា ចេង - ហុង............................................................................៥ $

២១ ឧបាសិកា ជា - ធាប..........................................................២0000៛

២២ ឧបាសក មិន - ឈឿន......................................................២0000៛

២៣ ឧបាសក ឈឿន - ផល្លី និងភរិយា.......................................២0000៛

២៤ ឧបាសិកា យុង - សុគន្ធា....................................................២0000៛

២៥ ឧបាសិកា មាស - គាត.......................................................២0000៛

២៦ ឧបាសក ឈុន - សួត ........................................................២0000៛

២៧ ឧបាសិកា ខាត់ -សុខុម.......................................................១៦000៛

២៨ ឧបាសិកា ខៀវ - អ៊ាម.......................................................១៦000៛

២៩ ឧបាសក មាស - កណ្ឌៀង ..................................................១៦000៛

៣0 ឧបាសក អ៊ា - គាង ឧបាសិកា តាត់ - យូ ..............................១៦000៛

៣១ ឧបាសក ឈី - គង់ ឧបាសិកា ជឹម - ស្រួយ ...............................១៦000៛

៣២ ឧបាសក បាវ - ស៊ក់ ឧបាសិកា ទឹម - គាវ...............................១៦000៛

៣៣ ឧបាសក ឈឿន - សារុធ .....................................................១៥000៛

៣៤ ឧបាសិកា ប៉ាយ - ណាឌី.......................................................១0000៛

៣៥ ឧបាសក ផេង - ហុង...........................................................១0000៛

៣៦ ឧបាសិកា អ៊ឹង - បេ និងបុត្រ ...............................................១0000៛

៣៧ ឧបាសក ឈាង - រិន ..........................................................១0000៛

៣៨ ឧបាសក ជុំ - ធារ៉ា .............................................................២ $

៣៩ ឧបាសិកា ពៅ រដ្ឋ .............................................................១ $

៤0 កញ្ញា នុត - ម៉ារីណា ...........................................................១ $

៤១ នុត - ចន្ថា .........................................................................១ $

៤២ នុត បុប្ផា .............................................................................១ $

៤៣ ឧបាសកម៉ក់-ច័ន្ទ ឧបាសក អ៊ិន-ច័ន្ទថុល នាង ម៉ក់-សុងកេង ..........៦០០០៛
៤៤ ឧបាសិកា ហេង - លាភ..........................................................................៥០០០៛
៤៥ ជុន - ជីវ័ន្ត ...........................................................................................៥០០០៛
៤៦ ឧបាសក ខុន - វណ្ណ ..................................................................................៥០០០៛
៤៧ ហាងបោះពុម្ព **ឌី.ទ៊ាយ**.......................................................................១០ក្បាល
៤៨ លោកគ្រូ ប៊ុត-បឿន...............................................................................៤៥០០០៛
៤៩ ឧបាសក ខៀវ-ស្រៀង............................................................................២០០០០៛
៥០ ឧបាសក ធូ-សុខជា..................................................................................២០០០០៛
៥១ ឧបាសិកា ហេង-លាភ.............................................................................២០០០០៛
៥២ ឧបាសិកា ហង្ស-ច័ន្ទសុម៉ាលី.....................................................................២០០០០៛
៥៣ ឧបាសិកា ហ៊ុន-សាយ.............................................................................១៦០០០៛
៥៤ ឧបាសិកា ....-យ៉ុម...................................................................................១០០០០៛
៥៥ ឧបាសិកា ពេទ្យឆេង............................................................................២០០០០៛
៥៦ លោក គ្រី-សុផាន់ណារិទ្ធ.....................................................................១០០០០០៛
៥៧ លោក កែវ-វី...........................................................................................១០០០០០៛
៥៨ លោក ផ្លុង-ពន្លឺរ័តន៏..................................................................................១០ $
៥៩ កុមារី រ័តន៏-ចន្ទលក្ខណា............................................................................៥ $
៦០ កញ្ញា ហែម-ចន្ទី...........................................................................................៥ $
៦១ នៅ-សាម៉ន់+ភរិយាព្រមទាំងមាតាបិតា និងប្អូន១............................១០ $
៦២ ជា-ពិចិត្ត....................................................................................................៥ $
៦៣ ឡៅ-ប៊ុនសរាក់.............................................................................................៥ $